ក្រសួងអប់រំយុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា
# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# ការគ្រប់គ្រងចំណូលអាករលើតម្លៃបន្ថែម
# របស់អគ្គនាយកដ្ឋានពន្ធដារ

VALUE ADDED TAX(VAT) REVENUE MANAGEMENT OF
THE GENERAL DEPARTMENT OF TAXATION

ជំនាញ: សវនកម្ម
រៀបរៀងដោយៈ ផេង ស្រីល័ក្ខ
អត្តលេខ:MA២០/០១១
ឆ្នាំសិក្សា ៖ ឆ្នាំ២០២២-២០២៤

# ក្រសួងអប់រំយុវជន និងកីឡា

**MINISTRY OF EDUCATION YOUTH AND SPORTS**

# វិទ្យាស្ថាន វ៉ាន់ដា

**VANDA INSTITUTE**


# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា

# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

## ការគ្រប់គ្រងចំណូលអាករលើតម្លៃបន្ថែម
## របស់អគ្គនាយកដ្ឋានពន្ធដារ

VALUE ADDED TAX (VAT) REVENUE MANAGEMENT OF THE GENERAL DEPARTMENT OF TAXATION

**ជំនាញ: សវនកម្ម**

**សាស្ត្រាចារ្យណែនាំ ៖ បណ្ឌិត កង ឱម**

**បេក្ខបណ្ឌិត យ៉ាក ទុទ្ធី**

**ឆ្នាំសិក្សា ៖  ឆ្នាំ២០២២-២០២៤**

**គណៈកម្មការត្រួតពិនិត្យរបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា**

**ប្រធានបទៈ ការគ្រប់គ្រងចំណូលអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ**

សាស្ត្រាចារ្យណែនាំ

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

សាស្ត្រាចារ្យណែនាំ

បណ្ឌិត កង ឌិម

គណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សា និងស្រាវជ្រាវ
ប្រធាន

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

**នាយកវិទ្យាស្ថាន**

**បណ្ឌិត ហេង វ៉ាន់ដា**

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការអភិវឌ្ឍន៍យ៉ាងល្អប្រសើរក្នុងរយៈពេលជាងមួយទសវត្សកន្លងមកនេះ ជាមួយនឹងអត្រាកំណើនសេដ្ឋកិច្ចជាមធ្យមជាង៧ភាគរយ និងកំណើនយ៉ាងគំហុកនៃការប្រមូលពន្ធ។ ការរីកចម្រើននេះមិនអាចកាត់ផ្ដាច់ចេញពីតួនាទីដ៏សំខាន់របស់វិស័យឯកជនបានឡើយ។ ជាក់ស្ដែង រាជរដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់គ្រប់ជ្រុងជ្រោយ ដើម្បីធ្វើឱ្យការធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជាកាន់តែប្រសើរឡើង តាមរយៈការរៀបចំបច្ចេកវិទ្យាក្នុងការស្វែងរកឈ្មោះពាណិជ្ជកម្មដែលមានលក្ខណៈសាមញ្ញ ដើម្បីជួយសម្រួលដល់ការចុះបញ្ជីពាណិជ្ជកម្មនឹងការធ្វើឱ្យនីតិវិធីសារពើពន្ធកាន់តែមានប្រសិទ្ធភាពឡើង។

យើងដឹងហើយថាចំពោះប្រទេសមួយ ក្រុមហ៊ុនមួយ ឬគ្រួសារមួយ ទាល់តែមានចំណូលទើបមានចំណាយ មិនអាចមានតែចំណាយហើយគ្មានចំណូលនោះទេ។ បើយើងនិយាយពីប្រភពចំណូលរបស់ប្រទេសយើងគឺមានច្រើនតែក្នុងនេះនាងខ្ញុំសុំបើកយក **ការគ្រប់គ្រងចំណូលអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ** ដែលជាការគ្រប់គ្រងមួយដ៏សំខាន់មកធ្វើការបកស្រាយ។

តាមរយៈការសិក្សាស្រាវជ្រាវនេះបានផ្ដល់សារៈសំខាន់យ៉ាងខ្លាំងដល់នាងខ្ញុំ ឱ្យយល់កាន់តែច្បាស់ពីប្រភេទពន្ធនៅកម្ពុជា ក៏សង្ឃឹមផងដែលថាឯកសារស្រាវជ្រាវនេះនឹងអាចជួយជាគំនិតយោបល់ជាប្រយោជន៍ដល់និស្សិតផ្សេងៗផងដែរ។

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី២០ ជំនាញសវនកម្ម នៃវិទ្យាស្ថាន វ៉ាន់ដា

**សូមសំដែង នូវការគោរពដឹងគុណ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភគាំទ្រទាំងសម្ភារថវិកា និងស្មារតីជំរុញលើកទឹកចិត្តដល់រូបនាងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះនាងខ្ញុំសូមសំដែងនូវការគោរព និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅ ដល់បណ្ដាសាស្រ្ដាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ដែលបានបណ្ដុះបណ្ដាលរូបនាងខ្ញុំនាពេលកន្លងមក។

នាយក គណៈគ្រប់គ្រង បុគ្គលិក សាស្រ្ដាចារ្យនៃវិទ្យាស្ថាន វ៉ាន់ដា ដែលជានិច្ចកាលតែងតែផ្ដល់នូវការលើកទឹកចិត្ត អនុគ្រោះដល់នាងខ្ញុំរហូតធ្វើឱ្យការសិក្សាបានបញ្ចប់និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ជាពិសេសសាស្រ្ដាចារ្យ **បណ្ឌិត គង ឌិម** និងសាស្រ្ដាចារ្យ **យ៉ាក ឧុទ្ធី** ដែលលោកបានឆ្លៀតពេលវេលាដ៏មានតម្លៃ ដើម្បីជួយដឹកនាំដល់ការរៀបចំសរសេររបាយការណ៍របស់នាងខ្ញុំឱ្យរឹតតែមានភាពល្អប្រសើរ។

ជាទីបញ្ចប់នាងខ្ញុំ សូមលើកដៃសំពះបួងសួងដល់គុណព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោកជួយបីបាច់ថែរក្សាដល់លោកអ្នកមានគុណខាងលើឱ្យជួបតែសេចក្ដីសុខគ្រប់ប្រការកុំបីអាក់ខានឡើយ។

សូមគោរពជូនពរដល់គុណូបការជនទាំងអស់ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ ដ៏មហាប្រសើរ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

នាងខ្ញុំ **ផេង ស្រីល័ក្ខ** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី២០ ជំនាញសវនកម្មនៃវិទ្យាស្ថានវ៉ាន់ដា សូមធានាអះអាង និងទទួលខុសត្រូវ លើខ្លឹមសារនៅក្នុងរបាយការណ៍ស្រាវជ្រាវនេះថា របាយការណ៍ស្រាវជ្រាវនេះ គឺជាស្នាដៃស្រាវជ្រាវផ្ទាល់របស់នាងខ្ញុំ ដោយគ្មានពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ចំពោះទិន្នន័យ លទ្ធផលនៃការស្រាវជ្រាវដែលមានក្នុងរបាយការណ៍ស្រាវជ្រាវនេះ គឺថ្មីហើយក៏មិនទាន់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុង របាយការណ៍ស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ២០២៤

ហត្ថលេខា

**ផេង ស្រីល័ក្ខ**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

យើងទាំងអស់គ្នាបានដឹង និងធ្លាប់ឮជាច្រើនមកហើយថាអ្វីទៅជាអាករលើតម្លៃបន្ថែម ហើយយើងក៏បានដឹងដែរថា យើងទាំងអស់គ្នាមានកាតព្វកិច្ចក្នុងការបង់ពន្ធនេះជូនរដ្ឋ។ ក្នុងមានយើងជាអ្នកជាប់កាតព្វកិច្ច យើងតែងតែចង់ដឹង ចង់ឮផងដែរ អំពីកាតព្វកិច្ចរបស់ខ្លួន យល់ដឹងពីវិធាន នីតិវិធី ក៏ដូចជាគោលការណ៍របស់អគ្គនាយកដ្ឋានពន្ធដារដែលតម្រូវឲ្យយើងត្រូវអនុវត្តតាម និងតាមដានថា តើក្នុងមួយឆ្នាំៗការគ្រប់គ្រងចំណូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារមានលទ្ធផលយ៉ាងដូចម្តេច? ដូច្នេះការស្រាវជ្រាវនេះ គឺយើងមានគោលបំណងក្នុងការបកស្រាយអំពី“**ការគ្រប់គ្រងចំណូលអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ**”។

ជាលទ្ធផលផងដែរ នាងខ្ញុំបានស្រាវជ្រាវ និងលើកយកមកបកស្រាយក្នុងរបាយការណ៍ដែលទាក់ទងនឹងការគ្រប់គ្រងចំណូលអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ អំពីប្រវត្តិ រចនាសម្ព័ន្ធ និងបេសកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ។ នៅក្នុងនេះផងដែរ ខ្ញុំចង់បរិយាយឲ្យកាន់តែច្បាស់អំពីវិធាននិងនីតិវិធីសម្រាប់ការចុះបញ្ជីអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ សិក្សាស្វែងយល់ទៅលើបុគ្គលដែលត្រូវចុះបញ្ជីអាករលើតម្លៃបន្ថែម អំពីគោលការណ៍របស់អគ្គនាយកដ្ឋានពន្ធដារក្នុងការប្រមូលពន្ធលើVAT និងបង្ហាញអំពីលទ្ធផលនៃការគ្រប់គ្រងចំណូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ។ របាយការណ៍ស្រាវជ្រាវនេះនាងខ្ញុំបានដកស្រង់ចេញពី ព្រះរាជក្រមស្តីពីច្បាប់សារពើពន្ធ ព្រះរាជក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម ប្រកាសស្តីពីអាករលើតម្លៃបន្ថែម និងឯកសារពាក់ព័ន្ធផ្សេងៗផងដែរដើម្បីបង្ហាញជាអំណះអំណាង។

តាមរយៈការស្រាវជ្រាវនេះ ការប្រមូលអាករលើតម្លៃបន្ថែម គឺជាយុទ្ធសាស្ត្រដ៏សំខាន់មួយក្នុងការបង្កើនប្រសិទ្ធភាព ក្នុងការគោរពកាតព្វកិច្ចពន្ធ និងការជួយបង្កើនចំណូលថវិកាជាតិ។ យើងអាចសន្និដ្ឋានបានថាការគ្រប់គ្រងចំណូលអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ ពិតជាមានភាពចាំបាច់ និងមានលក្ខណៈសុក្រឹត និងយុត្តិធម៌ ប្រកបដោយវិជ្ជាជីវៈពិតប្រាកដមែន។

# អក្សរកាត់

- អ.ព.ដ: អគ្គនាយកដ្ឋានពន្ធដារ
- GDT: General Department of Taxation
- អតប: អាករលើតម្លៃបន្ថែម
- E-VAT Refund: Electronic Value Added Tax Refund (ការបង្វិលសង និងការប្រើប្រាស់ឥណទានអាករលើតម្លៃបន្ថែមតាមប្រព័ន្ធអនឡាញ)

# មាតិកា

ទំព័រ

អារម្ភកថា ........ i

សេចក្តីថ្លែងអំណរគុណ ........ ii

អំណះអំណាង ........ iii

សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ iv

អក្សរកាត់ ........ v

## ជំពូកទី១

## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជាវ ........ ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២

១.៤ទំហំ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

១.៤.១ ទំហំ ដែនកំណត់ ........ ២

១.៤.២ វិសាលភាព ........ ៣

១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ. ........ ៣

១.៥.១ វិធីសាស្ត្រដែលបានយកមកប្រើប្រាស់ក្នុងការសរសេរ ........ ៣

១.៥.២ វិធីសាស្រ្តប្រមូលទិន្នន័យ ........ ៣

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

១.៧រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

## ជំពូកទី២

## ការគ្រប់គ្រងចំណូលអាករលើតម្លៃបន្ថែម

២.១ លក្ខណៈទូទៅនៃការគ្រប់គ្រងចំណូលអាករលើតម្លៃបន្ថែម ........ ៤

២.១.១ និយមន័យនៃការគ្រប់គ្រង ........ ៤

២.១.២ ប្រវត្តិនៃការគ្រប់គ្រង ........ ៤

២.១.៣ តួនាទីនៃការគ្រប់គ្រង ........ ៤

២.១.៤ មុខងារនៃការគ្រប់គ្រង ........ ៥

២.១.៥ កម្រិតនៃការគ្រប់គ្រង ........ ៥

២.២ បុគ្គលដែលត្រូវចុះបញ្ជីអាករលើតម្លៃបន្ថែម........................................................................៥
២.២.១ និយមន័យការចុះបញ្ជីអាករលើតម្លៃបន្ថែម ..............................................................៥
២.២.២ ប្រភពនីតិវិធី..................................................................................................................៥.៦
២.២.៣ ឋានុក្រមនៃនីតិវិធី ..........................................................................................................៦
២.៣ វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករ ..................................................................៦
២.៣.១ វិធាននិងនីតិវិធី ...............................................................................................................៦
២.៣.២ ប្រវត្តិនៃអាករលើតម្លៃបន្ថែម ............................................................................................៨
២.៤ គោលការណ៍នៃការប្រមូលពន្ធអាករលើតម្លៃបន្ថែម.............................................................៨
២.៤.១ និយមន័យពន្ធ.................................................................................................................៨
២.៤.២ ប្រវត្តិពន្ធ..........................................................................................................................៩.១៤
២.៤.៣ ប្រភេទពន្ធ.......................................................................................................................១០.១៧

# ជំពូកទី៣

# ការគ្រប់គ្រងចំណូលអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ

៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ.......................................................................១៥
៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ ...................................................................................១៥
៣.១.២ គោលនយោបាយនៃការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ ........................................១៥
៣.១.៣ រចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ.................................................................១៦.១៨
៣.១.៤ ទស្សនៈវិស័យ និងបេសកកម្ម.......................................................................... ១៨.១៩
៣.២ បុគ្គលដែលត្រូវចុះបញ្ជីអាករលើតម្លៃបន្ថែម .....................................................................១៩
៣.៣ វិធាន និងនីតិវិធីរបស់ពន្ធដារសម្រាប់ការចុះបញ្ជីពន្ធអាករលើតម្លៃបន្ថែម...........................២០
៣.២.១ កាតព្វកិច្ចការចុះបញ្ជី...................................................................................២០.២១
៣.២.២ គោលការណ៍ស្តីពីការចុះបញ្ជី...........................................................................................២១
៣.២.៣ ការតម្រូវចំពោះការចុះបញ្ជី.........................................................................២១.២៣
៣.៤ គោលការណ៍ក្នុងការប្រមូលពន្ធលើVAT.................................................................................២៣
៣.៤.១ ការផ្គត់ផ្គង់ជាប់អាករ.....................................................................................២៤.២៥
៣.៤.២ ការផ្គត់ផ្គង់ទំនិញដល់អ្នកប្រើប្រាស់...............................................................២៥.២៦
៣.៤.៣ ការផ្គត់ផ្គង់ដោយភ្នាក់ងារ..............................................................................................២៦
៣.៤.៤ ការប្រមូលអាករលើតម្លៃបន្ថែមលើការនាំចូល.................................................................២៦
៣.៤.៥ ការនាំចូលនូវទំនិញ និងសេវាក្នុងអត្រាសូន្យ..................................................................២៧

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និង ចំណុចខ្សោយ

៤.១ ការវិភាគលើចំណុច..........................................................................................២៨.២៩
៤.២ ការវិភាគលើចំណុចខ្សោយ...................................................................................២៩.៣០

## ជំពូកទី៥
## សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

៥.១ សេចក្ដីសន្និដ្ឋាន..................................................................................................៣១
៥ ២.ការផ្ដល់អនុសាសន៍..........................................................................................៣១.៣២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ (Background and Rational)

ប្រទេសកម្ពុជាជាប្រទេសមួយដែលមានវ័យចំណាស់ជាងគេនៅក្នុងឧបទ្វីបឥណ្ឌូចិន ដែលមានធនធានធម្មជាតិជាច្រើនសម្បូរបែប ដូចជាប្រព័ន្ធទឹក ដី ព្រៃឈើ រ៉ែជាដើម។ ជាហេតុធ្វើឲ្យមនុស្សនៅក្នុងប្រទេសនេះរស់យ៉ាងសុខស្រួលជាមួយនឹងធម្មជាតិទាំងនោះ ហើយមនុស្សសម័យនោះមានវិធីសាស្រ្តដោះដូរទំនិញដូចជា ការយករបស់មួយទៅដូរយករបស់មួយ។ បន្ទាប់មកក៏មានការផ្លាស់ប្តូរទៅជាការចាយប្រាក់ដួងប្រាក់សន្លឹក និងមាសជាដើម ដើម្បីសម្រេចទៅតាមតម្រូវការ និងជីវភាពរបស់ពួកគេ។ តែទទឹមនឹងនោះប្រទេសកម្ពុជាក៏បានឆ្លងកាត់ជាច្រើនយុគសម័យកាលរួចមកហើយ ហើយក៏បានឆ្លងកាត់សង្គ្រាមជាច្រើនលើកជាច្រើនសារដូចគ្នា ធ្វើឲ្យមានការផ្លាស់ប្តូរវិធីសាស្រ្តនៃការដោះដូរទំនិញទៅជាមានការបោះពុម្ពក្រដាសប្រាក់ជំនួសវិញ។ ហើយបន្ទាប់មកទៀតរាជរដ្ឋាភិបាលប្រទេសកម្ពុជាបានបង្កើតឡើងនូវច្បាប់ នឹងក្រសួងនានាជាច្រើន ព្រមទាំងអគ្គនាយកដ្ឋានពន្ធដារផងដែរ ដែលមានឈ្មោះដើមហៅថានាយកដ្ឋានពន្ធដារ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

សព្វថ្ងៃនេះរាជរដ្ឋាភិបាលប្រទេសកម្ពុជាបានបង្កើតពន្ធជាច្រើនបែបដូចជា អាករលើតម្លៃបន្ថែម ពន្ធប្រាក់បៀវត្ស ពន្ធកាត់ទុក ពន្ធប្រាក់រំដោះពន្ធលើប្រាកចំនេញ ពន្ធលើអចលនទ្រព្យ។ល។ រាជរដ្ឋាភិបាលកម្ពុជាមានភាពតឹងរឹងជាមួយនឹងអាករលើតម្លៃបន្ថែម ដែលអាករនេះគេយកពន្ធចេញតាមរយៈការទិញទំនិញ ការនាំចូល និងការនាំចេញទំនិញ ឬវត្ថុផ្សេងៗទៀត និងការផ្គត់ផ្គង់សេវានានាផងដែរ។ រាជរដ្ឋាភិបាលបានប្រមូលពន្ធតាមវិធីសាស្រ្ត២យ៉ាង ការប្រមូលពន្ធផ្ទាល់ និងការប្រមូលពន្ធប្រយោល។

ការបង់ពន្ធជូនរដ្ឋគឺជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូប ដើម្បីចូលរួមចំណែកក្នុងការកសាងសេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានានៃប្រទេសកម្ពុជា។ ពន្ធគឺជាចំណូលទាំងដុលរាជរដ្ឋាភិបាល ដើម្បីឲ្យរាជរដ្ឋាភិបាលយកថវិកាទាំងនោះឆ្លើយតបទៅនឹងការចំណាយទូទាំងប្រទេសដូចជា (បើកប្រាក់បៀវត្សជូនមន្រ្តីរាជការ ការសាងសងមន្ទីរពេទ្យ សាលារៀន ស្ពាន ផ្លូវ សេវាសាធារណៈនានា និងកម្មវិធីផ្សេងៗពាក់ព័ន្ធនឹងកិច្ចការជាតិ......)។ អាស្រ័យហេតុនេះ ទើបខ្ញុំបានលើកយកប្រធានបទទាក់ទងនឹងការគ្រប់គ្រងចំណូលអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីស្រាវជ្រាវនិងធ្វើការបកស្រាយ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ (Problem Statement)

ដើម្បីឱ្យច្បាស់អំពី នីតិវិធី ច្បាប់ បទប្បញ្ញត្តិ វិធីសាស្រ្ត ក្នុងការប្រកាសពន្ធយើងបានចោទជាសំណួរដូចខាងក្រោមៈ

១.តើបុគ្គលណាខ្លះត្រូវចុះបញ្ជីអាករលើតម្លៃបន្ថែម?

២.តើអគ្គនាយកដ្ឋានពន្ធដារមានវិធាន និងនីតិវិធីសម្រាប់ការចុះបញ្ជីអាករលើតម្លៃបន្ថែមយ៉ាងដូចម្តេច?

៣.តើអគ្គនាយកដ្ឋានពន្ធដារមានគោលការណ៍បែបណា ក្នុងការប្រមូលអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ (Research Objective)

ការប្រមូលអាករលើតម្លៃបន្ថែមនៅពេលនាំចូលមានដូចជា៖

-អាករដល់កំណត់នៅពេលនាំចូល និងត្រូវប្រមូលដោយទីចាត់ការគយនិងរដ្ឋាករ។

-អាករត្រូវបានប្រមូលតាមរយៈការប្រកាសក្នុងប្រតិវេទន៍គយសម្រាប់ការនាំចូល ហើយត្រូវបានចាត់ចែងតាមរបៀបដូចគ្នានឹងពន្ធគយ។

-តម្លៃជាប់អាករនៃការនាំចូលទំនិញគឺជាចំនួនសរុបនៃៈ

ក-តម្លៃទំនិញសម្រាប់គិតពន្ធគយស្របតាមច្បាប់ដែលទាក់ទិននឹងពន្ធគយ

ខ-ចំនួនទឹកប្រាក់នៃពន្ធគយ អាករពិសេសលើទំនិញនិងសេវាមួយចំនួន និងបន្ទុកសារពើ-ពន្ធផ្សេងទៀត ដែលត្រូវបង់លើទំនិញទាំងនោះក្រៅពីអាករលើតម្លៃបន្ថែម

គ-តម្លៃសេវាណាមួយដែលមានចែងក្នុងកថាខ័ណ្ឌ៣ នៃប្រការ៤៧ នៃប្រកាសនេះ ដែលមិនបានបូកបញ្ចូលក្នុងតម្លៃទំនិញសម្រាប់គិតពន្ធគយ ដូចមានចែងក្នុងវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌ៣ នៃប្រកាសនេះ។

-ទីចាត់ការគយនិងរដ្ឋាករ ត្រូវផ្តល់ឱ្យអ្នកនាំចូល នូវច្បាប់ចម្លងនៃប្រតិវេទន៍គយសម្រាប់ការនាំចូលដែលក្នុងនោះត្រូវៈ

ក-ចុះលេខអត្តសញ្ញាណកម្មអតប បើសិនជាអ្នកនាំចូលជាបុគ្គលជាប់អាករ

ខ-សរសេរថា ″គ្មាន″ ក្នុងប្រអប់សម្រាប់ចុះលេខអត្តសញ្ញាណកម្មអតប បើសិនជាអ្នកនាំចូលមិនមែនជាបុគ្គលជាប់អាករ

គ-បញ្ជាក់នូវចំនួនប្រាក់អាករដែលបានបង់ លើប្រតិវេទន៍គយសម្រាប់ការនាំចូល បើសិនជាអ្នកនាំចូល ជាបុគ្គលជាប់អាករធ្វើការនាំចូលដើម្បីប្រកបអាជីវកម្មជាប់អាករ។

ឃ-បញ្ជាក់អំពីអសុពលភាព នៃការបង្វិលសងប្រាក់អាករ ប្រសិនបើអ្នកនាំចូលមិនមែនជាបុគ្គលជាប់អាករ ឬធ្វើការនាំចូលដើម្បីប្រើប្រាក់ផ្ទាល់ខ្លួន។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

(Scope and Limitation of Research)

### ១.៤.១ ទំហំ ដែនកំណត់(Limitation)

ប្រធានបទដែលខ្ញុំលើកយកមកស្រាវជ្រាវនេះពាក់ព័ន្ធទៅនឹងច្បាប់បទប្បញ្ញត្តិ អំពីអាករលើតម្លៃបន្ថែម និងការគ្រប់គ្រងចំណូលអាករលើតម្លៃបន្ថែម(VAT) នៃព្រះរាជាណាចក្រកម្ពុជាដូចខាងក្រោម៖

១- ការផ្គត់ផ្គង់ទំនិញត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបងទំនិញនោះត្រូវបានប្រគល់ឱ្យ ទោះបីមានលក្ខណៈជាការផ្ទេរសិទ្ធប្រើប្រាស់ឬសិទ្ធចាត់ចែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំពោះករណីដែលការផ្គត់ផ្គង់ត្រូវមានការដឹកជញ្ជូន ការផ្គត់ផ្គង់ត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើទំនិញស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដែលការដឹកជញ្ជូនត្រូវបានថាចាប់ផ្តើម។

២- ការផ្គត់ផ្គង់សេវាត្រូវចាត់ទុកថាបានធ្វើឡើងនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើសេវានោះបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជាវៀរលែងតែៈ

ក- ការផ្គត់ផ្គង់សេវាជាប់ទាក់ទិននឹងអចលនទ្រព្យត្រូវកំណត់ថា សេវានោះបានធ្វើឡើងនៅទីកន្លែងដែលអចលនទ្រព្យនោះស្ថិតនៅ។

ខ- ការផ្គត់ផ្គង់សេវាជាប់ទាក់ទិននឹងការដឹកជញ្ជូនត្រូវកំណត់ថា សេវានោះបានធ្វើឡើងនៅទីកន្លែងនៃការដឹកជញ្ជូននោះ។

៣- ទំនិញត្រូវចាត់ទុកថាបាននាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើទំនិញនោះត្រូវបាននាំចូលមកក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជា។

**១.៤.២ វិសាលភាព**(Scope)

យោងតាមប្រធានបទដែលបានស្រាវជ្រាវឆ្នាំ២០២៣នេះ យើងខ្ញុំបានលើកយកអាករលើតម្លៃបន្ថែមអនុវត្តលើរាល់ការផ្គត់ផ្គង់ជាប់អាករនូវទំនិញឬសេវានៅព្រះរាជាណាចក្រកម្ពុជា។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ(Research Methodology)

**១.៥.១ វិធីសាស្ត្រដែលបានយកមកប្រើប្រាស់ក្នុងការសរសេរ**

វិធីសាស្ត្រដែលគេយកមកអនុវត្តន៍សម្រាប់ការស្រាវជ្រាវមានច្រើនរបៀប ចំណែកឯការសិក្សាស្រាវជ្រាវក្នុងរបាយការណ៍បញ្ចប់ការសិក្សារនេះ គឺខ្ញុំប្រើប្រាស់វិធីសាស្ត្របែបរុករក បែបប្រៀបធៀប និងបែបពិពណ៌នា ដើម្បីធ្វើការបកស្រាយ។

**១.៥.២ វិធីសាស្ត្រប្រមូលទិន្នន័យ**

ទិន្នន័យ និងឯកសារដែលបានស្រាវជ្រាវៈ

-ស្រាវជ្រាវឯកសារដែលមានស្រាប់តាមគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ

-តាមរយៈសារណារបស់សិស្សច្បងនិស្សិតជំនាន់មុន

-ស្វែងរកឯកសារនៅក្នុងបណ្ណាល័យរបស់វិទ្យាស្ថាន វ៉ានដា

-លើកយកឯកសារដែលមានស្រាប់ដូចជា ព្រះរាជក្រម ប្រកាស អនុក្រឹត្យ ពាក់ព័ន្ធនឹងច្បាប់ពន្ធ

-សៀវភៅសិក្សាគណនេយ្យអនុវត្ត របស់វិទ្យាស្ថានវ៉ានដាគណនេយ្យ

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ (The importance of Research)

តាមរយៈការស្រាវជ្រាវនេះ បានផ្តល់សារៈសំខាន់យ៉ាងខ្លាំងដល់ខ្ញុំឲ្យយល់កាន់តែច្បាស់អំពីអាករលើតម្លៃបន្ថែមនៃព្រះរាជណាចក្រកម្ពុជា នឹងច្បាប់ពន្ធក្នុងការគ្រប់គ្រងចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ ក៏សង្ឃឹមផងដែរថា ឯកសារស្រាវជ្រាវនេះនឹងអាចជួយជាគំនិតយោលបល់ ជាប្រយោជន៍ដល់និស្សិតផ្សេងៗផងដែរ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ(The organization of Research)

ជំពូកទី១៖ សង្ខេបទៅលើ លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់ វិសាលភាពនៃការស្រាវជ្រាវ និង វិធីសាស្ត្រនៃការស្រាវជ្រាវ។

ជំពូកទី២៖ រំលឹកទ្រឹស្តី

ជំពូកទី៣៖ ការគ្រប់គ្រងចំណូលអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ

ជំពូកទី៤៖ វិភាគពីចំណុចខ្លាំងនិងចំណុចខ្សោយ

ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍

# ជំពូកទី ២
# ការគ្រប់គ្រងចំណូលអាករលើតម្លៃបន្ថែម

## ២.១ លក្ខណៈទូទៅនៃការគ្រប់គ្រងចំណូលអាករលើតម្លៃបន្ថែម

### ២.១.១ និយមន័យនៃការគ្រប់គ្រង

ការគ្រប់គ្រង (Management) ៖ គឺជាដំណើរការនៃការរៀបផែនការ ការចាត់ចែងការងារ ការដឹកនាំនិង ការត្រួតពិនិត្យដោយប្រើធនធានមនុស្ស និងធនធានដទៃទៀតដើម្បីសម្រេចគោលដៅ។

### ២.១.២ ប្រវត្តិនៃការគ្រប់គ្រង

- ប្រជុំគ្នា និង ពិគ្រោះគ្នាជានិច្ចស្តីពីការងារ
- ព្រមព្រៀងគ្នាការពារប្រទេស
- កែប្រែច្បាប់ និង បង្កើតច្បាប់ជាបន្ទាន់ស្របតាមសភាពការណ៍ផង ស្របតាមសិទ្ធិមនុស្សផង
- ស្តាប់មតិអ្នកប្រាជ្ញ បណ្ឌិត និង ព្រឹទ្ធាចារ្យ
- ការពារនារី និង កុមារ
- គោរព និង ការពារបូជនីយដ្ឋាន និង កេមរតជាតិ ប្រពៃណីជាតិ
- រក្សាឃុំគ្រងបព្វជិត និងព្រះសង្ឃដែលមានធម៌
- រក្សាសត្វព្រៃ និងព្រៃឈើ អោយមានតុល្យភាពក្នុងប្រទេស
- ផ្តល់អាហាររូបករណ៍(បៀវត្ស) គ្រប់គ្រាន់ដល់ពលទាហាន និង មន្ត្រីរាជការស៊ីវិល
- បង្ក្រាបឧក្រិដ្ឋកម្មគ្រប់ប្រការ។

### ២.១.៣ តួនាទីនៃការគ្រប់គ្រង

តួនាទីនៃការគ្រប់គ្រងមាន៣គឺ៖

1. តួនាទីអន្តៈបុគ្គល ជាអ្នកតំណាង ជាអ្នកដឹកនាំ និងមានតួនាទីទំនាក់ទំនង
2. តួនាទីព័ត៌មាន ប្រមូលព័ត៌មានពីស្ថាប័នខាងក្រៅ តាមដានត្រួតពិនិត្យព័ត៌មាន និងការផ្សព្វផ្សាយ និងមានតួនាទីជាអ្នកដឹកនាំពាក្យ
3. តួនាទីធ្វើការសម្រេចចិត្ត គឺជាតួនាទីចុងក្រោយរបស់អ្នកគ្រប់គ្រងដែលបានកំណត់តួនាទីនោះជា៤ គឺ តួនាទី ជាសហគ្រិន តួនាទីជាអ្នកដោះស្រាយបែងចែងធនធាន និងតួនាទីចរចា។

### ២.១.៤ មុខងារនៃការគ្រប់គ្រង

មុខងារនៃការគ្រប់គ្រងមាន៤គឺ៖

1. ការធ្វើផែនការ គឺជាការកំណត់នូវគោលបំណងអង្គភាពបង្កើតយុទ្ធសាស្រ្តអភិវឌ្ឍឋានានុក្រម ផែនការនិងធ្វើការសម្របសម្រួលសកម្មភាពទាំងឡាយ។
2. ការចាត់តាំង គឺជាការទទួលខុសត្រូវចំពោះគម្រោងរចនាសម្ព័ន្ធរបស់អង្គភាពបែងចែកការងារតម្រូវ ទៅតាមសមត្ថភាពបុគ្គលដែរត្រូវធ្វើ។
3. ការដឹកនាំ គឺជាការដឹកនាំដោយផ្ទាល់និងសម្របសម្រួលជាមួយក្រុមមនុស្សទាំងអស់ ចេះលើកទឹកចិត្តបុគ្គលិកដឹកនាំសកម្មភាពអ្នកដទៃ ជ្រើសរើសរបៀបនៃការប្រស្រ័យទាក់ទងដែលមានប្រសិទ្ធភាពបំផុត នឹងដោះស្រាយជំលោះនៅក្នុងក្រុមការងារ។[1]

[1] Website ច្បាប់នៃការគ្រប់គ្រង

4. ការត្រួតពិនិត្យ គឺដើម្បីធានាថាកិច្ចការទាំងអស់ត្រូវទៅតាមផែនការដែលបានគ្រោងទុក ប្រៀបធៀបប្រតិបត្តិការជាក់ស្តែងទៅនឹងគោលបំណងអង្គភាព ហើយត្រូវធ្វើការកែប្រែលើចំណុចដែលចាំបាច់។

**២.១.៥ កម្រិតនៃការគ្រប់គ្រង**

អ្នកគ្រប់គ្រងមាន៣ កម្រិតដូចខាងក្រោម៖

1. អ្នកគ្រប់គ្រងកម្រិតខ្ពស់
2. អ្នកគ្រប់គ្រងថ្នាក់កណ្តាល
3. អ្នកគ្រប់គ្រងថ្នាក់ទាប ឬ អ្នកគ្រប់គ្រង់ផ្ទាល់[1]

## ២.២ បុគ្គលដែលត្រូវចុះបញ្ជីអាករលើតម្លៃបន្ថែម

### ២.២.១ និយមន័យការចុះបញ្ជីអាករលើតម្លៃបន្ថែម

ការចុះបញ្ជីត្រូវបានកំណត់ដូចខាងក្រោម៖

១-បុគ្គលជាប់អាករដូចមានចែងក្នុងមាត្រា៥៨នៃច្បាប់នេះ ត្រូវធ្វើការចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែមក្នុងរយៈពេល១៥ថ្ងៃ ក្រោយថ្ងៃដែលបុគ្គលនោះក្លាយជាបុគ្គលជាប់អាករ។

២-ចំពោះបុគ្គលដែលមានការតម្រូវឱ្យធ្វើការចុះបញ្ជី ហើយមិនបានធ្វើការចុះបញ្ជីរដ្ឋបាលសារពើពន្ធអាចធ្វើការចុះបញ្ជីបុគ្គលនោះ ចាប់តាំងពីពេលដែលបុគ្គលនោះត្រូវមកធ្វើការចុះបញ្ជី។ បុគ្គលដែលត្រូវបានចុះបញ្ជីតាមបែបនេះ ត្រូវទទួលខុសត្រូវចំពោះប្រាក់អាករទាំងអស់ក្នុងមាត្រា៦៥នៃច្បាប់នេះ ចាប់តាំងពីកាលបរិច្ឆេទដែលបុគ្គលនោះត្រូវមកធ្វើការចុះបញ្ជី។

៣-សម្រាប់ក្រុមបុគ្គលទាក់ទិនពីរនាក់ឬច្រើននាក់ ដែលក្នុងនោះបុគ្គលម្នាក់ឬច្រើននាក់មិនមែនជាបុគ្គលជាប់អាករទេនោះ រដ្ឋបាលសារពើពន្ធអាចចាត់ទុកបុគ្គលជាប់អាករណាមួយថាបានចុះបញ្ជីសម្រាប់សកម្មភាពសេដ្ឋកិច្ចទាក់ទិនទាំងមូលឬភាគណាមួយ។ ប្រសិនបើគ្មានបុគ្គលទាក់ទិនណាម្នាក់ជាបុគ្គលជាប់អាករទេនោះ រដ្ឋបាលសារពើពន្ធអាចចុះបញ្ជីនូវបុគ្គលក្នុងក្រុមម្នាក់ឬច្រើននាក់សម្រាប់សកម្មភាពសេដ្ឋកិច្ចទាក់ទិនទាំងមូលឬភាគណាមួយ។

៤-សម្រាប់គោលដៅនៃការចុះបញ្ជីនិងដោយមានការយល់ព្រមពីរដ្ឋបាលសារពើពន្ធ ចំពោះបុគ្គលជាប់អាករមួយក្រុមដែលជាប់ទាក់ទិនគ្នាដូចមានចែងក្នុងមាត្រា៥៧នៃច្បាប់នេះ សកម្មភាពរបស់សមាជិកនានានៅក្នុងក្រុម អាចចាត់ទុកជាសកម្មភាពរបស់សមាជិកជ្រើសរើសតាំងតែប៉ុណ្ណោះ។ ក្នុងករណីនេះសមាជិកម្នាក់ៗនៅក្នុងក្រុមត្រូវមានការទទួលខុសត្រូវមានការទទួលខុសត្រូវរួមគ្នា និងយ៉ាងពេញលេញចំពោះការប្រតិបត្តិតាមបទប្បញ្ញត្តិនៃជំពូក។[2]

### ២.២.២ ប្រភពនីតិ

ប្រភពនីតិរួមមានប្រភពសរសេរនិងប្រភពឥតសរសេរ

ប្រភពសរសេរមាន៖

- រដ្ឋធម្មនុញ្ញ: គឺជាច្បាប់កំពូលនិងជាគ្រឹះដែលមានឋានានុក្រមខ្ពស់ជាងគេបំផុតនៅព្រះរាជាណាចក្រកម្ពុជា

[2] ច្បាប់សារពើពន្ធមាត្រាទី៥៧ (04-10-2023)

- សន្ធិសញ្ញាអន្តរជាតិ: គឺជាកិច្ចព្រមព្រៀងរវាងរដ្ឋឬស្ថាប័នអង្គការអន្តរជាតិផ្សេងៗទៀត។
- ច្បាប់: គឺជាអត្ថបទដែលចេញពីអំណាចនីតិបញ្ញត្តិហើយត្រូវបានដាក់ឲ្យអនុម័តដោយស្ថាប័នអង្គការនីតិផ្សេងៗទៀតផងដែរ។
- ព្រះរាជក្រឹត្យ: គឺជាកិច្ចការរដ្ឋបាលចេញដោយប្រមុខរដ្ឋ។ ដែលប្រើប្រាស់ក្នុងវិស័យនីតិប្រតិបត្តិ។ វាគឺជាសេចក្តីសម្រេចរបស់ប្រមុខរដ្ឋសម្រាប់ប្រើប្រាស់ក្នុងការអនុវត្តច្បាប់ និងតែងតាំងផ្លាស់ប្តូរបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលចាប់ពីថ្នាក់ អគ្គនាយក អភិបាលខេត្ត ក្រុងឡើងទៅ។
- អនុក្រឹត្យ: គឺជាកិច្ចការរដ្ឋបាលដែលមានប្រភពចេញពីគណៈរដ្ឋមន្ត្រី និងចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីសម្រាប់អនុវត្តច្បាប់និងតែងតាំងផ្លាស់ប្តូរបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលចាប់ពីថ្នាក់អភិបាលរងខេត្ត ក្រុង និងអភិបាលក្របខណ្ឌ។
- ប្រកាស: គឺជារដ្ឋបាលកិច្ចដែលមានប្រភពចេញពីប្រធានស្ថាប័នពោលគឺ រដ្ឋមន្ត្រីរដ្ឋលេខាធិការដែលជាប្រធាននៃក្រសួង។ ប្រកាសនេះក៏សម្រាប់តែងតាំង ផ្លាស់ប្តូរ និងដកហូតមុខងាររបស់មន្ត្រីរាជការរបស់ក្រសួង ឬលេខាធិការដ្ឋានចាប់ពីថ្នាក់អនុប្រធាននាយកដ្ឋានចុញមកដល់កម្មករសមញ្ញ។
- ដីកា: គឺជាសេចក្តីសម្រេចរបស់អាជ្ញាធរ រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ដើម្បីបម្រើឲ្យវិស័យគ្រប់គ្រងទូទៅនៃសមត្ថកិច្ចនៅដែនដីរបស់ខ្លួន។

ប្រភពឥតសរសេរមាន៖

- ប្បវេណី: គឺជាការអុវត្ត ការធ្វើជាបន្តបន្ទាប់ឥតដាច់ទៀងទាត់និងមានរយៈពេលជាកំណត់ ពោលគឺអ្វីដែលធ្វើតាម។
- យុទ្ធិសាស្រ្ត: គឺជាសេចក្តីសម្រេចរបស់តុលាការលើបញ្ហាច្បាប់ហើយគេអាចធ្វើជាគម្រូក្នុងការអនុវត្តលើរឿងក្តីក្រោយៗទៀត។
- លទ្ធិ: គឺជាមិតិយោបល់ជាទ្រឹស្តីអ្នកច្បាប់ឬសាស្រ្តាចារ្យច្បាប់ធំៗ ដែលសិក្សាអំពីបញ្ហានានារបស់ច្បាប់។

### ២.២.៣ ឋានានុក្រមនៃនីតិ

ឋានានុក្រមនៃនីតិ៖

- រដ្ឋធម្មនុញ្ញ ព្រះរាជក្រម ឡាយព្រហស្តលេខាដោយព្រះមហាក្សត្រ
- សន្ធិសញ្ញា អនុក្រឹត្យ ចេញដោយនាយករដ្ឋមន្ត្រី
- ច្បាប់ ប្រកាស ចេញដោយប្រធានស្ថាប័ន ឬរដ្ឋមន្ត្រី
- បទបញ្ជា ដីកា ចេញដោយអាជ្ញាធរដែនដី
- យុត្តិសាស្រ្ត សារាចរ ចេញដោយអាជ្ញាធរមូលដ្ឋាន[3]

## ២.៣ វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករ

### ២.៣.១ វិធាននិងនីតិ

វិធាននិងនីតិនៃការគ្រប់គ្រងប្រមូលអាករលើតម្លៃបន្ថែមត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

[3] Websize ច្បាប់ (10-10-2023)

### ២.៣.២ ប្រវត្តិនៃអាករលើតម្លៃបន្ថែម

អាករលើតម្លៃបន្ថែម គឺជាអាករកំនត់ទៅលើការចំណាយទិញរបស់អ្នកប្រើប្រាស់ អាករនេះត្រូវប្រមូលពីការប្រកបអាជីវកម្ម និងការនាំចូល។ ការប្រកបអាជីវកម្មភាគច្រើនទាក់ទិនទៅនិងការផ្គត់ផ្គង់ទំនិញឬសេវាការប្រកបអាជីវកម្មទាំងនោះត្រូវជាប់អាករលើតម្លៃបន្ថែមប្រសិនបើការផ្គត់ផ្គង់៖

- ធ្វើឡើងក្នុងព្រះរាជណាចក្រកម្ពុជា
- ធ្វើឡើងដោយបុគ្គលជាប់អាករ
- ធ្វើឡើងក្នុងដំណាក់កាលប្រកបអាជីវកម្មឬដំណាក់កាលពង្រីកអាជីវកម្ម
- គ្មានការបញ្ជាក់ច្បាស់លាស់ថាមិនជាប់អាករឬជាប់អាករតាមអត្រា០%

ការផ្គត់ផ្គង់ធ្វើឡើងដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលមិនមែន ជាការផ្គត់ផ្គង់មិនជាប់អាករហៅថា ការផ្គត់ផ្គង់ជាប់អាករ។ បុគ្គលជាប់អាករគឺជារូបវន្តបុគ្គលក្រុមហ៊ុនសហកម្មសិទ្ធិក្រុមហ៊ុនមហាជន ឬបុគ្គលណាមួយដែលមានផលរបរបានមកពីការផ្គត់ផ្គង់ជាប់អាករលើសពីកម្រិតអប្បបរមានៃផលរបរត្រូវចុះបញ្ជីត្រូវទៅចុះបញ្ជីអាករលើតម្លៃបន្ថែម។ ការផ្គត់ផ្គង់ត្រូវនៅក្រៅដែនអនុវត្តអាករលើតម្លៃបន្ថែមប្រសិនបើការផ្គត់ផ្គង់នោះ៖

- ធ្វើឡើងដោយបុគ្គលដែលមិនមែនជាបុគ្គលជាប់អាករ
- មិនធ្វើឡើងក្នុងដំណាក់កាលប្រកបអាជីវកម្ម ឬដំណាក់កាលពង្រីកអាជីវកម្ម

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលធ្វើការផ្គត់ផ្គងជាប់អាករ ត្រូវមានកាតព្វកិច្ចចុះបញ្ជីអាករលើតម្លៃបន្ថែមនិងប្រមូលអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គងទំនិញឬសេវាឲ្យអតិថិជន។ ទំនិញសំដៅដល់ទ្រព្យរូបីក្រៅពីដីធ្លីនិងនិងប្រាក់កាសរីឯសេវា សំដៅដល់ការផ្តល់អ្វីមួយដែលមានតម្លៃក្រៅពីទំនិញ ដីធ្លី និងប្រាក់កាស។

**ការផ្គត់ផ្គង់ជាប់អាករសំដៅដល់៖**

- ការផ្គត់ផ្គង់ទំនិញឬសេវាដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ការដកទំនិញយកមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ
- ការផ្តល់ជាអំណោយឬការផ្គត់ផ្គង់ក្រោមតម្លៃពិត នូវទំនិញឬសេវាដោយបុគ្គលជាប់អាករ
- ការនាំចូលទំនិញមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា

**ការផ្គត់ផ្គង់មិនជាប់អាករមានដូចតទៅ៖**

- សេវាប្រៃសណីយ៍សាធារណៈ
- សេវារបស់មន្ទីរពេទ្យនិងគ្លីនិក សេវាខាងវេជ្ជសាស្រ្តនិងទន្តសាស្ត្រនិងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្រ្តនិងទន្តសាស្រ្តដែលទាក់ទិននិងការបំពេញសេវាទាំងនេះ
- សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ
- សេវាធានារ៉ាប់រង
- សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយ ក្នុងកម្រិតតម្លៃដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សកម្មភាពមិនស្វែងរកចំណេញ ដើម្បីបំរើផលប្រយោជន៍សាធារណៈដែលទទួលបានស្គាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការនាំចូលនិងការទិញទំនិញសម្រាប់ឬដោយបេសកកម្មទូត និងកុងស៊ុលបរទេសអង្គការអន្តរជាតិ និងទៅភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា សម្រាប់យកមកប្រើនៅក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន

អត្រាអាករលើតម្លៃបន្ថែមមាន៖

- ១០% សម្រាប់ការនាំចូល ឬសេវាក្នុងព្រះរាជណាចក្រកម្ពុជា
- ០% សម្រាប់ការនាំចេញ

ការគណនាអាករត្រូវបង់៖

- ប្រាក់អាករត្រូវបង់នៅពេលនាំចូលទំនិញ ឬប្រាក់អាករដែលបានបង់លើការទិញទំនិញ ឬសេវាសម្រាប់ប្រកបអាជីវកម្មហៅថា (អាករលើធាតុចូល)
- ប្រាក់អាករដែលបានគិតពីអតិថិជនពីការផ្គត់ផ្គង់ទំនិញ ឬសេវាហៅថា(អាករលើធាតុចេញ)
- ប្រាក់អាករត្រូវបង់= អាករលើធាតុចេញ - អាករលើធាតុចូល

អាករលើធាតុចេញដែលមិនអាចកាត់កងបាន៖

អាករលើធាតុចេញដែលមិនអាចកាត់កងបានរួមមានប្រាក់អាករដែលបានបង់លើ

- ចំណាយទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ លើកលែងតែបុគ្គលជាប់អាករដែលមានអាជីវកម្មជាអ្នកផ្គត់ផ្គង់ ការទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ
- ការទិញ ឬការនាំចូលរថយន្ត លើកលែងតែបុគ្គលជាប់អាករដែលមានអាជីវកម្មជាអ្នកលក់ ឬជួលរថយន្ត
- ការទិញ ឬការនាំចូលផលិតផលតែលសិលាមួយចំនួន លើកលែងតែបុគ្គលជាប់អាករដែលមានអាជីវកម្មជាអ្នកផ្គត់ផ្គង់ផលិតផលតែលសិលាទាំងនោះ[4]

## ២.៤ គោលការណ៍នៃការប្រមូលអាករលើតម្លៃបន្ថែម

### ២.៤.១ និយមន័យពន្ធ

ពន្ធ(Taxation)៖ ជាវិភាគទានមានលក្ខណៈកាតព្វកិច្ច(ការចាប់បង្ខំ)ស្របតាមច្បាប់កំណត់ដែលអ្នកជាប់ពន្ធទាំងរូបវន្តបុគ្គល និងនីតិបុគ្គលត្រូវបង់ជូនរដ្ឋ។ ការយកពន្ធជាមធ្យោបាយជាក់ស្តែងមួយដែលរដ្ឋប្រើប្រាស់សម្រាប់បង្កើនចំណូលនិងបំពេញការចំណាយរបស់រដ្ឋ។[5]

### ២.៤.២ ប្រវត្តិពន្ធ

- ពន្ធដារបានដើរតួនាទីសំខាន់ក្នុងការបង្កើតប្រភពចំណូលរបស់ថវិកាជាតិ
- រដ្ឋាភិបាលយកចំណូលទៅ ទ្រទ្រង់ដល់ការចំណាយសាធារណៈនានា ដូចជាសង់សាលារៀន សង់មន្ទីរពេទ្យ ធ្វើផ្លូវថ្នល់ ធ្វើស្ពានធ្វើសួនច្បារ ធ្វើកន្លែងកំសាន្ត
- ការប្រមូលពន្ធបានច្រើនជានានូវនិរន្តភាពនៃការចំណាយរបស់រដ្ឋ
- ពន្ធដារត្រូវបានគេចាត់ទុកថាជា ឧបករណ៍សម្រាប់ទប់ស្កាត់ប្រភេទអាជីវកម្មណាមួយដើម្បីប្រយោជន៍រួមរបស់សង្គម

[4] ប្រកាសលេខ១០៣១.ប្រក.សហវ.ពដ ស្តីពីអាករលើតម្លៃបន្ថែម (១៥ខែតុលា ឆ្នាំ២០២៣)

[5] ច្បាប់សារពើពន្ធ(១៥ខែតុលា ឆ្នាំ២០២៣)

- ពន្ធដារក៏បានដើរតួនាទីសំខាន់ផងដែរក្នុងការពង្រឹងនិងជំរុញ ការអភិវឌ្ឍន៍ខឿនសេដ្ឋកិច្ចជាតិ ព្រោះថាពន្ធដារ បានជះឥទ្ធិពលដល់ការផលិតនិងប្រើប្រាស់នៅក្នុងខឿនសេដ្ឋកិច្ច
- ពន្ធដារត្រូវបានប្រើប្រាស់ធ្វជាឧបករណ៍សម្រាប់បង្ការបញ្ហាស្ថានភាពសេដ្ឋកិច្ច។ ពន្ធត្រូវបានចាត់ទុកថាជាឧបករណ៍ទប់ស្កាត់ប្រភេទអាជីវកម្មណាមួយដើម្បីជាប្រយោជន៍រួមដល់សង្គម។

ពន្ធដារជះឥទ្ធិពលដល់សេដ្ឋកិច្ចពីរផ្នែកជាអាទិ៍៖

ផលិតកម្ម៖ ពន្ធដារការពារឧស្សាហកម្មក្នុងស្រុក។ ប្រសិនបើអត្រាពន្ធត្រូវបង់ជូនរដ្ឋខ្ពស់នោះចំណង់ឬលទ្ធភាពនៃការវិនិយោគថយចុះ ក៏ប៉ុន្តែប្រសិនបើអត្រាពន្ធត្រូវបង់ជូនរដ្ឋថយចុះនោះចំណងឬលទ្ធភាពនៃការវិនិយោគកើនឡើងដែរ។

ការប្រើប្រាស់៖ ពន្ធដារជះឥទ្ធិពលដល់បរិមាណប្រាក់ចំណូលរបស់បុគ្គលម្នាក់ប្រសិនបើអត្រាពន្ធមានការប្រែប្រួល។ ប្រព័ន្ធពន្ធដែលល្អគឺប្រព័ន្ធពន្ធដែលធ្វើអោយគម្លាតរវាងអ្នកមាននិងអ្នកក្រនៅជិតបំផុត។ វត្ថុប្រើប្រាស់ចាំបាច់ខ្ពស់ដូចជាគ្រឿងឧបភោគបរិភោគប្រចាំថ្ងៃកម្រត្រូវបានគិតពន្ធ។

- ពន្ធដារក៏បានដើរតួនាទីសំខាន់ផងក្នុងការជួយលើកកម្ពស់សុខមាលភាពសង្គមជូនប្រជាពលរដ្ឋវិញទៅតាមលទ្ធភាពរបស់ប្រទេសនីមួយៗ
- ជាវិបាកពន្ធដារជុំរុញការអភិវឌ្ឍន៍រដ្ឋបាលកណ្តាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ បន្ថែមលើសពីនេះទៀតទំនិញដែលបានធ្វើឲ្យប៉ះពាល់ដល់សុខភាពមនុស្សដូចជា ស្រា បារី ត្រូវបានបង់ពន្ធចើនដែលធ្វើអោយប្រជាពលរដ្ឋកាត់បន្ថយប្រើប្រាស់
- សរុបមកពន្ធដារបានចូលរួមចំណែកយ៉ាងខ្លាំងយ៉ាងខ្លាំង ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិលើគ្រប់វិស័យ។រដ្ឋាភិបាលប្រមូលពន្ធដើម្បីយកជាប្រាក់ចំណូលសម្រាប់ចំណាយលើការគ្រប់គ្រងរដ្ឋ រួមទាំងសងបំណុលបរទេសផងដែរ
- ពន្ធដារបានមកពីការបែងចែកប្រាក់ចំណូលរបស់អ្នកជាប់ពន្ធ ពោលគឺអ្នកមានចំណូលច្រើនត្រូវបង់ពន្ធច្រើនចំណែកឯអ្នកមានចំណូលតិចត្រូវបង់ពន្ធតិច។[6]

**២.៤.៣ ប្រភេទពន្ធ**

១.ពន្ធលើប្រាក់ចំណូល

ត្រូវបានកំណត់លើអ្នកជាប់ពន្ធនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជា និងប្រាក់ចំណូលប្រភពបរទេស។ សម្រាប់អ្នកជាប់ពន្ធអនិវាសនជន ពន្ធលើប្រាក់ចំណូលកំណត់តែលើប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ។

ប្រាក់ចំណូលជាប់ពន្ធ គឺជាប្រាក់ចំណូលសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការអាជីវកម្មគ្រប់ប្រភេទរួមបញ្ចូលទាំងចំណូលមូលធនដែលសម្រេចបានក្នុងពេលកំពុងប្រកបអាជីវកម្ម ឬនៅពេលបញ្ចប់អាជីវកម្មព្រមទាំងប្រាក់ចំណូលពីទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យសកម្មវិនិយោគការប្រាក់ថ្លៃឈ្នួលនិងសួយសារផង។ ប្រាក់ចំណូលជាប់ពន្ធក៏រួមបញ្ចូលផងដែរនូវចំណូលមូលធនទាំងអស់ពីអចលនទ្រព្យ ទ្រព្យហិរញ្ញវត្ថុ ឬទ្រព្យវិនិយោគ ដែលសម្រេចបានមកពីប្រតិបត្តិ ការនានាក្រៅពីប្រតិបត្តិការអាជីវកម្ម។

អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំមានដូចតទៅ៖

១-២០ភាគរយចំពោះប្រាក់ចំណូលដែលសម្រេចបានដោយនីតិបុគ្គល

[6] History of Taxes/Tax EDU/Tax Foundation (20-10-2023)

២- ៣០ភាគរយចំពោះប្រាក់ចំណូល ដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័ន ធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិរួមទាំង ព្រៃឈើ រ៉ែ មាសឬត្បូងថ្មមានតម្លៃនានា

៣- ០ភាគរយចំពោះប្រាក់ចំណូលរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធដែលកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៤- តាមអត្រាពន្ធកំណើនតាមថ្នាក់ខាងក្រោមចំពោះប្រាក់ចំណូលដែលសម្រេចបានដោយរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល និងចំណែកដែលត្រូវបែកចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល

| ភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០ ៛ | ដល់ | ១៦ ០០០ ០០០ ៛ | ០% |
| ពី | ១៦ ០០០ ០០១ ៛ | ដល់ | ២៤ ០០០ ០០០ ៛ | ៥% |
| ពី | ២៤ ០០០ ០០១ ៛ | ដល់ | ១០២ ០០០ ០០០ ៛ | ១០% |
| ពី | ១០២ ០០០ ០០១ ៛ | ដល់ | ១៥០ ០០០ ០០០ ៛ | ១៥% |
| ពី | លើលពី | | ១៥០ ០០០ ០០០ ៛ | ២០% |

៥- ចំពោះសហគ្រាសដែលមានសកម្មភាពជាសំខាន់ក្នុងការធានារ៉ាប់រងឬ ធានារ៉ាប់រងបន្តលើជីវិត ទ្រព្យសម្បត្តិឬហានិភ័យផ្សេងៗពន្ធលើប្រាក់ចំណូលត្រូវបានកំណត់ខាងក្រោមៈ

ក. ៥% នៃបុព្វលាភធានារ៉ាប់រងដុលដែលទទួលបាននៅក្នុងឆ្នាំជាប់ជាប់ពន្ធ ចំពោះការធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬនូវហានិភ័យផ្សេងៗនៅព្រះរាជណាចក្រកម្ពុជាៗ

ខ. ចំពោះសកម្មភាពធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើជីវិតដែលមានលក្ខណៈសន្សំ និងសកម្មភាពដទៃទៀតក្រៅពីធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗ

២.ពន្ធប៉ាតង់

ពន្ធប៉ាតង់ជាពន្ធកំណត់លើផលរបរសុបប្រចាំឆ្នាំដែលត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។ អ្នកជាប់ពន្ធដែលទើបចាប់ផ្តើមប្រកបអាជីវកម្មត្រូវបង់ពន្ធប៉ាតង់ពេញមួយឆ្នាំ ប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល៦ខែដើមឆ្នាំ ឬបង់ពន្ធប៉ាតង់ពាក់កណ្តាលឆ្នាំ ប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល៦ខែចុងឆ្នាំ។

៣.អាករលើតម្លៃបន្ថែម

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលធ្វើការផ្គត់ផ្គង់ជាប់អាករត្រូវមានកាតព្វកិច្ចចុះបញ្ជីអាករលើតម្លៃបន្ថែម ប្រមូលអាករតម្លៃបន្ថែមលើការផ្គត់ផ្គងទំនិញឬសេវាឱ្យអតិថិជន។ ទំនិញសំដៅដល់ទ្រព្យរូបីក្រៅពីដីធ្លីនិងប្រាក់កាសរីឯសេវាសំដៅដល់ការផ្តល់អ្វីមួយដែលមានតម្លៃក្រៅពីទំនិញដីធ្លីនិងប្រាក់កាស។[7]

[7] អគ្គនាយកដ្ឋានពន្ធដារ/ទំព័រដើម/(tax.gov.kh)(20-10-2023)

៤.ពន្ធអប្បបរមា

ពន្ធអប្បបរមាជាពន្ធមួយដាច់ដោយឡែកនិងផ្សេងៗពីពន្ធលើប្រាក់ចំណេញ។ ពន្ធនេះត្រូវបង់ដោយអ្នកជាប់ពន្ធ តាមរបបស្វ័យប្រកាស លើកលែងតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមអត្រា១ភាគរយលើផលរបរ ប្រចាំឆ្នាំរួមបញ្ចូលទាំងពន្ធអាករនានារៀលែងតែអាករលើតម្លៃបន្ថែម។ ពន្ធនេះត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ហើយអាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ។

៥.ពន្ធប្រាក់បៀវត្ស

ពន្ធលើប្រាក់បៀវត្សគឺជាពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្សដែលរូបវន្តបុគ្គលបានទទួលក្នុងក្របខណ្ឌនៃការបំពេញសកម្មភាពបំរើការងារ។ រូបវន្តបុគ្គលនិងនិវាសនជននៅក្នុងព្រះរាជណាចក្រកម្ពុជាត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជានិងប្រាក់បៀវត្សប្រភពបរទេស។ រូបវន្តបុគ្គលអនិវាសនជនត្រូវជាប់ពន្ធលើប្រាល់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា។ សហគ្រាសដែលជានិយោជកត្រូវមានកាតព្វកិច្ចកាត់ទុកពន្ធលើប្រាក់បៀវត្សនៅមុនពេល បើកប្រាក់បៀវត្សឱ្យដល់និយោជិត និងបង់ប្រាក់ពន្ធនេះជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតនៅថ្ងៃទី២០ នៃខែបន្ទាប់ ពីខែដែលប្រាក់បៀវត្សត្រូវបើក។ សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែនិងត្រូវកាត់ទុកតាមអត្រាកំណើនតាមថ្នាក់ដូចតទៅ៖

សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែនិងត្រូវកាត់ទុកតាមអត្រាកំណើនតាមថ្នាក់ដូចតទៅ៖

| ភាគនៃបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | 0 ៛ | ដល់ | ១ ៥00 000 ៛ | 0% |
| ពី | ១ ៥00 00១ ៛ | ដល់ | ២ 000 000 ៛ | ៥% |
| ពី | ២ 000 00១ ៛ | ដល់ | ៨ ៥00 000 ៛ | ១0% |
| ពី | ៨ ៥00 00១ ៛ | ដល់ | ១២ ៥00 000 ៛ | ១៥% |
| ពី | លើលពី | | ១២ ៥00 000 ៛ | ២0% |

សម្រាប់និយោជិតអនិវាសនជន ពន្ធលើប្រាក់បៀវត្សត្រូវបានកាត់ទុកតាមអត្រា ២0% នៃទឹកប្រាក់ត្រូវបើកឱ្យមុនការកាត់ទុក។ ពន្ធកាត់ទុកនេះគឺជាពន្ធចុងក្រោយនៃប្រាក់បៀវត្សសម្រាប់អនិវាសនជនជាអ្នកទទួលប្រាក់បៀវត្ស។ ចំពោះអត្ថប្រយោជន៍ជារៀងរាល់ខែ សហគ្រាស ក្រុមហ៊ុនត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធតាមអត្រា២0% នៃតម្លៃសរុបរបស់អត្ថប្រយោជន៍បន្ថែមដែលបានផ្តល់ឲ្យនិយោជិតទាំងអស់។ តម្លៃនៃអត្ថប្រយោជន៍បន្ថែមគឺជាតម្លៃទីផ្សាររួមទាំងពន្ធអាករទាំងអស់។[8]

[8] អគ្គនាយកដ្ឋានពន្ធដារ/ទំព័រដើម/(tax.gov.kh)(20-10-2023)

៦.អាករពិសេសលើទំនិញ និង សេវាមួយចំនួន

អាករពិសេសលើទំនិញ និងសេវាមួយចំនួន ត្រូវបានកំណត់លើទំនិញនិងសេវាមួយចំនួន។ ទំនិញដែលជាប់អាករនេះរួមមាន៖ ស្រា(៣៥%) ស្រាបៀរ(៣០%) និងបារី(២០%)។ ចំពោះសេវាដែលជាប់អាករនេះមានសេវាលំហែកម្សាន្តនិងសេវាដឹកអ្នកដំណើរតាមផ្លូវអាកាស(១០%) និងសេវាទូរស័ព្ទ(៣%)។ អ្នកជាប់ពន្ធដែលផលិតទំនិញ ឬផ្គត់ផ្គង់សេវាទាំងនេះត្រូវទទួលខុសត្រូវការបង់ប្រាក់អាករនេះជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។

៧.ពន្ធប្រថាប់ត្រា

- ពន្ធប្រថាប់ត្រាត្រូវកំណត់តាមអត្រា៤% ចំពោះការផ្ទេរកម្មសិទ្ធអចលនទ្រព្យ ឬការការផ្ទេរសិទ្ធិកាន់កាប់ដីដែលគ្មានសំណង់ក្រោមរូបភាពជាការលក់ការដោះដូរការទទួលអំណោយការដាក់ភាគទុនក្រុមហ៊ុន។
- ត្រូវជាប់ពន្ធប្រថាប់ត្រាតាមអត្រាសមាមាត្រ៤% ចំពោះការផ្ទេរកម្មសិទ្ធិមធ្យោបាយដឹកជញ្ជូន និងយានជំនិះ ដូចខាងក្រោម៖
  - រថយន្តដឹកទំនិញធុនធ្ងន់ រថយន្តដឹកទំនិញធុនស្រាល រថយន្ត ទោចក្រយានយន្ត
  - កាណូត សាឡាង កាប៉ាល់
- លិខិតមានលក្ខណៈគតិយុត្តិដូចខាងក្រោម ត្រូវជាប់ពន្ធប្រថាប់ត្រា៖

| | |
|---|---|
| -លិខិតស្តីពីការបង្កើតក្រុមហ៊ុន | ១,០០០,០០០ រៀល |
| -លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា | ១,០០០,០០០ រៀល |
| -លិខិតស្តីពីការបិទក្រុមហ៊ុន | ១,០០០,០០០ រៀល |

- ០,១% នៃតម្លៃចុះកិច្ចសន្យាចំពោះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវាដែលប្រើប្រាស់ថវិការដ្ឋ
- ០,១% នៃតម្លៃភាគហ៊ុនចំពោះការផ្ទេរចំណែកណាមួយ ឬ ទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន

ពន្ធប្រថាប់ត្រាត្រូវបានបង់ដោយអ្នកទទួលកម្មសិទ្ធ ទទួលសិទ្ធកាន់កាប់ដីធ្លីដែលគ្មានសំណង់ គិតជាសមាមាត្រ លើតម្លៃពិតប្រាកដនៃទ្រព្យសម្បត្តិនាថ្ងៃផ្ទេរកម្មសិទ្ធនិងសិទ្ធិកាន់កាប់។ ប៉ុន្តែដើម្បីឲ្យមានភាពងាយស្រួល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចកំណត់តម្លៃសម្រាប់រយៈកាលនីមួយៗ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការគិតគូរប្រាក់ពន្ធដែលត្រូវបង់។

៨.ពន្ធលើដីធ្លីមិនបានប្រើប្រាស់

ពន្ធនេះកំណត់លើដីដែលគ្មានសំណង់ និងដីដែលមានសំណង់បោះបង់ស្ថិតក្នុងទីក្រុងនានានិងក្នុងតំបន់ទាំងឡាយ ដែលកំណត់ដោយគណៈកម្មការវាយតម្លៃមិនបានប្រើប្រាស់។ ពន្ធដីធ្លីលើដីមិនបានប្រើប្រាស់ត្រូវបង់ដោយកម្មសិទ្ធករ។ មូលដ្ឋានកំណត់ពន្ធគឺជាថ្លៃដីគិតតាមថ្លៃទីផ្សារតាមទីក្រុង និងតាមតំបន់នីមួយៗដែលវាយតម្លៃទៅតាមតម្លៃគិត ក្នុងមួយម៉ែត្រក្រឡាកំណត់ដោយគណៈកម្មការ វាយតម្លៃដីមិនបានប្រើប្រាស់យ៉ាងយឺតបំផុត នៅថ្ងៃទី៣០ ខែមិថុនា នៃឆ្នាំប្រមូលពន្ធ។[9]

[9] អគ្គនាយកដ្ឋានពន្ធដារ/ទំព័រដើម/(tax.gov.kh)(20-10-2023)

ពន្ធនេះត្រូវកំណត់តាមអត្រា២% លើមូលដ្ឋានកំណត់ពន្ធដែលបានបែងចែកក្នុងមាត្រា៣០។ កម្មសិទ្ធករនៃដីធ្លីជាប់ពន្ធមានភារកិច្ចត្រូវគណនាប្រាក់ពន្ធតាមគំរូលិខិតប្រកាសផ្តល់ដោយអង្គការពន្ធ និងត្រូវបង់យ៉ាងយឺតបំផុតនៅថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំនីមួយៗជូនទៅផ្នែកពន្ធនៅកន្លែងដែលដីធ្លីជាប់ពន្ធស្ថិតនៅ។ ដីធ្លីជាប់ពន្ធនីមួយៗត្រូវធ្វើលិខិតប្រកាស០១ច្បាប់។

៩.អាករលើការស្នាក់នៅ

ត្រូវបានកំណត់តាមអត្រា២% លើការស្នាក់នៅក្នុងសណ្ឋាគារ ផ្ទះសំណាក់ ក្នុងព្រះរាជាណាចក្រកម្ពុជា។ អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់សេវាស្នាក់នៅត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករនេះជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។

១០.អាករបំភ្លឺសាធារណៈ

ត្រូវបានកំណត់តាមអត្រា ៣%លើការផ្គត់ផ្គង់គ្រប់ដំណាក់កាលនូវ សុរាមេរ័យ និងបារី។ អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ផលិតផលទាំងនេះត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករនេះជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។

១១.ពន្ធកាត់ទុក

ពន្ធកាត់ទុកទូទៅត្រូវបានកំណត់ដូចតទៅៈ

អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុ ឲ្យដល់អ្នកជាប់ពន្ធនិវាសនជនត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ដូចខាងក្រោមលើការទូទាត់មុនការកាត់ទុកប្រាក់ពន្ធៈ

- អត្រា១៥% ចំពោះប្រាក់ចំណូលដែលរូបវន្តបុគ្គលបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែលសួយសារចំពោះទ្រព្យអរូបី និងភាគកម្មក្នុងធនធានរ៉ែ ហើយនិងការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្មដែលមិនមែនជាធនាគារ ឬស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ឲ្យទៅអ្នកជាប់ពន្ធនិវាសនជន
- អត្រា ១០% ចំពោះប្រាក់ចំណូលពីការឲ្យជួលចលន ឬអចលនទ្រព្យ
- អត្រា ៦% ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ឲ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីបញ្ញើមានកាលកំណត់
- អត្រា ៤% ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ឲ្យទៅអ្នកជាប់ពន្ធនិវាសនជនដែល មានគណនីសន្សំគ្មានកាលកំណត់
- ការកាត់ទុកក្នុងមាត្រានេះមិនត្រូវអនុញ្ញាតចំពោះការប្រាក់ដែលបង់ឲ្យធនាគារ និងស្ថាប័នសញ្ញ័យធនក្នុងស្រុក និងការទូទាត់ចំពោះប្រាក់ចំណូលលើកលែងពន្ធដូចមានចែងក្នុងមាត្រា៩ ថ្មី នៃច្បាប់នេះ។ អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានទូទាត់ប្រាក់ចំណូលខាងក្រោមនេះ ឲ្យទៅអ្នកជាប់ពន្ធអនិវាសនជន ត្រូវកាត់ទុក និងបង់នូវប្រាក់ពន្ធ ចំនួន ១៤%នៃទឹកប្រាក់ត្រូវបើកៈ[10]

[10] អគ្គនាយកដ្ឋានពន្ធដារ/ទំព័រដើម/(tax.gov.kh)(20-10-2023)

- ការប្រាក់
- សួយសារ ថ្លៃឈ្នួល និងប្រាក់ចំណូលផ្សេងៗ ទាក់ទិននឹងការប្រើប្រាស់ទ្រព្យសម្បត្តិ
- ការទូទាត់ចំពោះសេវាគ្រប់គ្រងនិងសេវាបច្ចេកទេសនានាដែលនិងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ភាគលាភ

ពន្ធកាត់ទុកលើការទូទាត់ឲ្យដល់អ្នកជាប់ពន្ធនិវាសនជនតាមមាត្រា ២៥ថ្មី នៃច្បាប់នេះ និងពន្ធកាត់ទុកលើការទូទាត់ឲ្យដល់អនិវាសនជនតាមមាត្រា២៦ ថ្មីនៃច្បាប់នេះ ត្រូវចាត់ទុកថាជាពន្ធចុងក្រោយសម្រាប់អ្នកទទួលការទូទាត់ដែលមានបញ្ជាក់ក្នុងមាត្រាទាំង២ ខាងលើនេះ។

១២.ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

ពន្ធនេះត្រូវអនុវត្តទៅលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ។ អត្រាពន្ធ និងរយៈពេលត្រូវបង់ ត្រូវកំណត់តាមការប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[11]

[11] អគ្គនាយកដ្ឋានពន្ធដារ/ទំព័រដើម/(tax.gov.kh)(20-10-2023)

# ជំពូកទី ៣
# ការគ្រប់គ្រងចំណូលអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ
## ៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ
### ៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ



អគ្គនាយកដ្ឋានពន្ធដារដំបូងឡើយមានឈ្មោះថា នាយកដ្ឋានពន្ធដារបានបង្កើតឡើងក្នុងឆ្នាំ១៩៥៣ តែត្រូវបានលុបបំបាត់វិញក្នុងរបបប្រល័យពូជត្រូវបានដួលរលំ នាយកដ្ឋានពន្ធដារបានបង្កើតឡើងវិញក្នុងឆ្នាំ១៩៨០សាសន៍ក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ក្រោយរបបប្រល័យពូជសាសន៍បន្ទាប់មកនាយកដ្ឋានពន្ធដារបានដំឡើងឈ្មោះទៅជាអគ្គនាយកដ្ឋានពន្ធដារក្នុងឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្នស្ថិតក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ៣.១.២ គោលនយោបាយនការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ

គោលនយោបាយនៃការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារគឺ ដើម្បីបង្កើនប្រសិទ្ធិភាពកិច្ចដំណើរការការងារ និងប្រព័ន្ធការងារដែលមានភាព ច្បាស់លាស់ ទំនើប និង មានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន ក្នុងការគ្រប់គ្រងតាមរយៈគោលនយោបាយ។

**តួនាទី និង ភារកិច្ច**

អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចជាអាទិ៍ដូចតទៅៈ

- រៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាននានាស្តីពីពន្ធដារ កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការ ដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សារទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដោយផ្អែកលើការអង្កេត និងចុំព័ត៌មាន
- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងចំណូលផ្សេងៗ
- កសាងកម្មវិធី និងអនុវត្តការងារសេវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហការប្រតិបត្តិការអន្តរជាតិក្នុងផ្នែកពន្ធ
- អនុវត្តទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុក ដែលល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូនទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។

### ៣.១.៣ រចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ

**រចនាសម្ព័ន្ធនៃស្ថាប័ន**

- **អង្គការលេខរបស់អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**




**រចនាសម្ព័ន្ធនៃការគ្រប់គ្រង**

ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

ឯកឧត្តម **អ៊ុំ សីហា** អគ្គនាយករង

ឯកឧត្តម **ជាប ជាវុធ** អគ្គនាយករង

ឯកឧត្តម **ម៉ិញ ធានកុសល** អគ្គនាយករង

ឯកឧត្តម **កែន សម្បត្តិ** អគ្គនាយករង

ឯកឧត្តម **ហេង សុខណាង** អគ្គនាយករង

លោកជំទាវ **ម៉ុន នារី** អគ្គនាយករង

ឯកឧត្តម **រ័ត្ន មុនី** អគ្គនាយករង

ឯកឧត្តម **លីម ជីលុច** អគ្គនាយករង

ឯកឧត្តម **លីម ហ៊ុយជីវ** អគ្គនាយករង

## នាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ

1. នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
2. នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក
3. នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ
4. នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ
5. នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

6. នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ
7. នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
8. នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យម
9. នាយកដ្ឋានសវនកម្មសហគ្រាស
10. សាលាជាតិពន្ធដារ
11. ទីចាត់ការពន្ធដាររាជធានីភ្នំពេញ

**សាខាពន្ធដារខណ្ឌ-ខេត្ត**

1. សាខាពន្ធដារខណ្ឌ ឫស្សីកែវ
2. សាខាពន្ធដារខណ្ឌ ដូនពេញ
3.សាខាពន្ធដារខណ្ឌ ៧មករា
4. សាខាពន្ធដារខណ្ឌ មានជ័យ
5. សាខាពន្ធដារខណ្ឌ ចំការមន
6. សាខាពន្ធដារខណ្ឌ ទួលគោក
7. សាខាពន្ធដារខណ្ឌ ដង្កោ
8. សាខាពន្ធដារខណ្ឌ សែនសុខ
9. សាខាពន្ធដារខណ្ឌ ពោធិ៍សែនជ័យ
10. សាខាពន្ធដារខេត្ត កណ្តាល
11. សាខាពន្ធដារខេត្ត កំពង់ចាម
12. សាខាពន្ធដារខេត្ត បាត់ដំបង
13. សាខាពន្ធដារខេត្ត ព្រៃវែង
14. សាខាពន្ធដារខេត្ត សៀមរាប
15. សាខាពន្ធដារខេត្ត កំពង់ធំ
16. សាខាពន្ធដារខេត្ត តាកែវ
17. សាខាពន្ធដារខេត្ត ស្វាយរៀង
18, សាខាពន្ធដារខេត្ត ពោធិ៍សាត់
19, សាខាពន្ធដារខេត្ត កំពង់ឆ្នាំង
20, សាខាពន្ធដារខេត្ត កំពង់ស្ពឺ
21. សាខាពន្ធដារខេត្ត កំពត
22. សាខាពន្ធដារខេត្ត ព្រះសីហនុ
23. សាខាពន្ធដារខេត្ត កោះកុង
24.សាខាពន្ធដារខេត្ត ព្រះវិហារ

25. សាខាពន្ធដារខេត្ត ក្រចេះ
26. សាខាពន្ធដារខេត្ត រតនគិរី
27. សាខាពន្ធដារខេត្ត មណ្ឌលគិរី
28. សាខាពន្ធដារខេត្ត បន្ទាយមានជ័យ
29. សាខាពន្ធដារខេត្ត ស្ទឹងត្រែង
30. សាខាពន្ធដារខេត្ត កែប
31. សាខាពន្ធដារខេត្ត ប៉ៃលិន
32. សាខាពន្ធដារខេត្ត ឧត្តរមានជ័យ
33. សាខាពន្ធដារខេត្ត ត្បូងឃ្មុំ

**៣.១.៤ ទស្សនៈវិស័យ និង បេសកម្ម**

**ទស្សនៈវិស័យ** (Vision)

ចំពោះទស្សនៈវិស័យរបស់អគ្គនាយកដ្ឋានពន្ធដារ គឺធ្វើឲ្យមានការទទួលស្គាល់ និងគោរពពីសំណាក់អ្នកជាប់ពន្ធ ចំពោះភាគីត្រឹមត្រូវ និងគុណភាពនៃការគ្រប់គ្រង។

**បេសកម្ម** (Mission)

អគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មធ្វើឲ្យសម្រេចការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារតាមការៈ

- ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឲ្យអ្នកជាប់ពន្ធប្រតិបត្តិតាមត្រឹមត្រូវ តាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- អនុវត្តតាមកម្មវិធីចាប់បង្ខំ ដោយធ្វើសវនកម្ម ការអនុវត្តវិធានការតឹងទារ និងអនុវត្តទោសទណ្ឌតាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារ  ចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ប្រមូលចំណូលពន្ធ តាមការអនុវត្តត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ
- ផ្តល់សេវា និងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាឲ្យច្បាប់នានាស្តីពីពន្ធដារត្រូវបានគោរព និងអនុវត្តត្រឹមត្រូវ
- អនុវត្តតាមកម្មវិធីចាប់បង្ខំ ដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នាចំពោះអ្នកជាប់ពន្ធដែលមិនគោរពច្បាប់ និងបទបញ្ញត្តិស្តីពីសារពើពន្ធ
- អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ដើម្បីបង្កើនការជឿទុកចិត្តចំពោះរដ្ឋបាលសារពើពន្ធ
- បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធ ក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ខ្លួនធ្វើឲ្យមានភាពសាមញ្ញចំពោះតម្រូវការផ្សេងៗ និងបន្ថយការចំណាយរបស់អ្នកជាប់ពន្ធ

- បង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីបំពេញការងារឲ្យមានប្រសិទ្ធភាព
- បង្កើនសមត្ថភាពចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីបំពេញការងារឲ្យមានភាពប្រសើរឡើង និងមានប្រសិទ្ធភាព
- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងតាមរយៈ គោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធការងារដែលមានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន។

## ៣.២ បុគ្គលដែលត្រូវចុះបញ្ជីអាករលើតម្លៃបន្ថែម

- ក្រុមហ៊ុនដើមទុន អ្នកនាំចេញនាំចូល និងសហគ្រាសវិនិយោគទាំងអស់ត្រូវមានកាតព្វកិច្ចចុះបញ្ជី
- អាករលើតម្លៃបន្ថែមចាប់ពីថ្ងៃចាប់ផ្តើមប្រកបអាជីវកម្ម។ បុគ្គលណាដែលបានបង្កើតសហគ្រាសអាជីវកម្ម
- ឬមានបំណងបង្កើតសហគ្រាសអាជីវកម្មប្រសិនបើមាន ឬ រំពឹងថានឹងមានផលរបរជាប់អាករក្នុងរយៈពេលបីខែប្រតិទិនជាប់គ្នាលើសពី១២៥លានរៀលសម្រាប់ការផ្គត់ផ្គង់ទំនិញ និងលើសពី៦០លានរៀលសម្រាប់ការផ្គត់ផ្គង់សេវា បុគ្គលនោះអាចធ្វើការស្នើសុំចុះបញ្ជីអាករលើតម្លៃបន្ថែមបាន។ ម្យ៉ាងវិញទៀតក្នុងរយៈពេលដូចគ្នានេះ បុគ្គលណាដែលមានផលរបរជាប់អាករបានមកពីការចុះកិច្ចសន្យាជាមួយរដ្ឋលើសពី ៣០លានរៀលបុគ្គលនោះត្រូវតែចុះបញ្ជីអាករលើតម្លៃបន្ថែម។
- សម្រាប់គោលដៅនៃការចុះបញ្ជីអាករលើតម្លៃបន្ថែមពាក្យ "បុគ្គល" សំដៅដល់៖
- សហគ្រាសឯកបុគ្គល
- ក្រុមហ៊ុនសហកម្មសិទ្ធិ
- ក្រុមហ៊ុនឯកជន
- ក្រុមហ៊ុនមហាជន
- ក្រុមហ៊ុនចំរុះ
- ក្រុមអាជីវកម្ម
- ក្លឹប ឬ សមាគម ។ល។
- ពាក្យ "សហគ្រាសអាជីវកម្ម" សំដៅដល់អាជីវកម្មគ្រប់ប្រភេទដូចជា៖
  ក. អាជីវកម្មធម្មតា៖ ហាងលក់ទំនិញ អ្នកម៉ៅការ អ្នកផលិត អ្នកលក់ដុំ អ្នកផ្តល់សេវាផ្សេងៗ -ល-។
  ខ. ការធ្វើអាជីវកម្មនិងវិជ្ជាជីវៈ ៖ ស្ថាបត្យករ វិស្វករ គណនេយ្យករ មេធាវី -ល-។
  គ. សកម្មភាពដែលធ្វើឡើងដោយអង្គភាពមិនស្វែងរកចំណេញនានា៖ សហគម សមាគម ក្លឹបកីឡា-ល-។

## ៣.៣ វិធាន និងនីតិវិធីរបស់ពន្ធដារសម្រាប់ការចុះបញ្ជីអាករលើតម្លៃបន្ថែម

**៣.២.១ ភាតព្វកិច្ចចុះបញ្ជី** *(យោងតាមប្រកាស ប្រការ១)*

១. ដូចមានចែងក្នុងមាត្រា៥៩ និងមាត្រា៧៦ នៃច្បាប់សារពើពន្ធ អ្នកជាប់ពន្ធតាមរបបពិត ដែលបានធ្វើការផ្គត់ផ្គង់ជាប់អាករដូចមានចែងក្នុងប្រការ៦០ នៃច្បាប់សារពើពន្ធ គឺជាបុគ្គលជាប់អាករ។ បុគ្គលដូចមានចែងក្នុងវាក្យខ័ណ្ឌ ក នៃកថាខណ្ឌនេះ ត្រូវដាក់ពាក្យស្នើសុំទៅនាយកដ្ឋានពន្ធដារ ដើម្បីធ្វើការចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែមមុនពេលចាប់ផ្តើមប្រកបអាជីវកម្ម។ បុគ្គលដទៃទៀតត្រូវដាក់ពាក្យស្នើសុំទៅនាយកដ្ឋានពន្ធដារ ដើម្បីធ្វើការចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែមឲ្យបានស្រេចបាច់ក្នុងរយៈពេល៣០ថ្ងៃក្រោយថ្ងៃដែលបុគ្គលនោះក្លាយជាបុគ្គលជាប់អាករ។បុគ្គលទាំងនោះរួមមាន៖

- ក្រុមហ៊ុនគ្រប់ប្រភេទ សហគ្រាសនិហរ័ណអាហរ័ណ និងសហគ្រាសវិនិយោគទាំងអស់។
- សហគ្រាសដទៃទៀតដែលមានផលរបរជាប់ អតប ក្នុងរយៈពេល៣ខែប្រតិទិនជាប់គ្នាណាមួយចាប់ពី១២៥លានរៀលឡើងទៅសម្រាប់ការផ្គត់ផ្គង់ទំនិញ ឬចាប់ពី៦០លានរៀលឡើងទៅសម្រាប់ការផ្គត់ផ្គង់សេវា។
- សហគ្រាសទាំងឡាយដែលក្នុងពេលចាប់ផ្តើមនៃរយៈពេល៣ខែប្រតិទិនជាប់គ្នាណាមួយ មានមូលដ្ឋានជឿជាក់ថាក្នុងរយៈពេល៣ខែប្រតិទិនជាប់គ្នានោះ នឹងមានផលរបរជាប់ អតប ចាប់ពី១២៥លានរៀលឡើងទៅសម្រាប់ការផ្គត់ផ្គង់ទំនិញ ឬចាប់ពី៦០លានរៀលឡើងទៅសម្រាប់ការផ្គត់ផ្គង់សេវា។
- សហគ្រាសទាំងឡាយដែលក្នុងពេលចាប់ផ្តើមនៃរយៈពេល ៣ខែប្រតិទិនជាប់គ្នាណាមួយមានមូលដ្ឋានជឿជាក់ថាក្នុងរយៈពេល៣ខែប្រតិទិនជាប់គ្នានោះ និងមានផលរបរជាប់ អតប បានពីការធ្វើកិច្ចសន្យាជាមួយរដ្ឋ ចាប់ពី៣០លានរៀលឡើងទៅ។
- ក្នុងករណីដែលបុគ្គលធ្វើការផ្គត់ផ្គង់ទំនិញផង ផ្គត់ផ្គង់សេវាផង មានផលរបរជាប់អាករលើសពីកំរិតអប្បបរមានៃផលរបរត្រូវចុះបញ្ជីដែលបានកំណត់ក្នុងវាក្យខ័ណ្ឌ ខ វាក្យខ័ណ្ឌ គ និងវាក្យខ័ណ្ឌ ឃ នៃកថាខណ្ឌ ១ នៃប្រការនេះ បុគ្គលនោះត្រូវដាក់ពាក្យស្នើសុំចុះបញ្ជី។

សម្រាប់គោលដៅនៃបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ៖

- ពាក្យ ផលរបរជាប់អាករ សំដៅដល់ផលរបរដែលបានមកពីការផ្គត់ផ្គង់ជាប់អាករនូវទំនិញ ឬសេវា ឬការចុះកិច្ចសន្យាជាមួយរដ្ឋ ដោយមិនទាន់គិតបញ្ចូលអាករទេ។
- ពាក្យ អាករ មានន័យថា អាករលើតម្លៃបន្ថែម ហៅកាត់ថា អតប ។

២. កំរិតអប្បបរមានៃផលរបរជាប់អាករប្រចាំឆ្នាំ សម្រាប់ការចុះបញ្ជីអនុវត្តចំពោះបុគ្គលដែលមិនមានលក្ខណៈជា ក្រុមហ៊ុន សហគ្រាស អាហ័រណ-នីហ័រណ ឬ សហគ្រាសវិនិយោគ គឺ៥០០លានរៀលសម្រាប់ការផ្គត់ផ្គង់ទំនិញ២៥០លានរៀលសម្រាប់ការផ្គត់ផ្គង់សេវា និង១២៥លានរៀលសម្រាប់ការធ្វើកិច្ចសន្យាជាមួយនឹងរដ្ឋ។

៣. ស្ថាប័នរដ្ឋ ឬអង្គភាពរបស់ស្ថាប័នរដ្ឋគ្រប់លំដាប់ថ្នាក់ ដែលធ្វើសកម្មភាពអាជីវកម្មក្រោមរូបភាពស្វ័យភាពកិបាលសេដ្ឋកិច្ច ត្រូវដាល់ពាក្យស្នើសុំធ្វើការចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែមឲ្យបានស្រេចបាច់ក្នុងរយៈពេល៣០ថ្ងៃក្រោយថ្ងៃដែលស្ថាប័នរដ្ឋ ឬអង្គភាពនោះក្លាយជាបុគ្គលជាប់អាករ។

៤. បុគ្គលណាមួយដែលធ្វើការផ្គត់ផ្គង់ទំនិញ ឬសេវា ដោយមានតម្លៃដែលជាចំណែកមួយនៃសកម្មភាពអាជីវកម្មរបស់ខ្លួន ហើយដែលមិនស្ថិតក្រោមកាតព្វកិច្ចចុះបញ្ជីតាមការតម្រូវនៃកថាខ័ណ្ឌ១ ឬកថាខ័ណ្ឌ៣ នៃប្រការនេះបុគ្គលនោះអាចធ្វើការស្នើសុំទៅនាយកដ្ឋានពន្ធដារ ដើម្បីចុះបញ្ជីស្របទៅតាមបទប្បញ្ញត្តិនៃផ្នែកទី២ នៃប្រកាសនេះ។

**៣.២.២ គោលការណ៍ស្តីពីការចុះបញ្ជី** *(យោងតាមព្រះរាជក្រម មាត្រា៧៦)*

គោលការណ៍ស្តីពីការចុះបញ្ជីត្រូវបានកំណត់ដូចតទៅ៖

១- បុគ្គលជាប់អាករដូចមានចែងក្នុងមាត្រា៥៩ នៃច្បាប់នេះត្រូវធ្វើការចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែមឲ្យបានស្រេចបាច់ក្នុងរយៈពេល៣០ថ្ងៃ ក្រោយថ្ងៃដែលបុគ្គលជាប់អាករ។ វិធាន និងនីតិវិធីសម្រាប់ការចុះបញ្ជីនេះត្រូវកំណត់ដោយអនុក្រឹត្យ។

២- ចំពោះបុគ្គលដែលមានការតម្រូវឲ្យចុះបញ្ជីហើយដែលមិនបានធ្វើការចុះបញ្ជីនោះ រដ្ឋបាលសារពើពន្ធអាចធ្វើការចុះបញ្ជីបុគ្គលនោះ ចាប់តាំងពីពេលដែលបុគ្គលនោះត្រូវមកធ្វើការចុះបញ្ជី។ បុគ្គលដែលត្រូវបានចុះបញ្ជីតាមបែបនេះត្រូវមានការទទួលខុសត្រូវចំពោះប្រាក់អាករទាំងអស់ក្នុងមាត្រា៦៤ នៃច្បាប់នេះចាប់តាំងពីកាលបរិច្ឆេទដែលបុគ្គលនោះត្រូវមកធ្វើការចុះបញ្ជី។

៣- បើសិនជាបុគ្គលជាប់អាករណាមួយដែលបានចុះបញ្ជីតាមមាត្រានេះ យល់ឃើញថាខ្លួនមិនត្រូវជាបុគ្គលជាប់អាករសម្រាប់ឆ្នាំចរន្ត និងឆ្នាំបន្ទាប់ទេ បុគ្គលនោះអាចដាក់ពាក្យសុំលុបការចុះបញ្ជីវិញ។

៤- សម្រាប់ក្រុមបុគ្គលទាក់ទិន២នាក់ ឬច្រើននាក់ ដែលក្នុងនោះបុគ្គលម្នាក់ឬច្រើននាក់មិនអាចជាបុគ្គលជាប់អាករទេនោះ រដ្ឋបាលសារពើពន្ធចាត់ទុកបុគ្គលជាប់អាករណាមួយថាបានចុះបញ្ជីសម្រាប់សកម្មភាពសេដ្ឋកិច្ចទាក់ទិនទាំងមូល ឬភាគណាមួយ។ បើសិនជាគ្មានបុគ្គលទាក់ទិនណាម្នាក់ជាបុគ្គលជាប់អាករទេនោះ រដ្ឋបាលសារពើពន្ធអាចចុះបញ្ជីនូវបុគ្គលក្នុងក្រុម ម្នាក់ឬច្រើននាក់ សម្រាប់សកម្មភាពសេដ្ឋកិច្ចទាក់ទិនទាំងមូល ឬភាគណាមួយ។

៥- សម្រាប់គោលដៅនៃការចុះបញ្ជី និងដោយមានការយល់ព្រមពីរដ្ឋបាលសារពើពន្ធផង ចំពោះបុគ្គលជាប់អាករមួយក្រុមដែលជាប់ទាក់ទិនគ្នាដូចមានការចែងក្នុងមាត្រា៥៦ នៃច្បាប់នេះសកម្មភាពរបស់សមាជិកនានានៅក្នុងក្រុមអាចចាត់ទុកជាសកម្មភាពរបស់សមាជិកជ្រើសតាំងតែម្នាក់ប៉ុណ្ណោះ។ ក្នុងករណីនេះសមាជិកម្នាក់ៗនៅក្រុមត្រូវមានការទទួលខុសត្រូវរួមគ្នា និងយ៉ាងពេញលេញចំពោះការប្រតិបត្តិតាមបទប្បញ្ញត្តិនៃជំពូកនេះ។

**៣.២.៣ ការតម្រូវចំពោះការចុះបញ្ជី**

១. ទម្រង់នៃពាក្យស្នើសុំចុះបញ្ជី

ការដាក់ពាក្យស្នើសុំចុះបញ្ជី ដូចមានចែងក្នុងប្រការ១ នៃប្រកាស ត្រូវធ្វើឡើងតាមទម្រង់ដែលនាយកដ្ឋានពន្ធដារបានកំណត់ ហើយបុគ្គលដែលបានដាក់ពាក្យស្នើសុំត្រូវផ្តល់ព័ត៌មាននានាទៅតាមការតម្រូវរបស់នាយកដ្ឋានពន្ធដារ។

២. សិទ្ធិក្នុងការចុះបញ្ជី

នាយកដ្ឋានពន្ធដារ ត្រូវចុះបញ្ជីបុគ្គលដែលបានដាក់ពាក្យស្នើសុំ ដូចមានចែងក្នុងកថាខណ្ឌ័១ និង កថាខណ្ឌ៣ នៃប្រការ១ នៃប្រកាស ហើយត្រូវចេញឲ្យបុគ្គលនោះនូវវិញ្ញាបនប័ត្រចុះបញ្ជី ដែលក្នុងនោះ មានទាំងលេខអត្តសញ្ញាណកម្ម អតប ផង លើកលែងតែក្នុងករណីដែលនាយកដ្ឋានពន្ធដារយល់ឃើញ ថាបុគ្គលដែលបានដាក់ពាក្យស្នើសុំពុំមានកាតព្វកិច្ចចុះបញ្ជីតាមប្រការ១នៃប្រកាសនេះ ឬ ចំពោះករណី នៃការដាក់ពាក្យស្នើសុំតាមកថាខណ្ឌ័៤ នៃប្រការ១នៃប្រកាសនេះដោយមូលហេតុ

ក- បុគ្គលពុំមានកន្លែងស្នាក់នៅ ឬកន្លែងធ្វើអាជីវកម្មជាប់លាប់

ខ- នាយកដ្ឋានពន្ធដារមានមូលដ្ឋានត្រឹមត្រូវជឿជាក់ថាបុគ្គលនោះ

- នឹងមិនកាន់កាប់កត់ត្រាបានត្រឹមត្រូវនូវបញ្ជីឯកសារគណនេយ្យជាប់ទាក់ទិន នឹងសកម្មភាព អាជីវកម្មរបស់ខ្លួន
- នឹងមិនដាក់លិខិតប្រកាសសារពើពន្ធឲ្យបានទៀងទាត់ និងច្បាស់លាស់អាចប្រើការបាន តាម ការតម្រូវដូចមានចែងក្នុងមាត្រា៧០ នៃច្បាប់ស្តីពីសារពើពន្ធ។

៣. កាលបរិច្ឆេទមានប្រសិទ្ធិភាពក្នុងការចុះបញ្ជី

កាលបរិច្ឆេទមានប្រសិទ្ធិភាពនៃការចុះបញ្ជី គឺជាកាលបរិច្ឆេទដែលបុគ្គលស្នើសុំចុះបញ្ជីក្លាយជា បុគ្គលជាប់អាករ។ កាលបរិច្ឆេទមានប្រសិទ្ធិនេះចាប់ផ្តើមៈ

ក- ពីដើមខែ បន្ទាប់ពីខែដែលកាតព្វកិច្ចដាក់ពាក្យស្នើសុំចុះបញ្ជីបានកើតមានឡើងសម្រាប់ករណីនៃ ការដាក់ពាក្យស្នើសុំដូចមានចែងក្នុងកថាខណ្ឌ័១ឬ កថាខណ្ឌ៣ នៃប្រការ១ នៃប្រកាសនេះ។

ខ- ពីដើមខែ បន្ទាប់ពីខែដែលបានដាក់ពាក្យស្នើសុំចុះបញ្ជី សម្រាប់ករណីនៃការដាក់ពាក្យស្នើសុដូច មានចែងក្នុងកថាខណ្ឌ៤ នៃប្រការ១ នៃប្រកាសនេះ។

៤. វិញ្ញាបនប័ត្រចុះបញ្ជី

វិញ្ញាបនប័ត្រចុះបញ្ជីត្រូវមានចុះឈ្មោះលេខអត្តសញ្ញាណកម្ម អតប កាលបរិច្ឆេទមានប្រសិទ្ធភាព នៃការចុះបញ្ជី និងព័ត៌មានលំអិតផ្សេងទៀតរបស់បុគ្គលជាប់អាករ។

៥. ការដាក់តាំងវិញ្ញាបនប័ត្រចុះបញ្ជី

បុគ្គលជាប់អាករដែលបានចុះបញ្ជីត្រូវដាក់តាំង ឬព្យួរវិញ្ញាបនប័ត្រចុះបញ្ជីដែលបានចេញឲ្យតាម បទប្បញ្ញត្តិនៃប្រកាសនេះ នៅទីកន្លែងអាជីវកម្មជាសំខាន់របស់ខ្លួន។

៦. បញ្ជីអាករលើតម្លៃបន្ថែម

នាយកដ្ឋានពន្ធដារ ត្រូវមានបញ្ជីសម្រាប់កត់ត្រាតាមដាននូវព័ត៌មានលំអិតដែលទាក់ទិននឹងបុគ្គល ជាប់អាករម្នាក់ៗ។

៧. អំណាចក្នុងការចុះបញ្ជី

ប្រធាននាយកដ្ឋានពន្ធដារ មានសិទ្ធចុះបញ្ជីបុគ្គលណាមួយ បើសិនមានមូលដ្ឋានត្រឹមត្រូវជឿជាក់ថាបុគ្គលនោះមានកាតព្វកិច្ចដាក់ពាក្យស្នើសុំចុះបញ្ជីដូចមានចែងក្នុងកថាខណ្ឌ១ និង កថាខណ្ឌ៣ នៃប្រការ១នៃប្រកាសនេះ ក៏ប៉ុន្តែមិនបានដាក់ពាក្យស្នើសុំ ហើយការចុះបញ្ជីត្រូវមានប្រសិទ្ធិភាពចាប់ពីកាលបរិច្ឆេទដែលមានចុះក្នុងវិញ្ញាបនប័ត្រចុះបញ្ជី។

៨. សេចក្តីជូនដំណឹងអំពីការសម្រេចយល់ព្រម ឬមិនយល់ព្រមចុះបញ្ជី

នាយកដ្ឋានពន្ធដារ ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរ អំពីការសម្រេចយល់ព្រមឬមិនយល់ព្រមចុះបញ្ជីឲ្យដល់បុគ្គលដែលបានដាក់ពាក្យស្នើសុំដូចមានចែងក្នុងប្រការ៣ នៃប្រកាសនេះ ក្នុងរយៈពេល៣០ថ្ងៃក្រោយបានទទួលពាក្យស្នើសុំ។

៩. សេចក្តីជូនដំណឹងអំពីការ ចុះបញ្ជីជាឯកតោភាគី

នាយកដ្ឋានពន្ធដារ ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរអំពីការសម្រេចចុះបញ្ជីជាឯកតោភាគីឲ្យដល់បុគ្គលដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ ក្នុងរយៈពេល៣០ថ្ងៃក្រោយមានការសម្រេច។

១០. ការប្រែប្រួលព័ត៌មានបុគ្គលជាប់អាករ

បុគ្គលជាប់អាករ ត្រូវជូនដំណឹងជាលាយលក្ខ័អក្សរដល់នាយកដ្ឋានពន្ធដារ អំពីការប្រែប្រួលៈ

ក- នាមករណ៍ ឬ អស័យដ្ឋានរបស់បុគ្គលនោះ

ខ-ស្ថានភាពផ្សេងៗដែលបណ្តាលឲ្យបុគ្គលនោះមិនអាចបំពេញល័ក្ខខ័ណ្ឌនៃការចុះបញ្ជីតទៅទៀត

គ- ប្រភេទនៃសកម្មភាពអាជីវកម្ម ឬប្រភេទនៃការផ្គត់ផ្គង់ជាប់អាករដែលកំពុងអនុវត្ត និងព័ត៌មានផ្សេងៗទៀត។

ការជូនដំណឹងនេះត្រូវធ្វើរយៈពេល១៥ថ្ងៃក្រោយការប្រែប្រួលបានកើតមានឡើង។

## ៣.៤ គោលការណ៍ក្នុងការប្រមូលពន្ធលើ VAT

អាករលើតម្លៃបន្ថែមត្រូវបានរដ្ឋកំណត់យករួមមាន៖

- ការផ្គត់ផ្គង់ជាប់អាករ
- ការផ្គង់ផ្គង់ទំនិញដល់អ្នកប្រើប្រាស់
- ការផ្គត់ផ្គង់ដោយភ្នាក់ងារ
- ការប្រមូលអាករលើតម្លៃបន្ថែមលើការនាំចូល
- ការនាំចេញនូវទំនិញ និងសេវាក្នុងអត្រាសូន្យ

អត្រាអាករលើតម្លៃបន្ថែមត្រូវកំណត់ដូចខាងក្រោម៖

- អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រា១០ភាគរយលើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រា០ភាគរយលើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ចំពោះទំនិញនាំចេញពីព្រះរាជាណាចក្រកម្ពុជា ហើយនឹងការផ្គត់ផ្គង់សេវាជាប់អាករដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងមាត្រា៦៣ នៃច្បាប់សារពើពន្ធនៃព្រះរាជក្រម។

**៣.៤.១ ការផ្គត់ផ្គង់ជាប់អាករ**

*(យោងតាមអនុក្រឹត្យ /មាត្រា៤៤ ដល់ មាត្រា៤៨)*

១. ទីកន្លែងនៃការផ្គត់ផ្គង់ទំនិញ

ទីកន្លែងនៃការផ្គត់ផ្គង់ទំនិញ ត្រូវបានកំណត់ដូចតទៅ៖

ការផ្គត់ផ្គង់ទំនិញត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាទំនិញនោះត្រូវបានប្រគល់ឲ្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះបីការប្រគល់នេះមានលក្ខណៈជាការផ្ទេរសិទ្ធិបើប្រាស់ ឬសិទ្ធិចាត់ចែងក្តី។ ចំពោះករណីដែលការផ្គត់ផ្គង់ត្រូវមានការដឹកជញ្ជូន ការផ្គត់ផ្គង់ត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាទំនិញនោះស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដែលការដឹកជញ្ជូនត្រូវបានចាប់ផ្តើម។

២. ទីកន្លែងនៃការផ្គត់ផ្គង់សេវា

ការផ្គត់ផ្គង់សេវា ត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាសេវានោះត្រូវបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយឡែកតែ៖

ក- ការផ្គត់ផ្គង់សេវាដែលជាប់ទាក់ទងនឹងអចលនទ្រព្យ ត្រូវកំណត់ថាសេវានោះបានធ្វើឡើងនៅទីកន្លែងដែលអចលនទ្រព្យនោះស្ថិតនៅ។

ខ- ការផ្គត់ផ្គង់សេវាដែលជាប់ទាក់ទងនឹងការដឹកជញ្ជូន ត្រូវកំណត់ថាសេវានោះបានធ្វើឡើងនៅទីកន្លែងនៃការដឹកជញ្ជូននោះ។

គ- ការផ្គត់ផ្គង់សេវាសម្រាប់ការប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ថាបានធ្វើឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

៣.ទីកន្លែងផ្គត់ផ្គង់នៃការនាំចូល

ទីកន្លែងផ្គត់ផ្គង់នៃការនាំចូល គឺជាទីកន្លែងដែលទំនិញត្រូវបាននាំចូលមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា និងជាទីកន្លែងត្រូវបង់ពន្ធគយ និងបន្ទុកសារពើពន្ធផ្សេងទៀតនៃការនាំចូល។

៤. ការផ្គត់ផ្គង់លាយឡំគ្នារវាងទំនិញ និងសេវា

ក្នុងករណីដែលបុគ្គលជាប់ អតប ធ្វើការផ្គត់ផ្គង់លាយឡំគ្នារវាងទំនិញ និងសេវា ការផ្គត់ផ្គង់ទាំងនោះត្រូវបានកំណត់ដូចតទៅ:

1. ការផ្គត់ផ្គង់នូវសេវាបន្ទាប់បន្សំដែលរួមជាមួយនិងការផ្គត់ផ្គង់ទំនិញគឺជាចំណែកមួយនៃការផ្គត់ផ្គង់ទំនិញ។
2. ការផ្គត់ផ្គង់នូវទំនិញបន្ទាប់បន្សំដែលរួមជាមួយនិងការផ្គត់ផ្គង់សេវា គឺជាចំណែកមួយនៃការផ្គត់ផ្គង់សេវា។
3. ការផ្គត់ផ្គង់នូវសេវាបន្ទាប់បន្សំដែលរួមជាមួយនិងការនាំចូល គឺជាចំណែកមួយនៃការនាំចូល។
4. វិធាន និងនីតិវិធី សម្រាប់អនុវត្តមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៥.ពេលផ្គត់ផ្គង់

ពេលផ្គត់ផ្គង់ ត្រូវបានកំណត់ដូចខាងក្រោមនេះ ដើម្បីគណនាប្រាក់ អតប សម្រាប់រយៈពេលជាប់ អតប នីមួយៗ ដែលបុគ្គលជាប់ អតប ត្រូវប្រកាសបង់ជូននាយកដ្ឋានពន្ធដារ។ការប់គ្រងចំណូលពន្ធអាករលើតម្លៃបន្ថែមរបស់នាយកដ្ឋានពន្ធដារ

1. ពេលផ្គត់ផ្គង់ទំនិញ ឬសេវាត្រូវបានកំណត់ដូចតទៅៈ

   ក- ពេលផ្គត់ផ្គង់ទំនិញនិងសេវា គឺជាពេលដែលអ្នកផ្គត់ផ្គង់ត្រូវចេញវិក័យប័ត្រ ឬជាពេលដែលអ្នកផ្គត់ផ្គង់បានចេញវិក័យប័ត្រ ប្រសិនបើវិក័យប័ត្រនោះត្រូវបានចេញមុនពេលដែលអ្នកផ្គត់ផ្គង់ត្រូវចេញវិក័យប័ត្រ។ អ្នកផ្គត់ផ្គង់ត្រូវចេញវិក័យប័ត្រ អតប យ៉ាងយឺតបំផុត៧ថ្ងៃក្រោយការបញ្ជូនទំនិញ ឬការបំពេញសេវា ឬក្រោយការទូទាត់ក្នុងករណីដែលការទូទាត់ត្រូវបានធ្វើឡើងមុនការបញ្ជូនទំនិញឬការបំពេញសេវា។

   ខ- ក្នុងករណីដែលទំនិញត្រូវបានយកទៅប្រើប្រាស់ផ្ទាល់ខ្លួន ពេលផ្គត់ផ្គង់គឺជាពេលដែលទំនិញនោះត្រូវបានយកទៅប្រើប្រាស់ដំបូង។

   គ- ក្នុងករណីទំនិញ ឬសេវាត្រូវបានផ្គត់ផ្គង់ក្នុងលក្ខណៈជាអំណោយ ពេលផ្គត់ផ្គង់គឺជាពេលដែលទំនិញបានប្រគល់ឲ្យ ទោះជាមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ចាត់ចែងក្តី ឬពេលដែលសេវាផ្គត់ផ្គង់ឲ្យត្រូវបានបំពេញរួចរាល់។

2. ពេលផ្គត់ផ្គង់ទំនិញក្រោមកិច្ចសន្យាជួលដោយមានល័ក្ខខ័ណ្ឌទិញផ្តាច់ ឬកតិសន្យាហិរញ្ញវត្ថុ គឺជាពេលដែលទំនិញត្រូវបានប្រគល់ឲ្យ ទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ ឬសិទ្ធិចាត់ចែងក្តី។

3.ក្នុងករណីដែលៈ

- ទំនិញត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យាជួល ឬ អរិយ
- ទំនិញឬសេវាត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យា ឬច្បាប់ដែលចែងអំពីការទូទាត់ច្រើនលើក ឬ
-សេវាត្រូវបានផ្គត់ផ្គង់ជាប់បន្ត

ទំនិញ ឬសេវានោះ ត្រូវចាត់ទុកថាបានផ្គត់ផ្គង់រួចរាល់ចំពោះចំណែកដែលបានផ្គត់ផ្គង់រួចរាល់ក្នុងរយៈពេលនៃកិច្ចសន្យា ឬរយៈពេលដែលច្បាប់បានកំណត់ ហើយពេលផ្គត់ផ្គង់នៃចំណែកដែលបានផ្គត់ផ្គង់រួចរាល់នីមួយៗគឺជាកាលបរិច្ឆេទមុនគេ ក្នុងចំណោមកាលបរិច្ឆេទដែលការទូទាត់ត្រូវដល់កំណត់ និងកាលបរិច្ឆេទដែលបានទទួលការទូទាត់។

4. ចំពោះការនាំចូលទំនិញពេលផ្គត់ផ្គង់គឺជាពេលដែលអ្នកនាំចូលដាក់លិខិតប្រកាសជូនអាជ្ញាធរគយនិងរដ្ឋាករទៅតាមគោលការណ៍ជាធរមាន ហើយពន្ធគយ និងអាករនានាត្រូវបានបង់។

**៣.៤.២ ការផ្គត់ផ្គង់ទំនិញដល់អ្នកប្រើប្រាស់**

ការគណនាអាករលើការលក់ទំនិញដល់បុគ្គលមិនជាប់អាករ

បុគ្គលជាប់អាករដែលធ្វើការផ្គត់ផ្គង់ជាប់អាករតាមអត្រាស្តង់ដារឲ្យដល់បុគ្គលមិនជាប់អាករត្រូវកាន់បញ្ជីគណនេយ្យនិងកំណត់ត្រានានាដូចមានចែងក្នុងប្រការ៥០នៃប្រកាស ហើយត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោមនេះៈ

ក-ក្នុងករណីដែលបានចេញវិក័យប័ត្រធម្មតា បើសិនជានៅលើវិក័យប័ត្រមានបញ្ជាក់ចំនួនទឹកប្រាក់អាករដោយឡែកនោះ ប្រាក់អាករដល់កំណត់ក្នុងខែ ត្រូវគណនាចេញពីកំណត់ត្រាការលក់។

ខ-បើសិនជានៅលើវិក័យប័ត្រគ្មានបញ្ជាក់ចំនួនទឹកប្រាក់អាករដោយឡែកទេ ឬបុគ្គលជាប់អាករធ្វើការលក់រាយដោយមិនបានចេញវិក័យប័ត្រ បុគ្គលជាប់អាករត្រូវកាន់កំណត់ត្រាលក់សរុបប្រចាំថ្ងៃនៃការលក់ជាប់អាករនិងការលក់មិនជាប់អាករ។ ក្នុងការគណនាប្រាក់អាករ ត្រូវយកតម្លៃសរុបនៃការលក់ប្រចាំខែទៅគុណប្រភាគអាករ។ ប្រភាគអាករសម្រាប់អត្រា១០ភាគរយគឺ ១/១១ ដើម្បីរកតម្លៃជាប់អាករត្រូវយកតម្លៃសរុបនៃការលក់ប្រចាំខែ ដកទឹកប្រាក់អាករចេញ។

**៣.៤.៣ ការផ្គត់ផ្គង់ដោយភ្នាក់ងារ**

ល័ក្ខខ័ណ្ឌនៃការផ្គត់ផ្គង់ទំនិញ ឬសេវាដោយភ្នាក់ងារ

១.ការផ្គត់ផ្គង់ទំនិញ ឬសេវា ធ្វើឡើងដោយបុគ្គលជាភ្នាក់ងារ ដើម្បីជាគុណប្រយោជន៍របស់បុគ្គលម្នាក់ទៀតដែលជាបុគ្គលដើម ត្រូវបានចាត់ទុកថាជាការផ្គត់ផ្គង់របស់បុគ្គលដើមនោះ។

២.ក្នុងករណីដែលភ្នាក់ងារជាបុគ្គលជាប់អាករ ភ្នាក់ងារនោះត្រូវគិតអាករលើកម្រៃដែលបានមកពីការផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមជាបុគ្គលម្នាក់ទៀតដែលជាបុគ្គលដើម។ បើសិនជាបុគ្គលដើមនិងភ្នាក់ងារជាបុគ្គលជាប់អាករទាំងពីរនាក់ ប្រាក់អាករដែលកំណត់លើប្រាក់កម្រៃដោយភ្នាក់ងារត្រូវចាត់ទុកជាអាករលើធាតុចូលរបស់បុគ្គលដើម។

**៣.៤.៤ ការប្រមូលអាករលើតម្លៃបន្ថែមលើការនាំចូល**

ការប្រមូលអាករលើតម្លៃបន្ថែមនៅពេលនាំចូល

១. អាករដល់កំណត់នៅពេលនាំចូលនឹងត្រូវប្រមូលដោយទីចាត់ការគយនិងរដ្ឋាករ។

២.អាករត្រូវបានប្រមូលតាមរយៈ ការប្រកាសក្នុងប្រតិវេទន៏គយសម្រាប់ការនាំចូលហើយត្រូវបានចាត់ចែងតាមរបៀបដូចគ្នានឹងពន្ធគយ។

៣. តម្លៃជាប់អាករនៃការនាំចូលទំនិញគឺជាចំនួនសរុបនៃ:

ក-តម្លៃទំនិញសម្រាប់គិតពន្ធគយស្របតាមច្បាប់ដែលទាក់ទិននឹងពន្ធគយ

ខ-ចំនួនទឹកប្រាក់នៃពន្ធគយ អាករពិសេសលើទំនិញនិងសេវាមួយចំនួននិងបន្ទុកសារពើពន្ធផ្សេងទៀតដែលត្រូវបង់លើទំនិញទាំងនោះក្រៅពីអាករលើតម្លៃបន្ថែម

គ-តម្លៃសេវាណាមួយដែលមានចែងក្នុងកថាខ័ណ្ឌ៣ នៃប្រការ៤៧ នៃប្រកាសនេះ ដែលមិនបានបូកបញ្ចូលក្នុងតម្លៃទំនិញសម្រាប់គិតពន្ធគយ ដូចមានចែងក្នុងកថាខ័ណ្ឌ ក នៃកថាខ័ណ្ឌ៣ នៃប្រការនេះ

៤.ទីចាត់ការគយនិងរដ្ឋាករ ត្រូវផ្តល់ឲ្យអ្នកនាំចូលនូវច្បាប់ចម្លងនៃប្រតិវេទន៍គយសម្រាប់ការនាំចូលដែលក្នុងនោះត្រូវ:

ក- ចុះលេខអត្តសញ្ញាណកម្ម អតប បើសិនជាអ្នកនាំចូលជាបុគ្គលជាប់អាករ។

ខ-សរសេរថា "គ្មាន" ក្នុងប្រអប់សម្រាប់ចុះលេខអត្តសញ្ញាណកម្ម អតប បើសិនជាអ្នកនាំចូលមិនមែនជាបុគ្គលជាប់អាករ។

គ-បញ្ជាក់នូវចំនួនប្រាក់អាករដែលបានបង់លើប្រតិវេទន៍គយលើការនាំចូល បើសិនជាអ្នកនាំចូលជាបុគ្គលជាប់អាករធ្វើការនាំចូល ដើម្បីប្រកបអាជីវកម្មជាប់អាករ។

ឃ-បញ្ជាក់អំពីអសុពលភាព នៃការបង្វិលសងប្រាក់អាករ ប្រសិនបើអ្នកនាំចូលមិនមែនជាបុគ្គលជាប់អាករ ឬធ្វើការនាំចូលដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន។

**៣.៤.៥ ការនាំចេញទូវទំនិញ និងសេវាក្នុងអត្រាសូន្យ**

ដែនអនុវត្តនៃអត្រាសូន្យភាគរយសម្រាប់ការនាំចេញទំនិញ និងសេវា

១. ស្របតាមកថាខ័ណ្ឌ២ នៃមាត្រា៦៤ នៃច្បាប់ស្តីពីសារពើពន្ធអាករលើតម្លៃបន្ថែម ត្រូវកំណត់តាមអត្រាសូន្យភាគរយលើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ទំនិញនីមួយៗដែលបាននាំចេញពីព្រះរាជណាចក្រកម្ពុជា ឬការផ្គត់ផ្គង់ជាប់អាករនៃសេវាដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

ដែនអនុវត្តនៃបទប្បញ្ញត្តិត្រូវរួមបញ្ចូល ៖

ក- ការផ្គត់ផ្គង់ទំនិញ ទៅទីកន្លែងណាមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា ដែលមានឯកសារភស្តុតាងមានការយល់ព្រមពីនាយកដ្ឋានពន្ធដារ

ខ- ការផ្គត់ផ្គង់សេវា សម្រាប់ការប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា ដែលមានឯកសារភស្តុតាងមានការយល់ព្រមពីនាយកដ្ឋានពន្ធដារ

គ- ការផ្គត់ផ្គង់សេវាដឹកជញ្ជូនអ្នកដំណើរនិងទំនិញអន្តរជាតិ

ឃ- ការផ្គត់ផ្គង់សេវាដែលទាក់ទិននឹងការដឹកជញ្ជូនអ្នកដំណើរនិងទំនិញអន្តរជាតិ។

២. សម្រាប់គោលដៅនៃវាក្យខ័ណ្ឌ គ នៃកថាខ័ណ្ឌ១ នៃប្រការនេះ ការដឹកជញ្ជូនអ្នកដំណើរ និងទំនិញតាមផ្លូវគោក ផ្លូវទឹក ឬផ្លូវអាកាស គឺជាការដឹកជញ្ជូនអន្តរជាតិ បើសិនជាការដឹកជញ្ជូននោះត្រូវបានធ្វើឡើង៖

ក-ពីកន្លែមួយក្នុងព្រះរាជាណាចក្រកម្ពុជា ទៅកន្លែងមួយទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជា

ខ- ពីកន្លែងមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា មកកន្លែងមួយក្នុងព្រះរាជាណាចក្រកម្ពុជា

គ-ពីកន្លែងមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា ទៅកន្លែងមួយទៀតនៅក្រៅព្រះរាជាណាចក្រ កម្ពុជាជាក្នុងករណីដែលការដឹកជញ្ជូន ឬចំណែកណាមួយ នៃការដឹកជញ្ជូនឆ្លងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី៤
# ការវិភាគពីចំណុចខ្លាំង និងចំណុចខ្សោយ

ជាធម្មតាការវិភាគចំណុចខ្លាំង និងចំណុចខ្សោយលើការអនុវត្តការងារ ឬច្បាប់ដែលបានកំណត់តែងតែមាន។ ការវាយតម្លៃពិតជាមានសារៈសំខាន់ណាស់ ដើម្បីឱ្យយើងដឹងពីចំណុចខ្លាំងចំណុចខ្សោយសម្រាប់ យកកែលម្អឱ្យកាន់តែល្អប្រសើរ និងកាន់តែច្បាស់លាស់ក្នុងការអនុវត្តជាក់ស្តែងក៏ដូចជាការគ្រប់គ្រងផងដែរ។ ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើការគ្រប់គ្រងចំណូលអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ បន្ទាប់ពីការស្រាវជ្រាវរួចមកនាងខ្ញុំបានរកឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួនដូចជា៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

1.ការប្រមូលអាករនេះគឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការប្រមូលពន្ធនេះសម្រាប់ចូលថវិកាជាតិ វាបានចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិតាមរយៈ ការកសាងហេដ្ឋារចនាសម្ព័ន្ធក៏ដូចជាសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពាន និងវត្តអារាមជាដើម។ ចំណូលពីការប្រមូលអាករនេះមានការកើនឡើងជាលំដាប់ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះដោយសារតែការខិតខំប្រឹងប្រែងរបស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការកែទម្រង់គោលនយោបាយសារពើពន្ធ និងពង្រឹងអភិបាលកិច្ចល្អរបស់រដ្ឋបាលសាពើពន្ធក្នុងការផ្សព្វផ្សាយពីច្បាប់សារពើពន្ធ និងកាតព្វកិច្ចសារពើពន្ធរបស់អ្នកជាប់ពន្ធបានយ៉ាងទូលំទូលាយ។

2.ទោះរីករាលដាលនៃជំងឺកូវីដគួបផ្សំនឹងភាពមិនប្រាកដប្រជា នៃស្ពាន ២០២០នៅដើមឆ្នាំ ១៩--ភាពសេដ្ឋកិច្ចសកលនៅឆ្នាំ២០២២ដែលបណ្តាលមកពីសង្គ្រាមរវាងប្រទេស រុស្ស៊ីនិងអ៊ុយក្រែន ភាពតានតឹងនៃភូមិសាស្ត្រនយោបាយ នៃប្រទេសមហាអំណាច និងការកើនឡើងសម្ពាធអតិផ-រណា ក៏បានជះឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជា ផងដែរ។

3.បានផ្តល់ជូននូវសេវាសមស្របដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ពត៌មានអប់រំចំណេះដឹង ការពន្យល់ណែនាំដែលទាក់ទងនឹងការបង់ពន្ធផ្សេងៗ ដែលធ្វើឱ្យអ្នកជាប់ពន្ធយល់កាន់តែច្បាស់ និងពេញចិត្ត បង់ពន្ធដោយភាពស្មោះត្រង់។

4.មានបទបង្ហាញច្បាស់លាស់ និងមានសិក្ខាសាលាក្នុងការបង្ហាញច្បាប់ថ្មី ស្តីពីសវនកម្មពន្ធដារ ដែលមានភាពងាយស្រួលដល់អ្នកជាប់ពន្ធថ្មី និងចាស់អាចយល់ដឹងបន្ថែម។

5.បង្ហាញពីផលប្រយោជន៍ដែលអ្នកបង់ពន្ធទទួលបានតាមរយៈការបង់ពន្ធរបស់ខ្លួននោះ គឺមានលក្ខណៈប្រយោល ដូចជាការបើកប្រាក់បៀវត្សជូនមន្ត្រី ការសាងសង់មន្ទីរពេទ្យ សាលារៀន ផ្លូវថ្នល់ ស្ពាន សួនច្បារជាដើម (ប្រយោជន៍សាធារណៈ)។ ពន្ធជាប្រភពចំណូលដ៏សំខាន់សម្រាប់ថវិកាជាតិ ជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។ កាត់បន្ថយគំលាត់រវាងអ្នកក្រ និងអ្នកមាន ដោយអ្នកមានចំណូលតិចបង់ពន្ធតិចនិងអ្នកមានចំណូលច្រើនបង់ពន្ធច្រើន។

6. ពន្ធដារបានដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រង ការប្រកាសពន្ធអាជីវកម្មតាមអនឡាញ ដែលបានជួយសម្រួលដល់ការដាក់លិខិតប្រកាសពន្ធផ្សេងៗ ចំណេញពេលវេលា និងពន្ធដារបានប្រមូលពន្ធបានឆាប់រហ័ស និងប្រសិទ្ធិភាពខ្ពស់។
7. រាល់ការបង់ពន្ធ មានភាពយឺតយ៉ាវ តម្រូវឱ្យបង់ប្រាក់ពន្ធបន្ថែមលើទឹកប្រាក់ ដែលត្រូវបង់តាមអត្រាដែលបានកំណត់សម្រាប់ការខកខានក្នុងខែ និងពិន័យការប្រាក់បន្ថែមទៀតប្រសិនបើឈានដល់ខែបន្ទាប់។ នេះជាវិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រជាច្រើន ក្នុងការប្រមូលពន្ធ ឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា។
8. ការផ្តល់សិទ្ធិដល់អ្នកជាប់ពន្ធ ក្នុងការដាក់ពាក្យតវ៉ា រាល់ការមានកំហុសដោយអចេតនាលើការ គណនាលេខផ្សេងៗ ចំពោះការដាក់លិខិតប្រកាសពន្ធ
9. ការប្រមូលអាករតម្លៃបន្ថែមត្រូវបានជួយប្រជាជនតាមលក្ខណៈប្រយោលដូចជា ផ្តល់ជាប្រាក់របស់របរប្រើប្រាស់ ឬ ជាស្បៀងអាហារ ក្នុងពេលដែលវីរុសកូវីត១៩ បានចូលមកក្នុងប្រទេស។
10. អត្រាលម្អៀងលើប្រាក់ពន្ធតាមថ្នាក់នីមួយៗនៃការគិតពន្ធ មានភាពសមស្រប មានន័យថាទឹកប្រាក់បង់ពន្ធតិច ឬច្រើនគឺអាស្រ័យតាមចំណូលអង្គភាពនីមួយៗ។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទន្ទឹមនឹងការរកឃើញចំណុចខ្លាំងមួយចំនួនខាងលើ ពួកយើងក៏បានរកឃើញចំណុចអសកម្មមួយចំនួនផងដែរ ដែលបានរារាំងក៏ដូចជាផ្តល់ផលប៉ះពាល់ដល់ការគ្រប់គ្រងចំណូលអាករលើតម្លៃបន្ថែម។ ទោះបីជាចំណូលពីការប្រមូលអាករមានការកើនឡើង ក៏ប៉ុន្តែក្នុងនោះភាពខ្វះខាត ភាពខ្សោយ នៅតែមានដូចខាងក្រោម៖

- ចំនួននិងសមត្ថភាពនៃមន្ត្រីពន្ធនៅមានកម្រិត(មន្ត្រីមួយចំនួននៅពេលដែលមានការសាកសួរនូវបញ្ហាផ្សេងៗតែងតែរុញឲ្យទៅផ្នែកនេះផ្នែកនោះមិនច្បាស់ថាផ្នែកណាអោយប្រាកដ និងពេលដែលសួរព័ត៌មានតែងតែផ្តល់ព័ត៌មានត្រឡប់មកវិញមិនច្បាស់លាស់ និងមិនត្រូវតាមតម្រូវការ។
- មន្ត្រីពន្ធមួយចំនួន គ្មានភាពទទួលខុសត្រូវក្នុងការងាររបស់ខ្លួន (ខ្លួនធ្វើខុស តែបង្វែរទៅជាអ្នកជាប់ពន្ធជាអ្នកធ្វើខុស អ្នកជាប់ពន្ធក្លាយជាជនរងគ្រោះ) ដូចជាការដាក់ឯកសារផ្សេងៗ គាត់បានឃើញចំណុចខុសប៉ុន្តែមិនបានប្រាប់មកខាងអ្នកជាប់ពន្ធដើម្បីយល់បន្ថែមឬកែតម្រូវភ្លាមៗឡើយ។
- អត្រាក្រុមហ៊ុនដែលមិនបានប្រកាសពន្ធ និងអនុវត្តច្បាប់ពន្ធ នៅតែមានច្រើន (មានក្រុមហ៊ុនជាច្រើនឧទាហរណ៍៖ក្រុមហ៊ុនចិនមួយចំនួនដែលបានបើកអាជីវកម្ម ក្រុមហ៊ុនពួកគាត់តែងគេចមិនអនុវត្តតាមច្បាប់)
- ករណីមន្ត្រីពន្ធ និង អ្នកជាប់ពន្ធឃុបឃិតគ្នាប្រព្រឹត្តអំពើពុករលួយនៅតែមាន (ឧទាហរណ៍៖ អ្នកជាប់ពន្ធទៅដាក់លិខិតប្រកាសពន្ធនៅតាមបណ្តាសាខាណាមួយ ដែលអ្នកជាប់ពន្ធ ឬបុគ្គលិកស្គាល់មន្ត្រីតែងតែមានសំណូកដើម្បីទទួលបានសេវា ឬធ្វើឯកសារផ្សេងៗមុនអ្នកដទៃដែលមកមុនខ្លួន។)

- យកច្បាប់ពន្ធមកគំរាម ជំនួសឲ្យការអប់រំណែនាំ (នៅពេលដែលអ្នកជាប់ពន្ធមិនបានយល់ដឹងពីច្បាប់ពន្ធ តែងទទួលការគំរាមថានឹងត្រូវពិន័យហួសស្មាន ឬបិទអាជីវកម្ម ជំនួសដោយការណែនាំឲ្យពួកគាត់ទៅបំពេញកាតព្វកិច្ចទៅវិញ។)
- អ្នកបង់ពន្ធនៅតែមានភាពឈឺចាប់ក្នុងការបង់ពន្ធជូនរដ្ឋ បង្កើតឲ្យមានករណីគេចពន្ធ (ករណីនេះនៅពេលអ្នកបង់ពន្ធម្នាក់បានបង់ពន្ធស្របតាមច្បាប់ តែមានបុគ្គលដែលនៅជាប់គាត់គេធ្វើអាជីវកម្មដូចគាត់ដែរ តែគេអត់បង់ពន្ធ ហើយគាត់នៅតែបន្តអាជីវកម្មរបស់គាត់បានធម្មតា ធ្វើឲ្យអ្នកបង់ពន្ធស្រប់ច្បាប់នោះមានចិត្តខឹង អន់ចិត្ត ច្រណែន ហេតុអ្វីគេបើកអាជីវកម្មដូចគ្នា តែគាត់ត្រូវបង់ពន្ធតែឯង នេះហើយបានបង្កើតឲ្យមានការឈឺចាប់ដល់គាត់ក្នុងនាមជាអ្នកបង់ពន្ធស្របច្បាប់ និងបង្កើតឲ្យមានការគេចពន្ធតាមរូបភាពផ្សេងៗ តាមដែលគាត់អាចធ្វើទៅបាន)។
- ទោះបីជាមានប្រព័ន្ធប្រមូលពន្ធតាមរបបស្វ័យប្រកាសក៏ដោយ តែអ្នកប្រើប្រាស់តែងរអ៊ូអំពីភាពយឺតយ៉ាវ និងមានបញ្ហាបច្ចេកទេស។
- ការទំនាក់ទំនងរវាងនាយកដ្ឋានពន្ធដារ ទីចាត់ការគយនិងរដ្ឋាករ ក្រសួងពាណិជ្ជកម្ម ធនាគារ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហាក់បីដូចជាមិនមានភាពសហការគ្នា ទាំងនេះហើយជាចន្លោះខ្វះខាតដែលជាឱកាសអាចឲ្យមានករណីគេចពន្ធ តាមគ្រប់រូបភាព។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាននិង ការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន (Conclusion)

សរុបមកពន្ធដារ បានរួមចំណែកយ៉ាងខ្លាំងក្នុងការអភិវឌ្ឍន៍ប្រទេសជាតិលើគ្រប់វិស័យ។ រដ្ឋាភិបាលប្រមូលពន្ធ ដើម្បីយកជាប្រាក់ចំណូលសម្រាប់ចំណាយលើការគ្រប់គ្រងរដ្ឋ រួមទាំងសងបំណុលបរទេសផងដែរ។ ពន្ធដាបានមកពីការបែងចែកប្រាក់ចំណូលរបស់អ្នកជាប់ពន្ធ ពោលគឺអ្នកមានចំណូលច្រើនត្រូវបង់ពន្ធច្រើន ចំណែកឯអ្នកមានចំណូលតិចត្រូវបង់ពន្ធតិច។

តាមរយៈការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះរួចមក យើងអាចសន្និដ្ឋានបានថា ការប្រមូលអាករលើតម្លៃបន្ថែម គឺជាយុទ្ធសាស្ត្រដ៏សំខាន់មួយ ក្នុងការបង្កើនប្រសិទ្ធភាព ក្នុងការគោរពកាតព្វកិច្ចពន្ធ និងការជួយបង្កើនចំណូលចូលថវិកាជាដី។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់សារពើពន្ធ និងបទប្បញ្ញត្តិពាក់ព័ន្ធ គឺបានចែងមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយនោះទេ ពោលគឺនៅមានភាពខ្វះចន្លោះមួយចំនួនទៀតដែលត្រូវការបំពេញបន្ថែម។

អ្នកជាប់ពន្ធនៅមានការយល់ដឹងតិចតួចនៅឡើយអំពីកាតព្វកិច្ចសារពើពន្ធ ខណៈដែលមន្ត្រីពន្ធដារមួយចំនួននៅតែបន្តសកម្មភាពពុករលួយរបស់ខ្លួន ដោយទទួលយកសំណូកជាថ្នូរនឹងការមិនថោកពិន័យ ឬការកាត់បន្ថយនៃការផាកពិន័យ ពីច្រើនមកតិចជាដើម។ សរុបមកក្នុងបរិបទបច្ចុប្បន្ននេះការបំពេញកាតព្វកិច្ចពន្ធពីសំណាក់អ្នកជាប់ពន្ធកាន់តែប្រសើរឡើងពីមួយឆ្នាំ ទៅមួយឆ្នាំតាមរយៈការកែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារដោយបានបញ្ជៀបវប្បធម៌បង់ពន្ធឲ្យបានទូលំទូលាយ។ ចំណែកឯនីតិវិធីនៃការបង់ពន្ធត្រូវបានកែលម្អឡើងវិញ មន្ត្រីពន្ធក៏បានកែប្រែអត្តចរិករបស់ខ្លួនព្រមទាំងបានពង្រឹងសមត្ថភាពរបស់ខ្លួនអោយកាន់តែប្រសើសជាងមុន។

## ៥.២ ការផ្តល់អនុសាសន៍ (Recommendations)

តាមរយៈការសិក្សាស្រាវជ្រាវបានផ្តល់លទ្ធភាពឲ្យមានការលើកឡើងនូវសំណូមពរមួយចំនួនដើម្បីចូលរួមចំណែកជំរុញការប្រមូលពន្ធ ឲ្យកាន់តែមានប្រសិទ្ធិភាពថែមទៀត ដូចជា៖

- បន្តពង្រឹងការគ្រប់គ្រងធនធានមនុស្ស(មន្ត្រីពន្ធ) ស្របតាមកម្មវិធីកែទម្រង់ផ្នែកធនធានមនុស្សរបស់អគ្គនាយកដ្ឋានពន្ធដារ និងបន្តការអភិវឌ្ឍស្ថាប័ន
- អនុវត្តឲ្យបានតឹងរឹងទៅលើតួនាទី និងទំនួលខុសត្រូវរបស់មន្ត្រីពន្ធភាព
- សិក្សារៀបចំបន្ថែមនូវបទបញ្ញត្តិពាក់ព័ន្ធនឹងការលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យមក្នុងគោលដៅពង្រឹងប្រសិទ្ធិភាពនៃការអនុវត្តអនុក្រឹត្យ នៃការលើកទឹកចិត្តផ្នែកពន្ធដារ ជំរុញកំណើនសកម្មភាពសេដ្ឋកិច្ចពង្រឹង និងជំរុញការកាន់បញ្ជីការគណនេយ្យ ព្រមទាំងបន្តផ្សព្វផ្សាយឲ្យបានជ្រួតជ្រាបដល់អ្នកជាប់ពន្ធអំពីកាតព្វកិច្ចរបស់ខ្លួន។

- រឹតបន្តឹងសុក្រឹតភាព ភាពស្មោះត្រង់ ជៀសវាសការប្រព្រឹត្តអំពើពុករលួយរបស់មន្ត្រី
- យកច្បាប់ពន្ធមកគំរាម ជំនួសឲ្យការអប់រំណែនាំ (នៅពេលដែលអ្នកជាប់ពន្ធមិនបានយល់ដឹងពីច្បាប់ពន្ធ តែងទទួលការគំរាមថានឹងត្រូវពិន័យហួសស្មាន ឬបិទអាជីវកម្ម ជំនួសដោយការណែនាំឲ្យពួកគាត់ទៅបំពេញកាតព្វកិច្ចទៅវិញ។)
- អ្នកបង់ពន្ធនៅតែមានភាពឈឺចាប់ក្នុងការបង់ពន្ធជូនរដ្ឋ បង្កើតឲ្យមានករណីគេចពន្ធ (ករណីនេះនៅពេលអ្នកបង់ពន្ធម្នាក់បានបង់ពន្ធស្របតាមច្បាប់ តែមានបុគ្គលដែលនៅជាប់គាត់គេធ្វើអាជីវកម្មដូចគាត់ដែរ តែគេអត់បង់ពន្ធ ហើយគាត់នៅតែបន្តអាជីវកម្មរបស់គាត់បានធម្មតា ធ្វើឲ្យអ្នកបង់ពន្ធស្រប់ច្បាប់នោះមានចិត្តខឹង អន់ចិត្ត ច្រណែន ហេតុអ្វីគេបើកអាជីវកម្មដូចគ្នា តែគាត់ត្រូវបង់ពន្ធតែឯង នេះហើយបានបង្កើតឲ្យមានការឈឺចាប់ដល់គាត់ក្នុងនាមជាអ្នកបង់ពន្ធស្របច្បាប់ និងបង្កើតឲ្យមានការគេចពន្ធផ្សេងៗតាមដែលគាត់អាចធ្វើទៅបាន)
- បន្តធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានតាមរយៈការអភិវឌ្ឍន៍ និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធ និងកម្មវិធីថ្មី ធ្វើយ៉ាងណាឲ្យមានភាពរហ័ស និងងាយស្រួលដល់អ្នកប្រើប្រាស់។
- គួរតែពង្រឹងការទំនាក់ទំនង និងសហប្រត្តិបត្តិការរវាងនាយកដ្ឋានពន្ធដារ ទីចាត់ការគយនិងរដ្ឋាករ ក្រសួងពាណិជ្ជកម្ម ធនាគារ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីផ្តល់ព័ត៌មានទៅវិញទៅមកអំពីសកម្មភាពផ្សេងនៃទម្រង់ការងាររបស់ស្ថាប័ន។

# ឯកសារយោង

របាយការណ៍ខាងលើនេះ ក្រុមយើងខ្ញុំបានដកស្រង់តាមរយៈ៖

១. www.tax.gov.kh

២. សេចក្តីប្រកាសព័ត៌មានស្តីពីកិច្ចប្រជុំបូកសរុបលទ្ធប្រមូលចំណូលពន្ធប្រចាំឆ្នាំខែធ្នូនិងប្រចាំឆ្នាំ២០២២

៣. ប្រកាសស្តីពីអាករលើតម្លៃបន្ថែម លេខ.១០៣១.ប្រក.សហវ.ពដ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៨

៤. ព្រះរាជក្រម ច្បាប់ស្តិពីសារពើពន្ធ លេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

៥. អនុក្រឹត ស្តីពីអាករលើតម្លៃបន្ថែម លេខ.១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩

# ឧបសម្ព័ន្ធ
## រូបភាព ៖ ទាក់ទងនៃការសាកសួរព័ត៌មាន



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

L20230131053STD2647

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
# កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រមូលចំណូលពន្ធ ប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២២ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្ត របស់អគ្គនាយកដ្ឋានពន្ធដារសម្រាប់ឆ្នាំ២០២៣

ថ្ងៃអង្គារ ១០កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
អគ្គនាយកដ្ឋានពន្ធដារ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣


ⓒ រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាថ្ងៃអង្គារ ១០កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ នៅសាលប្រជុំសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធ ប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២២ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារសម្រាប់ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តមបណ្ឌិតសភាចារ្យ **វង្ស វិសុត្ថ** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានវត្តមានចូលរួមរបស់ឯកឧត្តមអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ តំណាងអគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ព្រមទាំងវត្តមានចូលរួមរបស់ឯកឧត្តមទីប្រឹក្សាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម-លោកជំទាវអគ្គនាយករង ថ្នាក់ដឹកនាំនាយកដ្ឋានថ្នាក់កណ្តាល ទីចាត់ការពន្ធដាររាជធានីភ្នំពេញ សាលាជាតិពន្ធដារ សាខាពន្ធដារខេត្ត-ខណ្ឌ និងការចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ (Zoom Meeting) របស់ថ្នាក់ដឹកនាំនាយកដ្ឋានថ្នាក់កណ្តាល សាខាពន្ធដារខេត្ត-ខណ្ឌ និងមន្ត្រីរាជការពន្ធដារពាក់ព័ន្ធទាំងអស់ ក្រោមចំណុះរបស់អគ្គនាយកដ្ឋានពន្ធដារ។

ចំពោះលទ្ធផលប្រមូលពន្ធក្នុងខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **គន់ ទិមុល** បានបង្ហាញនូវចំណូលពន្ធ-អាករគ្រប់ប្រភេទ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន ដាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារមាន ៩៧៥,៤៦ ប៊ីលានរៀល (ប្រមាណជា ២៤០,៨៥ លានដុល្លារ) ស្មើនឹង ៨,៥៤% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។ ប្រៀបធៀបនឹងចំណូលពន្ធ-អាករប្រចាំខែធ្នូ ឆ្នាំ២០២១ ឃើញថាកើនឡើងចំនួន ៧៧,៦៤ ប៊ីលានរៀល (ប្រមាណជា ១៩,១៧ លានដុល្លារ) ស្មើនឹង ៨,៦៥%។ សរុបរយៈពេល ១២ខែ ឆ្នាំ២០២២ ចំណូលពន្ធ-អាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានដាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន ១៣ ៩៩៣,២០ ប៊ីលានរៀល (ប្រមាណជា ៣ ៤៥៥,១១ លានដុល្លារ) ស្មើនឹង ១២២,៥៤% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ២០២២ ធៀបនឹងចំណូលពន្ធ-អាករក្នុងរយៈពេលដូចគ្នា ឆ្នាំ២០២១ ឃើញថាកើនឡើងចំនួន ២ ៧០២,៧៣ ប៊ីលានរៀល (ប្រមាណជា ៦៦៧,៣៤ លានដុល្លារ) ស្មើនឹង ២៣,៩៦%។ លើសពីនេះ សម្រាប់រយៈពេល ១២ខែ ក្នុងឆ្នាំ២០២២ ចំណូលពីប្រភេទពន្ធសំខាន់ៗ បានរក្សាកំណើនធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ ក្នុងនោះ ពន្ធលើប្រាក់ចំណូល ២៣,៧៣% អាករលើតម្លៃបន្ថែម ៣៤,១០% ពន្ធលើប្រាក់បៀវត្ស ២២,៤៥% អាករពិសេស ២៥,៧០% និងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ និងសិទ្ធិកាន់កាប់អចលនទ្រព្យ ១២,៧០%។

ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី បានបញ្ជាក់បន្ថែមថាលទ្ធផលជាទីមោទនៈនេះ គឺមិនអាចកាត់ផ្តាច់ចេញពីការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសការគ្រប់គ្រងស្ថានការណ៍នៃជំងឺកូវីដ-១៩ បានពេញលេញនិងមានប្រសិទ្ធភាពខ្ពស់តាមរយៈការចាត់វិធានការជាយុទ្ធសាស្ត្រក្នុងការចាក់វ៉ាក់សាំងជូនប្រជាជនកម្ពុជាប្រកបដោយស្មារតីបុរេសកម្មនិងទាន់ពេលវេលា ដែលអាចកសាងភាពស៊ាំក្នុងសហគមន៍ទៅនឹងជំងឺរាតត្បាតនេះ ហើយឈានទៅបើកប្រទេសជាតិឱ្យដំណើរការសេដ្ឋកិច្ច-សង្គមឡើងវិញកាលពីខែវិច្ឆិកា ឆ្នាំ២០២១ កន្លងទៅនេះ ហើយបាននិងកំពុងអនុវត្តការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩។ បន្ថែមពីនេះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី បានយកចិត្តទុកដាក់លើការគ្រប់គ្រងប្រមូលចំណូលពន្ធ ដែលតែងតែដឹកនាំចង្អុលបង្ហាញប្រកបដោយភាពឈ្លាសវៃ និងការដាក់ផែនការយ៉ាងមុតស្រួចលើការអនុវត្តកំណែទម្រង់សំខាន់ៗ និងវិធានការជាយុទ្ធសាស្ត្រនាពេលកន្លងមក ដែលបានជំរុញនិងលើកកម្ពស់អនុលោមភាពសារពើពន្ធ និងធានាបាននូវការប្រកួតប្រជែងដោយស្មើភាពក្នុងចំណោមមជ្ឈដ្ឋានវិនិយោគ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
Ministry Of Economy And Finance
Fax/Phone: (855) 23 427798

លេខ .១០៣១.ប្រក.សហវ.ពដ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ១៩៩៨

# ប្រកាស

## ស្តីពី

## អាករលើតម្លៃបន្ថែម

### ទេសរដ្ឋមន្ត្រី
### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦
- បានឃើញច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ជស/រកម/០១០៨/០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៩៨
- បានឃើញការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច :**

# ផ្នែកទី១
# វិធាននិងនីតិវិធីសម្រាប់ការចុះបញ្ជីបុគ្គលជាប់អាករ

**ប្រការ១ .. ភាតព្វកិច្ចចុះបញ្ជី**

១. ដូចមានចែងក្នុងមាត្រា៩៩ និងមាត្រា៧៦ នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធតាមរបបពិត ដែលបានធ្វើការផ្គត់ផ្គង់ជាប់អាករដូចមានចែងក្នុងប្រការ៦០ នៃច្បាប់ស្តីពីសារពើពន្ធ គឺជាបុគ្គលជាប់អាករ ។ បុគ្គលដូចមានចែងក្នុងវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌនេះ ត្រូវដាក់ពាក្យស្នើសុំទៅនាយកដ្ឋានពន្ធដារដើម្បីធ្វើការចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែមមុនពេលចាប់ផ្តើមប្រកបអាជីវកម្ម ។ បុគ្គលដទៃទៀតត្រូវដាក់ពាក្យស្នើសុំទៅនាយកដ្ឋានពន្ធដារដើម្បីធ្វើការចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែមឱ្យបានស្រេចបាច់ក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយថ្ងៃដែលបុគ្គលនោះក្លាយជាបុគ្គលជាប់អាករ ។ បុគ្គលទាំងនោះរួមមាន :

ក- ក្រុមហ៊ុនគ្រប់ប្រភេទ សហគ្រាសនិហ័រណអាហ័រណ និង សហគ្រាសវិនិយោគទាំងអស់

ខ- សហគ្រាសដទៃទៀតដែលមានផលរបរជាប់អាករ ក្នុងរយៈពេល៣ខែប្រតិទិនជាប់គ្នាណាមួយចាប់ពី១២៥លានរៀលឡើងទៅសម្រាប់ការផ្គត់ផ្គង់ទំនិញ ឬចាប់ពី៦០លានរៀលឡើងទៅសម្រាប់ការផ្គត់ផ្គង់សេវា

គ- សហគ្រាសទាំងឡាយ ដែលក្នុងពេលចាប់ផ្តើមនៃរយៈពេល៣ខែប្រតិទិនជាប់គ្នាណាមួយ មានមូលដ្ឋានជឿជាក់ថាក្នុងរយៈពេល៣ខែប្រតិទិនជាប់គ្នានោះ នឹងមានផលរបរជាប់អាករចាប់ពី១២៥លានរៀលឡើងទៅសម្រាប់ការផ្គត់ផ្គង់ទំនិញ ឬចាប់ពី៦០លានរៀលឡើងទៅសម្រាប់ការផ្គត់ផ្គង់សេវា

ឃ- សហគ្រាសទាំងឡាយ ដែលក្នុងពេលចាប់ផ្តើមនៃរយៈពេល៣ខែប្រតិទិនជាប់គ្នាណាមួយ មានផលរបរជាប់អាករបានមកពីការធ្វើកិច្ចសន្យាជាមួយរដ្ឋចាប់ពី៣០លានរៀលឡើងទៅ ។

ក្នុងករណីដែលបុគ្គលធ្វើការផ្គត់ផ្គង់ទំនិញផង ផ្គត់ផ្គង់សេវាផង មានផលរបរជាប់អាករលើសពីកំរិតអប្បបរមានៃផលរបរត្រូវចុះបញ្ជីដែលបានកំណត់ក្នុងវាក្យខ័ណ្ឌ ខ វាក្យខ័ណ្ឌ គ និងវាក្យខ័ណ្ឌ ឃ នៃកថាខ័ណ្ឌ ១ នៃប្រការនេះ បុគ្គលនោះត្រូវដាក់ពាក្យស្នើសុំចុះបញ្ជី ។

សម្រាប់គោលដៅនៃបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ :

- ពាក្យ "ផលរបរជាប់អាករ" សំដៅ ដល់ផលរបរដែលបានមកពីការផ្គត់ផ្គង់ជាប់អាករនូវទំនិញឬសេវា ឬ ការចុះកិច្ចសន្យាជាមួយរដ្ឋ ដោយមិនទាន់គិតបញ្ចូលអាករទេ ។
- ពាក្យ "អាករ" មានន័យថា អាករលើតម្លៃបន្ថែម ហៅកាត់ថា " អតប " ។

២. កំរិតអប្បបរមានៃផលរបរជាប់អាករប្រចាំឆ្នាំ សម្រាប់ការចុះបញ្ជីអនុវត្តចំពោះបុគ្គលដែលមិនមានលក្ខណៈជា ក្រុមហ៊ុន សហគ្រាសនិហ័រណ-អាហ័រណ ឬ សហគ្រាសវិនិយោគ គឺ ៥០០លានរៀលសម្រាប់ការផ្គត់ផ្គង់ទំនិញ ២៥០លានរៀលសម្រាប់ការផ្គត់ផ្គង់សេវា និង ១២៥លានរៀល សម្រាប់ការធ្វើកិច្ចសន្យាជាមួយនឹងរដ្ឋ ។

៣. ស្ថាប័នរដ្ឋ ឬ អង្គភាពរបស់ស្ថាប័នរដ្ឋគ្រប់លំដាប់ថ្នាក់ ដែលធ្វើសកម្មភាពអាជីវកម្មក្រោមរូបភាពស្វ័យភិបាលសេដ្ឋកិច្ច ត្រូវដាក់ពាក្យស្នើសុំធ្វើការចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែមឱ្យបានស្រេចបាច់ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃដែលស្ថាប័នរដ្ឋឬអង្គភាពនោះ ក្លាយជាបុគ្គលជាប់អាករ ។

៤. បុគ្គលណាមួយដែលធ្វើការផ្គត់ផ្គង់ទំនិញ ឬសេវា ដោយមានតម្លៃ ដែលជាចំណែកមួយនៃសកម្មភាពអាជីវកម្មរបស់ខ្លួន ហើយដែលមិនស្ថិតក្រោមកាតព្វកិច្ចចុះបញ្ជីតាមការតម្រូវនៃកថាខ័ណ្ឌ១ ឬកថាខ័ណ្ឌ៣ នៃប្រការនេះ បុគ្គលនោះអាចធ្វើការស្នើសុំទៅនាយកដ្ឋានពន្ធដារដើម្បីចុះបញ្ជីស្របទៅតាមបទប្បញ្ញត្តិនៃផ្នែកទី២ នៃប្រកាសនេះ ។

# ជំពូកទី២
# ការតម្រូវចំពោះការចុះបញ្ជី

**ប្រការ២ .. ទម្រង់នៃពាក្យស្នើសុំចុះបញ្ជី**

ការដាក់ពាក្យស្នើសុំចុះបញ្ជីដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ ត្រូវធ្វើឡើងតាមទម្រង់ដែលនាយកដ្ឋានពន្ធដារបានកំណត់ ហើយបុគ្គលដែលបានដាក់ពាក្យស្នើសុំត្រូវផ្តល់ពត៌មាននានា ទៅតាមការតម្រូវរបស់នាយកដ្ឋានពន្ធដារ ។

**ប្រការ៣ .. សិទ្ធិក្នុងការចុះបញ្ជី**

នាយកដ្ឋានពន្ធដារ ត្រូវចុះបញ្ជីបុគ្គលដែលបានដាក់ពាក្យស្នើសុំ ដូចមានចែងក្នុងកថាខ័ណ្ឌ១ និងកថាខ័ណ្ឌ៣ នៃប្រការ១ នៃប្រកាសនេះ ហើយត្រូវចេញឱ្យបុគ្គលនោះនូវវិញ្ញាបនប័ត្រចុះបញ្ជី ដែលក្នុងនោះមានទាំងលេខអត្ត-សញ្ញាណកម្ម អតប ផង លើកលែងតែក្នុងករណីដែលនាយកដ្ឋានពន្ធដារយល់ឃើញថា បុគ្គលដែលបានដាក់ពាក្យស្នើសុំពុំមានកាតព្វកិច្ចចុះបញ្ជីតាមប្រការ១ នៃប្រកាសនេះ ឬ ចំពោះករណីនៃការដាក់ពាក្យស្នើសុំតាមកថាខ័ណ្ឌ ៤ នៃប្រការ១ នៃប្រកាសនេះដោយមូលហេតុ :

ក- បុគ្គលពុំមានកន្លែងស្នាក់នៅ ឬ កន្លែងធ្វើអាជីវកម្មជាប់លាប់

ខ- នាយកដ្ឋានពន្ធដារមានមូលដ្ឋានត្រឹមត្រូវជឿជាក់ថាបុគ្គលនោះ :

- នឹងមិនកាន់កាប់កត់ត្រាបានត្រឹមត្រូវ នូវបញ្ជីឯកសារគណនេយ្យជាប់ទាក់ទិននឹងសកម្មភាពអាជីវកម្មរបស់ខ្លួន
- នឹងមិនដាក់លិខិតប្រកាសសារពើពន្ធឱ្យបានទៀតទាត់ និងច្បាស់លាស់អាចប្រើការបាន តាមការតម្រូវដូចមានចែងក្នុងមាត្រា៧០ នៃច្បាប់ស្តីពីសារពើពន្ធ ។

**ប្រការ៤ .. កាលបរិច្ឆេទមានប្រសិទ្ធិភាពនៃការចុះបញ្ជី**

កាលបរិច្ឆេទមានប្រសិទ្ធិភាពនៃការចុះបញ្ជី គឺជាកាលបរិច្ឆេទដែលបុគ្គលស្នើសុំចុះបញ្ជីក្លាយជាបុគ្គលជាប់អាករ ។ កាលបរិច្ឆេទមានប្រសិទ្ធិភាពនេះចាប់ផ្តើម :

ក- ពីដើមខែ បន្ទាប់ពីខែដែលកាតព្វកិច្ចដាក់ពាក្យស្នើសុំចុះបញ្ជីបានកើតមានឡើង សម្រាប់ករណីនៃការដាក់ពាក្យស្នើសុំដូចមានចែងក្នុងកថាខ័ណ្ឌ១ ឬ កថាខ័ណ្ឌ៣ នៃប្រការ១ នៃប្រកាសនេះ

ខ- ពីដើមខែ បន្ទាប់ពីខែដែលបុគ្គលបានដាក់ពាក្យស្នើសុំចុះបញ្ជី សម្រាប់ករណីនៃការដាក់ពាក្យស្នើសុំដូចមានចែងក្នុងកថាខ័ណ្ឌ៤ នៃប្រការ១ នៃប្រកាសនេះ ។

**ប្រការ៥ .. វិញ្ញាបនប័ត្រចុះបញ្ជី**

វិញ្ញាបនប័ត្រចុះបញ្ជីត្រូវមានចុះ ឈ្មោះ លេខអត្តសញ្ញាណកម្មអតប កាលបរិច្ឆេទមានប្រសិទ្ធិភាពនៃការចុះបញ្ជី និង ពត៌មានលំអិតផ្សេងទៀតរបស់បុគ្គលជាប់អាករ ។

**ប្រការ៦ .. ការដាក់តាំងវិញ្ញាបនប័ត្រចុះបញ្ជី**

បុគ្គលជាប់អាករដែលបានចុះបញ្ជីត្រូវដាក់តាំង ឬព្យួរវិញ្ញាបនប័ត្រចុះបញ្ជីដែលបានចេញឱ្យតាមបទប្បញ្ញត្តិនៃប្រកាសនេះ នៅទីកន្លែងអាជីវកម្មជាសំខាន់របស់ខ្លួន ។

**ប្រការ៧ .. បញ្ជីអាករលើតម្លៃបន្ថែម**

នាយកដ្ឋានពន្ធដារ ត្រូវមានបញ្ជីសម្រាប់កត់ត្រាតាមដាននូវពត៌មានលំអិត ដែលទាក់ទិននឹងបុគ្គលជាប់អាករម្នាក់ៗ ។

**ប្រការ៨ .- អំណាចក្នុងការចុះបញ្ជី**

ប្រធាននាយកដ្ឋានពន្ធដារ មានសិទ្ធចុះបញ្ជីបុគ្គលណាមួយ បើសិនមានមូលដ្ឋានត្រឹមត្រូវជឿជាក់ថាបុគ្គលនោះមានកាតព្វកិច្ចដាក់ពាក្យស្នើសុំចុះបញ្ជីដូចមានចែងក្នុងកថាខ័ណ្ឌ១ និង កថាខ័ណ្ឌ៣ នៃប្រការ១ នៃប្រកាសនេះ ក៏ប៉ុន្តែមិនបានដាក់ពាក្យស្នើសុំ ហើយការចុះបញ្ជីត្រូវមានប្រសិទ្ធិភាពចាប់ពីកាលបរិច្ឆេទដែលមានចុះនៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជី ។

**ប្រការ៩ .- សេចក្តីជូនដំណឹងអំពីការសម្រេចយល់ព្រមឬមិនយល់ព្រមចុះបញ្ជី**

នាយកដ្ឋានពន្ធដារ ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរ អំពីការសម្រេចយល់ព្រមឬមិនយល់ព្រមចុះបញ្ជីឱ្យដល់បុគ្គលដែលបានដាក់ពាក្យស្នើសុំដូចមានចែងក្នុងប្រការ៣ នៃប្រកាសនេះ ក្នុងរយៈពេល៣០ថ្ងៃ ក្រោយបានទទួលពាក្យស្នើសុំ ។

**ប្រការ១០ .- សេចក្តីជូនដំណឹងអំពីការចុះបញ្ជីជាឯកតោភាគី**

នាយកដ្ឋានពន្ធដារ ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរអំពីការសម្រេចចុះបញ្ជីជាឯកតោភាគីឱ្យដល់បុគ្គលដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ ក្នុងរយៈពេល៣០ថ្ងៃក្រោយពេលមានការសម្រេច ។

**ប្រការ១១ .- ការកែប្រែប្រួលពត៌មានបុគ្គលជាប់អាករ**

បុគ្គលជាប់អាករ ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរដល់នាយកដ្ឋានពន្ធដារ អំពីការប្រែប្រួល :

ក- នាមករណ៍ ឬ អស័យដ្ឋានរបស់បុគ្គលនោះ

ខ- ស្ថានភាពផ្សេងៗដែលបណ្តាលឱ្យបុគ្គលនោះមិនអាចបំពេញល័ក្ខខ័ណ្ឌនៃការចុះបញ្ជីតទៅទៀត

គ- ប្រភេទនៃសកម្មភាពអាជីវកម្ម ឬប្រភេទនៃការផ្គត់ផ្គង់ជាប់អាករដែលកំពុងអនុវត្ត និងពត៌មានផ្សេងៗទៀត ។

ការជូនដំណឹងនេះត្រូវធ្វើក្នុងរយៈពេល១៥ថ្ងៃ ក្រោយការប្រែប្រួលបានកើតមានឡើង ។

## ផ្នែកទី៣

## ការចុះបញ្ជីសហគ្រាសវិនិយោគ

**ប្រការ១២ .- ការចុះបញ្ជីសហគ្រាសវិនិយោគ**

បុគ្គលដែលមានការទទួលស្គាល់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសហគ្រាសវិនិយោគ ហើយដែលមិនទាន់បានធ្វើការផ្គត់ផ្គង់ជាប់អាករ អាចស្នើសុំទៅនាយកដ្ឋានពន្ធដារ ដើម្បីធ្វើការចុះបញ្ជីសហគ្រាសវិនិយោគសម្រាប់រយៈពេលមិនលើសពី ២ឆ្នាំ ។

**ប្រការ១៣ .- ល័ក្ខខ័ណ្ឌនៃការចុះបញ្ជី**

បុគ្គលដែលស្នើសុំចុះបញ្ជីសហគ្រាសវិនិយោគ ត្រូវផ្តល់នូវកិច្ចសន្យានិងវត្ថុធានាទៅតាមការតម្រូវរបស់នាយកដ្ឋានពន្ធដារ សម្រាប់ទូទាត់សងវិញនូវប្រាក់អាករដែលនាយកដ្ឋានពន្ធដារបានបង្វិលសង បើសិនជាបុគ្គលនោះមិនបានធ្វើការផ្គត់ផ្គង់ជាប់អាករក្នុងរយៈពេលដែលត្រូវបានចុះបញ្ជីសហគ្រាសវិនិយោគ ។

**ប្រការ១៤ .- ការបង្វិលសងវិញនូវអាករលើធាតុចូល**

សហគ្រាសវិនិយោគអាចទាមទារ និងត្រូវបានបង្វិលសងវិញនូវអាករលើធាតុចូលដែលបានបង់លើចំណាយលើធាតុចូល ទោះបីជាការនាំចូល ឬជាការទទួលក្នុងស្រុកក្តី ដែលទាក់ទិនទៅនឹងគំរោងសកម្មភាពអាជីវកម្មជាប់អាកររបស់សហគ្រាស ។

**ប្រការ១៥ ._ ភារកិច្ចរបស់សហគ្រាសវិនិយោគ**

សហគ្រាសវិនិយោគត្រូវគោរពប្រតិបត្តិរាល់ភារកិច្ច និងកាតព្វកិច្ចទាំងអស់របស់បុគ្គលជាប់អាករដែលបានចុះបញ្ជី មានជាអាទិ៍ ការកាន់កាប់ថែរក្សាបញ្ជីគណនេយ្យ និង ការដាក់លិខិតប្រកាសឱ្យបានទៀតទាត់ ។

**ប្រការ១៦ ._ ការបញ្ចប់លក្ខណៈសម្បត្តិជាសហគ្រាសវិនិយោគ**

ការចុះបញ្ជីសហគ្រាសវិនិយោគរបស់បុគ្គលណាមួយ ត្រូវបានបញ្ចប់ភ្លាមកាលណា :

ក- បុគ្គលបានធ្វើការផ្គត់ផ្គង់ជាប់អាករក្នុងដំណើរការប្រកបអាជីវកម្ម

ខ- ផុតរយៈពេល២ឆ្នាំក្រោយពីកាលបរិច្ឆេទចុះបញ្ជី បើសិនជាបុគ្គលពុំបានធ្វើការផ្គត់ផ្គង់ជាប់អាករ ។

## ផ្នែកទី៤
## ការលុបចោលការចុះបញ្ជី

**ប្រការ១៧ ._ ការបញ្ចប់អាជីវកម្ម**

បុគ្គលជាប់អាករត្រូវស្នើសុំជាលាយល័ក្ខអក្សរទៅនាយកដ្ឋានពន្ធដារ ឱ្យលុបចោលការចុះបញ្ជីរបស់ខ្លួន បើសិនជាបុគ្គលនោះឈប់ធ្វើការផ្គត់ផ្គង់ទំនិញឬសេវាដោយមានតម្លៃ ដែលជាចំណែកមួយនៃសកម្មភាពអាជីវកម្មរបស់ខ្លួន។

**ប្រការ១៨ ._ ការថយចុះផលរបរជាប់អាករ**

បុគ្គលជាប់អាករអាចស្នើសុំជាលាយល័ក្ខអក្សរទៅនាយកដ្ឋានពន្ធដារ ឱ្យធ្វើការលុបចោលការចុះបញ្ជីរបស់ខ្លួនប្រសិនបើកំរិតផលរបរជាប់អាកររបស់ខ្លួនក្នុងរយៈពេល៣ខែប្រតិទិនចុងក្រោយ មានចំនួនមិនលើសពីកំរិតអប្បបរមានៃផលរបរត្រូវចុះបញ្ជី ដូចមានចែងក្នុងកថាខ័ណ្ឌ១ នៃប្រការ១ នៃប្រកាសនេះ ឬប្រសិនបើកំរិតផលរបរជាប់អាករសម្រាប់រយៈពេល ១២ខែប្រតិទិនចុងក្រោយ មានចំនួនមិនលើសពី ៧៥ ភាគរយ នៃកំរិតអប្បបរមា នៃផលរបរប្រចាំឆ្នាំ ត្រូវចុះបញ្ជី ។

**ប្រការ១៩ ._ ការលុបចោលការចុះបញ្ជីដោយស្ម័គ្រចិត្ត**

ចំពោះបុគ្គលជាប់អាករដែលស្នើសុំចុះបញ្ជីតាមកថាខ័ណ្ឌ៤នៃប្រការ១នៃប្រកាសនេះ ការស្នើសុំលុបចោលការចុះបញ្ជីតាមប្រការ១៨នៃប្រកាសនេះ អាចធ្វើទៅបានតែក្រោយរយៈពេល២ឆ្នាំនៃកាលបរិច្ឆេទចុះបញ្ជីប៉ុណ្ណោះ ។

**ប្រការ២០ ._ សិទ្ធិលុបចោលការចុះបញ្ជី**

ប្រធាននាយកដ្ឋានពន្ធដារ មានសិទ្ធិលុបចោលការចុះបញ្ជី :

ក- របស់បុគ្គលដែលបានស្នើសុំលុបតាមប្រការ១៧ ឬប្រការ១៨ នៃប្រកាសនេះ

ខ- របស់បុគ្គលដែលមិនបានស្នើសុំលុបការចុះបញ្ជី ដោយប្រធាននាយកដ្ឋានពន្ធដារយល់ឃើញថាបុគ្គលនោះគ្មានការតម្រូវឬគ្មានសិទ្ធិចុះបញ្ជីតាមប្រការ១ នៃប្រកាសនេះ

គ- របស់បុគ្គលដែលមិនបានដាក់ពាក្យស្នើសុំលុបចោលការចុះបញ្ជី ក៏ប៉ុន្តែមិនបានប្រកាសអំពីការផ្គត់ផ្គង់ជាប់អាករ ក្នុងរយៈពេល៣ខែប្រតិទិនជាប់គ្នា ។

**ប្រការ២១ ._ សិទ្ធិលុបចោលការចុះបញ្ជីដោយស្ម័គ្រចិត្ត**

ប្រធាននាយកដ្ឋានពន្ធដារ មានសិទ្ធិលុបចោលការចុះបញ្ជីរបស់បុគ្គលដែលស្នើសុំចុះបញ្ជីតាម កថាខ័ណ្ឌ៤ នៃប្រការ១ នៃប្រកាសនេះ ក្នុងករណីដែលបុគ្គលនោះ :

ក- គ្មានទីកន្លែងស្នាក់នៅ ឬ កន្លែងអាជីវកម្មជាប់លាប់

ខ- មិនបានរក្សាទុកបញ្ជីគណនេយ្យត្រឹមត្រូវ ដែលទាក់ទិនទៅនឹងសកម្មភាពអាជីវកម្មណាមួយរបស់បុគ្គលនោះ

គ- មិនបានដាក់លិខិតប្រកាស អតប ទៀងទាត់និងត្រឹមត្រូវ ដូចមានចែងក្នុងមាត្រា៧០ នៃច្បាប់ស្តីពីសារពើពន្ធ ។

**ប្រការ២២ .- លិខិតជូនដំណឹងដែលទាក់ទិននឹងការស្នើសុំលុបចោលការចុះបញ្ជី**

នាយកដ្ឋានពន្ធដារ ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរដល់បុគ្គលជាប់អាករ អំពីការសម្រេចយល់ព្រម ឬ មិនយល់ព្រមលុបចោលការចុះបញ្ជីតាមផ្នែកនេះ ក្នុងរយៈពេល៣០ថ្ងៃក្រោយពេលទទួលពាក្យស្នើសុំលុបចោលការចុះបញ្ជី តាមកថាខ័ណ្ឌ ក នៃប្រការ២០ នៃប្រកាសនេះ ឬ ក្នុងរយៈពេល៣០ថ្ងៃក្រោយ ការសម្រេចលុបចោលការចុះបញ្ជីតាមកថាខ័ណ្ឌ ខ នៃប្រការ២០ និងប្រការ២១ នៃប្រកាសនេះ ។

**ប្រការ២៣ .- កាលបរិច្ឆេទមានប្រសិទ្ធិភាពនៃការលុបចោលការចុះបញ្ជី**

ការលុបចោលការចុះបញ្ជីត្រូវមានប្រសិទ្ធិភាពចាប់ពីដំណាច់ខែ ដែលការចុះបញ្ជីត្រូវបានលុបចោល ។

**ប្រការ២៤ .- ការលុបចេញពីបញ្ជី**

ក្នុងករណីដែលការចុះបញ្ជីរបស់បុគ្គលត្រូវបានលុបចោល នាយកដ្ឋានពន្ធដារត្រូវលុបឈ្មោះបុគ្គលនោះ និងពតិមានលំអិតដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះចេញពីបញ្ជីបុគ្គលជាប់អាករ ។

**ប្រការ២៥ .- បំណុលអាករនៅពេលលុបចោលការចុះបញ្ជី**

នៅពេលដែលបុគ្គលជាប់អាករត្រូវបានលុបឈ្មោះចេញពីបញ្ជីតាមផ្នែកនេះ បុគ្គលជាប់អាករត្រូវចាត់ទុកថាបានធ្វើការផ្គត់ផ្គង់ជាប់អាករនូវទំនិញទាំងអស់ដែលនៅក្នុងដៃរួមទាំងទំនិញជាមូលធនផង និងត្រូវបង់អាករលើធាតុចេញលើរាល់ទំនិញទាំងអស់ដែលបានទទួលឥណទានអាករលើធាតុចូលរួចមកហើយ ។ អាករលើធាតុចេញត្រូវបង់ត្រូវផ្អែកតាមតម្លៃទីផ្សារនៃទំនិញ នៅពេលលុបចោលការចុះបញ្ជីនោះ ។

**ប្រការ២៦ .- ប្រសិទ្ធិភាពនៃការលុបចោលចំពោះកាតព្វកិច្ចតាមផ្លូវច្បាប់**

ការលុបចោលការចុះបញ្ជីរបស់បុគ្គលពុំមានផលប៉ះពាល់ដល់ កាតព្វកិច្ច បំណុលនិងទោសទណ្ឌរបស់បុគ្គលដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ រួមទាំងការតម្រូវឱ្យដាក់លិខិតប្រកាសតាមមាត្រា៧០ នៃច្បាប់ស្តីពីសារពើពន្ធដែលបុគ្គលបានធ្វើឬមិនបានធ្វើនៅពេលដែលខ្លួនជាបុគ្គលជាប់អាករ ។

## ផ្នែកទី៥
## ឥណទានអាករលើធាតុចូល

**ប្រការ២៧ .- ឥណទានអាករលើធាតុចូលនៅពេលចាប់ផ្តើមចុះបញ្ជីអាករលើតម្លៃបន្ថែម**

១. នៅពេលដែលបានចុះបញ្ជី បុគ្គលជាប់អាករត្រូវបានអនុញ្ញាតឱ្យនូវឥណទានសម្រាប់អាករលើធាតុចូលដែលបានបង់ឬត្រូវបង់ចំពោះ :

ក- ការផ្គត់ផ្គង់ជាប់អាករទាំងអស់នូវទំនិញ រួមទាំងទ្រព្យសកម្មជាមូលធន ដែលបុគ្គលបានទទួលមុនពេលចុះបញ្ជី

ខ- ការនាំចូលទាំងអស់នូវទំនិញរួមទាំងទ្រព្យសកម្មជាមូលធន ដែលបុគ្គលបានធ្វើមុនពេលចុះបញ្ជី ។

២. ល័ក្ខខ័ណ្ឌនៃការអនុញ្ញាតឱ្យជាឥណទានត្រូវបានកំណត់ដូចតទៅ :

ក- ទំនិញត្រូវបានទិញសម្រាប់ការលក់ជាប់អាករ ឬសម្រាប់ប្រើប្រាស់ដើម្បីធ្វើការផ្គត់ផ្គង់ជាប់អាករ របស់បុគ្គលជាប់អាករ

ខ- ទំនិញដែលមានចុះក្នុងបញ្ជីសារពើភ័ណ្ឌ ត្រូវនៅក្នុងដែនកាលបរិច្ឆេទមានប្រសិទ្ធិភាពនៃការចុះបញ្ជី

គ- ការផ្គត់ផ្គង់ ឬ ការនាំចូលទាំងនោះត្រូវបានធ្វើឡើងមិនលើសពី៦០ថ្ងៃ មុនកាលបរិច្ឆេទមានប្រសិទ្ធិភាពនៃការចុះបញ្ជី

ឃ- ពាក្យស្នើសុំឥណទាន ត្រូវបានធ្វើឡើងតាមទម្រង់ដែលនាយកដ្ឋានពន្ធដារបានកំណត់

ង- ត្រូវមានឯកសារភស្តុតាងត្រឹមត្រូវច្បាស់លាស់ជូននាយកដ្ឋានពន្ធដារ បញ្ជាក់ថាបុគ្គលបានបង់អាករដែលអាចអនុញ្ញាតជាឥណទានពិតមែន ។

**ប្រការ២៨ .- ការគណនាអាករដែលត្រូវបង់**

នៅពេលបុគ្គលជាប់អាករគណនាប្រាក់អាករដែលត្រូវបង់ក្នុងខែ បុគ្គលជាប់អាករនោះត្រូវបានអនុញ្ញាតឱ្យជាឥណទានសម្រាប់អាករដែលបានបង់លើ :

ក- រាល់ការផ្គត់ផ្គង់ជាប់អាករដែលបុគ្គលជាប់អាករបានទទួលក្នុងខែ

ខ- រាល់ការនាំចូលទំនិញដោយបុគ្គលជាប់អាករក្នុងខែ

ឥណទានអាករ ត្រូវបានអនុញ្ញាតផ្តល់ឱ្យតែចំពោះការផ្គត់ផ្គង់ជាប់អាករឬការនាំចូល សម្រាប់ប្រើប្រាស់ដើម្បីធ្វើការផ្គត់ផ្គង់ជាប់អាករតែប៉ុណ្ណោះ ។

**ប្រការ២៩ .- កាលបរិច្ឆេទដល់កំណត់នៃអាករលើធាតុចូល**

ឥណទានអាករលើធាតុចូលត្រូវកើតមានឡើងនៅពេលដូចខាងក្រោមនេះ :

ក- នៅពេលដែលទំនិញឬសេវា ត្រូវបានផ្គត់ផ្គង់ឱ្យបុគ្គលជាប់អាករ ឬនាំចូលដោយបុគ្គលជាប់អាករ ក្នុងករណីឥណទានអាករដូចមានចែងក្នុងប្រការ២៨ នៃប្រកាសនេះ

ខ- នៅពេលបុគ្គលជាប់អាករត្រូវបានចុះបញ្ជី ក្នុងករណីឥណទានអាករដូចមានចែងក្នុងប្រការ២៧ នៃប្រកាសនេះ ។

**ប្រការ៣០ .- អាករលើធាតុចូលដែលមិនអនុញ្ញាតជាឥណទានអាករ**

បុគ្គលជាប់អាករទាំងឡាយ មិនត្រូវបានអនុញ្ញាតឱ្យជាឥណទានអាករលើធាតុចូលទេ ចំពោះប្រាក់អាករដែលបានបង់លើ :

ក- ចំណាយទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ លើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មផ្គត់ផ្គង់ការទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ

ខ- ការទិញឬការនាំចូល រថយន្ត លើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មលក់ឬជួលរថយន្ត

គ- ការទិញឬការនាំចូលផលិតផលតេលសិលាមួយចំនួន លើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មផ្គត់ផ្គង់ផលិតផលតេលសិលាទាំងនោះ ។

**ប្រការ៣១ .- អាករលើធាតុចូលត្រូវបានប្រើប្រាស់មួយចំណែកជាការផ្គត់ផ្គង់ជាប់អាករ និងមួយចំណែកទៀតជាការផ្គត់ផ្គង់មិនជាប់អាករ**

ក្នុងករណីទំនិញឬសេវាទិញចូល ត្រូវបានប្រើប្រាស់មួយចំណែកជាការផ្គត់ផ្គង់ជាប់អាករ និងមួយចំណែកទៀតជាការផ្គត់ផ្គង់មិនជាប់អាករ ឥណទានអាករត្រូវបានអនុញ្ញាតឱ្យតែចំពោះចំណែកដែលបានប្រើប្រាស់ជាការផ្គត់ផ្គង់ជាប់អាករ ។

**ប្រការ៣២ .- ការគណនាឥណទានអាករលើធាតុចូល**

អាករលើធាតុចូលដែលអាចអនុញ្ញាតជាឥណទានឱ្យបុគ្គលជាប់អាករក្នុងរយៈពេលជាប់អាករគឺ :

ក- អាករលើធាតុចូលទាំងអស់ដែលមានបញ្ជាក់នៅក្នុងប្រការ២៨នៃប្រកាសនេះ ក្នុងករណីដែលការផ្គត់ផ្គង់ទាំងអស់របស់បុគ្គលជាប់អាករក្នុងរយៈពេលជាប់អាករនោះ ជាការផ្គត់ផ្គង់ជាប់អាករ

ខ- ក្នុងករណីដែលការផ្គត់ផ្គង់របស់បុគ្គលជាប់អាករនៅក្នុងរយៈពេលជាប់អាករ មានតែមួយផ្នែកប៉ុណ្ណោះជាការផ្គត់ផ្គង់ជាប់អាករចំនួនឥណទានដែលអាចផ្តល់ឱ្យត្រូវបានគណនាតាមរូបមន្ត :

$$ក \times \frac{ខ}{គ} ។$$

ក = ទឹកប្រាក់សរុបនៃអាករលើធាតុចូលក្នុងរយៈពេលជាប់អាករ

ខ = តម្លៃសរុបគ្មាន អតប នៃការផ្គត់ផ្គង់ជាប់អាករ ដែលធ្វើឡើងដោយបុគ្គលជាប់អាករក្នុងរយៈពេលជាប់អាករ

គ = តម្លៃសរុបគ្មាន អតប នៃការផ្គត់ផ្គង់ជាប់អាករនិងការផ្គត់ផ្គង់មិនជាប់អាករដែលធ្វើឡើងដោយបុគ្គលជាប់អាករក្នុងរយៈពេលជាប់អាករ លើកលែងតែតម្លៃនៃការផ្គត់ផ្គង់មិនជាប់អាករនៃការផ្ទេរអាជីវកម្ម ។

**ប្រការ៣៣ .- ការផ្គត់ផ្គង់ជាប់អាករដែលមានលក្ខណៈតិចតួច**

ក្នុងករណីដែលប្រភាគ $\frac{ខ}{គ}$ ក្នុងប្រការ៣២ នៃប្រកាសនេះ តិចជាង ០,០៥ បុគ្គលជាប់អាករមិនត្រូវបានផ្តល់ឥណទានអាករលើធាតុចូលនៅក្នុងរយៈពេលជាប់អាករទេ ។

**ប្រការ៣៤ .- ការផ្គត់ផ្គង់មិនជាប់អាករដែលមានលក្ខណៈតិចតួច**

ក្នុងករណីដែលប្រភាគ $\frac{ខ}{គ}$ ក្នុងប្រការ៣២ នៃប្រកាសនេះ ច្រើនជាង ០,៩៥ បុគ្គលជាប់អាករត្រូវបានអនុញ្ញាតនូវឥណទានអាករចំពោះអាករលើធាតុចូលទាំងអស់នៅក្នុងរយៈពេលជាប់អាករ ។

**ប្រការ៣៥ .- វិធីផ្សេងទៀតសម្រាប់គណនាអាករលើធាតុចូលដែលអាចកាត់កងបាន**

ក្នុងករណីដែលបុគ្គលជាប់អាករធ្វើការផ្គត់ផ្គង់ជាប់អាករផងនិងការផ្គត់ផ្គង់មិនជាប់អាករផងមានផលវិបាកដោយសារការអនុវត្តន៍បទប្បញ្ញត្តិនៃវាក្យខ័ណ្ឌ ខ នៃប្រការ៣២ នៃប្រកាសនេះ នាយកដ្ឋានពន្ធដារអាចអនុញ្ញាតឱ្យបុគ្គលជាប់អាករអនុវត្តតាមរបៀបមួយផ្សេងទៀតដូចខាងក្រោមនេះ ដើម្បីគណនាអាករលើធាតុចូលដែលអាចកាត់កងបាន :

ក- បែងចែកអាករលើធាតុចូលនៃការផ្គត់ផ្គង់ជាប់អាករ និងអាករលើធាតុចូលនៃការផ្គត់ផ្គង់មិនជាប់អាករក្នុងករណីដែលអាចធ្វើទៅបាន ។ ក្នុងករណីនេះបុគ្គលជាប់អាករអាចស្នើសុំឥណទានសម្រាប់អាករលើធាតុចូលទាំងអស់ដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ជាប់អាករ តែមិនអាចស្នើសុំឥណទានសម្រាប់អាករលើធាតុចូលដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់មិនជាប់អាករទេ

ខ- ចំពោះអាករលើធាតុចូលនៅសល់ ដែលមិនអាចបែងចែកតាមវាក្យខ័ណ្ឌ ក នៃប្រការនេះបានឥណទានអាករត្រូវគណនាតាមបទប្បញ្ញត្តិនៃវាក្យខ័ណ្ឌ ខ នៃប្រការ៣២ នៃប្រកាសនេះ ។

**ប្រការ៣៦ .- ជម្រើសវិធីគណនាឥណទានអាករលើធាតុចូលដែលអាចកាត់កងបាន**

ក្នុងករណីដែលបុគ្គលជាប់អាករ ធ្វើការផ្គត់ផ្គង់ជាប់អាករផងនិងការផ្គត់ផ្គង់មិនជាប់អាករផង ចង់ប្រើវិធីគណនាអាករលើធាតុចូលដែលអាចកាត់កងបាន តាមវិធីណាមួយទៀតក្រៅពីវិធីដែលបានចែងក្នុង វាក្យខ័ណ្ឌ ខ នៃ

ប្រការ៣២ នៃប្រកាសនេះ បុគ្គលជាប់អាករនោះត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខអក្សរទៅនាយកដ្ឋានពន្ធដារ និងត្រូវមានការយល់ព្រមជាលាយលក្ខអក្សរពីនាយកដ្ឋានពន្ធដារ ។

**ប្រការ៣៧ .- ការគណនាប្រចាំឆ្នាំនៃអាករលើធាតុចូលដែលអាចកាត់កងបាន**

នៅក្នុងខែដំបូងនៃឆ្នាំប្រតិទិនបន្ទាប់ បុគ្គលជាប់អាករដែលបានគណនាអាករលើធាតុចូល តាមវាក្យខ័ណ្ឌ ខ នៃប្រការ៣២ វាក្យខ័ណ្ឌ ខ នៃប្រការ៣៥ ឬប្រការ៣៦ នៃប្រកាសនេះ ត្រូវធ្វើការគណនាឥណទានអាករដែលអាចកាត់កងបានសម្រាប់ឆ្នាំប្រតិទិនកន្លងមក ដោយផ្អែកលើចំនួនទឹកប្រាក់សរុបប្រចាំឆ្នាំនៃ :

ក- អាករលើធាតុចូលដែលមិនអាចបែងចែកបាន

ខ- ការផ្គត់ផ្គង់ជាប់អាករគ្មានអតប

គ- ការផ្គត់ផ្គង់ជាប់អាករគ្មានអតបនិងការផ្គត់ផ្គង់មិនជាប់អាករ លើកលែងតែការផ្គត់ផ្គង់មិនជាប់អាករនៃការផ្ទេរអាជីវកម្ម ។

**ប្រការ៣៨ .- កំណែតម្រូវប្រចាំឆ្នាំនៃអាករលើធាតុចូលដែលអាចកាត់កងបាន**

ក្នុងករណីដែល :

ក- ឥណទានអាករប្រចាំឆ្នាំប្រតិទិនមានចំនួនលើសឥណទានអាករក្នុងលិខិតប្រកាស ចំនួនលំអៀងត្រូវចាត់ទុកជាឥណទាន សម្រាប់ខែដំបូងនៃឆ្នាំប្រតិទិនបន្ទាប់

ខ- ឥណទានអាករប្រចាំឆ្នាំប្រតិទិនមានចំនួនតិចជាងឥណទានអាករក្នុងលិខិតប្រកាស ចំនួនលំអៀងត្រូវចាត់ទុកជាអាករដែលបុគ្គលជាប់អាករប្រមូលពីការផ្គត់ផ្គង់ជាប់អាករក្នុងខែដំបូងនៃឆ្នាំប្រតិទិនបន្ទាប់ ។

**ប្រការ៣៩ .- តម្រូវការដើម្បីស្នើសុំឥណទានអាករលើធាតុចូលដែលអាចកាត់កងបាន**

ដើម្បីស្នើសុំឥណទានអាករលើធាតុចូលដែលអាចកាត់កងបាន តាមបទប្បញ្ញត្តិនៃប្រកាសនេះ បុគ្គលជាប់អាករត្រូវមាន :

ក- ច្បាប់ដើមនៃវិក្កយប័ត្រអាករសម្រាប់ការផ្គត់ផ្គង់ជាប់អាករ ឬ

ខ- ប្រតិវេទន៍នាំចូលដែលបញ្ជាក់ដោយទីចាត់ការគយនិងរដ្ឋាករ ជាភស្តុតាងនៃទឹកប្រាក់អាករដែលបានបង់លើការនាំចូលទំនិញ ។

**ប្រការ៤០ .- ការបង្វិលសងឥណទានអាករលើធាតុចូលលើស**

១. ដូចមានចែងក្នុងមាត្រា៧២ និងមាត្រា៧៣ នៃច្បាប់ស្តីពីសារពើពន្ធ បុគ្គលជាប់អាករដែលធ្វើការនាំចេញឬបានចុះបញ្ជីជាសហគ្រាសវិនិយោគ បុគ្គលនោះអាចស្នើសុំបង្វិលសងអាករលើធាតុចូលលើស ជារៀងរាល់ខែ ។ រីឯបុគ្គលជាប់អាករដទៃទៀតដែលមានអាករលើធាតុចូលលើសក្នុងរយៈពេល៣ខែជាប់បន្ត ឬច្រើនជាង បុគ្គលនោះអាចដាក់ពាក្យស្នើសុំទៅនាយកដ្ឋានពន្ធដារឱ្យបង្វិលសងនូវអាករលើធាតុចូលលើសនោះនៅដំណាច់ខែទី៣ ឬនៅក្នុងខែណាមួយជាបន្តមកទៀត ។ ពាក្យស្នើសុំត្រូវធ្វើទៅតាមទម្រង់ដែលនាយកដ្ឋានពន្ធដារបានកំណត់ហើយត្រូវដាក់ក្នុងរយៈពេល២០ថ្ងៃក្រោយដំណាច់ខែ ។

២. ចំពោះបុគ្គលជាប់អាករស្នើសុំបង្វិលសងប្រាក់អាករ ក៏ប៉ុន្តែមិនបានប្រកាសនូវការផ្គត់ផ្គង់ជាប់អាករ នាយកដ្ឋានពន្ធដារមិនត្រូវធ្វើការបង្វិលសងឡើយ លើកលែងតែបុគ្គលជាប់អាករនោះបានចុះបញ្ជីជាសហគ្រាសវិនិយោគ ។

៣. នៅក្នុងខែណាមួយដែលបុគ្គលជាប់អាករត្រូវបានទទួលការបង្វិលសងប្រាក់អាករ ហើយបុគ្គលនោះបានដាក់ពាក្យស្នើសុំបង្វិលសងក្នុងរយៈពេល២០ថ្ងៃក្រោយដំណាច់ខែ នាយកដ្ឋានពន្ធដារត្រូវបង្វិលសងប្រាក់អាករនោះនៅដំណាច់ខែ បន្ទាប់ពីខែដែលការស្នើសុំបានធ្វើឡើង ។

៤. ក្នុងករណីដែលនាយកដ្ឋានពន្ធដារ ខកខានមិនបានធ្វើការបង្វិលសងទៅតាមរយៈពេល ដូចមានចែងក្នុងកថាខ័ណ្ឌ៣ នៃប្រកាសនេះ នាយកដ្ឋានពន្ធដារត្រូវបង់ការប្រាក់ទៅឱ្យបុគ្គលជាប់អាករ ចំនួន២ ភាគរយ ក្នុងមួយខែ ឬចំណែកនៃខែដែលប្រាក់បង្វិលសងនៅជំពាក់ ។

៥. បើសិនជាបុគ្គលជាប់អាករដែលស្នើសុំបង្វិលសង មានការតម្រូវពីនាយកដ្ឋានពន្ធដារឱ្យផ្តល់ឯកសារគណនេយ្យឬកំណត់ត្រាដើម្បីបញ្ជាក់ភស្តុតាងនៃការស្នើសុំបង្វិលសង មិនបានផ្តល់ឯកសារទាំងនោះទៅតាមបែបបទដែលកំណត់ដោយនាយកដ្ឋានពន្ធដារក្នុងរយៈពេល ០៧ថ្ងៃ ក្រោយមានការតម្រូវទេនោះ រយៈពេលដែលត្រូវធ្វើការបង្វិលសងដូចមានចែងក្នុងកថាខ័ណ្ឌ៣នៃប្រកាសនេះ មិនមានតម្លៃអនុវត្តន៍ទៅលើនាយកដ្ឋានពន្ធដារទេ ។

**ប្រការ៤១ .- និយមន័យនៃពាក្យ**

វៀរលែងតែមានចែងយ៉ាងណាផ្សេងវិញនោះ សម្រាប់គោលដៅនៃប្រកាសនេះ :

ក- ពាក្យ " ការទទួលភ្ញៀវ " មានន័យថា ការផ្គត់ផ្គង់ម្ហូបអាហារ ភេសជ្ជៈ ថ្នាំជក់ កន្លែងស្នាក់អាស្រ័យ ឬ បដិសណ្ឋារកិច្ចណាមួយ

ខ- ពាក្យ "រថយន្ត" សំដៅដល់ រថយន្តសម្រាប់តែដឹកមនុស្សដែលមានកន្លែងអង្គុយមិនលើសពី ១០

គ- ពាក្យ "ផលិតផលគេលសិលា" សំដៅដល់ប្រេងសាំងធម្មតា ប្រេងសាំងស៊ុបពែរ និងប្រេងរំអិល ។

ឃ- ពាក្យ " ឥណទានអាករប្រចាំឆ្នាំប្រតិទិន " មានន័យថា អាករលើធាតុចូលសរុបដែលអាចកាត់កងបានសម្រាប់ឆ្នាំប្រតិទិន ដោយផ្អែកលើការគណនាសរុបប្រចាំឆ្នាំ ។

ង- ពាក្យ " ឥណទានអាករក្នុងលិខិតប្រកាស " មានន័យថា អាករលើធាតុចូលសរុបដែលបានស្នើសុំជាឥណទាន ក្នុងខែនីមួយៗនៃឆ្នាំប្រតិទិន ។

# ផ្នែកទី ៦

# វិក្កយប័ត្រអាករ

**ប្រការ៤២ .- លក្ខខណ្ឌដែលទាក់ទិននិងការចេញ និង ការប្រើប្រាស់វិក្កយប័ត្រអាករ**

បន្ថែមលើសេចក្តីចែងនៃមាត្រា៧៧ នៃច្បាប់ស្តីពីសារពើពន្ធ ការប្រើប្រាស់វិក្កយប័ត្រអាករ ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិដូចតទៅ :

ក- នៅពេលធ្វើការផ្គត់ផ្គង់ទៅឱ្យបុគ្គលជាប់អាករម្នាក់ទៀត បុគ្គលជាប់អាករត្រូវចេញវិក្កយប័ត្រអាករដល់បុគ្គលជាប់អាករនោះ

ខ- វិក្កយប័ត្រអាករត្រូវមានចុះលេខអត្តសញ្ញាណកម្មនៃការចុះបញ្ជីអាករលើតម្លៃបន្ថែមនៃអ្នកទិញ

គ- បុគ្គលជាប់អាករអាចទាមទារឱ្យបុគ្គលជាប់អាករម្នាក់ទៀត ដែលជាអ្នកធ្វើការផ្គត់ផ្គង់ទំនិញឬសេវាឱ្យខ្លួន ផ្តល់វិក្កយប័ត្រអាករនៃការផ្គត់ផ្គង់នោះ

ឃ- បុគ្គលជាប់អាករ ដែលមិនបានផ្តល់វិក្កយប័ត្រអាករអោយទៅបុគ្គលជាប់អាករផ្សេងទៀតត្រូវទទួលទោសទណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ

ង- បុគ្គលជាប់អាករមិនត្រូវចេញវិក្កយប័ត្រអាករ ទៅឱ្យអតិថិជនដែលមិនមែនជាបុគ្គលជាប់អាករទេ ប៉ុន្តែត្រូវចេញវិក្កយប័ត្រធម្មតា ឬ ឯកសារផ្សេងទៀតទៅឱ្យអតិថិជនដែលមិនមែនជាបុគ្គលជាប់អាករ

ច- នៅពេលធ្វើការផ្គត់ផ្គង់ បុគ្គលជាប់អាករត្រូវរក្សាច្បាប់ចម្លងវិក័យប័ត្រអាករ វិក្ក័យប័ត្រធម្មតា ឬឯកសារផ្សេងទៀតដែលបានចេញឱ្យអតិថិជនរបស់ខ្លួន ។

# ផ្នែកទី ៧

# ការផ្គត់ផ្គង់មិនជាប់អាករចំពោះបេសកកម្មទូតនិងអង្គការអន្តរជាតិ

**ប្រការ៤៣ .- ការផ្គត់ផ្គង់មិនជាប់អាករចំពោះបេសកកម្មទូតនិងអង្គការអន្តរជាតិ**

ការផ្គត់ផ្គង់មិនជាប់អាករចំពោះបេសកកម្មទូតនិងអង្គការអន្តរជាតិ ត្រូវបានកំណត់ដូចតទៅ :

១. ការនាំចូលទំនិញសម្រាប់ ឬដោយបេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា សម្រាប់យកមកប្រើប្រាស់ក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន ត្រូវកំណត់ថាជាការផ្គត់ផ្គង់មិនជាប់អាករ ។ ការផ្គត់ផ្គង់មិនជាប់អាករត្រូវបានផ្តល់ឱ្យតែក្នុងករណីមានការបញ្ជាក់ពីប្រធានបេសកកម្មជូននាយកដ្ឋានពន្ធដារថា ទំនិញទាំងនោះត្រូវបាននាំចូលមកសម្រាប់គោលដៅនៃការប្រើប្រាស់ដូចខាងលើនេះមែន ។

២. បេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា អាចដាក់ពាក្យស្នើសុំបង្វិលសងប្រាក់អាករលើទំនិញដែលបានទិញក្នុងស្រុក ដែលមានចុះនៅក្នុងបញ្ជីរាយមុខទំនិញ កំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ការបង្វិលសងប្រាក់អាករអាចអនុវត្តទៅបានតែក្នុងករណីមានការបញ្ជាក់ពីប្រធានបេសកកម្មជូននាយកដ្ឋានពន្ធដារថា ទំនិញត្រូវបានទិញសម្រាប់យកទៅប្រើប្រាស់នៅក្នុងការបំពេញមុខងារជាផ្លូវការរបស់អង្គភាពសាមី ។

៣. ការស្នើសុំបង្វិលសងប្រាក់អាករដូចមានចែងក្នុងកថាខ័ណ្ឌ២ នៃប្រការនេះ ត្រូវអនុវត្តតាមលក្ខខ័ណ្ឌដូចខាងក្រោម:

ក- ពាក្យស្នើសុំត្រូវធ្វើតាមទម្រង់ដែលនាយកដ្ឋានបានកំណត់

ខ- វិក្ក័យប័ត្រទិញនីមួយៗ ត្រូវមានទឹកប្រាក់សរុបគ្មាន អតប នៃទំនិញដែលបានអនុញ្ញាតឱ្យបង្វិលសងប្រាក់អាករ ចាប់ពី ១០០.០០០ រៀលឡើងទៅ

គ- ពាក្យស្នើសុំបង្វិលសងនីមួយៗត្រូវមានទឹកប្រាក់សរុបគ្មានអតប ចាប់ពី៥០០.០០០រៀលឡើងទៅ

ឃ- ការស្នើសុំអាចធ្វើបានតែ១ ដងក្នុងមួយខែ ។

ចំពោះការស្នើសុំបង្វិលសងប្រាក់អាករដូចមានចែងក្នុងកថាខ័ណ្ឌ ២ នៃប្រការនេះ នាយកដ្ឋានពន្ធដារត្រូវជូនដំណឹងពីការយល់ព្រម ឬមិនយល់ព្រមបង្វិលសងប្រាក់អាករ ក្នុងរយៈពេល១ខែ ក្រោយពេលទទួលពាក្យស្នើសុំ ។

# ផ្នែកទី ៨

# ទីតាំងនិងនីតិវិធីសម្រាប់ការផ្គត់ផ្គង់ជាប់អាករ

**ប្រការ៤៤ .- ទីកន្លែងនៃការផ្គត់ផ្គង់ទំនិញ**

ទីកន្លែងនៃការផ្គត់ផ្គង់ទំនិញ ត្រូវបានកំណត់ដូចតទៅ :

១. ការផ្គត់ផ្គង់ទំនិញ ត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាទំនិញនោះត្រូវបានប្រគល់ឱ្យ ទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងក្តី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ចំពោះ

ករណីដែលការផ្គត់ផ្គង់ត្រូវមានការដឹកជញ្ជូន ការផ្គត់ផ្គង់ត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាបើសិនជាទំនិញស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដែលការដឹកជញ្ជូនត្រូវបានចាប់ផ្តើម ។

**ប្រការ៤៥ .- ទីកន្លែងនៃការផ្គត់ផ្គង់សេវា**

ការផ្គត់ផ្គង់សេវា ត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាសេវានោះត្រូវបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយឡែកតែ :

ក- ការផ្គត់ផ្គង់សេវាដែលជាប់ទាក់ទងនឹងអចលនទ្រព្យ ត្រូវកំណត់ថាសេវានោះបានធ្វើឡើងនៅទីកន្លែងដែលអចលនទ្រព្យនោះស្ថិតនៅ

ខ- ការផ្គត់ផ្គង់សេវាដែលជាប់ទាក់ទងនឹងការដឹកជញ្ជូន ត្រូវកំណត់ថាសេវានោះបានធ្វើឡើងនៅទីកន្លែងនៃការដឹកជញ្ជូននោះ

គ- ការផ្គត់ផ្គង់សេវាសម្រាប់ការប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ថាបានធ្វើឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤៦ .- ទីកន្លែងផ្គត់ផ្គង់នៃការនាំចូល**

ទីកន្លែងផ្គត់ផ្គង់នៃការនាំចូល គឺជាទីកន្លែងដែលទំនិញត្រូវបាននាំចូលមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា និងជាទីកន្លែងត្រូវបង់ពន្ធគយនិងបន្ទុកសារពើពន្ធផ្សេងទៀតនៃការនាំចូល ។

**ប្រការ៤៧ .- ការផ្គត់ផ្គង់ឈាយនុវត្តរវាងទំនិញនិងសេវា**

១. ការផ្គត់ផ្គង់នូវសេវាបន្ទាប់បន្សំដែលរួមជាមួយនិងការផ្គត់ផ្គង់ទំនិញ គឺជាចំណែកមួយនៃការផ្គត់ផ្គង់ទំនិញ ។

២. ការផ្គត់ផ្គង់នូវទំនិញបន្ទាប់បន្សំដែលរួមជាមួយនិងការផ្គត់ផ្គង់សេវា គឺជាចំណែកមួយនៃការផ្គត់ផ្គង់សេវា ។

៣. ការផ្គត់ផ្គង់នូវសេវាបន្ទាប់បន្សំដែលរួមជាមួយនិងការនាំចូល គឺជាចំណែកមួយនៃការនាំចូល ។

**ប្រការ៤៨ .- ពេលផ្គត់ផ្គង់**

១. ពេលផ្គត់ផ្គង់ទំនិញ ឬសេវា ត្រូវបានកំណត់ដូចតទៅ :

ក- ពេលផ្គត់ផ្គង់ទំនិញនិងសេវា គឺជាពេលដែលអ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយប័ត្រ ឬជាពេលដែលអ្នកផ្គត់ផ្គង់បានចេញវិក្កយប័ត្រ ប្រសិនបើវិក្កយប័ត្រនោះត្រូវបានចេញមុនពេលដែលអ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយប័ត្រ ។ អ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយប័ត្រអាករ យ៉ាងយឺតបំផុត ៧ថ្ងៃក្រោយការបញ្ជូនទំនិញឬការបំពេញសេវា ឬ ក្រោយការទូទាត់ ក្នុងករណីដែលការទូទាត់ត្រូវបានធ្វើឡើងមុនការបញ្ជូនទំនិញឬការបំពេញសេវា ។

ខ- ក្នុងករណីដែលទំនិញត្រូវបានយកទៅប្រើប្រាស់ផ្ទាល់ខ្លួន ពេលផ្គត់ផ្គង់គឺជាពេលដែលទំនិញនោះត្រូវបានយកទៅប្រើប្រាស់ដំបូង ។

គ- ក្នុងករណីទំនិញឬសេវាត្រូវបានផ្គត់ផ្គង់ក្នុងលក្ខណៈជាអំណោយ ពេលផ្គត់ផ្គង់គឺជាពេលដែលទំនិញត្រូវបានប្រគល់ឱ្យ ទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងក្តី ឬពេលដែលសេវាផ្គត់ផ្គង់ឱ្យត្រូវបានបំពេញរួចរាល់ ។

២. ពេលផ្គត់ផ្គង់ទំនិញក្រោមកិច្ចសន្យាជួលទិញ ឬកតិសន្យាហិរញ្ញវត្ថុ គឺជាពេលដែលទំនិញត្រូវបានប្រគល់ឱ្យ ទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងក្តី ។

៣. ក្នុងករណីដែល :

ក- ទំនិញត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យាជួល ឬ

ខ- ទំនិញឬសេវាត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យាឬច្បាប់ដែលចែងអំពីការទូទាត់ច្រើនលើក ឬ

គ- សេវាត្រូវបានផ្គត់ផ្គង់ជាប់បន្ត

ទំនិញឬសេវា ត្រូវចាត់ទុកថាបានផ្គត់ផ្គង់រួចរាល់ចំពោះចំណែកដែលបានផ្គត់ផ្គង់រួចរាល់ក្នុងរយៈពេលនៃកិច្ចសន្យាឬរយៈពេលដែលច្បាប់បានកំណត់ ហើយពេលផ្គត់ផ្គង់នៃចំណែកដែលបានផ្គត់ផ្គង់រួចរាល់នីមួយៗ គឺជាកាលបរិច្ឆេទមុនគេ ក្នុងចំណោមកាលបរិច្ឆេទដែលការទូទាត់ត្រូវដល់កំណត់ និងកាលបរិច្ឆេទដែលបានទទួលការទូទាត់ ។

៤- ចំពោះការនាំចូលទំនិញ ពេលផ្គត់ផ្គង់ គឺជាពេលដែលអ្នកនាំចូលដាក់លិខិតប្រកាសជូនអាជ្ញាធរគយនិងរដ្ឋាករ ទៅតាមគោលការណ៍ជាធរមាន ហើយពន្ធគយនិងអាករនានាត្រូវបានបង់ ។

## ផ្នែកទី ៩

## ការកែតម្រូវទឹកប្រាក់អាករ

**ប្រការ៤៩ .-និតិវិធីកែតម្រូវទឹកប្រាក់អាករនៅក្រោយពេលផ្គត់ផ្គង់និងពេលចេញវិក្កយបត្រ**

១. បុគ្គលជាប់អាករដែលបានចេញវិក្កយបត្រអាករឬបានដាក់លិខិតប្រកាសប្រចាំខែរួចហើយ បុគ្គលនោះអាចធ្វើការកែតម្រូវទឹកប្រាក់អាករឡើងវិញបានបើសិនជាមានហេតុការណ៍ដូចខាងក្រោមនេះបានកើតឡើង :

ក- ការផ្គត់ផ្គង់ត្រូវបានលុបចោល ឬ

ខ- ចរិកនៃការផ្គត់ផ្គង់ត្រូវបានប្រែប្រួល ឬបានផ្លាស់ប្តូរជាមូលដ្ឋាន ឬ

គ- អត្ថប្រយោជន៍សម្រាប់ការផ្គត់ផ្គង់ដែលបានព្រមព្រៀងគ្នាពីពេលមុន ត្រូវបានប្រែប្រួល ឬបានផ្លាស់ប្តូរដោយកិច្ចព្រមព្រៀងថ្មីជាមួយនឹងអ្នកទទួលការផ្គត់ផ្គង់ ដោយមូលហេតុនៃការបញ្ចុះថ្លៃ ឬ ដោយហេតុផលផ្សេងទៀត ឬ

ឃ- ទំនិញឬចំណែកណាមួយនៃទំនិញឬសំបកវេចខ្ចប់ ត្រូវបានបញ្ជូនត្រឡប់មកអ្នកផ្គត់ផ្គង់វិញ ឬសេវាមិនត្រូវបានបំពេញរួចរាល់ ។

២. ក្នុងករណីមានការកែតម្រូវដូចមានចែងក្នុងកថាខ័ណ្ឌ១ នៃប្រការនេះ បុគ្គលជាប់អាករត្រូវធ្វើការកែតម្រូវបន្ទុកអាកររបស់ខ្លួនដូចតទៅ :

ក- បើសិនជាប្រាក់អាករលើធាតុចេញកែតម្រូវ មានចំនួនលើសពីប្រាក់អាករលើធាតុចេញ ដែលបុគ្គលជាប់អាករបានកត់ត្រា ចំនួនលើសត្រូវបានចាត់ទុកជាប្រាក់អាករដែលបុគ្គលជាប់អាករបាន

ប្រមូលនៅក្នុងខែដែលហេតុការណ៍ដូចមានចែងក្នុងកថាខ័ណ្ឌ១នៃប្រការនេះបានកើតឡើង

ខ- បើសិនជាប្រាក់អាករលើធាតុចេញដែលបុគ្គលជាប់អាករបានកត់ត្រា មានចំនួនលើសពីប្រាក់អាករលើធាតុចេញកែតម្រូវ ចំនួនលើសត្រូវបានចាត់ទុកជាឥណទានអាករសម្រាប់ខែដែលហេតុការណ៍ដូចមានចែងក្នុងកថាខ័ណ្ឌ១នៃប្រការនេះបានកើតឡើង ។

៣. ចំពោះការផ្គត់ផ្គង់ឱ្យបុគ្គលដែលមិនមែនជាបុគ្គលជាប់អាករ ប្រាក់អាករលើស ដូចមានចែងក្នុងវាក្យខ័ណ្ឌ ខ នៃកថាខ័ណ្ឌ២ នៃប្រការនេះ មិនត្រូវបានអនុញ្ញាតជាឥណទានអាករទេ លើកលែងតែបុគ្គលជាប់អាករបានទូទាត់សងប្រាក់អាករលើសឱ្យអ្នកទទួលការផ្គត់ផ្គង់វិញ ជាសាច់ប្រាក់ឬជាការកាត់កងនឹងបំណុលដែលអ្នកទទួលការផ្គត់ផ្គង់ជំពាក់បុគ្គលជាប់អាករ ។

៤. ក្នុងករណីដែលបុគ្គលជាប់អាករ បានចេញវិក្កយប័ត្រអាករ ដោយមកពីហេតុការណ៍ដូចមានចែងក្នុងកថាខ័ណ្ឌ១ នៃប្រការនេះ ហើយចំនួនប្រាក់អាករដែលបានកត់ត្រាលើវិក្កយប័ត្រមានចំនួនលើសពីប្រាក់អាករកែតម្រូវនៃការផ្គត់ផ្គង់ទំនិញ បុគ្គលជាប់អាករដែលធ្វើការផ្គត់ផ្គង់ទំនិញត្រូវផ្តល់អោយអ្នកទទួលការផ្គត់ផ្គង់នូវ លិខិតឥណទានអាករដែលមាននិទ្ទេសដូចមានចែងក្នុងផ្នែក៦ នៃប្រកាសនេះ និង មាត្រា៧៧ នៃច្បាប់ស្តីពីសារពើពន្ធ ។

៥. ក្នុងករណីដែលបុគ្គលជាប់អាករ បានចេញវិក្កយប័ត្រអាករ ដោយមកពីហេតុការណ៍ដូចមានចែងក្នុងកថាខ័ណ្ឌ១ នៃប្រការនេះ ហើយប្រាក់អាករដែលបានកត់ត្រាលើវិក្កយប័ត្រមានចំនួនតិចជាងប្រាក់អាករកែតម្រូវនៃការផ្គត់ផ្គង់ទំនិញ បុគ្គលជាប់អាករដែលធ្វើការផ្គត់ផ្គង់ទំនិញត្រូវផ្តល់អោយអ្នកទទួលការផ្គត់ផ្គង់នូវ លិខិតឥណពន្ធអាករដែលមាននិទ្ទេសដូចមានចែងក្នុងផ្នែក៦ នៃប្រកាសនេះ និងមាត្រា៧៧ នៃច្បាប់ស្តីពីសារពើពន្ធ ។

៦. បុគ្គលជាប់អាករជាអ្នកធ្វើការផ្គត់ផ្គង់ ឬជាអ្នកទទួលការផ្គត់ផ្គង់ដែលបានចេញឬបានទទួលលិខិតឥណពន្ធឬលិខិតឥណទានអាករ ត្រូវកត់ត្រាចលនាទឹកប្រាក់នៃលិខិតឥណពន្ធឬលិខិតឥណទានអាករដូចគ្នាទៅនឹងចលនាទឹកប្រាក់នៃវិក្កយប័ត្រអាករដែរ ។

## ផ្នែកទី ១០
## បញ្ជីគណនេយ្យ កំណត់ត្រា និង ពត៌មាន

**ប្រការ៥០ .- បញ្ជីគណនេយ្យ និង កំណត់ត្រាដែលត្រូវកាន់កាប់ថែរក្សាដោយបុគ្គលជាប់អាករ**

បុគ្គលជាប់អាករ ត្រូវកាន់កាប់និងកត់ត្រាបញ្ជីគណនេយ្យនៃការផ្គត់ផ្គង់ទាំងអស់ដែលខ្លួនបានធ្វើនិងបានទទួលនៅក្នុងដំណើរការប្រកបអាជីវកម្ម រួមទាំងការផ្គត់ផ្គង់ដែលជាប់អាករតាមអត្រាសូន្យ និងការផ្គត់ផ្គង់មិនជាប់អាករ ។

សម្រាប់គោលដៅនៃគណនេយ្យអាករលើតម្លៃបន្ថែម បុគ្គលជាប់អាករត្រូវកាន់កាប់ និងថែរក្សា បញ្ជីគណនេយ្យ កំណត់ត្រានិងពតិមានដូចខាងក្រោមនេះ :

ក- គណនីអាករលើតម្លៃបន្ថែមប្រចាំខែ ដែលបញ្ជាក់អំពីអាករលើធាតុចេញសរុប អាករលើធាតុចូលសរុប ប្រាក់អាករត្រូវបង់ ឬ ឥណទានអាករលើសត្រូវយោងទៅមុខឬដល់កំណត់ត្រូវបង្វិលសងវិញ

ខ- កំណត់ត្រាទិញទាំងអស់ ដែលលំអិតអំពីការទិញទាំងអស់ដែលបានបង់អាករនិងការទិញទាំងអស់ដែលគ្មានបង់អាករ ។ ច្បាប់ដើមនៃវិក្កយប័ត្រអាករសម្រាប់ការទិញក្នុងស្រុកដែលបានបង់អាករ ប្រតិវេទន៍នាំចូលបញ្ជាក់ដោយទីចាត់ការគយដែលបង្ហាញអំពីអាករបានបង់ ហើយនិងវិក្កយប័ត្រនៃការទិញដែលគ្មានបង់អាករ ត្រូវរក្សាទុកតាមលំដាប់ថ្ងៃខែ និង លេខរៀង

គ- កំណត់ត្រាលក់ទាំងអស់ ដែលរួមមានការលក់ជាប់អាករតាមអត្រាស្តង់ដា ១០ ភាគរយ អត្រាសូន្យ និងការលក់មិនជាប់អាករ ។ ច្បាប់ចំលងនៃវិក្កយប័ត្រដែលទាក់ទិននឹងការលក់ជាប់អាករ ហើយនិងវិក្កយប័ត្រដែលទាក់ទិននឹងការលក់មិនជាប់អាករ ត្រូវរក្សាទុកតាមលំដាប់ថ្ងៃ ខែ និងលេខរៀង

ឃ- លិខិតឥណពន្ធនិងលិខិតឥណទាន ដែលបានចេញនិងបានទទួល ត្រូវរក្សាទុកតាមលំដាប់ថ្ងៃ ខែ និងលេខរៀង

ង- កំណត់ត្រាលើរាល់ការនាំចេញនូវទំនិញនិងសេវាតាមអត្រាសូន្យ ព្រមទាំងប្រតិវេទន៍គយសម្រាប់ការនាំចេញ ច្បាប់ចម្លងនៃវិក្កយប័ត្រដែលបានចេញឱ្យអ្នកទិញបរទេស ឯកសារដឹកជញ្ជូនសម្រាប់ការនាំចេញទំនិញ លិខិតបញ្ជាទិញឬកិច្ចសន្យាជាមួយអ្នកទិញបរទេស ហើយនិងភស្តុតាងនៃការទូទាត់ប្រាក់ តាមវិធីផ្ទេរប្រាក់តាមធនាគារដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬតាមលិខិតឥណទាន។ ចំពោះលិខិតឥណទាន ត្រូវមានចុះបញ្ជាក់ឱ្យបើកប្រាក់ទូទាត់ពីធនាគារបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការយល់ព្រមណាមួយ

ច- កំណត់ត្រាចលនាសាច់ប្រាក់របស់ អ្នកលក់រាយដែលរួមមានបញ្ជីបេឡា និងបញ្ជីប្រាក់នៅធនាគារ ប័ណ្ណចំណាយប្រាក់បេឡា និងកំណត់ត្រាគណនេយ្យផ្សេងទៀត រួមទាំងច្បាប់ចំលងនៃបង្កាន់ដៃទទួលប្រាក់ ឬបញ្ជីលំអិតអំពីចំនួនទឹកប្រាក់នៃការលក់ដូរប្រចាំថ្ងៃ

ឆ- កំណត់ត្រាដោយកុំព្យូទ័របើសិនជាមាន

ជ- ពតិមានលំអិតស្តីពីការគណនាអាករលើធាតុចូល ក្នុងករណីដែលបុគ្គលជាប់អាករធ្វើការផ្គត់ផ្គង់ជាប់អាករផង និងការផ្គត់ផ្គង់មិនជាប់អាករផង

ឈ-ឯកសារ កំណត់ត្រានានា និងទម្រង់ស្នើសុំឥណទានចំពោះអាករលើផលរបរនិងអាករប្រើប្រាស់ក្នុងរយៈពេលអន្តរកាល

ញ- កំណត់ត្រាស្តុក ដែលបង្ហាញអំពីការបញ្ចូលបញ្ចេញទំនិញ និង កំណត់ត្រាផលិតកម្ម

ដ- កំណត់ត្រាបញ្ជាទិញ និងប័ណ្ណប្រគល់ទំនិញ

ឋ- លិខិតឆ្លើយឆ្លងអាជីវកម្ម

ឌ- សៀវភៅណាត់ជួប និង សៀវភៅការងារ

ឍ- របាយការណ៍គណនេយ្យប្រចាំឆ្នាំ រួមមានគណនីលទ្ធផល តារាងតុល្យការ និងតារាងពតិមានបន្ថែម

ណ-កំណត់ត្រាខាងធនាគារ រួមមានសម្រង់គណនី គល់សៀវភៅមូលប្បទានប័ត្រ និងប័ណ្ណបង់ប្រាក់ចូលធនាគារ ។

កំណត់ត្រាទាំងអស់ ត្រូវធ្វើឡើងទៅតាមទម្រង់ដែលនាយកដ្ឋានពន្ធដារបានកំណត់ឬបានទទួលស្គាល់ហើយ ត្រូវថែរក្សានិងត្រៀមបំរុងសម្រាប់ការត្រួតពិនិត្យ ក្នុងរយៈពេល១០ឆ្នាំ ។

## ផ្នែកទី១១

## ការផ្គត់ផ្គង់ទំនិញដល់អ្នកប្រើប្រាស់

**ប្រការ៥១ .. ការគណនាអាករលើការលក់ទំនិញដល់បុគ្គលមិនជាប់អាករ**

បុគ្គលជាប់អាករដែលធ្វើការផ្គត់ផ្គង់ជាប់អាករតាមអត្រាស្តង់ដា ឱ្យដល់បុគ្គលមិនជាប់អាករ ត្រូវកាន់បញ្ជីគណនេយ្យនិងកំណត់ត្រានានាដូចមានចែងក្នុងប្រការ៥០ នៃប្រកាសនេះ ហើយត្រូវអនុវត្តតាមវិធីគិតដូចខាងក្រោមនេះ:

ក. ក្នុងករណីដែលបានចេញវិក្កយប័ត្រធម្មតា បើសិនជានៅលើវិក្កយប័ត្រមានបញ្ជាក់ចំនួនទឹកប្រាក់អាករដោយឡែកនោះ ប្រាក់អាករដល់កំណត់ក្នុងខែ ត្រូវគណនាចេញពីកំណត់ត្រាការលក់ ។

ខ. បើសិនជានៅលើវិក្កយប័ត្រគ្មានបញ្ជាក់ចំនួនទឹកប្រាក់អាករដោយឡែកទេ ឬបុគ្គលជាប់អាករធ្វើការលក់រាយដោយមិនបានចេញវិក្កយប័ត្រ បុគ្គលជាប់អាករត្រូវកាន់កំណត់ត្រាការលក់សរុបប្រចាំថ្ងៃនៃការលក់ជាប់អាករនិងការលក់មិនជាប់អាករ ។ ក្នុងការគណនាប្រាក់អាករ ត្រូវយកតម្លៃសរុបនៃការលក់ប្រចាំខែទៅគុណប្រភាគអាករ ។ ប្រភាគអាករសម្រាប់អត្រា ១០ ភាគរយគឺ: $\frac{១}{១១}$ ។

ដើម្បីរកតម្លៃជាប់អាករត្រូវយកតម្លៃសរុបនៃការលក់ប្រចាំខែ ដកទឹកប្រាក់អាករចេញ ។

## ជំពូកទី ១២

## ការផ្គត់ផ្គង់ដោយភ្នាក់ងារ

**ប្រការ៤២ .- លំនាំទំនងនៃការផ្គត់ផ្គង់ទំនិញឬសេវាដោយភ្នាក់ងារ**

១. ការផ្គត់ផ្គង់ទំនិញឬសេវា ធ្វើឡើងដោយបុគ្គលជាភ្នាក់ងារដើម្បីជាគុណប្រយោជន៍របស់បុគ្គលម្នាក់ទៀតដែលជាបុគ្គលដើម ត្រូវបានចាត់ទុកថាជាការផ្គត់ផ្គង់របស់បុគ្គលដើមនោះ ។

២. ក្នុងករណីដែលភ្នាក់ងារជាបុគ្គលជាប់អាករ ភ្នាក់ងារនោះត្រូវគិតអាករលើកម្រៃដែលបានមកពីការផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមបុគ្គលម្នាក់ទៀតដែលជាបុគ្គលដើម ។ បើសិនជាបុគ្គលដើមនិងភ្នាក់ងារជាបុគ្គលជាប់អាករទាំងពីរនាក់ ប្រាក់អាករដែលកំណត់លើប្រាក់កម្រៃដោយភ្នាក់ងារត្រូវចាត់ទុកជាអាករលើធាតុចូលរបស់បុគ្គលដើម ។

## ជំពូកទី ១៣

## ការប្រមូលអាករលើតម្លៃបន្ថែមលើការនាំចូល

**ប្រការ៤៣ .- ការប្រមូលអាករលើតម្លៃបន្ថែមនៅពេលនាំចូល**

១. អាករដល់កំណត់នៅពេលនាំចូល និងត្រូវប្រមូលដោយទីចាត់ការគយនិងរដ្ឋាករ ។

២. អាករត្រូវបានប្រមូលតាមរយៈការប្រកាសក្នុងប្រតិវេទន៍គយសម្រាប់ការនាំចូល ហើយត្រូវបានចាត់ចែងតាមរបៀបដូចគ្នានឹងពន្ធគយ ។

៣. តម្លៃជាប់អាករនៃការនាំចូលទំនិញគឺជាចំនួនសរុបនៃ :

ក- តម្លៃទំនិញ សម្រាប់គិតពន្ធគយស្របតាមច្បាប់ដែលទាក់ទិននឹងពន្ធគយ

ខ- ចំនួនទឹកប្រាក់នៃពន្ធគយ អាករពិសេសលើទំនិញនិងសេវាមួយចំនួន និងបន្ទុកសារពើពន្ធផ្សេងទៀត ដែលត្រូវបង់លើទំនិញទាំងនោះក្រៅពីអាករលើតម្លៃបន្ថែម

គ- តម្លៃសេវាណាមួយដែលមានចែងក្នុងកថាខ័ណ្ឌ៣ នៃប្រការ៤៧ នៃប្រកាសនេះ ដែលមិនបានបូកបញ្ចូលក្នុងតម្លៃទំនិញសម្រាប់គិតពន្ធគយ ដូចមានចែងក្នុងវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌ៣ នៃប្រការនេះ ។

៤. ទីចាត់ការគយនិងរដ្ឋាករ ត្រូវផ្តល់ឱ្យអ្នកនាំចូល នូវច្បាប់ចម្លងនៃប្រតិវេទន៍គយសម្រាប់ការនាំចូលដែលក្នុងនោះត្រូវ :

ក- ចុះលេខអត្តសញ្ញាណកម្មអតប បើសិនជាអ្នកនាំចូលជាបុគ្គលជាប់អាករ

ខ- សរសេរថា "គ្មាន" ក្នុងប្រអប់សម្រាប់ចុះលេខអត្តសញ្ញាណកម្មអតប បើសិនជាអ្នកនាំចូលមិនមែនជាបុគ្គលជាប់អាករ

គ- បញ្ជាក់នូវចំនួនប្រាក់អាករដែលបានបង់ លើប្រតិវេទន៍គយសម្រាប់ការនាំចូល បើសិនជាអ្នកនាំចូល ជាបុគ្គលជាប់អាករធ្វើការនាំចូលដើម្បីប្រកបអាជីវកម្មជាប់អាករ ។

ឃ- បញ្ជាក់អំពីអសុពលភាព នៃការបង្វិលសងប្រាក់អាករ ប្រសិនបើអ្នកនាំចូលមិនមែនជាបុគ្គលជាប់អាករ ឬធ្វើការនាំចូលដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន ។

# ផ្នែកទី ១៤

# អត្រាសូន្យភាគរយនៃការនាំចេញនូវទំនិញនិងសេវា

**ប្រការ៥៤ .- ដែនអនុវត្តនៃអត្រាសូន្យភាគរយសម្រាប់ការនាំចេញទំនិញនិងសេវា**

១. ស្របតាមកថាខ័ណ្ឌ២ នៃមាត្រា៦៤ នៃច្បាប់ស្តីពីសារពើពន្ធ អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រាសូន្យភាគរយ លើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ទំនិញនិមួយៗដែលបាននាំចេញពីព្រះរាជាណាចក្រកម្ពុជា ឬការផ្គត់ផ្គង់ជាប់អាករនៃសេវាដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជា"។

ដែនអនុវត្តនៃបទបញ្ញត្តិនេះត្រូវរួមបញ្ចូល :

ក- ការផ្គត់ផ្គង់ទំនិញ ទៅទីកន្លែងណាមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា ដែលមានឯកសារភស្តុតាង មានការយល់ព្រមពីនាយកដ្ឋានពន្ធដារ

ខ- ការផ្គត់ផ្គង់សេវា សម្រាប់ការប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា ដែលមានឯកសារភស្តុតាងមានការយល់ព្រមពីនាយកដ្ឋានពន្ធដារ

គ- ការផ្គត់ផ្គង់សេវាដឹកជញ្ជូនអ្នកដំណើរនិងទំនិញជាអន្តរជាតិ

ឃ- ការផ្គត់ផ្គង់សេវាដែលទាក់ទិននឹងការដឹកជញ្ជូនអ្នកដំណើរនិងទំនិញជាអន្តរជាតិ ។

២. សម្រាប់គោលដៅនៃវាក្យខ័ណ្ឌ គ នៃកថាខ័ណ្ឌ១ នៃប្រការនេះ ការដឹកជញ្ជូនអ្នកដំណើរ និងទំនិញតាមផ្លូវគោក ផ្លូវទឹក ឬផ្លូវអាកាស គឺជាការដឹកជញ្ជូនអន្តរជាតិ បើសិនជាការដឹកជញ្ជូននោះត្រូវបានធ្វើឡើង :

ក- ពីកន្លែងមួយក្នុងព្រះរាជាណាចក្រកម្ពុជា ទៅកន្លែងមួយទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជា

ខ- ពីកន្លែងមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា មកកន្លែងមួយក្នុងព្រះរាជាណាចក្រកម្ពុជា

គ- ពីកន្លែងមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា ទៅកន្លែងមួយទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងករណីដែលការដឹកជញ្ជូនឬចំណែកណាមួយនៃ ការដឹកជញ្ជូនឆ្លងកាត់ដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

## ផ្នែកទី ១៥
## ការផ្ទេរអាជីវកម្ម

**ប្រការ៥៥ ._ លក្ខខណ្ឌនិងការតម្រូវសម្រាប់ការផ្ទេរអាជីវកម្ម**

ការផ្ទេរអាជីវកម្មពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតស្របទៅតាមល័ក្ខខ័ណ្ឌខាងក្រោមនេះ មិនត្រូវជាប់អាករលើតម្លៃបន្ថែមទេ :

ក- អាជីវកម្មត្រូវបានផ្ទេរពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតដើម្បីបន្តធ្វើអាជីវកម្មក្រោមកម្មសិទ្ធិថ្មី

ខ- បុគ្គលជាប់អាករដែលផ្ទេរអាជីវកម្មត្រូវជូនដំណឹងដល់ការិយាល័យប្រមូលពន្ធតាមរបបពិត អំពីការផ្ទេរអាជីវកម្ម ក្នុងរយះពេល១០ថ្ងៃក្រោយកាលបរិច្ឆេទនៃការផ្ទេរ

គ- បុគ្គលជាប់អាករដែលផ្ទេរអាជីវកម្ម ត្រូវស្នើសុំលុបចោលការចុះបញ្ជីរបស់ខ្លួន ហើយត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិនៃមាត្រា៨១ នៃច្បាប់ស្តីពីសារពើពន្ធ និងប្រការដែលពាក់ព័ន្ធទាំងឡាយក្នុងផ្នែកទី៤ នៃប្រកាសនេះ

ឃ- អ្នកទទួលអាជីវកម្ម ត្រូវចុះបញ្ជីជាបុគ្គលជាប់អាករសម្រាប់អាករលើតម្លៃបន្ថែម នៅពេលដែលទទួលអាជីវកម្ម និងត្រូវគិតអាករលើទំនិញក្នុងស្តុកនិងទ្រព្យសកម្មដែលបានទទួលនៅពេលធ្វើការផ្គត់ផ្គង់ទំនិញនិងទ្រព្យសកម្មទាំងនោះ

ង- បុគ្គលដែលទទួលអាជីវកម្ម ត្រូវរក្សាទុកឯកសារអាករដែលទាក់ទិននឹងអាជីវកម្មដែលបានផ្ទេរនោះ ក្នុងរយះពេល១០ឆ្នាំដូចមានចែងក្នុងមាត្រា៩៨ នៃច្បាប់ស្តីពីសារពើពន្ធ ។

## ផ្នែកទី១៦
## ឥណទានសម្រាប់អាករលើផលរបរ ឬអាករប្រើប្រាស់
## ដែលបានបង់លើទំនិញក្នុងស្តុកនៅពេលចាប់ផ្តើមអនុវត្តអាករលើតម្លៃបន្ថែម

**ប្រការ៥៦ ._ ភាពអាចទទួលបាននូវឥណទានអាករលើផលរបរ ឬឥណទានអាករប្រើប្រាស់**

នៅថ្ងៃទី ០១ ខែមករា ឆ្នាំ១៩៩៩ បើសិនជាបុគ្គលជាប់អាករមាននៅក្នុងស្តុករបស់ខ្លួននូវ ទំនិញជាមូលធន និងទំនិញផ្សេងទៀត ដែលបានបង់អាករលើផលរបរ ឬ អាករប្រើប្រាស់ បុគ្គលនោះអាចមានសិទ្ធិស្នើសុំឥណទានសម្រាប់អាករទាំងនោះបានចំពោះតែទំនិញដែលបានទិញក្នុងរយៈពេល ៦០ ថ្ងៃមុន ថ្ងៃទី ០១ ខែមករា ឆ្នាំ១៩៩៩ ។

**ប្រការ៥៧ ._ លក្ខខណ្ឌក្នុងការស្នើសុំឥណទានអាករលើផលរបរ ឬឥណទានអាករប្រើប្រាស់**

ល័ក្ខខ័ណ្ឌដែលអាចស្នើសុំឥណទានអាករលើផលរបរឬឥណទានអាករប្រើប្រាស់មានដូចតទៅ :

ក- បុគ្គលដែលស្នើសុំឥណទាន ត្រូវចុះបញ្ជីអាករលើតម្លៃបន្ថែម ហើយក្លាយទៅជាបុគ្គលជាប់អាករចាប់តាំងពី ថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៩

ខ- ការស្នើសុំឥណទាន តាមប្រការ៥៦ នៃប្រកាសនេះ ត្រូវធ្វើទៅតាមទម្រង់កំណត់ដោយនាយកដ្ឋានពន្ធដារ

គ- បុគ្គលស្នើសុំឥណទានតាមប្រការ៥៦ នៃប្រកាសនេះ ត្រូវផ្តល់បញ្ជីសារពើភ័ណ្ឌនៃទំនិញមាននៅក្នុងដៃនៅ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ទាំងអស់ ដែលទាក់ទិននឹងការស្នើសុំឥណទានអាករ ។

ឃ- ការស្នើសុំឥណទានអាករលើផលរបរ ឬឥណទានអាករប្រើប្រាស់ ត្រូវមានឯកសារភស្តុតាងបញ្ជាក់អំពីការបង់អាករលើផលរបរ និងអាករប្រើប្រាស់

ង- ពាក្យស្នើសុំឥណទានតាមវាក្យខ័ណ្ឌ ខ នៃប្រការនេះ ត្រូវដាក់ជូននាយកដ្ឋានពន្ធដារយ៉ាងយឺតបំផុតនៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៩ ។

ច- បុគ្គលជាប់អាករត្រូវរក្សាទុករាល់ឯកសារពាក់ព័ន្ធដល់ការស្នើសុំឥណទាន ក្នុងរយៈពេល១០ឆ្នាំ ហើយត្រូវផ្តល់ឯកសារទាំងនេះជូននាយកដ្ឋានពន្ធដារត្រួតពិនិត្យ ក្នុងករណីមានសំណូមពរ ។

**ប្រការ៥៨ .. វិធីស្នើសុំឥណទានអាករ**

ក្នុងករណីដែលការស្នើសុំឥណទានតាមប្រការ៥៦ នៃប្រកាសនេះត្រូវបានបញ្ជាក់យល់ព្រមដោយប្រធាននាយកដ្ឋានពន្ធដារ ចំនួនដែលបានបញ្ជាក់ជាឥណទាន អាចត្រូវបានស្នើសុំជាឥណទាននៅក្នុងលិខិតប្រកាសប្រចាំខែដំបូងរបស់បុគ្គលជាប់អាករ ។

**ប្រការ៥៩ .. សិទ្ធិនៃការប្រមូលមកវិញនូវឥណទានអាករ**

ដោយមិនទាន់គិតដល់ទោសទណ្ឌដទៃទៀតដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ ក្នុងករណីដែលពិនិត្យឃើញថាបុគ្គលជាប់អាករបានប្រព្រឹត្តិល្មើសនឹងច្បាប់ វិញ្ញាបនប័ត្រចុះបញ្ជីដែលបានចេញឱ្យបុគ្គលជាប់អាករ តាមប្រការ៥ នៃប្រកាសនេះ ត្រូវបានលុបចោលទាំងស្រុងឬមួយផ្នែកដោយប្រធាននាយកដ្ឋានពន្ធដារ ហើយឥណទានណាមួយដែលបានអនុញ្ញាតកន្លងមកត្រូវបានប្រមូលមកវិញ ។

## ផ្នែកទី ១៧
## បទប្បញ្ញត្តិស្តីពីទំនិញមួយចំនួន

**ប្រការ ៦០.. អាករលើតម្លៃបន្ថែមលើទំនិញមួយចំនួន**

អាករលើតម្លៃបន្ថែមនៃទំនិញដែលរាយមុខខាងក្រោម ត្រូវអនុវត្តតាមបែបបទដោយឡែក :

- បារី
- ស្រាដែលមានជាតិសុរាក្នុងឯកតាចំណុះពី ៣៥ភាគរយ នៃចំណុះឬលើសពីនេះ
- ទោចក្រយានយន្តថ្មី
- ថាមពលអគ្គិសនី និង ទឹក ។

## ជំពូកទី ១៨

## អវសានប្បញ្ញត្តិ

**ប្រការ ៦១.- ការអនុវត្តន៍**

អគ្គនាយកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋាននានាចំណុះឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាយកដ្ឋានពន្ធដារ ទីចាត់ការគយនិងរដ្ឋាករ និងគ្រប់មន្ទីរស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាព ។

**ប្រការ ៦២.- កាលបរិច្ឆេទចូលជាធរមាននៃប្រកាស**

ប្រកាសនេះមានប្រសិទ្ធិភាពនិងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន** :

- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់អង្គភាពពន្ធដារ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ-ឯកសារ

លេខ ........៧៥៦............ ចលរាជ

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ ១២ ឆ្នាំ១៩៩៨

នាយកដ្ឋានពន្ធដារ

ហុង.ចាំ

# ព្រះរាជក្រម

នស/រកម/០២៩៧/០៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * * * * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស_៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស_រកប_០១៩៦_១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង របស់ ទេសរដ្ឋមន្ត្រី ទទួលបន្ទុកនីតិសម្បទា និង អភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី សារពើពន្ធ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៨ ខែ មករា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ជំពូកទី១

# បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញ

## ផ្នែកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងច្បាប់ស្តីអំពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៦ នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៨នស ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១ នស ៩៤ ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ១៩៩៤ និងច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ ។

**មាត្រា ២.-**

ពន្ធលើប្រាក់ចំណេញ គឺជាបំណុលរបស់បុគ្គលនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជា និង ប្រាក់ចំណូលប្រភពបរទេសនិងរបស់បុគ្គលអនិវាសនជន ចំពោះប្រាក់ចំណូលប្រភពកម្ពុជា ។

**មាត្រា ៣.-**

សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីសារពើពន្ធ :

១- ពាក្យ "អ្នកជាប់ពន្ធនិវាសនជន" សំដៅដល់ :

ក. រូបវន្តបុគ្គលដែលស្នាក់នៅឬមានកន្លែងស្នាក់នៅជាគោលដើម នៅក្នុងព្រះរាជាណាចក្រកម្ពុជាឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា លើសពី១៨២ថ្ងៃ នៅក្នុងឆ្នាំប្រតិទិន

ខ. នីតិបុគ្គលឬក្រុមអាជីវកម្ម ដែលត្រូវបានបង្កើតឬត្រូវបានគ្រប់គ្រងនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬដែលមានកន្លែងប្រកបអាជីវកម្មជាគោលដើម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ គ្រឹះស្ថានអចិន្ត្រៃយ៍ត្រូវចាត់ទុកជានីតិបុគ្គលនិវាសនជនចំពោះតែប្រាក់ចំណូលប្រភពកម្ពុជា ។

២- ពាក្យ "អនិវាសនជន" មានន័យថា ដែលមិនមែនជានិវាសនជនកម្ពុជា ។

៣- ពាក្យ "នីតិបុគ្គល" សំដៅដល់ សហគ្រាសឬអង្គការនានា ដែលប្រកបអាជីវកម្មទោះបីជាបានឬមិនទាន់បានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្តី ។ ពាក្យ"នីតិបុគ្គល" រួមបញ្ចូលផងដែរ នូវស្ថាប័នរដ្ឋាភិបាល អង្គការសាសនា អង្គការសប្បុរសធម៌ឬអង្គការមិនស្វែងរកចំណេញ ។ ចំពោះបុគ្គលអនិវាសនជន ពាក្យ"នីតិបុគ្គល" សំដៅដល់គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ពាក្យ"នីតិបុគ្គល" ពុំរាប់បញ្ចូលនូវក្រុមអាជីវកម្មឬសហគ្រាសឯកបុគ្គល ។

៤- ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" សំដៅដល់ទីកន្លែងប្រកបអាជីវកម្មជាប់លាប់នៅព្រះរាជាណាចក្រកម្ពុជា សាខារបស់ក្រុមហ៊ុនបរទេស ឬភ្នាក់ងារនិវាសនជននៅព្រះរាជាណាចក្រកម្ពុជា ដែលតាមរយៈនេះបុគ្គលអនិវាសនជនប្រកបអាជីវកម្មរបស់ខ្លួន ។ ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" រួមបញ្ចូលផងដែរ នូវសមាគមឬរូបភាពទំនាក់ទំនងផ្សេងទៀត ដែលតាមរយៈនេះបុគ្គលអនិវាសនជនធ្វើសកម្មភាពសេដ្ឋកិច្ច នៅព្រះរាជាណាចក្រកម្ពុជា ។

៥- ពាក្យ "ក្រុមអាជីវកម្ម" សំដៅដល់ក្រុមសមូហធាយដែលមានម្ចាស់ភាគហ៊ុនជារូបវន្តបុគ្គលនិវាសនជនយ៉ាងច្រើន ១០នាក់ ហើយក្នុងនោះចំណែកសមាមាត្ររបស់ម្ចាស់ភាគហ៊ុននៅក្នុងខ្ទង់មូលធន ប្រាក់ចំណេញនិងការខាតបង់ត្រូវស្របតាមលក្ខណៈវិនិច្ឆ័យ ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។ ក្នុងនិយមន័យនេះ "ក្រុមអាជីវកម្ម" មិនអាចជាសមាជិករបស់ក្រុមហ៊ុនបុគ្គលណាមួយ ហើយក៏មិនរាប់បញ្ចូលផងនូវក្រុមហ៊ុនដើមទុន គ្រឹះស្ថានអចិន្ត្រៃយ៍ឬសហគ្រាសឯកបុគ្គល ។

៦- ពាក្យ "សហគ្រាសឯកបុគ្គល" សំដៅដល់សហគ្រាសអាជីវកម្មដែលជាកម្មសិទ្ធិ ១០០ភាគរយរបស់រូបវន្តបុគ្គលណាម្នាក់ ។ ក្នុងនិយមន័យនេះ ប្តី ប្រពន្ធនិងកូនក្នុងបន្ទុក ត្រូវចាត់ទុកថាជារូបវន្តបុគ្គលតែម្នាក់ ។

៧- ពាក្យ "អាជីវកម្ម" សំដៅដល់ សកម្មភាពសេដ្ឋកិច្ចរបស់បុគ្គលដែលមានគោលដៅទាញយកប្រាក់ចំណូលអំពីការផលិតនិងលក់ទំនិញ ការផ្តល់ផ្គង់សេវា កសិកម្ម ការជួលឬការលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងទៀត ។

៨- ពាក្យ "ភាគលាភ" សំដៅដល់ ចំណែកជាសាច់ប្រាក់ឬជាទ្រព្យដែលនីតិបុគ្គលបានចែកឱ្យអ្នកចូលហ៊ុនទៅតាមកម្រិតនៃភាគកម្មរបស់ខ្លួននៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល លើកលែងតែភាគលាភជាប័ណ្ណភាគហ៊ុននិងការបែងចែកទាំងនា ក្នុងពេលជំរះបញ្ជីរំលាយក្រុមហ៊ុនទាំងស្រុង ។ ចំណែកណាមួយ ដែលចាត់ទុកថាជាភាគលាភឬមិនមែនជាភាគលាភ ត្រូវផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះ ដោយពុំគិតថានីតិបុគ្គលមានឬគ្មានប្រាក់ចំណូលឬប្រាក់ចំណេញចរន្តឬលទ្ធផលយោងសារជាថ្មីឡើយ ។

៩- ពាក្យ "អ្នកចូលហ៊ុន" សំដៅដល់ បុគ្គលដែលមានចំណែកភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល ។ សម្រាប់គោលដៅនៃពន្ធនេះ នីតិបុគ្គលណាមួយនោះបើមិនមែនជាក្រុមហ៊ុនដើមទុនក្តី ត្រូវចាត់ទុកដូចជាក្រុមហ៊ុនដើមទុន ហើយបុគ្គលដែលមានចំណែកភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល ឬក៏បុគ្គលអាចបានទទួលប្រាក់ចំណូលឬប្រាក់ចំណេញ ក្នុងឋានៈជាអ្នកបានចូលរួមក្នុងនីតិបុគ្គលនោះ ត្រូវចាត់ទុកថាជាអ្នកចូលហ៊ុនរបស់នីតិបុគ្គលដែរ ។

១០- ពាក្យ "សហគ្រាសវិនិយោគ" សំដៅដល់ សហគ្រាសដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានទទួលស្គាល់ថាជាសហគ្រាសវិនិយោគនិងដែលបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ។

១១- ពាក្យ "បុគ្គលទាក់ទិន" សំដៅដល់ :

ក. សមាជិកណាម្នាក់ក្នុងគ្រួសារអ្នកជាប់ពន្ធ

ខ. សហគ្រាសដែលគ្រប់គ្រងលើអ្នកជាប់ពន្ធឬសហគ្រាសត្រូវបានអ្នកជាប់ពន្ធគ្រប់គ្រង ឬក៏សហគ្រាសនោះនិងអ្នកជាប់ពន្ធស្ថិតនៅក្រោមការគ្រប់គ្រងរួមគ្នា ។ ពាក្យ "គ្រប់គ្រង" មានន័យថាមានកម្មសិទ្ធិចាប់ពី ៥១ភាគរយ ឡើងទៅលើតម្លៃឬសិទ្ធិបោះឆ្នោតនៃភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់សហគ្រាស ។ ដើម្បីកំណត់ទំហំនៃការគ្រប់គ្រងរបស់អ្នកជាប់ពន្ធជារូបវន្តបុគ្គលណាម្នាក់ ត្រូវគិតបញ្ចូលទាំងអស់នូវកម្មសិទ្ធិលើភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់រូបវន្តបុគ្គលនោះនិងកម្មសិទ្ធិផ្ទាល់ឬប្រយោលរបស់សហព័ទ្ធអ្នកជាប់ពន្ធ ។

អគ្គនាយកដ្ឋាន
ពន្ធដារ

**មាត្រា ៤.-**

របបកំណត់ពន្ធមានដូចតទៅ ៖

១- ការកំណត់ពន្ធលើប្រាក់ចំណេញ ត្រូវអនុវត្តតាមរបបពិត របបប៉ាន់ប្រមាណនិងរបបម៉ៅការ ។

២- វិធាននិងនីតិវិធី ដើម្បីចាត់បញ្ចូលអ្នកជាប់ពន្ធឱ្យស្ថិតក្នុងរបបកំណត់ពន្ធណាមួយនៃរបបទាំង៣ ខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ដោយផ្អែកលើទ្រង់ទ្រាយអាជីវកម្ម ប្រភេទសកម្មភាពអាជីវកម្មនិងកម្រិតផលរបរ ។

## ផ្នែកទី២
## ប្រាក់ចំណេញជាប់ពន្ធនិងអត្រាពន្ធ

**មាត្រា ៥.-**

ឆ្នាំជាប់ពន្ធត្រូវបានកំណត់ដូចខាងក្រោម ៖

១- ពន្ធលើប្រាក់ចំណេញអនុវត្តចំពោះរបបពិត ត្រូវគណនាចេញពីលទ្ធផលនៃពុល្យការសម្រេចបានក្នុងឆ្នាំសារពើពន្ធកន្លងទៅ ។

២- ប្រសិនជាពុំមានពុល្យការណាមួយ បានបញ្ចប់ក្នុងកំឡុងនៃឆ្នាំណាមួយទេនោះ ពន្ធដែលត្រូវបង់សម្រាប់ឆ្នាំបន្ទាប់ ត្រូវគិតយកលើប្រាក់ចំណេញក្នុងរយៈវេលាដែលកន្លងទៅ ចាប់តាំងពីថ្ងៃចុងរយៈពេលជាប់ពន្ធដែលកន្លងហួសទៅនោះ ។ ចំពោះសហគ្រាសថ្មី ត្រូវគិតចាប់តាំងពីថ្ងៃដែលផ្តើមធ្វើប្រតិបត្តិការមកទល់នឹងថ្ងៃទី៣១ ធ្នូ នៃឆ្នាំដែលត្រូវគិតពន្ធ ។

៣- កាលបើមានធ្វើពុល្យការជាច្រើនតៗគ្នា ក្នុងកំឡុងនៃឆ្នាំមួយដដែលនោះ លទ្ធផលនៃពុល្យការទាំងឡាយនេះ ត្រូវបូករួមគ្នាធ្វើជាមូលដ្ឋាននៃពន្ធដែលត្រូវបង់ ។

៤- ពន្ធលើប្រាក់ចំណេញអនុវត្តចំពោះរបបប៉ាន់ប្រមាណនិងរបបម៉ៅការ ត្រូវគណនាតាមវិធីគណនេយ្យមូលដ្ឋានសាច់ប្រាក់នៅក្នុងឆ្នាំប្រតិទិនកន្លងមក ។

៥- សេចក្តីណែនាំនានា ស្តីអំពីការធ្វើរបាយការណ៍ ការដាក់លិខិតប្រកាសចុងក្រោយសម្រាប់សហគ្រាសដែលបញ្ចប់អាជីវកម្មឬរៀបចំឡើងវិញឬត្រូវបានលក់ឬផ្ទេរក្នុងឆ្នាំប្រតិទិន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៦.-**

វិធានគណនេយ្យត្រូវបានកំណត់ដូចខាងក្រោម ៖

១- ចំពោះអ្នកជាប់ពន្ធតាមរបបប៉ាន់ប្រមាណដែលប្រើវិធីគណនេយ្យមូលដ្ឋានសាច់ប្រាក់ ប្រាក់ចំណូលត្រូវគិតបញ្ចូលនៅក្នុងឆ្នាំដែលបានទទួលជាក់ស្តែងនូវសាច់ប្រាក់ឬទ្រព្យដទៃទៀត ទោះបីជាការទូទាត់បានធ្វើឡើងសម្រាប់ឆ្នាំផ្សេងទៀតក្តី ។ ឯចំណាយឬការកាត់កងនានា អាចដាក់ចេញនៅក្នុងឆ្នាំដែលចំណាយឬខ្ទង់ផ្សេងទៀត ត្រូវបានទូទាត់សងជាក់ស្តែង លើកលែងតែចំណាយទូទាត់មុននិងចាយផ្ទាល់ឱ្យដល់រំលស់ ។

២- ចំពោះអ្នកជាប់ពន្ធតាមរបបពិត ដែលប្រើវិធីគណនេយ្យតាមបង្គរ ... ប្រាក់ចំណូលត្រូវគិតបញ្ចូលនៅក្នុងឆ្នាំដែលចំណូលនោះបានកើតឡើង ទោះបីប្រាក់ចំណូលនោះបានទូទាត់ឬមិនទាន់ទូទាត់ក្តី ... ។

អគ្គនាយកដ្ឋានពន្ធដារ

ក្នុងចំណាយណាមួយអាចធ្វើទៅបាន លុះណាតែហេតុការណ៍បញ្ជាក់នូវបន្ទុករបស់អ្នកជាប់ពន្ធបានកើតឡើង លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទងដល់ខ្ទង់ចំណាយនោះបានកើតឡើងនិងចំនួនទឹកប្រាក់ដែលជាបន្ទុករបស់អ្នកជាប់ព[illegible] បង្ហាញច្បាស់លាស់ ។

៣- ចំពោះអ្នកជាប់ពន្ធតាមរបបពិត ចំណាយនានាធ្វើឡើងចំពោះបុគ្គលទាក់ទិនដែលស្ថិតក្រោមការ[illegible] បំណុលមិនអនុញ្ញាតឱ្យដាក់ចេញមុនការទូទាត់ជាក់ស្តែងឡើយ ។

៤- ចំពោះធនាគារនិងស្ថាប័នសញ្ញ័យធនក្នុងស្រុក ត្រូវបានអនុញ្ញាតឱ្យធ្វើសវិធានធនសម្រាប់ឥណទេយ្យជាប់សង្ស័យ ដើម្បីកំណត់ប្រាក់ចំណេញជាប់ពន្ធ ។ វិធាននិងនីតិវិធី ស្តីពីការកាត់កងនានា ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧.-**

ប្រាក់ចំណេញជាប់ពន្ធ គឺជាប្រាក់ចំណេញសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការគ្រប់ប្រភេទដែលសហគ្រាសសម្រេចបាន រួមបញ្ចូលទាំងតម្លៃលើសបានមកពីការលក់ចំណែកនានានៃទ្រព្យសកម្ម ក្នុងពេលកំពុងប្រកបអាជីវកម្មឬនៅពេលបញ្ចប់អាជីវកម្ម ព្រមទាំងប្រាក់ចំណូលពីកិច្ចប្រតិបត្តិការហិរញ្ញវត្ថុឬវិនិយោគ ការប្រាក់ ថ្លៃឈ្នួលនិងសួយសារផង ។

**មាត្រា ៨.-**

ប្រាក់ចំណេញជាប់ពន្ធ កើតចេញពីចំនួនលើសនៃផលផុលដែលសម្រេចបាន អាស្រ័យដោយមានការចំណាយដើម្បីនាំមកវិញនិងរក្សាទុកនូវចំណេញ ។

**មាត្រា ៩.-**

ប្រាក់ចំណូលលើកលែងពន្ធត្រូវបានកំណត់ដូចតទៅ :

១- វៀរលែងតែមានបទបញ្ញត្តិផ្ទុយនិងលើកលែងតែប្រាក់ចំណូលដែលត្រូវជាប់ពន្ធតាមមាត្រា២២នៃច្បាប់នេះ ពន្ធលើប្រាក់ចំណេញមិនត្រូវអនុវត្តចំពោះ :

ក. ប្រាក់ចំណូលរបស់រាជរដ្ឋាភិបាលឬប្រាក់ចំណូលស្ថាប័នរាជរដ្ឋាភិបាល

ខ. ប្រាក់ចំណូលរបស់អង្គការណាមួយដែល :

- ត្រូវបានរៀបចំឡើងនិងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រឬអប់រំ
- គ្មានចំណែកណាមួយនៃទ្រព្យឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន

គ. ប្រាក់ចំណូលរបស់អង្គការពលករឬសភាពាណិជ្ជកម្ម ឧស្សាហកម្មឬកសិកម្ម ក្នុងករណីដែលប្រាក់ចំណូលរបស់អង្គការទាំងនោះមិនត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុនឬរូបវន្តបុគ្គល

ឃ. ប្រាក់ចំណេញដែលបានមកពីការលក់ផលិតផលកសិកម្មដែលបុគ្គលមិនមែនជាអ្នកជាប់ពន្ធតាមរបបពិតផលិតបានដោយខ្លួនឯង ទោះបីផលិតផលនោះមិនទាន់កែច្នៃឬកែច្នៃហើយក៏ដោយទៅតាមទម្លាប់នៃការងារកសិកម្ម ។ ប្រតិបត្តិការតាមមធ្យោបាយឧស្សាហកម្ម រួមទាំងការកែច្នៃ ការរក្សាគុណភាព ការវេចខ្ចប់សម្រាប់លក់ ពុំត្រូវបានចាត់ទុកជាទម្លាប់នៃការងារកសិកម្មឡើយ ។

២- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសអំពីនីតិវិធី[illegible]លើកលែងពន្ធ ភាពបាត់បង់លក្ខណៈលើកលែងពន្ធ ការប្រកាសសារពើពន្ធនិងការចុះបញ្ជី ។

**មាត្រា ១០.-**

ប្រាក់ចំណូលរបស់ក្រុមអាជីវកម្មត្រូវបានកំណត់ដូចតទៅ :

១- ចំពោះក្រុមអាជីវកម្ម ក្នុងការកំណត់ប្រាក់ចំណូលរបស់ខ្លួនសម្រាប់ឆ្នាំជាប់ពន្ធណាមួយសមាជិកម្នាក់ៗ ត្រូវគិតជាប់ដោយឡែកពីគ្នានូវចំណែករៀងៗខ្លួន នៅក្នុងខ្ទង់ចំណូល ចំណេញ ខាត ការកាត់កង ឥណទាន និងវិភាគទានសប្បុរសធម៌ក្នុងឆ្នាំនោះ ។ ល ពេលនោះ ខ្ទង់នីមួយៗត្រូវរក្សាចរិតលក្ខណៈនៅដដែល ហើយត្រូវចាត់ទុកថាបានបែងចែកនៅក្នុងឆ្នាំជាប់ពន្ធ ទោះបីជាមានឬគ្មានការបែងចែកជាក់ស្តែងក្តី ។ ការខាតបង់ដែលត្រូវយោងទៅឆ្នាំមុខនឹងត្រូវកំណត់ឡើងក្រោយពីបានបែងចែកខ្ទង់ទាំងនោះហើយ ។

២- វិធានសម្រាប់កំណត់ចំនួនទឹកប្រាក់ដែលត្រូវបែងចែក ការចាត់ចែងចំពោះវិភាគទានផ្សេងៗនិងការកែតម្រូវទៅលើចំណែកជាមូលដ្ឋានរបស់សមាជិកម្នាក់ៗនៃក្រុមអាជីវកម្មនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី៣

## ការកាត់កង

**មាត្រា ១១.-**

ការកាត់កងដែលអនុញ្ញាតត្រូវបានកំណត់ដូចតទៅ :

១- វៀរលែងតែបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា១២ ដល់មាត្រា១៨ នៃច្បាប់នេះ ចំណាយដែលអនុញ្ញាតឱ្យកាត់កងរួមមានបន្ទុកដែលអ្នកជាប់ពន្ធបានទូទាត់ឬត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធដើម្បីប្រកបអាជីវកម្ម ។

២- ថ្លៃឈ្នួល ការប្រាក់ ការប៉ះប៉ូវ ការទូទាត់ឬកម្រៃនានាដែលបានបើកឱ្យអ្នកទទួលខុសត្រូវឬអភិបាលរបស់សហគ្រាស សមាជិកភាគទុនឬសមាជិករបស់ក្រុមអាជីវកម្ម សមាជិកនៃគ្រួសារអ្នកជាប់ពន្ធឬបុគ្គលទាក់ទិនផ្សេងទៀត ក្នុងករណីមានភស្តុតាងបញ្ជាក់ថា ការទូទាត់នោះបានអនុវត្តចំពោះការបំពេញសេវាជាក់ស្តែង ហើយក្នុងកំរិតសមហេតុសមផលផងដែរ ។

៣- ប្រាក់ដែលបានទូទាត់លើអាគារថ្មីឬទ្រព្យសកម្មដទៃទៀត ការកែលំអជាប់លាប់ឬការកែលំអនានា ក្នុងនោះមានទាំងការប្រាក់និងប្រាក់ពន្ធអាករ ដែលបានបង់ក្នុងរយៈពេលសាងសង់ឬទិញចូលផង ។ ទឹកប្រាក់នេះត្រូវកត់ត្រាចូលក្នុងគណនីទ្រព្យសកម្មដែលពាក់ព័ន្ធ ហើយត្រូវកាត់កងតាមការរំលស់ ដូចមានចែងក្នុងមាត្រា១៣ នៃច្បាប់នេះ ។

**មាត្រា ១២.-**

ត្រូវបានអនុញ្ញាតឱ្យកាត់កងនូវចំណាយលើការប្រាក់ដែលអ្នកជាប់ពន្ធបានទូទាត់ឬត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធដើម្បីប្រកបអាជីវកម្ម ប៉ុន្តែមិនឱ្យលើសពីផលបូកនៃចំណូលការប្រាក់របស់អ្នកជាប់ពន្ធ និង ៥០ភាគរយនៃប្រាក់ចំណូលសុទ្ធក្រៅពីការប្រាក់របស់អ្នកជាប់ពន្ធនៅក្នុងឆ្នាំជាប់ពន្ធ ។

ចំណូលសុទ្ធក្រៅពីការប្រាក់ គឺជាប្រាក់ចំណូលដុលក្រៅពីចំណូលការប្រាក់ ដកខ្ទង់ចំណាយទាំងឡាយដែលអនុញ្ញាតឱ្យកាត់ចេញលើកលែងតែចំណាយការប្រាក់ ។

ចំណាយការប្រាក់ដែលសល់ពីការកាត់កងខាងលើ ត្រូវចាត់ទុកជាចំណាយការប្រាក់សម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ ហើយការផាត់ចេញត្រូវអនុវត្តតាមខ្លឹមសារនៃមាត្រានេះដូចគ្នា ។

មាត្រា ១៣.-

លក្ខខណ្ឌនៃរំលស់ទ្រព្យរូបីត្រូវបានកំណត់ដូចតទៅ :

១- ទាយជ្ជទានឱ្យរំលស់ត្រូវគណនាតាមវិធីរំលស់ស្មើភាពឬវិធីរំលស់ថយជាលំដាប់ ។ ទ្រព្យរូបីដែលអាចរំលស់បាន គឺទ្រព្យរូបីប្រើប្រាស់ក្នុងអាជីវកម្មដែលតែងតែបាត់បង់តម្លៃដោយការប្រើប្រាស់ឬភាពហួសសម័យ ។ ដីធ្លីមិនមែនជាទ្រព្យអាចរំលស់បានទេ ។

២- ទ្រព្យរូបីទាំងអស់ ត្រូវបានបែងចែកជា ៤ប្រភេទ :

ក. ប្រភេទទី១ រួមមាន អាគារនិងសំណង់ ដែលជាឧបសម្ព័ន្ធនៃអាគារនោះ។ ទ្រព្យនីមួយៗក្នុងប្រភេទនេះ ត្រូវរំលស់តាមវិធីស្មើភាពតាមអត្រា ៥ភាគរយក្នុង១ឆ្នាំ

ខ. ប្រភេទទី២ រួមមាន ទ្រព្យដែលមានអាយុកាលប្រើប្រាស់ត្រឹម ៤ឆ្នាំ ហើយអត្រារំលស់ស្មើភាពលើទ្រព្យនីមួយៗ គឺ ២៥ភាគរយ

គ. ប្រភេទទី៣ រួមមាន ទ្រព្យដែលមានអាយុកាលប្រើប្រាស់លើសពី ៤ឆ្នាំ ដល់ ៨ឆ្នាំ ហើយអត្រារំលស់ស្មើភាពលើទ្រព្យនីមួយៗ គឺ ១២,៥ភាគរយ

ឃ. ប្រភេទទី៤ រួមមាន ទ្រព្យរូបីឯទៀតទាំងអស់ ហើយអត្រារំលស់ស្មើភាពលើទ្រព្យនីមួយៗ គឺ ១០ភាគយ ។

៣- អ្នកជាប់ពន្ធដែលជ្រើសយកវិធីរំលស់ថយជាលំដាប់ ត្រូវប្រើអត្រារំលស់ស្មើនឹង ២០០ភាគរយនៃអត្រារំលស់តាមវិធីស្មើភាព ហើយត្រូវអនុវត្តលើតម្លៃសរុបមិនទាន់រំលស់អស់នៃទ្រព្យទាំងអស់ នៅក្នុងប្រភេទនីមួយៗ។ ត្រូវបានអនុញ្ញាតឱ្យប្រើវិធីរំលស់ថយជាលំដាប់តែចំពោះទ្រព្យប្រភេទទី២ ទី៣ និងទី៤ តែប៉ុណ្ណោះ។

៤- សហគ្រាសដែលស្ថិតក្រោមច្បាប់វិនិយោគត្រូវប្រើវិធីរំលស់ស្មើភាពចំពោះទ្រព្យគ្រប់ប្រភេទ ។

៥- នីតិវិធីក្នុងការបង្កើតប្រភេទទ្រព្យ ការបញ្ចូលទ្រព្យថ្មីទៅក្នុងប្រភេទណាមួយ ការបញ្ចេញទ្រព្យពីប្រភេទណាមួយ ហើយនិងការចាត់ចែងចំពោះបញ្ហាជួសជុលព្រមទាំងចំណាយផ្សេងៗ ត្រូវកំណត់ដោយអនុក្រឹត្យ ។

៦- អ្នកជាប់ពន្ធដែលស្ថិតក្រោមច្បាប់ពន្ធលើប្រាក់ចំណេញនៅមុនថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៧ ត្រូវធ្វើការជ្រើសរើសដែលមិនអាចកែប្រែវិញបាន នូវវិធីរំលស់តាមវិធីស្មើភាពឬតាមវិធីរំលស់ថយជាលំដាប់ ចំពោះទ្រព្យដែលមិនទាន់រំលស់អស់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ។ ចំពោះអ្នកជាប់ពន្ធថ្មី ការជ្រើសរើសត្រូវធ្វើឡើងយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំចុះបញ្ជី ។

មាត្រា ១៤.-

ចំពោះទ្រព្យអរូបី ដែលរួមមានប្រកាសនីយបត្រពាណិជ្ជកម្ម សិទ្ធិចម្លង គំនូរប្លង់ គំរូនិងសិទ្ធិអាជីវកម្មដែលមានអាយុកាលមានកំណត់ អត្រារំលស់លើទ្រព្យនីមួយៗ ត្រូវគណនាដោយផ្អែកលើអាយុកាលរបស់ទ្រព្យនោះតាមវិធីរំលស់ស្មើភាព ។ បើសិនជាអាយុកាលនៃទ្រព្យអរូបីមិនអាចកំណត់បាន រំលស់ប្រចាំឆ្នាំត្រូវអនុវត្តតាមអត្រា ១០ភាគរយ លើតម្លៃទ្រព្យអរូបី ។

មាត្រា ១៥.-

ការរំលស់ធនធានធម្មជាតិត្រូវបានកំណត់ដូចតទៅ :

១- ទាយជូទានឱ្យដល់ការរំលស់លើធនធានធម្មជាតិ មានជាអាទិ៍ ប្រេងកាតនិងឧស្ម័នធម្មជាតិ ត្រូវបានកំណត់ដូចតទៅ :

ក. ចំណាយក្នុងការរុករកនិងអភិវឌ្ឍន៍ ក្នុងនោះមានទាំងការប្រាក់ដែលជាប់ទាក់ទងដល់ចំណាយនោះផង ត្រូវបូកបញ្ចូលទៅក្នុងគណនីទ្រព្យសកម្មនៃធនធាននោះ ។

ខ. ទឹកប្រាក់រំលស់លើធនធានធម្មជាតិនីមួយៗដែលត្រូវដាត់ចេញនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវគណនាដោយយកសមតុល្យនៃគណនីធនធានធម្មជាតិ ទៅគុណនិងផលចែករវាងបរិមាណដែលបានផលិតចេញអំពីធនធានធម្មជាតិនៅក្នុងឆ្នាំនិងចំនួនប៉ាន់ស្មាននៃផលិតផលសរុបដែលអាចទាញយកបានពីធនធាននោះ ។

២- នីតិវិធីសម្រាប់កំណត់ចំនួនប៉ាន់ស្មាននៃផលិតផលសរុប ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៦.-**

ត្រូវបានអនុញ្ញាតឱ្យដាត់ចេញនូវវិភាគទានសប្បុរសធម៌ដែលបានបរិច្ចាគឱ្យអង្គការនានា ដូចមានចែងក្នុងមាត្រា៩ នៃច្បាប់នេះ ប៉ុន្តែមិនត្រូវឱ្យលើសពី ៥ភាគរយ នៃប្រាក់ចំណេញជាប់ពន្ធមុនពេលកាត់កងវិភាគទានសប្បុរសធម៌ទាំងនោះឡើយ ។

លក្ខណៈវិនិច្ឆ័យនៃវិភាគទានសប្បុរសធម៌ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៧.-**

ក្នុងករណីដែលមានការខាតបង់នៅក្នុងឆ្នាំជាប់ពន្ធណាមួយ ការខាតបង់នោះត្រូវចាត់ជាបន្ទុកសម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ ហើយត្រូវកាត់ចេញពីប្រាក់ចំណេញសម្រេចបាននៅក្នុងឆ្នាំជាប់ពន្ធបន្ទាប់នោះ ។ បើប្រាក់ចំណេញនេះមិនគ្រប់គ្រាន់សម្រាប់ទូទាត់ជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ ត្រូវយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់ រហូតដល់ឆ្នាំជាប់ពន្ធទី៥ ។

នៅពេលណាដែលការខាតបង់មានលើសពីមួយឆ្នាំ មាត្រានេះត្រូវអនុវត្តចំពោះការខាតបង់ទាំងឡាយតាមលំដាប់ដែលការខាតបង់បានកើតឡើង ។

**មាត្រា ១៨.-**

ក្នុងករណីសហគ្រាសចាប់ពី ២ ឡើងទៅ ទោះបីជាបានបង្កើតឬរៀបចំឡើងនៅក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជា ហើយដែលស្ថិតក្រោមកម្មសិទ្ធិរួមគ្នា ក្នុងករណីចាំបាច់រដ្ឋបាលសារពើពន្ធអាចធ្វើការបែងចែកប្រាក់ចំណូលដុលប្រាក់ដាត់ចេញឬអត្ថប្រយោជន៍ផ្សេងៗក្នុងចំណោមសហគ្រាសនិងម្ចាស់កម្មសិទ្ធិទាំងនោះ ដើម្បីទប់ស្កាត់ការគេចវេសពន្ធឬក៏ដើម្បីឆ្លុះបញ្ចាំងឱ្យបានច្បាស់លាស់នូវប្រាក់ចំណូលរបស់សហគ្រាសឬរបស់ម្ចាស់កម្មសិទ្ធិ ។

សម្រាប់គោលដៅនៃមាត្រានេះ សហគ្រាសចាប់ពី ២ ឡើងទៅ ត្រូវស្ថិតក្រោមកម្មសិទ្ធិរួមគ្នា បើសិនជាមានបុគ្គលណាម្នាក់មានកម្មសិទ្ធិចាប់ពី ២០ភាគរយ ឡើងទៅ លើតម្លៃឬភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់សហគ្រាសនីមួយៗ ។

**មាត្រា ១៩.-**

សម្រាប់បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញ ចំណាយដែលមិនអនុញ្ញាតឱ្យដាត់ចេញមាន :

១- ចំណាយលើសកម្មភាពទាំងឡាយដែលជាទូទៅចាត់ទុកជាការកំសាន្ត ... ការទទួលភ្ញៀវឬការប្រើប្រាស់មធ្យោបាយណាមួយដែលជាប់ទាក់ទងនឹងសកម្មភាពទាំងនេះ ។

អគ្គនាយកដ្ឋាន ពន្ធដារ

២- ចំណាយសម្រាប់ការរស់នៅផ្ទាល់ខ្លួនឬក្រុមគ្រួសារ លើកលែងតែអត្ថប្រយោជន៍បន្ថែមជាប្រាក់ ឬជាវត្ថុ ដែលប្រាក់ពន្ធត្រូវបានកាត់ទុកតាមបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស ។

៣- ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញបានកំណត់និងពន្ធកាត់ទុកដែលបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្សបានកំណត់ ។

៤- ការខាតបង់លើការលក់ឬដោះដូរទ្រព្យសម្បត្តិ នោះដោយផ្ទាល់ឬប្រយោលក្តី រវាងបុគ្គលទាក់ទិន ។

៥- ចំណាយនានា វៀរលែងតែចំណាយដែលកើតមានហើយ ហើយអ្នកជាប់ពន្ធអាចបញ្ជាក់ច្បាស់លាស់នូវចំនួនទឹកប្រាក់និងគោលដៅអាជីវកម្មស្របទៅតាមបែបបទដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

## ផ្នែកទី៤

## អត្រាពន្ធនិងប្រាក់ពន្ធត្រូវបង់

**មាត្រា ២០.-**

អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ មានដូចតទៅ :

១- ២០ ភាគរយ ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយនីតិបុគ្គល ។

៣០ ភាគរយ ចំពោះប្រាក់ចំណេញដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័នធម្មជាតិឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ រួមទាំងព្រៃឈើ រ៉ែ មាសឬត្បូងថ្មមានតម្លៃនានា។

៣- ៩ ភាគរយ ចំពោះសហគ្រាសវិនិយោគដែលផុតរយៈពេលលើកលែងពន្ធ ។

៤- ០ ភាគរយ ចំពោះសហគ្រាសវិនិយោគ ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធ ។

៥- តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ខាងក្រោម ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយរូបវន្តបុគ្គលនិងចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមអាជីវកម្ម ដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល :

| ភាគនៃប្រាក់ចំណេញប្រចាំឆ្នាំដែលត្រូវជាប់ពន្ធ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០ ៛ | ដល់ | ៦.០០០.០០០ ៛ | ០% |
| ពី | ៦.០០០.០០១ ៛ | ដល់ | ១៥.០០០.០០០ ៛ | ៥% |
| ពី | ១៥.០០០.០០១ ៛ | ដល់ | ១០២.០០០.០០០ ៛ | ១០% |
| ពី | ១០២.០០០.០០១ ៛ | ដល់ | ១៥០.០០០.០០០ ៛ | ១៥% |
| | | លើសពី | ១៥០.០០០.០០០ ៛ | ២០% |

**មាត្រា ២១.-**

ពន្ធលើសហគ្រាសធានារ៉ាប់រងត្រូវបានកំណត់ដូចតទៅ :

១- ចំពោះសហគ្រាសដែលមានសកម្មភាពជាសំខាន់ ក្នុងការធានារ៉ាប់រងឬធានារ៉ាប់រងបន្តលើជីវិត ទ្រព្យសម្បត្តិឬហានិភ័យផ្សេងៗ ពន្ធលើប្រាក់ចំណេញត្រូវបានកំណត់ដូចតទៅ :

អគ្គនាយកដ្ឋានពន្ធដារ

ក. ៥ ភាគរយ នៃបុព្វលាភធានារ៉ាប់រងដុល ដែលទទួលបានទៅក្នុងឆ្នាំជាប់ពន្ធ ចំពោះ: ការធានារ៉ាប់រងឬធានារ៉ាប់រងបន្ត នូវហានិភ័យនៅព្រះរាជាណាចក្រកម្ពុជា

ខ. តាមអត្រាកំណត់ក្នុងមាត្រា២០ នៃច្បាប់នេះ ចំពោះសកម្មភាពដទៃទៀត ដែលមិនមែនជាការធានារ៉ាប់រងឬធានារ៉ាប់រងបន្ត ។

៦- វិធាននិងនីតិវិធីនៃការបង់ពន្ធលើប្រាក់ចំណេញរបស់សហគ្រាសធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ២២.-**

ចំពោះអាជីវកម្មមិនទាក់ទិន ពន្ធលើប្រាក់ចំណេញត្រូវបានកំណត់ដូចតទៅ :

១- ពន្ធលើប្រាក់ចំណេញត្រូវកំណត់ស្មើនឹង ២០ភាគរយ លើចំនួនប្រាក់ចំណូលជាប់ពន្ធនៃអាជីវកម្មមិនទាក់ទិនរបស់អង្គការនានា ដូចមានចែងក្នុងមាត្រា៩ នៃច្បាប់នេះ ។

២- សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណេញ ពាក្យ "ប្រាក់ចំណូលជាប់ពន្ធនៃអាជីវកម្មមិនទាក់ទិន" គឺជាផលដករវាងប្រាក់ចំណូលដុលសម្រេចបានពីអាជីវកម្មមិនទាក់ទិន ដែលអង្គការណាមួយបានធ្វើជាទៀងទាត់និងការកាត់កងនានា ទាក់ទិនផ្ទាល់ទៅនឹងការធ្វើអាជីវកម្ម ដែលបទបញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញបានអនុញ្ញាត ។

៣- ពាក្យ "អាជីវកម្មមិនទាក់ទិន" សំដៅដល់ អាជីវកម្មខាងពាណិជ្ជកម្មឬឧស្សាហកម្មឬអាជីវកម្មផ្សេងទៀតរបស់អង្គការ ដើម្បីស្វែងរកប្រាក់ចំណេញឬមូលនិធិ ហើយពុំមានទាក់ទិនជាសំខាន់ដល់គោលដៅឬមុខងារដែលជាមូលដ្ឋាននៃការលើកលែងពន្ធ ដូចមានចែងក្នុងមាត្រា៩ នៃច្បាប់នេះ ។

**មាត្រា ២៣.-**

ពន្ធបង់មុនលើការបែងចែកភាគលាភ ត្រូវបានកំណត់ដូចតទៅ :

១- បើសិនជាសហគ្រាសណាមួយបែងចែកភាគលាភឱ្យទៅអ្នកចូលហ៊ុនក្នុងស្រុកនិងអ្នកចូលហ៊ុនបរទេសរបស់ខ្លួនទៅក្នុងឆ្នាំជាប់ពន្ធ សហគ្រាសនោះត្រូវកាត់ទុកនិងត្រូវបង់ប្រាក់ពន្ធដែលមានចំនួនស្មើនឹងផលគុណនៃទឹកប្រាក់ភាគលាភបំពេញទៅតាមអត្រាពន្ធលើប្រាក់ចំណេញ គុណនឹងអត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ដូចមានចែងក្នុងមាត្រា២០ នៃច្បាប់នេះ ។

២- ប្រាក់ពន្ធដែលបានកាត់ទុកខាងលើនេះ ត្រូវក្លាយជាឥណទានពន្ធនៃពន្ធលើប្រាក់ចំណេញរបស់សហគ្រាសដែលបែងចែកភាគលាភ សម្រាប់ឆ្នាំជាប់ពន្ធដែលបានធ្វើការកាត់ទុកនោះ ។ បើសិនជាឥណទានពន្ធមានចំនួនលើសពីប្រាក់ពន្ធលើប្រាក់ចំណេញ ចំនួនលើសនោះត្រូវយោងទៅមុខហើយក្លាយទៅជាឥណទានពន្ធសម្រាប់ឆ្នាំបន្ទាប់ ។ ដោយឡែកចំពោះពន្ធកាត់ទុកលើការបែងចែកភាគលាភ ដោយសហគ្រាសធានារ៉ាប់រង ដែលជាប់ពន្ធតាមមាត្រា២១ នៃច្បាប់នេះ មិនអាចប្រើជាឥណទានពន្ធបានទេ ។

៣- សហគ្រាសណាមួយ (តទៅនេះហៅថា "សហគ្រាសទីមួយ") ដែលមានកម្មសិទ្ធិចាប់ពី ២០ភាគរយឡើងទៅ លើដើមទុនផ្ទាល់របស់សហគ្រាសទីពីរ ត្រូវតែបង្កើតនូវគណនីភាគលាភ ។ ពេលណាសហគ្រាសទីមួយបានទទួលភាគលាភបានបង់ពន្ធរួចហើយពីសហគ្រាសទីពីរ សហគ្រាសទីមួយ ត្រូវកត់ត្រាចំនួនប្រាក់ភាគលាភនោះទៅក្នុងគណនីភាគលាភរបស់ខ្លួន ។ ពេលណាសហគ្រាសទីមួយបែងចែកភាគលាភជាបន្តទៀតដល់ម្ចាស់ហ៊ុនរបស់ខ្លួន នូវប្រាក់បែងចែកដែលត្រូវដកចេញពីគណនីភាគលាភ មិនត្រូវមានការកាត់ទុកពន្ធដូចក្នុងកថាខណ្ឌ១ នៃមាត្រានេះទេ ។

៤- រូបវន្តបុគ្គលឬសហគ្រាសដែលបានទទួលភាគលាភអំពីសហគ្រាសដែលមានការកាត់ទុកពន្ធ

អគ្គនាយកដ្ឋាន ពន្ធដារ

ទុកតាមកថាខ័ណ្ឌ១ នៃមាត្រានេះ ឬក៏បានទទួលភាគលាភដកចេញពីគណនីភាគលាភ ដូចមានចែងក្នុងកថាខ័ណ្ឌ៣ នៃមាត្រានេះ មិនត្រូវកត់ត្រាភាគលាភនេះក្នុងប្រាក់ចំណូលទេ ។

## ផ្នែកទី៥
## ពន្ធដទៃទៀត

**មាត្រា ២៤.-**

ពន្ធអប្បបរមា ត្រូវបានកំណត់លើអ្នកជាប់ពន្ធតាមរបបពិត ។ ពន្ធអប្បបរមា ជាពន្ធមួយដាច់ដោយឡែកនិងផ្សេងពីពន្ធលើប្រាក់ចំណេញ ។ ពន្ធនេះត្រូវបង់ដោយអ្នកជាប់ពន្ធតាមរបបពិត ទោះបីអ្នកជាប់ពន្ធនោះបានទទួលលក្ខណៈសម្បត្តិជាសហគ្រាសវិនិយោគក៏ដោយ ។ ពន្ធអប្បបរមា ត្រូវកំណត់តាមអត្រា ១ភាគរយ លើផលរបរប្រចាំឆ្នាំរួមបញ្ចូលទាំងពន្ធអាករនានា ហើយត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ។

ពន្ធអប្បបរមា អាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំដែលបានបង់ជាក់ស្តែងតាមវិធានដែលមានចែងក្នុងមាត្រា៣៧ មាត្រា៣៨និងមាត្រា៣៩ នៃច្បាប់នេះ ។

## ផ្នែកទី៦
## ពន្ធកាត់ទុកនិងប្រាក់រំដោះពន្ធលើប្រាក់ចំណេញ

**មាត្រា ២៥.-**

ពន្ធកាត់ទុកទូទៅត្រូវបានកំណត់ដូចតទៅ :

១- អ្នកបើកប្រាក់និវាសនជនដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ឬជាវត្ថុ ឱ្យដល់បុគ្គលនិវាសនជន ត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ដូចខាងក្រោម លើចំនួនទូទាត់មុនការកាត់ទុកប្រាក់ពន្ធ :

ក. អត្រា ១៥ ភាគរយ ចំពោះ :

- ប្រាក់ចំណូលដែលរូបវន្តបុគ្គលបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ឬសេវាប្រហាក់ប្រហែល
- សួយសារចំពោះទ្រព្យអរូបីនិងភាគកម្មក្នុងធនធានរ៉ែ ប្រេងកាតឬឧស្ម័នធម្មជាតិ ហើយនិងការប្រាក់ដែលបង់ទៅឱ្យរូបវន្តបុគ្គលឬសហគ្រាស លើកលែងតែការប្រាក់ដែលបង់ទៅឱ្យធនាគារ និងស្ថាប័នសញ្ច័យធនក្នុងស្រុក

ខ. អត្រា ១០ ភាគរយ ចំពោះប្រាក់ចំណូលពីការឱ្យជួលចលនឬអចលនទ្រព្យ

គ. អត្រា ៥ ភាគរយ ចំពោះការប្រាក់ដែលធនាគារឬស្ថាប័នសញ្ច័យធនក្នុងស្រុក បង់ឱ្យទៅរូបវន្តបុគ្គលនិវាសនជន ដែលមានគណនីសន្សំគ្មានកាលកំណត់ ។

២- ការកាត់ទុកក្នុងមាត្រានេះ មិនត្រូវអនុវត្តទេចំពោះការទូទាត់ ចំពោះប្រាក់ចំណូលដែលរួចពន្ធ ដូចមានចែងក្នុងមាត្រា៩ នៃច្បាប់នេះ ។

៣- សម្រាប់គោលដៅនៃមាត្រានេះនិងមាត្រា២៦ នៃច្បាប់នេះ ពាក្យ "អ្នកបើកប្រាក់និវាសនជន" សំដៅដល់ :

ក. សហគ្រាសនិវាសនជនឬក្រុមអាជីវកម្មនិវាសនជន

ខ. រូបវន្តបុគ្គល ចំពោះតែការបើកប្រាក់ទាំងឡាយ ដែលរូបវន្តបុគ្គលនោះធ្វើឡើងក្នុងការប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៦.-**

អ្នកបើកប្រាក់និវាសនជន ដែលបានទូទាត់ប្រាក់ចំណូលប្រភពកម្ពុជា ឱ្យទៅបុគ្គលអនិវាសនជនត្រូវកាត់ទុកនិងបង់នូវប្រាក់ពន្ធចំនួន ១៥ ភាគរយ នៃទឹកប្រាក់ត្រូវបើក មុនការកាត់ទុក ។

មាត្រានេះមិនត្រូវអនុវត្តចំពោះភាគលាភដែលមានចែងក្នុងមាត្រា២៣ នៃច្បាប់នេះទេ ។

**មាត្រា ២៧.-**

ពន្ធកាត់ទុកដែលបានអនុវត្តលើការបែងចែកទានាតាមមាត្រា២៣ នៃច្បាប់នេះ ពន្ធកាត់ទុកលើការទូទាត់ឱ្យដល់រូបវន្តបុគ្គលនិវាសនជនតាមមាត្រា២៥ នៃច្បាប់នេះ និងពន្ធកាត់ទុកលើការទូទាត់ឱ្យដល់បុគ្គលអនិវាសនជនតាមមាត្រា២៦ នៃច្បាប់នេះ ត្រូវចាត់ទុកជាជាពន្ធចុងក្រោយសម្រាប់អ្នកទទួលការទូទាត់ឬការបែងចែកដែលមានបញ្ជាក់ក្នុងមាត្រាទាំងឡាយនេះ ។

**មាត្រា ២៨.-**

សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណេញតាមរបបពិត ក្នុងនោះមានទាំងសហគ្រាសវិនិយោគដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩ភាគរយ មានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែសម្រាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ១ភាគរយ នៃផលរបរគិតរួមបញ្ចូលទាំងពន្ធអាករគ្រប់ប្រភេទដែលសម្រេចបានក្នុងខែមុន ។ ប្រាក់រំដោះនេះនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណេញ នៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ ។

## ផ្នែកទី៧
## កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

**មាត្រា ២៩.-**

អ្នកជាប់ពន្ធតាមរបបពិតនិងរបបបំព្រួញមានកាតព្វកិច្ច :

១- អ្នកជាប់ពន្ធលើប្រាក់ចំណេញដែលត្រូវបង់ពន្ធតាមរបបពិតឬរបបបំព្រួញ ត្រូវផ្ញើជូនជារៀងរាល់ឆ្នាំទៅរដ្ឋបាលសារពើពន្ធ នូវលិខិតប្រកាសប្រាក់ចំណេញដែលខ្លួនសម្រេចបានក្នុងឆ្នាំសារពើពន្ធមុន ។ លិខិតប្រកាសនោះត្រូវចុះបញ្ជីជាដាច់ខាតក្នុងរយៈវេលា៣ខែ ក្រោយពីដំណាច់ឆ្នាំសារពើពន្ធ ។

២- អ្នកជាប់ពន្ធតាមរបបពិតត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់ជាមួយនូវ :

ក. តារាងតុល្យការ

ខ. គណនីលទ្ធផល

ឥ. តារាងពត៌មានបន្ថែម ។

៣- អ្នកជាប់ពន្ធតាមរបបបំរួញ ត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់ជាមួយនូវឯកសារនានា តាមគំរូដែលរដ្ឋបាលសារពើពន្ធបានផ្តល់ជូន ។

៤- ចំពោះសហគ្រាសដែលមានការខាតបង់ ក៏ត្រូវដាក់លិខិតប្រកាសសារពើពន្ធតាមបែបបទនិងក្នុងរយៈវេលាដូចគ្នាដែរ ។

**មាត្រា ៣០.-**

អ្នកជាប់ពន្ធតាមរបបម៉ៅការមានភារកិច្ច :

១- អ្នកជាប់ពន្ធតាមរបបម៉ៅការ ត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ឆ្នាំ យ៉ាងយឺតបំផុតនៅថ្ងៃទី៣១ តុលា តាមគំរូដែលរដ្ឋបាលសារពើពន្ធបានផ្តល់ជូន ។

២- ចំនួនប្រាក់ចំណេញម៉ៅការត្រូវកំណត់ដោយរដ្ឋបាលសារពើពន្ធ បន្ទាប់ពីបានត្រួតពិនិត្យ និងពិភាក្សាជាមួយអ្នកជាប់ពន្ធឬអ្នកតំណាង ។ ប្រាក់ចំណេញម៉ៅការនេះ ត្រូវគិតតាមអត្រាចំណេញទៅតាម ប្រភេទនិងតាមមុខរបរអាជីវកម្ម ដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៣- កំរិតពន្ធលើប្រាក់ចំណេញម៉ៅការត្រូវកំណត់ជាស្ថេរវត្តសម្រាប់រយៈពេលមួយមានកំណត់ ៣ខែ ៦ខែ ឬ១ឆ្នាំ ។

៤- អ្នកជាប់ពន្ធលើប្រាក់ចំណេញតាមរបបម៉ៅការ ត្រូវបង់ពន្ធនេះជារៀងរាល់ខែ តាមពេលវេលាដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ ។

**មាត្រា ៣១.-**

បុគ្គលឬអ្នកទទួលភារៈបើកប្រាក់ ដែលកាត់ទុកប្រាក់ពន្ធតាមមាត្រា២៥ និងមាត្រា២៦ នៃច្បាប់នេះ ឬដែលបានកាត់ទុកប្រាក់ពន្ធពីភាគលាភតាមមាត្រា២៣ នៃច្បាប់នេះ ត្រូវដាក់លិខិតប្រកាសសារពើពន្ធនិងបង់ប្រាក់ពន្ធដែលបានកាត់ទុកជូនរដ្ឋបាលសារពើពន្ធ ទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុក ។

**មាត្រា ៣២.-**

បុគ្គលដែលមានភារកិច្ចបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ត្រូវដាក់លិខិតប្រកាសសារពើពន្ធនិងបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញជូនរដ្ឋបាលសារពើពន្ធ ទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់ពីខែដែលបំណុលបានកើតឡើង ។

## ផ្នែកទី៨

## ប្រភពប្រាក់ចំណូល

**មាត្រា ៣៣.-**

វៀរលែងតែមានបទបញ្ញត្តិផ្ទុយ នៅក្នុងច្បាប់នេះ ប្រាក់ចំណូលដូចខាងក្រោម ត្រូវចាត់ទុកជាមានប្រភពក្នុងព្រះរាជាណាចក្រកម្ពុជា :

អគ្គនាយកដ្ឋានពន្ធដារ

១- ការប្រាក់ដែលបង់ដោយសហគ្រាសនិវាសនជន ក្រុមអាជីវកម្មនិវាសនជនឬស្ថាប័នរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

២- ភាគលាភដែលបានបែងចែកដោយសហគ្រាសនិវាសនជននៃព្រះរាជាណាចក្រកម្ពុជា ។

៣- ប្រាក់ចំណូលពីសេវាកម្មដែលបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៤- ប្រាក់ចំណូលដែលបានមកពីការអោយជួលចលនៈឬអចលនទ្រព្យដែលប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

៥- ប្រាក់សួយសារដែលបានមកពីការប្រើប្រាស់ ឬសិទ្ធិប្រើប្រាស់ទ្រព្យអរូបី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៦- ផលចំណេញពីការលក់អចលនទ្រព្យដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬផលចំណេញពីការផ្ទេរផលប្រយោជន៍ណាមួយនៃអចលនទ្រព្យ ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៧- ផលចំណេញពីការលក់ចលនទ្រព្យក្រៅពីសារពើភ័ណ្ឌ ក្នុងករណីដែលអ្នកលក់ជានិវាសនជននៃព្រះរាជាណាចក្រកម្ពុជា ។

៨- បុព្វលាភធានារ៉ាប់រងឬធានារ៉ាប់រងបន្ត ចំពោះហានិភ័យនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៤.-**

និយមន័យនៃប្រាក់ចំណូលប្រភពបរទេស ត្រូវកំណត់ឡើងដោយយកនិយមន័យប្រាក់ចំណូល ដូចមានចែងក្នុងមាត្រា៣៣ នៃច្បាប់នេះមកប្រើ ហើយក្នុងនោះពាក្យ "ព្រះរាជាណាចក្រកម្ពុជា" ត្រូវជំនួសដោយពាក្យ "ប្រទេសណាមួយ ក្រៅពីព្រះរាជាណាចក្រកម្ពុជា" ។

**មាត្រា ៣៥.-**

ក្នុងករណីដែលគ្មានព័ត៌មានគ្រប់គ្រាន់ ដើម្បីកំណត់ប្រភពចំណូលឬបើសិនជាវិធាននានាដែលមានរួចមកហើយ ពុំអាចឆ្លុះបញ្ចាំងឱ្យបានច្បាស់លាស់នូវប្រាក់ចំណូលពីប្រភពណាមួយបានទេនោះ រដ្ឋបាលសារពើពន្ធជាអ្នកកំណត់ប្រភពនៃប្រាក់ចំណូលនោះ ។

## ផ្នែកទី៩
## គណនាប្រាក់ពន្ធប្រចាំឆ្នាំត្រូវបង់

**មាត្រា ៣៦.-**

អ្នកជាប់ពន្ធនិវាសនជនដែលបានទទួលប្រាក់ចំណូលប្រភពបរទេសនិងបានបង់ពន្ធតាមច្បាប់ពន្ធដារបរទេស ត្រូវបានទទួលនូវឥណទានពន្ធសម្រាប់កាត់កងពីប្រាក់ពន្ធលើប្រាក់ចំណេញ ដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែលុះណាតែមានការបង្ហាញឯកសារបញ្ជាក់អំពីការបង់ពន្ធនៅបរទេសនោះ ។

ដើម្បីគណនាប្រាក់ពន្ធដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា មុនពេលកាត់ឥណទានពន្ធនេះ ត្រូវយកចំនួនសរុបនៃប្រាក់ចំណូលដែលបានទទួលអំពីប្រភពកម្ពុជានិងប្រភពបរទេសមកគិត ។

ឥណទានពន្ធត្រូវបានកំណត់ដាច់ដោយឡែកពីគ្នាសម្រាប់ប្រាក់ពន្ធដែលបានបង់ដោយនិវាសនជនកម្ពុជានៅប្រទេសក្រៅនីមួយៗ ។ ប៉ុន្តែឥណទានពន្ធដែលអនុញ្ញាតឱ្យកាត់កងសម្រាប់ឆ្នាំជាប់ពន្ធ គឺចំនួនដែលទាបជាងគេក្នុងចំណោម ៖

ក. ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយ

ខ. ចំនួនដែលបានមកពីការយកប្រាក់ពន្ធលើប្រាក់ចំណេញសរុបពីគ្រប់ប្រភពសម្រាប់រយៈពេលជាមួយគ្នា ដែលគណនាតាមអត្រាពន្ធក្នុងមាត្រា២០ នៃច្បាប់នេះ ទៅគុណនឹងផលចែករវាងប្រាក់ចំណូលដែលបានទទួលនៅប្រទេសក្រៅនោះនិងប្រាក់ចំណូលសរុបពីគ្រប់ប្រភព ។

ឥណទានពន្ធបរទេសអាចផ្តល់ឱ្យបាន លុះណាតែអ្នកជាប់ពន្ធនិវាសនជនបានបំពេញបែបបទ ព្រមទាំងផ្តល់ឯកសារនានាកំណត់ដោយរដ្ឋបាលសារពើពន្ធ ជាពិសេសសេចក្តីបញ្ជាក់របស់អ្នកទូទាត់ប្រាក់ពន្ធនៅបរទេសនិងរដ្ឋបាលសារពើពន្ធបរទេសនោះ ។

ក្នុងករណីឥណទានពន្ធមានចំនួនលើសពីបំណុលពន្ធ ចំនួនលើសនោះអាចយោងទៅប្រើនៅឆ្នាំបន្តបន្ទាប់រហូតដល់ឆ្នាំទី៥ គិតពីឆ្នាំបន្ទាប់នៃឆ្នាំដែលឥណទានពន្ធនោះបានកើតឡើង ។ បើសិនជាមានឥណទានពន្ធច្រើនឆ្នាំ ត្រូវយកឥណទានពន្ធទាំងនោះមកប្រើតាមលំដាប់ឆ្នាំដែលបានកើតឡើង ។

**មាត្រា ៣៧.-**

ការគណនាបំណុលពន្ធលើប្រាក់ចំណេញត្រូវបានកំណត់ដូចតទៅ ៖

១- គណនាបំណុលពន្ធសរុបតាមមាត្រា២០ នៃច្បាប់នេះ ។

២- ដកឥណទានពន្ធបរទេសតាមមាត្រា៣៦ នៃច្បាប់នេះ ប៉ុន្តែមិនឱ្យលើសបំណុលពន្ធក្នុងកថាខណ្ឌ១ នៃមាត្រានេះទេ ។

៣- ដកប្រាក់ពន្ធដែលអ្នកជាប់ពន្ធបានបង់លើការបែងចែកភាគលាភតាមមាត្រា២៣ នៃច្បាប់នេះ ប៉ុន្តែមិនឱ្យលើសពីបំណុលពន្ធក្រោយការកាត់កងឥណទានពន្ធបរទេស ដូចក្នុងកថាខណ្ឌ២ នៃមាត្រានេះទេ ។

**មាត្រា ៣៨.-**

ការគណនាប្រាក់ពន្ធត្រូវបង់ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធត្រូវបានកំណត់ដូចតទៅ ៖

១- ក្នុងករណីដែលលទ្ធផលគណនាតាមមាត្រា៣៧ នៃច្បាប់នេះ មានចំនួនច្រើនជាងផលបូកនៃចំនួនប្រាក់ពន្ធដែលបានកាត់ទុកក្នុងនាមអ្នកជាប់ពន្ធតាមមាត្រា២៥ នៃច្បាប់នេះ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណេញដែលអ្នកជាប់ពន្ធបានបង់ប្រចាំឆ្នាំតាមមាត្រា២៨ នៃច្បាប់នេះ អ្នកជាប់ពន្ធត្រូវបង់បន្ថែមចំនួនដែលលំអៀងនោះ ជូនរដ្ឋបាលសារពើពន្ធ ។

២- ប្រសិនបើលទ្ធផលគណនាតាមមាត្រា៣៧ នៃច្បាប់នេះ មានចំនួនតិចជាងផលបូកនៃចំនួនប្រាក់ពន្ធដែលបានកាត់ទុកក្នុងនាមអ្នកជាប់ពន្ធតាមមាត្រា២៥ នៃច្បាប់នេះ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណេញដែលអ្នកជាប់ពន្ធបានបង់សម្រាប់ឆ្នាំជាប់ពន្ធតាមមាត្រា២៨ នៃច្បាប់នេះ ក្រោយពីបានគិតបំណុលពន្ធអប្បបរមារួចហើយ អ្នកជាប់ពន្ធអាចសុំបង្វិលសងវិញនូវចំនួនដែលលំអៀងឬយោងទៅប្រើជាប្រាក់រំដោះសម្រាប់ឆ្នាំបន្ទាប់ ។

៣- មុននឹងធ្វើការទូទាត់ប្រាក់ពន្ធតាមកថាខណ្ឌ១ ឬក៏សុំបង្វិលសងតាមកថាខណ្ឌ២ អ្នកជាប់ពន្ធត្រូវតែកំណត់ជាមុននូវបំណុលពន្ធអប្បបរមា តាមនីតិវិធីដែលមានចែងក្នុងមាត្រា៣៩ នៃច្បាប់នេះ ។

**មាត្រា ៣៩.-**

ការគណនាប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធត្រូវបានកំណត់ដូចតទៅ:

១- អ្នកជាប់ពន្ធត្រូវបង់ពន្ធអប្បបរមានៅពេលធ្វើការទូទាត់ប្រាក់ពន្ធលើប្រាក់ចំណេញ ។ ពន្ធអប្បបរមាត្រូវបង់អាចត្រូវបានកាត់បន្ថយ ដោយបំណុលពន្ធលើប្រាក់ចំណេញក្នុងឆ្នាំជាប់ពន្ធជាមួយគ្នាតាមមាត្រា២០ នៃច្បាប់នេះ ។

២- ក្នុងករណីបំណុលពន្ធលើប្រាក់ចំណេញ លើសពីបំណុលពន្ធអប្បបរមា :

ក. អ្នកជាប់ពន្ធត្រូវទូទាត់ប្រាក់ពន្ធត្រូវបង់តាមមាត្រា៣៧ នៃច្បាប់នេះ នៅពេលដាក់លិខិតប្រកាសសារពើពន្ធ

ខ. ប្រសិនបើចំនួនទឹកប្រាក់ដែលបានកាត់ទុកតាមមាត្រា២៥ និងមាត្រា២៨ នៃច្បាប់នេះ មានចំនួនលើសពីបំណុលពន្ធអប្បបរមា អ្នកជាប់ពន្ធអាចស្នើសុំជាឥណទានពន្ធបាន

គ. ក្នុងករណីដូចក្នុងកថាខ័ណ្ឌ២ នៃមាត្រានេះ អ្នកជាប់ពន្ធមិនជាប់ពន្ធអប្បបរមាទេ ។

៣- ប្រសិនបើបំណុលពន្ធលើប្រាក់ចំណេញ តិចជាងបំណុលពន្ធអប្បបរមា :

ក. ឥណទានពន្ធរបស់អ្នកជាប់ពន្ធតាមកថាខ័ណ្ឌ២ មាត្រា៣៨ នៃច្បាប់នេះ ត្រូវបានកាត់បន្ថយដោយទឹកប្រាក់លំអៀងខាងលើ

ខ. ឥណទានពន្ធដែលបានកាត់បន្ថយចុះក្នុងការអនុវត្តតាមវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌនេះ ត្រូវចាត់ជាការទូទាត់ប្រាក់ពន្ធអប្បបរមាសម្រាប់ឆ្នាំជាប់ពន្ធ ។

# ជំពូកទី២

# បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស

## ផ្នែកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ៤០.-**

បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១.នស.៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋ ។

**មាត្រា ៤១.-**

ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្ស ដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបំរើការងារ ។

រូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជានិងប្រាក់បៀវត្សប្រភពបរទេស ។

រូបវន្តបុគ្គលអនិវាសនជន ត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ចំពោះប្រាក់បៀវត្សប្រភពកម្ពុជា ។

**មាត្រា ៤២.-**

សម្រាប់គោលដៅនៃបទបញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស :

១- ពាក្យ"និវាសនជន" ក្នុងករណីដែលប្រើចំពោះនិយោជិត អ្នកជាប់ពន្ធឬរូបវន្តបុគ្គល មានន័យថាដែលស្នាក់នៅឬមានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា លើសពី១៨២ថ្ងៃនៅក្នុងឆ្នាំប្រតិទិន ។

២- ពាក្យ "អនិវាសនជន" មានន័យថា ដែលមិនមែនជានិវាសនជន ។

៣- លើកលែងតែមានបទបញ្ញត្តិផ្ទុយ ការប្រើពាក្យនិយោជិត អ្នកជាប់ពន្ធនិងរូបវន្តបុគ្គល គឺសំដៅដល់ទាំងនិវាសនជននិងអនិវាសនជន ដូចមានចែងក្នុងមាត្រានេះ ។

៤- ពាក្យ "និយោជក" រួមមាន ស្ថាប័នរដ្ឋ នីតិបុគ្គលនិវាសនជន ក្រុមអាជីវកម្មនិវាសនជន គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា អង្គការមិនស្វែងរកចំណេញ ឬរូបវន្តបុគ្គលនិវាសនជនដែលប្រកបអាជីវកម្ម ។

៥- ពាក្យ "និយោជិត" សំដៅដល់ រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្សអំពីសកម្មភាពបំរើការងាររបស់ខ្លួន រួមបញ្ចូលទាំងមន្ត្រីរាជការ មន្ត្រីជ្រើសតាំងដោយការបោះឆ្នោតនិងអ្នកទទួលខុសត្រូវឬអភិបាលរបស់សហគ្រាសផង ។

៦- ពាក្យ "ប្រាក់បៀវត្សប្រភពកម្ពុជា" មានន័យថា ប្រាក់បៀវត្សដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបំរើការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដោយឡែកចំពោះប្រាក់បៀវត្សដែលអនិវាសនជនបានទទួលក្នុងការផ្តល់ជំនួយបច្ចេកទេស ត្រូវចាត់ទុកថាមានប្រភពនៅក្នុងប្រទេសដែលអ្នកទូទាត់ប្រាក់បៀវត្សនោះស្នាក់នៅ ។

៧- ពាក្យ "បរទេស" :

ក. ពេលណាប្រើជាមួយរូបវន្តបុគ្គល មានន័យថា ដែលជាអនិវាសនជន

ខ. ចំពោះការកំណត់ប្រភពប្រាក់ចំណូល មានន័យថា ក្រៅព្រះរាជាណាចក្រកម្ពុជា ។

៨- ពាក្យ "ប្រាក់បៀវត្ស" សំដៅដល់ លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានានិងអត្ថប្រយោជន៍បន្ថែម ដែលបានទូទាត់ឱ្យដល់និយោជិតឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ឬប្រយោលដល់និយោជិតចំពោះការបំពេញសកម្មភាពបំរើការងារ ។

## ផ្នែកទី២
## ប្រាក់បៀវត្សលើកលែងពន្ធ

**មាត្រា ៤៣.-**

ការលើកលែងពន្ធលើប្រាក់បៀវត្សរបស់មន្ត្រីការទូតនិងមន្ត្រីបរទេសដទៃទៀតត្រូវបានកំណត់ដូចតទៅ:

១- ត្រូវបានលើកលែងពន្ធលើប្រាក់បៀវត្ស ចំពោះ :

ក. ប្រាក់បៀវត្សដែលមន្ត្រីនិងនិយោជិតនៃបេសកកម្មទូតឬកុងស៊ុលរបស់រដ្ឋាភិបាលបរទេសណាមួយ

មួយដែលកាន់លិខិតឆ្លងដែនការទូតឬផ្លូវការរបស់ប្រទេសនោះ បានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ខ. ប្រាក់បៀវត្សដែលតំណាង មន្ត្រីនិងនិយោជិតបរទេសរបស់អង្គការអន្តរជាតិ និងរបស់ទីភ្នាក់ងារខាងសហប្រតិបត្តិការបច្ចេកទេសនៃរដ្ឋាភិបាលដទៃទៀត បានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- ការលើកលែងពន្ធក្នុងមាត្រានេះ ត្រូវឈរលើគោលការណ៍បដិការរវាងរដ្ឋាភិបាលដែលពាក់ព័ន្ធ។

**មាត្រា ៤៤.–**

ត្រូវបានលើកលែងពន្ធ :

១- ប្រាក់សំណងដោយពិតប្រាកដនូវចំណាយខាងវិជ្ជាជីវៈ ដែលបានចាយដោយនិយោជិតតាមសេចក្ដីបង្គាប់និងសម្រាប់ជាប្រយោជន៍នៃនិយោជក ហើយដែលបានបំពេញល័ក្ខខ័ណ្ឌ៣ ដូចតទៅ :

ក. បានចាយក្នុងផលប្រយោជន៍ផ្ទាល់និងដាច់ខាតរបស់សហគ្រាស

ខ. មិនបង្ហាញលក្ខណៈហួសប្រមាណឬស្អកស្កុំហួសហេតុ

គ. បានបង្ហាញជាភស្តុតាងដោយវិក្កយបត្រ វាយលំអិតនិងបានទូទាត់ស្របច្បាប់ ហើយដែលបានធ្វើក្នុងនាមអ្នកបានទទួលប្រាក់សំណងនូវចំណាយពិតប្រាកដ ។

២- ប្រាក់បំណាច់នៃការបញ្ឈប់លែងឱ្យធ្វើការក្នុងកំរិតដែលបានបញ្ញត្តិក្នុងច្បាប់ការងារ ។

៣- លាភការបន្ថែមមានលក្ខណៈខាងសង្គមកិច្ច ក្នុងករណីដែលបានបញ្ញត្តិក្នុងច្បាប់ការងារ ។

៤- ការផ្ដល់ជូនឱ្យដោយឥតយកថ្លៃឬយកថ្លៃទាបជាងថ្លៃដើមនូវឯកសណ្ឋានឬបរិក្ខារសម្រាប់វិជ្ជាជីវៈពិសេស ។

៥- ប្រាក់បំណាច់ម៉ៅការសម្រាប់ចំណាយបេសកកម្មនិងការធ្វើដំណើរ ។ ប្រាក់បំណាច់នេះមិនត្រូវត្រួតគ្នាជាមួយប្រាក់សំណងពិតប្រាកដ នូវចំណាយដូចមានចែងក្នុងមាត្រានេះឡើយ ។

## ផ្នែកទី៣
## មូលដ្ឋានគិតពន្ធប្រចាំខែ ប្រាក់បៀវត្សជាប់ពន្ធ
## ប្រចាំខែនិងការកំណត់ប្រាក់ពន្ធប្រចាំខែ

**មាត្រា ៤៥.–**

លើកលែងតែអត្ថប្រយោជន៍បន្ថែម ដែលត្រូវកំណត់ពន្ធតាមមាត្រា៤៨ នៃច្បាប់នេះ មូលដ្ឋានគិតពន្ធប្រចាំខែរបស់និវាសនជន គឺជាប្រាក់បៀវត្សជាប់ពន្ធ ដោយដកចេញនូវ :

១- ប្រាក់កាត់ទុកដែលជាកាតព្វកិច្ចក្នុងការប្រតិបត្តិតាមច្បាប់ការងារ ដើម្បីបង្កើតបេឡាសោធននិងធានាសុខុមាលភាពសង្គម ។

២- ការទូទាត់នានា ដែលត្រូវបានលើកលែងពន្ធដូចមានចែងក្នុងមាត្រា៤៤ នៃច្បាប់នេះ ។

**មាត្រា ៤៦.–**

ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែត្រូវបានកំណត់ដូចតទៅ :

១- ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែរបស់និយោជិតនិវាសនជនរួមមាន :

ក. ប្រាក់បៀវត្សដែលបានទទួលពីប្រភពកម្ពុជា

ខ. ប្រាក់បៀវត្សដែលបានទទួលពីប្រភពបរទេស

គ. ប្រាក់បុរេប្រទាន ប្រាក់ឱ្យខ្ចីឬប្រាក់រំដោះ ដែលនិយោជកបានបើកឱ្យនិយោជិត ។ ប្រាក់បុរេប្រទាន ប្រាក់ឱ្យខ្ចីឬប្រាក់រំដោះ ត្រូវបូកបន្ថែមលើបៀវត្សជាប់ពន្ធនៃខែដែលប្រាក់ទាំងនោះបានបើក ហើយត្រូវកាត់បន្ថយពីប្រាក់បៀវត្សក្នុងខែដែលនិយោជិតបានបង់សងវិញ ។

២- ផ្អែកលើការបង្ហាញភស្តុតាងនៃស្ថានភាពគ្រួសារ និយោជិតនិវាសនជនណាមួយដែលមាន :

ក. កូនស្ថិតក្នុងបន្ទុកនាពេលដែលត្រូវបង់ពន្ធ ត្រូវបានទទួលនូវការបន្ថយមូលដ្ឋានកំណត់ពន្ធចំនួន ៧៥.០០០រៀល (ប្រាំពីរម៉ឺនប្រាំពាន់រៀល) ក្នុងកូនម្នាក់ៗក្នុងមួយខែ ។

ខ. សហព័ទ្ធដែលធ្វើតែជាមេផ្ទះ ត្រូវបានទទួលនូវការបន្ថយមូលដ្ឋានកំណត់ពន្ធចំនួន៧៥.០០០រៀល (ប្រាំពីរម៉ឺនប្រាំពាន់រៀល) សម្រាប់តែម្នាក់ក្នុងមួយខែ ។

៣- ចំពោះអ្នកជាប់ពន្ធអនិវាសនជន ប្រាក់បៀវត្សជាប់ពន្ធរួមមានប្រាក់បៀវត្សប្រភពកម្ពុជា ដែលត្រូវជាប់ពន្ធតាមបទបញ្ញត្តិទាំងឡាយនៃជំពូកនេះ ។

**មាត្រា ៤៧.-**

សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែនិងត្រូវកាត់ទុកដោយនិយោជក តាមអត្រាកំណើនតាមថ្នាក់ ដូចតទៅ :

| ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | | | | | អត្រាពន្ធ |
|---|---|---|---|---|---|
| ពី | ០ ៛ ០០ | ដល់ | ៥០០.០០០ ៛ ០០ | | ០% |
| ពី | ៥០០.០០១ ៛ ០០ | ដល់ | ១.២៥០.០០០ ៛ ០០ | | ៥% |
| ពី | ១.២៥០.០០១ ៛ ០០ | ដល់ | ៨.៥០០.០០០ ៛ ០០ | | ១០% |
| ពី | ៨.៥០០.០០១ ៛ ០០ | ដល់ | ១២.៥០០.០០០ ៛ ០០ | | ១៥% |
| | | លើសពី | ១២.៥០០.០០០ ៛ ០០ | | ២០% |

**មាត្រា ៤៨.-**

ចំពោះអត្ថប្រយោជន៍បន្ថែម ជារៀងរាល់ខែនិយោជកត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធតាមការកំណត់តាមអត្រា ២០ភាគរយ នៃតម្លៃសរុបរបស់អត្ថប្រយោជន៍បន្ថែម ដែលបានផ្តល់ឱ្យនិយោជិតទាំងអស់ ។ តម្លៃនៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សាររួមទាំងពន្ធអាករទាំងអស់ ។

**មាត្រា ៤៩.-**

វៀរលែងតែអត្ថប្រយោជន៍បន្ថែមដែលត្រូវកំណត់ពន្ធតាមមាត្រា៤៨ នៃច្បាប់នេះ សម្រាប់អ្នកជាប់ពន្ធអនិវាសនជនប្រាក់ពន្ធត្រូវកាត់ទុកដោយអ្នកបើកប្រាក់ឱ្យតាមអត្រា ១៥ភាគរយ លើរាល់ការទូទាត់ប្រាក់បៀវត្សជាប់ពន្ធដែលមានចែងក្នុងកថាខណ្ឌ៣ មាត្រា៤៦ នៃច្បាប់នេះ ។ ពន្ធកាត់ទុកនេះ គឺជាពន្ធចុងក្រោយនៃការបើកប្រាក់បៀវត្សសម្រាប់អនិវាសនជនជាអ្នកទទួលប្រាក់បៀវត្ស ។

**មាត្រា ៥០.-**

អ្នកជាប់ពន្ធនិវាសនជនដែលបានទទួលប្រាក់បៀវត្សប្រភពបរទេស និងបានបង់ពន្ធតាមច្បាប់ពន្ធដារបរទេស ត្រូវបានទទួលនូវឥណទានពន្ធសម្រាប់កាត់កងពីប្រាក់ពន្ធលើប្រាក់បៀវត្សដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែលុះណាតែមានការបង្ហាញឯកសារបញ្ជាក់អំពីការបង់ពន្ធនៅបរទេសនោះ ។

ក. ដើម្បីគណនាប្រាក់ពន្ធដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា មុនពេលកាត់ឥណទានពន្ធនេះ ត្រូវយកចំនួនសរុបប្រាក់បៀវត្សដែលបានទទួលអំពីប្រភពកម្ពុជានិងប្រភពបរទេសមកគិត

ខ. ឥណទានពន្ធត្រូវបានកំណត់ដាច់ដោយឡែកពីគ្នាសម្រាប់ប្រាក់ពន្ធដែលបានបង់ដោយនិវាសនជនកម្ពុជានៅប្រទេសក្រៅនីមួយៗ ។ ប៉ុន្តែឥណទានពន្ធផ្តល់ឱ្យសម្រាប់ពន្ធលើប្រាក់បៀវត្សដែលបានបង់នៅប្រទេសក្រៅ គឺជាចំនួនដែលទាបជាងគេ ក្នុងចំណោម :

- ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយ
- ចំនួនដែលបានមកពីការយកប្រាក់ពន្ធលើប្រាក់បៀវត្សសរុបពីគ្រប់ប្រភព ក្នុងរយៈពេលជាមួយគ្នា ដែលគណនាតាមអត្រាកំណើនតាមថ្នាក់ក្នុងមាត្រា៤៧ នៃច្បាប់នេះ ទៅគុណនិងផលធៀបរវាងប្រាក់បៀវត្សដែលបានទទួលនៅប្រទេសក្រៅនោះនិងប្រាក់បៀវត្សសរុបពីគ្រប់ប្រភព ។

ការបង្វិលសងឥណទានពន្ធបរទេសអាចធ្វើទៅបាន លុះណាតែអ្នកជាប់ពន្ធនិវាសនជនបានបំពេញបែបបទព្រមទាំងផ្តល់ឯកសារនានាកំណត់ដោយរដ្ឋបាលសារពើពន្ធ ជាពិសេសសេចក្តីបញ្ជាក់របស់និយោជកនិងរដ្ឋបាលសារពើពន្ធនៃទីកន្លែងបំពេញការងារនៅឯបរទេស ។

## ផ្នែកទី៤
## ភារកិច្ចរបស់និយោជកនិងនិយោជិត

**មាត្រា ៥១.-**

ការបើកបៀវត្ស បង្កើតជាហេតុបណ្តាលឱ្យជាប់ពន្ធ ។

**មាត្រា ៥២.-**

បំណុលពន្ធនិងកាតព្វកិច្ចកាត់ទុកប្រាក់ពន្ធ ត្រូវបានកំណត់ដូចតទៅ :

១- ពន្ធនេះ គឺជាបំណុលរបស់រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្ស រួមទាំងរូបវន្តបុគ្គលបរទេសផង វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិ ។

២- ពន្ធលើប្រាក់បៀវត្សត្រូវប្រមូលតាមរបៀបកាត់ទុកជាមុនជារៀងរាល់ខែ ដោយនិយោជកនៅរាល់ពេលបើកប្រាក់បៀវត្ស ។

៣- ប្រសិនបើនិយោជកស្នាក់នៅបរទេស តំណាងសារពើពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនិយោជកបានចាត់តាំង គឺជាអ្នកទទួលភារៈកាត់ទុកពន្ធលើប្រាក់បៀវត្សមុនពេលបើកប្រាក់បៀវត្សទៅឱ្យនិយោជិតនិងបង្វែរប្រាក់ពន្ធទាំងនោះជូនរដ្ឋ ។

៤- និយោជកឬតំណាងនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់និយោជកអនិវាសនជន ព្រមទាំងនិយោជិតត្រូវទទួលខុសត្រូវរួមគ្នាក្នុងការបង់ពន្ធលើប្រាក់បៀវត្សក្នុងព្រះរាជាណាចក្រកម្ពុជា ដោយបំពេញកាតព្វកិច្ចជាប្រចាំ

អគ្គនាយកដ្ឋានពន្ធដារ

បៀវត្សបានបើកឱ្យនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬនៅបរទេសឡើយ ។ ក្នុងករណីមិនបានកាត់ទុកប្រាក់ពន្ធលើប្រាក់បៀវត្ស និយោជកត្រូវទទួលខុសត្រូវចំពោះច្បាប់នេះ ទោះបីជាប្រាក់ពន្ធត្រូវបានបង់ដោយនិយោជិតរួចហើយក្តី ។

**មាត្រា ៥៣.-**

ប្រាក់ពន្ធកាត់ទុកដែលទាក់ទងជាការបើកប្រាក់បៀវត្សធ្វើឡើងក្នុងខែណាមួយ ត្រូវបង់យ៉ាងយឺតបំផុតនៅថ្ងៃទី១៥ នៃខែបន្ទាប់ ជូនទៅរដ្ឋបាលសារពើពន្ធៈនាទីកន្លែងនៃលំនៅដ្ឋានឬគ្រឹះស្ថានជាគោលដើមនៃអ្នកទទួលភារៈកាត់ទុកប្រាក់ពន្ធនេះ ។

**មាត្រា ៥៤.-**

គ្រប់និយោជកដែលបើកប្រាក់បៀវត្សត្រូវជាប់ពន្ធ ត្រូវទទួលបំពេញភារកិច្ច :

១- កាត់ទុកប្រាក់ពន្ធមុនពេលបើកបៀវត្ស ។

២- រាយការណ៍ជូនរដ្ឋបាលសារពើពន្ធនិងនិយោជិតអំពីស្ថានភាពប្រាក់ពន្ធដែលបានកាត់ទុក ។

៣- កាន់កាប់និងថែរក្សាបញ្ជីការដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

# ជំពូកទី៧

# បទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម

## ផ្នែកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៥.-**

ចាប់តាំងពីថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៨ តទៅ និងត្រូវបានបង្កើតអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់ជាប់អាករ ដើម្បីជាប្រយោជន៍ដល់ថវិការដ្ឋ ។

**មាត្រា ៥៦.-**

សម្រាប់គោលដៅនៃបទបញ្ញត្តិៈស្តីពីអាករលើតម្លៃបន្ថែម :

១- ពាក្យ "ទំនិញ" សំដៅដល់ទ្រព្យរូបី ក្រៅពីដីធ្លីនិងប្រាក់កាស ។

២- ពាក្យ "សេវា" សំដៅដល់ការផ្តល់អ្វីមួយដែលមានតម្លៃក្រៅពីទំនិញ ដីធ្លីនិងប្រាក់កាស ។

៣- ពាក្យ "ការផ្គត់ផ្គង់ទំនិញ" សំដៅដល់ការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងក្នុងឋានៈជាម្ចាស់កម្មសិទ្ធិទំនិញ ទោះបីមានសំណងឬគ្មានសំណងក្តី ។ ការផ្គត់ផ្គង់សេវាបន្ទាប់បន្សំដែលទាក់ទិននឹងការផ្គត់ផ្គង់ទំនិញ ត្រូវចាត់ទុកដូចជាការផ្គត់ផ្គង់ទំនិញ ។

៤- ពាក្យ "ការផ្គត់ផ្គង់សេវា" សំដៅដល់ការផ្គត់ផ្គង់ ដែលមិនមែនជាការផ្គត់ផ្គង់ទំនិញ ដីធ្លីឬប្រាក់កាស ដែលធ្វើឡើងដើម្បីបានទទួលសំណងអ្វីមួយ ។ ការផ្គត់ផ្គង់ទំនិញបន្ទាប់បន្សំដែលទាក់ទិននឹងការផ្គត់ផ្គង់សេវា ត្រូវចាត់ទុកដូចជាការផ្គត់ផ្គង់សេវា ។

អគ្គនាយកដ្ឋានពន្ធដារ

៥- ពាក្យ "បុគ្គល" សំដៅដល់បុគ្គលឬក្រុមបុគ្គលដែលធ្វើអាជីវកម្ម ហើយនិងបុគ្គលណាមួយទៀត ដែលទាក់ទិនជាមួយបុគ្គលនោះ ។

៦- ពាក្យ "ទាក់ទិន" ចំពោះបុគ្គលណាមួយ មានន័យថា :

ក. បុគ្គលណាមួយដែលមានកម្មសិទ្ធិចាប់ពី ២០ភាគរយ ឡើងទៅលើតម្លៃឬសិទ្ធិបោះឆ្នោតនៃភាគកម្មនៅក្នុងដើមទុនផ្ទាល់នៃបុគ្គលដែលលើកយកមកពិចារណា

ខ. មានការគ្រប់គ្រងរួមគ្នាឬមាននាយករួមគ្នាជាមួយបុគ្គល

គ. ជាសមាជិកគ្រួសារឬជាសហព័ន្ធឬជាសមាជិកក្រុមគ្រួសារនៃសហព័ន្ធរបស់បុគ្គល

ឃ. បានទិញចាប់ពី ៣០ភាគរយ ឡើងទៅ នៃធាតុចេញសរុបរបស់បុគ្គល ក្នុងរយៈពេលបីខែបន្តបន្ទាប់ ។

៧- ពាក្យ "អាករ" ក្នុងផ្នែកនេះ សំដៅដល់អាករលើតម្លៃបន្ថែម ។

**មាត្រា ៥៧.-**

ការផ្គត់ផ្គង់មិនជាប់អាករ មានដូចតទៅ :

១- សេវាប្រៃសណីយ៍សាធារណៈ ។

២- សេវារបស់មន្ទីរពេទ្យនិងគ្លីនិក សេវាខាងវេជ្ជសាស្ត្រនិងធ្មេញសាស្ត្រនិងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រនិងធ្មេញសាស្ត្រ ដែលទាក់ទិននឹងការបំពេញសេវាទាំងនេះ ។

៣- សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ ។

៤- សេវាធានារ៉ាប់រង ។

៥- សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ ដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៦- ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយ ក្នុងកម្រិតតម្លៃដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៧. សកម្មភាពមិនស្វែងរកប្រាក់ចំណេញ ដើម្បីបំរើផលប្រយោជន៍សាធារណៈ ដែលបានទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៥៨.-**

ការផ្គត់ផ្គង់មិនជាប់អាករចំពោះបេសកកម្មទូតនិងអង្គការអន្តរជាតិ ត្រូវបានកំណត់ដូចតទៅ :

១- ការនាំចូលនូវទំនិញសម្រាប់ឬដោយបេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិនិងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា សម្រាប់យកមកប្រើនៅក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន ត្រូវកំណត់ថាជាការផ្គត់ផ្គង់មិនជាប់អាករ ។ ការផ្គត់ផ្គង់មិនជាប់អាករត្រូវបានផ្តល់ឱ្យតែក្នុងករណីមានការបញ្ជាក់អំពីប្រធានបេសកកម្មឬនាយកស្ថានពន្ធដារថា ទំនិញទាំងនោះបាននាំចូលមកសម្រាប់គោលដៅនៃការប្រើប្រាស់ខាងលើនេះមែន ។

២- ការនាំចូលទំនិញសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិកផ្លូវការនៃបេសកកម្មឬអង្គការ ដូចមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ត្រូវកំណត់ថាជាការផ្គត់ផ្គង់មិនជាប់អាករចំពោះតែមុខទំនិញនិងបរិមាណដែលបានចុះនៅក្នុងបញ្ជីរាយមុខទំនិញ ដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៣- ការផ្គត់ផ្គង់មិនជាប់អាករទៅក្នុងមាត្រានេះ ត្រូវឈរលើគោលការណ៍បដិការរវាងរដ្ឋាភិបាលពាក់ព័ន្ធ ។

## វគ្គទី២
## គោលការណ៍ទូទៅនៃអាករលើតម្លៃបន្ថែម

**មាត្រា ៥៩.-**

បុគ្គលជាប់អាករ សំដៅដល់បុគ្គលដែលត្រូវជាប់ពន្ធតាមរបបពិត ហើយដែលធ្វើការផ្គត់ផ្គង់ជាប់អាករ ដូចមានចែងក្នុងមាត្រា៦០ នៃច្បាប់នេះ ។

បុគ្គលដែលជាប់ពន្ធតាមរបបប៉ាន់ស្មាន អាចស្នើសុំឱ្យចាត់ជាបុគ្គលជាប់អាករបាន ។ លក្ខខណ្ឌនិងនីតិវិធីសម្រាប់ការស្នើសុំនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

សម្រាប់គោលដៅនៃជំពូកនេះ និយោជិតមិនត្រូវបានចាត់ទុកថាជាបុគ្គលជាប់អាករទេ ចំពោះសកម្មភាពដែលបានបំពេញក្នុងឋានៈជានិយោជិត ។

**មាត្រា ៦០.-**

លើកលែងតែមានបទប្បញ្ញត្តិផ្សេង នៅក្នុងជំពូកនេះ ពាក្យ"ការផ្គត់ផ្គង់ជាប់អាករ" សំដៅដល់ :

១. ការផ្គត់ផ្គង់ទំនិញឬសេវាដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២. ការដកយកទំនិញមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ ។

៣. ការផ្តល់ជាអំណោយឬការផ្គត់ផ្គង់ក្រោមតម្លៃពិត នូវទំនិញឬសេវាដោយបុគ្គលជាប់អាករ។

៤. ការនាំចូលទំនិញមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា ។

វិធាននិងនីតិវិធីសម្រាប់ការអនុវត្តមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៦១.-**

តម្លៃជាប់អាករត្រូវបានកំណត់ដូចតទៅ :

១- តម្លៃជាប់អាករនៃការផ្គត់ផ្គង់ គឺជាថ្លៃទំនិញឬសេវា ដែលអ្នកលក់យកពីអ្នកទិញ ។ តម្លៃជាប់អាកររួមមានបន្ទុកផឹកជញ្ជូន ហើយនិងខ្ចប់ផងដែរ ដែលត្រូវទូទាត់ឱ្យអ្នកលក់ចំពោះការផ្គត់ផ្គង់នោះ រួមបញ្ចូលទាំងអាករពិសេសលើទំនិញនិងសេវាមួយចំនួន លើកលែងតែអាករលើតម្លៃបន្ថែម ។ នីតិវិធីសម្រាប់ធ្វើការកែតម្រូវតម្លៃជាប់អាករនៅពេលផ្គត់ផ្គង់ឬក្រោយពេលផ្គត់ផ្គង់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

២- ក្នុងករណីដែលការទូទាត់ចំពោះការផ្គត់ផ្គង់ជាប់អាករជាសំណងអ្វីមួយក្រៅពីប្រាក់កាស ដើម្បីជាផលប្រយោជន៍ផ្ទាល់ឬប្រយោលដល់អ្នកលក់ សំណងនោះត្រូវគិតបញ្ចូលក្នុងតម្លៃជាប់អាករតាមតម្លៃទីផ្សារ ។

៣- តម្លៃជាប់អាកររបស់ទំនិញនាំចូល គឺជាតម្លៃគយរួមបញ្ចូលទាំងតម្លៃធានារ៉ាប់រងនិងដឹកជញ្ជូន ដោយបូកបន្ថែមនូវពន្ធគយនិងអាករពិសេសលើទំនិញនិងសេវាមួយចំនួន ។ បើសិនជាគ្មានតម្លៃគយកែតម្រូវនេះទេ ត្រូវកំណត់យកតាមតម្លៃទីផ្សារ ។

អគ្គនាយកដ្ឋានពន្ធដារ

៤- បើសិនជាតម្លៃជាប់អាករបស់ទំនិញឬសេវាដែលបានផ្គត់ផ្គង់មិនតំណាងឱ្យតម្លៃពិតទេនោះ រដ្ឋបាលសារពើពន្ធអាចកំណត់ចេញនូវតម្លៃមួយសម្រាប់ទំនិញឬសេវា ហើយតម្លៃនោះត្រូវចាត់ទុកជាតម្លៃត្រឹមត្រូវ រហូតដល់ពេលមានភស្តុតាងបញ្ជាក់ផ្សេងដែលរដ្ឋបាលសារពើពន្ធបានយល់ព្រមផង ។

៥- តម្លៃជាប់អាករនៃទំនិញប្រើរួចហើយ ដែលបុគ្គលជាប់អាករបានទិញពីអ្នកប្រើប្រាស់ដើម្បីលក់ជាប្រចាំឬលក់ជូនសមុខឱ្យអ្នកប្រើប្រាស់ គឺជាចំនួនលំអៀងរវាងថ្លៃលក់និងថ្លៃទិញឬប្រាក់កម្រៃដែលបានមកពីការលក់ទំនិញនោះ ។

**មាត្រា ៦២.-**

ពេលផ្គត់ផ្គង់ត្រូវបានកំណត់ដូចតទៅ :

១- អាករលើតម្លៃបន្ថែមត្រូវគេកំណត់និងត្រូវបង់នៅពេលផ្គត់ផ្គង់ ។

២- ពេលផ្គត់ផ្គង់ទំនិញនិងសេវា គឺជាពេលដែលអ្នកលក់ត្រូវចេញវិក្កយបត្រឬជាពេលដែលអ្នកលក់បានចេញវិក្កយបត្រ ប្រសិនបើវិក្កយបត្រនោះត្រូវបានចេញមុនពេលដែលអ្នកលក់ត្រូវចេញវិក្កយបត្រ ។

៣- វិក្កយបត្រអាករលើតម្លៃបន្ថែម ត្រូវចេញយ៉ាងយឺតបំផុតតាំងថ្ងៃក្រោយការបញ្ជូនទំនិញ ឬការបំពេញសេវាឬក្រោយការទូទាត់ក្នុងករណីដែលការទូទាត់ធ្វើឡើងមុនការបញ្ជូនទំនិញឬការបំពេញសេវា ។ ប្រសិនបើការបញ្ជូនទំនិញពុំមានវិក្កយបត្រភ្ជាប់ជាមួយទេ ត្រូវមានភ្ជាប់ឯកសារបញ្ជូនទំនិញដែលបានកត់ត្រាត្រឹមត្រូវក្នុងទិន្នានុប្បវត្តិបញ្ជូនទំនិញ ។

៤- ចំពោះការផ្គត់ផ្គង់ទំនិញឬសេវា ដែលធ្វើឡើងជាបន្តឬដែលមានការទូទាត់ច្រើនលើក ពេលផ្គត់ផ្គង់ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៥- ចំពោះការនាំចូលទំនិញ ពេលផ្គត់ផ្គង់គឺជាពេលដែលអ្នកនាំចូលដាក់លិខិតប្រកាសជូនអាជ្ញាធរគយ នៅតាមគោលការណ៍ជាធរមាន ។

**មាត្រា ៦៣.-**

ទីកន្លែងផ្គត់ផ្គង់ត្រូវបានកំណត់ដូចតទៅ :

១- ការផ្គត់ផ្គង់ទំនិញត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាទំនិញនោះត្រូវបានប្រគល់ឱ្យ ទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងក្តី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ចំពោះករណីដែលការផ្គត់ផ្គង់ត្រូវមានការដឹកជញ្ជូន ការផ្គត់ផ្គង់ត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺបើសិនជាទំនិញស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដែលការដឹកជញ្ជូនត្រូវបានចាប់ផ្តើម ។

២- ការផ្គត់ផ្គង់សេវាត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាសេវានោះបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយវៀរលែង :

ក. ការផ្គត់ផ្គង់សេវាជាប់ទាក់ទងនិងអចលនទ្រព្យ ត្រូវកំណត់ថាសេវានោះបានធ្វើឡើងនៅទីកន្លែងដែលទ្រព្យនោះស្ថិតនៅ

ខ. ការផ្គត់ផ្គង់សេវាជាប់ទាក់ទងនិងការដឹកជញ្ជូន ត្រូវកំណត់ថាសេវានោះបានធ្វើឡើងនៅទីកន្លែងនៃការដឹកជញ្ជូននោះ ។

៣- ទំនិញត្រូវចាត់ទុកថាបាននាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាទំនិញនោះត្រូវបាននាំចូលមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា ។

## ផ្នែកទី៣

## អត្រាអាករនិងការគណនាប្រាក់អាករ

**មាត្រា ៦៤.-**

អត្រាអាករត្រូវបានកំណត់ដូចតទៅ ៖

១- អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រា ១០ភាគរយ លើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រា ០ ភាគរយ លើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗចំពោះទំនិញនាំចេញពីព្រះរាជាណាចក្រកម្ពុជា ហើយនិងការផ្គត់ផ្គង់សេវាជាប់អាករ ដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងមាត្រា៦៣ នៃច្បាប់នេះ ។

៣- រដ្ឋបាលសារពើពន្ធអាចប្រើប្រាស់ឯកសារមួយចំនួន ដើម្បីបញ្ជាក់ថាមានការនាំចេញជាក់ស្តែងមែន ក្នុងនោះមានជាអាទិ៍ សេចក្តីបញ្ជាក់ការនាំចេញរបស់ទីចាត់ការគយនិងរដ្ឋាករ ឯកសារនាំចូលរបស់ប្រទេសនាំចូល លិខិតឥណទានបានប្រើប្រាស់និងការទូទាត់ដែលធនាគារក្នុងស្រុកបានទទួល ។

**មាត្រា ៦៥.-**

ឥណទានអាករលើធាតុចូលនិងការផ្គត់ផ្គង់មិនជាប់អាករត្រូវបានកំណត់ដូចតទៅ ៖

១- ប្រាក់អាករដែលបុគ្គលជាប់អាករបានបង់លើទំនិញនិងសេវា សម្រាប់ប្រើប្រាស់ក្នុងអាជីវកម្មដែលបុគ្គលជាប់អាករម្នាក់ទៀតបានផ្គត់ផ្គង់ឱ្យឬប្រាក់អាករដែលបានបង់ដោយបុគ្គលជាប់អាករក្នុងឋានៈជាអ្នកនាំចូលលើទំនិញ ឬសេវានាំចូលសម្រាប់ប្រើប្រាស់នៅក្នុងអាជីវកម្មរបស់ខ្លួន ត្រូវក្លាយជាឥណទានអាករលើធាតុចូលសម្រាប់កាត់កងចេញពីអាករលើធាតុចេញ។ ធាតុចូលមានន័យថា ទំនិញឬសេវាដែលបានទិញចូល ហើយធាតុចេញមានន័យថា ទំនិញឬសេវាដែលបានលក់ចេញ ។

២- ក្នុងករណីទំនិញនិងសេវាទិញចូលត្រូវបានប្រើប្រាស់មួយចំណែកជាការផ្គត់ផ្គង់ជាប់អាករនិងមួយចំណែកទៀតជាការផ្គត់ផ្គង់មិនជាប់អាករ ឥណទានអាករត្រូវបានអនុញ្ញាតឱ្យតែចំពោះចំណែកដែលបានប្រើប្រាស់ជាការផ្គត់ផ្គង់ជាប់អាករ ។

**មាត្រា ៦៦.-**

ប្រាក់អាករត្រូវបានកំណត់ដូចតទៅ ៖

១- អាករដែលបានកំណត់ក្នុងមាត្រា៦៤ នៃច្បាប់នេះ ត្រូវចាត់ទុកជាបំណុលចំពោះរដ្ឋនៅពេលផ្គត់ផ្គង់ ។

២- ប្រាក់អាករត្រូវបង់ជូនរដ្ឋ ស្មើនឹង ប្រាក់អាករលើធាតុចេញសរុបតាមអត្រាក្នុងមាត្រា៦៤ នៃច្បាប់នេះ ដកឥណទានអាករលើធាតុចូលដែលបានអនុញ្ញាតសរុបក្នុងខែជាមួយគ្នា ។

**មាត្រា ៦៧.-**

ក្នុងករណីអចលកម្មប្រើនៃអាជីវកម្មណាមួយដែលបានទទួលឥណទានអាករ ដូចក្នុងមាត្រា៦៥ នៃច្បាប់នេះ ត្រូវឈប់ប្រើប្រាស់នៅក្នុងអាជីវកម្មរបស់បុគ្គលជាប់អាករ ទ្រព្យនោះត្រូវចាត់ទុកជាបានលក់និងត្រូវបង់អាករតាមតម្លៃទីផ្សារនៅពេលឈប់ប្រើការនោះ ។

អគ្គនាយកដ្ឋានពន្ធដារ

**មាត្រា ៦៨.-**

សំណើសុំឥណទានអាករលើធាតុចូល ត្រូវភ្ជាប់មកជាមួយនូវ ៖

១- វិក្កយបត្រអាករលើតម្លៃបន្ថែម ដែលបានធ្វើឡើងស្របតាមមាត្រា៧៨ នៃច្បាប់នេះ ។

២- ប្រតិវេទន៍គយសម្រាប់ការនាំចូល ដែលអាជ្ញាធរគយបានបញ្ជាក់ត្រឹមត្រូវ ។ ប្រតិវេទន៍នោះត្រូវមានចុះឈ្មោះបុគ្គលជាប់អាករ ដែលជាអ្នកទទួលទំនិញឬជាអ្នកនាំចូលនិងចំនួនប្រាក់ពន្ធអាករដែលបានបង់នៅពេលនាំចូល ។

**មាត្រា ៦៩.-**

អាករលើធាតុចូលដែលមិនអនុញ្ញាតឱ្យប្រើជាឥណទាន រួមមានប្រាក់អាករដែលបុគ្គលជាប់អាករបានបង់លើការចំណាយទទួលភ្ញៀវ កំសាន្តឬសំរាកលំហែ ការទិញរថយន្តឬការទិញផលិតផលពេលសិលាមួយចំនួន ។

## ផ្នែកទី៤
## ការបង់ប្រាក់អាករ

**មាត្រា ៧០.-**

លិខិតប្រកាសអាករលើតម្លៃបន្ថែមសម្រាប់ខែណាមួយ ត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ ហើយត្រូវបង់ប្រាក់អាករនោះតាមចំនួនដែលបានប្រកាសនៅពេលដាក់លិខិតប្រកាសនោះ ។

**មាត្រា ៧១.-**

បើសិនជាអាករលើធាតុចូលដែលបុគ្គលជាប់អាករបានបង់តាមមាត្រា៦៤ នៃច្បាប់នេះ មានចំនួនខ្ពស់ជាងអាករលើធាតុចេញដែលបុគ្គលនោះប្រមូលសម្រាប់ខែណាមួយ ៖

១- ចំនួនលើសត្រូវប្រើជាឥណទានអាករចំពោះប្រាក់អាករលើតម្លៃបន្ថែមដែលបុគ្គលនោះជំពាក់ខែកន្លងទៅ ។

២- ចំនួនលើសដែលនៅសល់ទៀតនោះ ត្រូវចាត់ទុកជាឥណទានអាករលើធាតុចូលនៃមាត្រា៦៥ នៃច្បាប់នេះ សម្រាប់ខែបន្ទាប់ ។

**មាត្រា ៧២.-**

រដ្ឋបាលសារពើពន្ធអាចបង្វិលសងនូវឥណទានអាករលើធាតុចូលលើសប្រចាំខែ តាមការស្នើសុំរបស់បុគ្គលជាប់អាករដែលមានសកម្មភាពនាំចេញជាសំខាន់ ប្រសិនបើបុគ្គលនោះបានបង្ហាញឯកសារបញ្ជាក់ច្បាស់លាស់ក្នុងការនាំចេញ ហើយនិងបានប្រតិបត្តិត្រឹមត្រូវនូវកាតព្វកិច្ចកាន់បញ្ជីការនិងឯកសារផ្សេងទៀត ។

**មាត្រា ៧៣.-**

បើសិនជាបុគ្គលជាប់អាករមានឥណទានអាករលើធាតុចូលលើសចាប់ពី ៣ខែឡើងទៅ បុគ្គលនោះអាចដាក់ពាក្យសុំបង្វិលសងប្រាក់អាករនៅដំណាច់ខែទី៣ ឬនៅក្នុងខែណាមួយជាបន្តមកទៀត ។ ដើម្បីឱ្យមានការបង្វិលសងសម្រាប់ខែណាមួយ ពាក្យសុំត្រូវដាក់ស្នើក្នុងរយៈពេល២០ថ្ងៃក្រោយដំណាច់ខែនោះ ។

អគ្គនាយកដ្ឋានពន្ធដារ

**មាត្រា ៧៤.-**

បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា អាចដាក់ពាក្យសុំបង្វិលសងប្រាក់អាករលើទំនិញដែលបានទិញនៅក្នុងស្រុក ដែលនឹងមានចុះនៅក្នុងបញ្ជីរាយមុខទំនិញកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ការបង្វិលសងប្រាក់អាករអាចអនុវត្តទៅបានតែក្នុងករណីមានការបញ្ជាក់អំពីប្រធានបេសកកម្មជូនទៅរដ្ឋបាលសារពើពន្ធថា ទំនិញត្រូវបានទិញមកសម្រាប់យកទៅប្រើប្រាស់នៅក្នុងការបំពេញមុខងារជាផ្លូវការរបស់អង្គភាពសាមី ។

**មាត្រា ៧៥.-**

ការទទួលខុសត្រូវចំពោះការប្រមូលនិងការបង់អាករ ត្រូវបានកំណត់ដូចតទៅ :

១- បុគ្គលជាប់អាករឬអ្នកនាំចូលមានភារកិច្ចត្រូវបង់អាករ ដែលកំណត់ដោយមាត្រា៦៤ នៃច្បាប់នេះ លើរាល់ការផ្គត់ផ្គង់ជាប់អាករដែលបុគ្គលជាប់អាករឬអ្នកនាំចូលបានអនុវត្ត ។

២- លក្ខខណ្ឌពិសេសបញ្ជាក់អំពីការទទួលខុសត្រូវរបស់អ្នកទិញចំពោះប្រាក់អាករ ក្នុងករណីដែលអ្នកផ្គត់ផ្គង់គ្មានធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងករណីដែលមានឧបសគ្គផ្សេងទៀតដល់ការប្រមូលប្រាក់អាករអំពីអ្នកផ្គត់ផ្គង់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

៣- បុគ្គលណាមួយដែលបានធ្វើការផ្គត់ផ្គង់ទំនិញនិងសេវា ក្នុងនាមម្ចាស់កម្មសិទ្ធិនឹងមិនមែនក្នុងឋានៈជានិយោជិតរបស់គេនោះ ហើយដែលមានការគ្រប់គ្រងលើការផ្គត់ផ្គង់ ត្រូវចាត់ទុកថាជាបុគ្គលជាប់អាករសម្រាប់ការផ្គត់ផ្គង់នោះ ។

## ជំពូកទី៥
## បទប្បញ្ញត្តិខាងរដ្ឋបាល

**មាត្រា ៧៦.-**

គោលការណ៍ស្តីពីការចុះបញ្ជី ត្រូវបានកំណត់ដូចតទៅ :

១- បុគ្គលជាប់អាករដូចមានចែងក្នុងមាត្រា៥៩ នៃច្បាប់នេះ ត្រូវធ្វើការចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែមឱ្យបានស្របចាប់ក្នុងរយៈពេល៣០ថ្ងៃក្រោយថ្ងៃដែលបុគ្គលនោះក្លាយជាបុគ្គលជាប់អាករ ។ វិធាននិងនីតិវិធីសម្រាប់ការចុះបញ្ជីនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

២- ចំពោះបុគ្គលដែលមានការតម្រូវឱ្យធ្វើការចុះបញ្ជី ហើយដែលមិនបានធ្វើការចុះបញ្ជីនោះ រដ្ឋបាលសារពើពន្ធអាចធ្វើការចុះបញ្ជីបុគ្គលនោះ ចាប់តាំងពីពេលដែលបុគ្គលនោះត្រូវមកធ្វើការចុះបញ្ជី ។ បុគ្គលដែលត្រូវបានចុះបញ្ជីតាមបែបនេះ ត្រូវមានការទទួលខុសត្រូវចំពោះប្រាក់អាករទាំងអស់ក្នុងមាត្រា៦៤ នៃច្បាប់នេះ ចាប់តាំងពីកាលបរិច្ឆេទដែលបុគ្គលនោះត្រូវមកធ្វើការចុះបញ្ជី ។

៣- បើសិនជាបុគ្គលជាប់អាករណាមួយដែលបានចុះបញ្ជីតាមមាត្រានេះ យល់ឃើញថាខ្លួនមិនត្រូវជាបុគ្គលជាប់អាករសម្រាប់ឆ្នាំចរន្តនិងឆ្នាំបន្ទាប់ទេ បុគ្គលនោះអាចដាក់ពាក្យសុំលុបការចុះបញ្ជីវិញ ។

៤- សម្រាប់ក្រុមបុគ្គលនាក់និង ២នាក់ឬច្រើននាក់ ដែលក្នុងនោះបុគ្គលម្នាក់ឬច្រើននាក់ មិនមែនជាបុគ្គលជាប់អាករនោះ រដ្ឋបាលសារពើពន្ធអាចចាត់ទុកបុគ្គលជាប់អាករណាមួយថាបានចុះបញ្ជីសម្រាប់សកម្មភាពសេដ្ឋកិច្ច

ទាក់ទិនទាំងមូលឬភាគណាមួយ ។ បើសិនជាក្នុងបុគ្គលទាក់ទិនណាម្នាក់ជាបុគ្គលជាប់អាករនោះ រដ្ឋបាលសារពើពន្ធអាចចុះបញ្ជីនូវបុគ្គលក្នុងក្រុម ម្នាក់ឬច្រើននាក់ សម្រាប់សកម្មភាពសេដ្ឋកិច្ចទាក់ទិនទាំងមូលឬភាគណាមួយ ។

៥- សម្រាប់គោលដៅនៃការចុះបញ្ជីនិងដោយមានការយល់ព្រមពីរដ្ឋបាលសារពើពន្ធផង ចំពោះបុគ្គលជាប់អាករមួយក្រុមដែលជាប់ទាក់ទិនគ្នាដូចមានចែងក្នុងមាត្រា៥៦ នៃច្បាប់នេះ សកម្មភាពរបស់សមាជិកនានានៅក្នុងក្រុមអាចចាត់ទុកជាសកម្មភាពរបស់សមាជិកជ្រើសតាំងតែម្នាក់ប៉ុណ្ណោះ ។ ក្នុងករណីនេះសមាជិកម្នាក់ៗនៅក្នុងក្រុមត្រូវមានការទទួលខុសត្រូវរួមគ្នានិងយ៉ាងពេញលេញចំពោះការប្រតិបត្តិតាមបទបញ្ញត្តិនៃជំពូកនេះ ។

**មាត្រា ៧៧.-**

គោលការណ៍ស្តីពីវិក្កយបត្រអាករលើតម្លៃបន្ថែម ត្រូវបានកំណត់ដូចតទៅ :

១- បុគ្គលជាប់អាករដែលធ្វើការផ្គត់ផ្គង់ ត្រូវចេញវិក្កយបត្រអាករលើតម្លៃបន្ថែមដែលមានចុះលេខរៀងត្រឹមត្រូវឱ្យទៅអ្នកទិញ ។

២- វិក្កយបត្រដែលកថាខណ្ឌ១ នៃមាត្រានេះ បានតម្រូវឡើងសម្រាប់ការផ្គត់ផ្គង់ណាមួយ ត្រូវដាក់ចំណងជើងថា "វិក្កយបត្រអាករលើតម្លៃបន្ថែម ហើយត្រូវមានចុះនិទ្ទេសដូចតទៅ :

ក. ឈ្មោះនិងលេខចុះបញ្ជីរបស់អ្នកលក់

ខ. កាលបរិច្ឆេទចេញវិក្កយបត្រ

គ. ឈ្មោះរបស់អ្នកទិញឬរបស់និយោជិតឬភ្នាក់ងាររបស់អ្នកទិញ

ឃ. បរិមាណ សេចក្តីបរិយាយនិងថ្លៃលក់ ទំនិញឬសេវា

ង. តម្លៃសរុបដែលមិនទាន់គិតអាករពិសេសលើទំនិញនិងសេវាមួយចំនួន ហើយនិងអាករលើតម្លៃបន្ថែម

ច. តម្លៃជាប់អាករសរុប បើសិនជាខុសគ្នាពីចំនួនទឹកប្រាក់នៅក្នុងវាក្យខណ្ឌ ង នៃកថាខណ្ឌនេះ

ឆ. ប្រាក់អាករត្រូវបង់

ជ. កាលបរិច្ឆេទនៃការផ្គត់ផ្គង់ទំនិញឬសេវា បើសិនជាខុសគ្នាពីកាលបរិច្ឆេទចេញវិក្កយបត្រ ។

៣- បុគ្គលទាំងឡាយមិនអាចចេញវិក្កយបត្រ ឬឯកសារផ្សេងទៀតបញ្ជាក់នូវទឹកប្រាក់ណាមួយថាជាប្រាក់អាករលើការផ្គត់ផ្គង់ទំនិញឬសេវាបានទេ លើកលែងតែបុគ្គលនោះជាបុគ្គលជាប់អាករបានចុះបញ្ជីស្របតាមមាត្រា៧៧ នៃច្បាប់នេះ ហើយទំនិញឬសេវាផ្គត់ផ្គង់ គឺជាទំនិញឬសេវាជាប់អាករ ។

៤- ក្រៅអំពីទោសទណ្ឌដទៃទៀត បើសិនជាវិក្កយបត្រណាមួយត្រូវបានប្រកាសអះអាងដោយក្លែងបន្លំថាជាវិក្កយបត្រអាករលើតម្លៃបន្ថែម ហើយវិក្កយបត្រនោះបានបង្ហាញថាមានទឹកប្រាក់អាករមួយចំនួនត្រូវបង់ បុគ្គលអ្នកចេញវិក្កយបត្រត្រូវបង់ជូនរដ្ឋបាលសារពើពន្ធ ក្នុងរយៈពេលប្រាំពីរថ្ងៃក្រោយកាលបរិច្ឆេទចេញវិក្កយបត្រនូវទឹកប្រាក់ដែលបានចុះលើវិក្កយបត្រនោះ នោះបីជាទឹកប្រាក់អាករត្រូវបង់មែនឬមិនមែនក្តី ។

៥- ក្នុងករណីមានការលក់រាយដែលក្នុងនោះការលក់ភាគច្រើនមិនបានធ្វើជាមួយបុគ្គលជាប់អាករ វិក្កយបត្រដែលតម្រូវដោយកថាខណ្ឌ១ នៃមាត្រានេះ ត្រូវចាត់ទុកថាបានបំពេញគ្រប់គ្រាន់ បើសិនជាអ្នកលក់ផ្តល់បង្កាន់ដៃទទួលប្រាក់លំអិតសម្រាប់បញ្ជីបេឡាឬក៏ឯកសារផ្សេងទៀត ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៦- ចំពោះការនាំចូល ប្រតិវេទន៍គយដែលបានបំពេញត្រឹមត្រូវនិងដែលមានសេចក្ដីបញ្ជាក់អំពីការបង់ប្រាក់អាករ ត្រូវប្រើប្រាស់ជាឯកសារត្រួតពិនិត្យដើម្បីកំណត់លក្ខណៈអាចទទួលបាននូវឥណទានអាករ ។

**មាត្រា ៧៨.-**

ការមិនបានចេញវិក្កយបត្រអាករលើតម្លៃបន្ថែម ត្រូវរងទោសទណ្ឌដូចតទៅ ៖

១- ក្រៅអំពីទោសទណ្ឌដទៃទៀត បើសិនជារដ្ឋបាលសារពើពន្ធរកឃើញជាលើកទី២ថា គ្រឹះស្ថានណាមួយរបស់បុគ្គលជាប់អាករ មិនបានចេញវិក្កយបត្រតាមការតម្រូវនោះ រដ្ឋបាលសារពើពន្ធអាចបិទគ្រឹះស្ថាននោះក្នុងរយៈពេលមានកំណត់មួយដែលមិនលើសពីប្រាំពីរថ្ងៃ ។

២- បើសិនជាគ្រឹះស្ថានណាមួយ ដែលធ្លាប់ត្រូវបានបិទដូចក្នុងកថាខណ្ឌ១ នៃមាត្រានេះ នៅតែប្រព្រឹត្តបទល្មើសបែបនោះជាថ្មីទៀត គ្រឹះស្ថាននោះអាចត្រូវបានបិទជាថ្មីទៀត ក្នុងរយៈពេលមានកំណត់មួយដែលមិនលើសពីប្រាំពីរថ្ងៃ ។

**មាត្រា ៧៩.-**

គោលការណ៍ស្ដីពីបញ្ជីកំណត់ត្រាពត៌មាន សម្រាប់អាករលើតម្លៃបន្ថែមត្រូវបានកំណត់ដូចតទៅ ៖

១- សម្រាប់គោលដៅបទប្បញ្ញត្តិទាំងឡាយក្នុងជំពូកនេះ បុគ្គលជាប់អាករត្រូវរក្សាទុកនូវច្បាប់ចម្លងវិក្កយបត្រទាំងអស់ដែលបានធ្វើចេញនិងវិក្កយបត្រទាំងអស់ដែលបានទទួល ។

២- បុគ្គលជាប់អាករត្រូវកត់ត្រានិងរក្សាទុកឱ្យបានត្រឹមត្រូវ នូវបញ្ជី កំណត់ត្រានៃរាល់កិច្ចការជំនួញដែលបានធ្វើ ហើយត្រូវមានគណនីតាមដានទឹកប្រាក់អាករដែលបានប្រមូលលើការលក់និងទឹកប្រាក់អាករដែលបានបង់លើការទិញទំនិញរបស់ខ្លួន ព្រមទាំងសេចក្ដីកែតម្រូវផ្សេងៗលើតម្លៃលក់ឬទឹកប្រាក់អាករ នៅតាមបែបបទដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ ។

៣- កិច្ចការដូចមានចែងក្នុងកថាខណ្ឌ២ នៃមាត្រានេះ ត្រូវធ្វើប្រចាំថ្ងៃ ហើយត្រូវធ្វើការបូកសរុបនិងគណនាសមតុល្យនៅចំណាច់ខែនីមួយៗ ។ បុគ្គលជាប់អាករត្រូវធ្វើជារៀងរាល់ខែ នូវសម្រង់អាករលើតម្លៃបន្ថែមនៅតាមបែបបទកំណត់ដោយរដ្ឋបាលសារពើពន្ធ ។

៤- វិក្កយបត្រ កំណត់ត្រានិងឯកសារផ្សេងទៀត ដែលជាប់ទាក់ទងនឹងអាករនេះ ត្រូវរក្សាទុកតាមលំដាប់ថ្ងៃខែ តាមបែបបទនិងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់ក្នុងរយៈពេល១០ឆ្នាំយ៉ាងតិចក្រោយការបញ្ចប់កិច្ចការជំនួញចុងក្រោយបំផុត ដែលជាប់ទាក់ទងនឹងឯកសារទាំងនេះ ។

៥- ឯកសារនិងកំណត់ត្រាទាំងអស់ដែលត្រូវរក្សាទុកតាមមាត្រានេះ ហើយនិងឯកសារនិងកំណត់ត្រាឯទៀត ដែលទាក់ទងនឹងអាជីវកម្មរបស់បុគ្គល ត្រូវផ្ដល់ឱ្យរដ្ឋបាលសារពើពន្ធត្រួតពិនិត្យនៅពេលមានសំណើ ។

**មាត្រា ៨០.-**

បទប្បញ្ញត្តិនានានៃជំពូកនេះ ដែលទាក់ទងនឹងការនាំចូលត្រូវគ្រប់គ្រងដោយទីចាត់ការគយនិងរដ្ឋាករ នៅតាមបែបបទដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨១.-**

វិធាននៃការបញ្ឈប់អាជីវកម្ម ត្រូវបានកំណត់ដូចតទៅ ៖

១- ក្នុងរយៈពេល១០ថ្ងៃ ក្រោយការបញ្ឈប់អាជីវកម្មដែលបុគ្គលជាប់អាករបានធ្វើការ[illegible] បុគ្គលនោះត្រូវដាក់លិខិតប្រកាសមួយនៅតាមទម្រង់ដែលបានកំណត់ ជូនរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកជាមួយនូវ[illegible]

លំអិតអំពីការលក់និងការទិញនានា ក្រោយពីការ ប្រកាសសារពើពន្ធចុងក្រោយបំផុតនិងពត៌មានលំអិតអំពីទំនិញទាំងអស់នៅក្នុងស្តុកដែលមិនទាន់បង់អាករឬដែលបានទទួលឥណទានអាកររួចហើយ ព្រមទាំងបង់ប្រាក់អាករដល់កំណត់ទាំងនោះ ។

២- វិធាននិងនីតិវិធី សម្រាប់ការបញ្ឈប់អាជីវកម្ម ការលុបឈ្មោះពីបញ្ជី ហើយនិងការទទួលខុសត្រូវរបស់អ្នកតំណាងតាមផ្លូវការ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨២.-**

ការផ្ទេរអាជីវកម្មពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតស្របតាមល័ក្ខខ័ណ្ឌដែលត្រូវកំណត់ដោយអនុក្រឹត្យមិនត្រូវជាប់អាករលើតម្លៃបន្ថែមទេ ។ វិធាននិងនីតិវិធីនៃការជូនដំណឹងអំពីការផ្ទេរ ការចុះបញ្ជីរបស់បុគ្គលអ្នកទទួលអាជីវកម្ម ការទទួលខុសត្រូវរបស់បុគ្គលអ្នកផ្ទេរអាជីវកម្ម ការទទួលខុសត្រូវរបស់បុគ្គលអ្នកទទួលអាជីវកម្មនិងកិច្ចរក្សាកំណត់ត្រាផ្សេងៗ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨៣.-**

គោលការណ៍អនុវត្តចំពោះកិច្ចសន្យាដែលបានធ្វើមុនកាលបរិច្ឆេទចូលជាធរមាននៃអាករ ត្រូវបានកំណត់ដូចតទៅ :

១- ត្រូវដាក់ឱ្យអនុវត្តនូវអាករតាមមាត្រា៥៥ នៃច្បាប់នេះ លើការផ្គត់ផ្គង់ជាប់អាករនានា ក្រោមកិច្ចសន្យាដែលបានធ្វើឡើងមុនកាលបរិច្ឆេទចូលជាធរមាននៃអាករនេះ បើសិនជាការផ្គត់ផ្គង់ត្រូវបានធ្វើឡើងនៅចំឬនៅក្រោយកាលបរិច្ឆេទចូលជាធរមាននៃអាករ ។

២- ចំពោះការផ្គត់ផ្គង់ជាប់អាករដូចមានចែងក្នុងកថាខ័ណ្ឌ១នៃមាត្រានេះ ប្រាក់អាករលើតម្លៃបន្ថែមដែលបានកត់ត្រាក្រៅពីកិច្ចសន្យា ត្រូវចាត់ទុកជាសំណងបន្ថែមចំពោះមុខទំនិញឬសេវាដែលបានទិញនិងជាកាតព្វកិច្ចតាមផ្លូវច្បាប់របស់អ្នកទិញចំពោះអ្នកលក់ ។

**មាត្រា ៨៤.-**

ឥណទានអាករចំពោះទំនិញស្តុកត្រូវបានកំណត់ដូចតទៅ :

១- ចំពោះបុគ្គលទើបបានចុះបញ្ជី ហើយនៅថ្ងៃចុះបញ្ជីនោះ មានស្តុកទំនិញដែលបានបង់អាករលើតម្លៃបន្ថែមឬអាករលើផលរបររួចហើយ បុគ្គលនោះអាចដាក់ពាក្យសុំឱ្យរដ្ឋបាលសារពើពន្ធអនុញ្ញាតនូវឥណទានអាករចំពោះប្រាក់អាករដែលបានបង់លើស្តុកទាំងនោះ បន្ទាប់ពីរដ្ឋបាលសារពើពន្ធបានត្រួតពិនិត្យឃើញថាវិក្កយប័ត្រឬច្បាប់ចម្លងនៃប្រតិវេទន៍គយរបស់ទំនិញទាំងនោះមានលក្ខណៈត្រឹមត្រូវ ។

២- បើមានការឯកភាពចំពោះលក្ខណៈត្រឹមត្រូវនៃឯកសារទាំងនោះហើយ រដ្ឋបាលសារពើពន្ធអាចអនុញ្ញាតនូវឥណទានអាករ ចំពោះការផ្គត់ផ្គង់ដែលបានធ្វើក្នុងអំឡុង៦០ថ្ងៃ មុនថ្ងៃចុះបញ្ជី ឬមុនថ្ងៃដែលច្បាប់នេះចូលជាធរមាន ។ ឥណទានអាករនេះអាចយកទៅប្រើក្នុងប្រកាសសារពើពន្ធទាំងឡាយសម្រាប់អាករនេះ ទៅតាមល័ក្ខខ័ណ្ឌដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ ។

អគ្គនាយកដ្ឋាន ពន្ធដារ

# ជំពូកទី៤

## វិសោធនកម្មលើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ១៩៩៤ និងលើ
## ច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥

### ផ្នែកទី១

### បទប្បញ្ញត្តិស្តីពីការកែប្រែអាករពិសេសលើទំនិញមួយចំនួន
### មកជាអាករពិសេសលើទំនិញនិងសេវាមួយចំនួន

**មាត្រា ៨៥.-**

ចាប់ពីថ្ងៃប្រកាសឱ្យប្រើច្បាប់នេះ អាករពិសេសលើទំនិញមួយចំនួននៃច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៩៩៧/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ត្រូវហៅថា "អាករពិសេសលើទំនិញនិងសេវាមួយចំនួន"វិញ ហើយមាត្រាមួយចំនួនត្រូវបានធ្វើវិសោធនកម្ម ដូចមានចែងក្នុងជំពូកនេះ ។

មាត្រា១៨ នៃច្បាប់ដូចយោងខាងលើ ត្រូវបានកែប្រែដូចតទៅ :

- ៣០ភាគរយ សម្រាប់រថយន្តដែលមានបញ្ជាក់ក្នុងតារាងពន្ធគយ លេខសំគាល់៨៧.០៣ ដែលមានស៊ីឡាំងទ្រធំជាង ២.០០០cc ព្រមទាំងគ្រឿងបន្លាស់សម្រាប់ប្រភេទរថយន្តទាំងនេះ:
- ២០ភាគរយ សម្រាប់ផលិតផលពេលសិលា និងរថយន្ត ដែលមានបញ្ជាក់ក្នុងតារាងពន្ធគយ លេខសំគាល់ ៨៧.០៣ ដែលមានស៊ីឡាំងទ្រពី ២.០០០ cc ចុះក្រោម ព្រមទាំងគ្រឿងបន្លាស់សម្រាប់ប្រភេទរថយន្តទាំងនេះ:
- ១០ភាគរយ សម្រាប់ភេសជ្ជៈ បារីគ្រប់ប្រភេទ សណ្ឋាគារនិងសេវាលំហែកំសាន្តផ្សេងៗ ព្រមទាំងយានយន្តគ្រប់ប្រភេទនិងគ្រឿងបន្លាស់ ដែលមានបញ្ជាក់ក្នុងតារាងពន្ធគយ លេខសំគាល់ ៨៧.០២ ៨៧០៤-២១ ដល់ ៨៧០៤-៩០ ៨៧០៦ ៨៧០៨ ៨៧១៤និង៨៧១១ ដែលមានស៊ីឡាំងទ្រចាប់ពី ១២៥cc ឡើងទៅ
- ២ភាគរយ សម្រាប់ថ្លៃលក់សំបុត្រក្នុងស្រុក លើការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស ពីក្នុងព្រះរាជាណាចក្រកម្ពុជាទៅបរទេស សេវាទូរគមនាគមន៍ពីក្នុងព្រះរាជាណាចក្រកម្ពុជា ទៅបរទេស ។

ពាក្យ "ថ្លៃលក់កត់ត្រាក្នុងវិក្កយប័ត្រ" ក្នុងកថាខ័ណ្ឌ២ នៃមាត្រា២១ នៃច្បាប់ដូចយោងខាងលើ ត្រូវបានកែប្រែជា "ថ្លៃលក់ចេញពីរោងចក្រកត់ត្រាក្នុងវិក្កយប័ត្រ" ។

បន្ថែមកថាខ័ណ្ឌខាងក្រោមក្នុងមាត្រា២១ នៃច្បាប់ដូចយោងខាងលើ :

"៣- សេវាផ្តល់ជូនទៅព្រះរាជាណាចក្រកម្ពុជា គឺថ្លៃក្នុងវិក្កយប័ត្រនៃសេវាដែលបានផ្តល់ជូន"

ពាក្យ "ចំពោះទំនិញផលិត" ក្នុងកថាខ័ណ្ឌ២ ក្នុងមាត្រា២២ នៃច្បាប់ដូចយោងខាងលើ ត្រូវបានកែប្រែជា "ចំពោះទំនិញផលិតនិងសេវាផ្តល់ជូន"

បន្ថែមកថាខណ្ឌខាងក្រោមក្នុងមាត្រា២៣ នៃច្បាប់ដូចយោងខាងលើ ៖

"៣- អ្នកផ្គត់ផ្គង់ ចំពោះសេវាផ្គត់ផ្គង់នៅព្រះរាជាណាចក្រកម្ពុជា" ។

បន្ថែមកថាខណ្ឌខាងក្រោមក្នុងមាត្រា២៤ នៃច្បាប់ដូចយោងខាងលើ ៖

"៣- ចំពោះសេវាទូរគមនាគមន៍និងដឹកជញ្ជូន នៅព្រះរាជាណាចក្រកម្ពុជា ត្រូវមានបញ្ជីដោយឡែកដែលមានចុះកាលបរិច្ឆេទនិងតម្លៃនៃសេវាដែលបានផ្គត់ផ្គង់ពីចំណុចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទៅចំណុចនៅក្រៅព្រះរាជាណាចក្រកម្ពុជា" ។

## ផ្នែកទី២

## បទប្បញ្ញត្តិស្តីពីការកែប្រែអាករលើផលរបរ

**មាត្រា ៤៦.-**

អាករលើផលរបរ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ត្រូវបានកែប្រែដូចតទៅ ៖

១- លុបកថាខណ្ឌ២ ក្នុងមាត្រា៣៩ នៃច្បាប់ដូចយោងខាងលើ ។

២- ពាក្យ "តម្លៃក្រៅគយ" ក្នុងមាត្រា៤៦ នៃច្បាប់ដូចយោងខាងលើ ត្រូវបានកែប្រែជា "តម្លៃមានពន្ធគយនិងអាករពិសេសលើទំនិញនិងសេវាមួយចំនួន" ។

៣- បន្ថែមកថាខណ្ឌខាងក្រោម ក្នុងមាត្រា៤៧ នៃច្បាប់ដូចយោងខាងលើ ៖

"នាយកដ្ឋានពន្ធដារអាចប្រមូលអាករលើការប្រើប្រាស់និងអនុវត្តទោសទណ្ឌលើរាល់ទំនិញដែលដាក់លក់នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលអ្នកលក់ពុំមានឯកសារបញ្ជាក់គ្រប់គ្រាន់ថាបានបង់អាករលើការប្រើប្រាស់នៅពេលនាំចូល" ។

៤- បន្ថែមកថាខណ្ឌ ង ដូចខាងក្រោម ក្នុងមាត្រា៤៩ នៃច្បាប់ដូចយោងខាងលើ ៖

"ង- ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៧ តទៅ អ្នកជាប់ពន្ធទាំងអស់ត្រូវ ៖

- ប្រើវិធាននៃពេលផ្គត់ផ្គង់ ដូចមានចែងក្នុងមាត្រា៦២ នៃច្បាប់នេះដែលចែងអំពីអាករលើតម្លៃបន្ថែម ដើម្បីកំណត់កាលបរិច្ឆេទដែលអាករត្រូវក្លាយជាបំណុលរបស់អ្នកជាប់ពន្ធ ចំពោះរដ្ឋ ។
- ចេញវិក្កយប័ត្រស្របតាមវិធាននិងនីតិវិធីដូចមានចែងក្នុងមាត្រា៦២ នៃច្បាប់នេះ ដែលចែងអំពីអាករលើតម្លៃបន្ថែម ។
- ចាត់ទុកថាបានរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ និងទទួលរងទោសទណ្ឌតាមមាត្រា១៣៣ នៃច្បាប់នេះ ក្នុងករណីមិនប្រតិបត្តិតាមមាត្រា៤៩ កថាខណ្ឌ ង នេះ" ។

៥- ក្នុងច្បាប់ស្តីពីការកែសម្រួលនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ត្រូវបន្ថែមមួយកថាខណ្ឌក្នុងមាត្រា៣៣ ថា ៖

ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៨ តទៅ ៖

- អ្នកជាប់ពន្ធតាមរបបពិតប្រាកដ មិនត្រូវជាប់អាករលើផលរបរទេ

- អ្នកជាប់ពន្ធតាមរបបផ្សេងទៀត ត្រូវជាប់អាករលើផលរបរតាមអត្រា ២ភាគរយ

- មាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ មាត្រា៤៧និងមាត្រា៤៨ នៃច្បាប់ស្តីអំពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ១៩៩៤ និងមាត្រា៣៧ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ត្រូវទុកជានិរាករណ៍ ។

# ជំពូកទី៩
# បទប្បញ្ញត្តិស្តីពីរដ្ឋបាលនិងនីតិវិធីសារពើពន្ធ

## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៨៧.-**

ត្រូវបានបង្កើតដោយបទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះ នូវសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធនិងរបស់រដ្ឋបាលសារពើពន្ធ នីតិវិធីនៃការពិនិត្យឡើងវិញនូវប្រាក់ពន្ធបានបង់ នីតិវិធីដោះស្រាយវិវាទបទល្មើសនិងទោសទណ្ឌសារពើពន្ធ ។

បទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះ ត្រូវអនុវត្តចំពោះពន្ធគ្រប់ប្រភេទ លើកលែងតែពន្ធដោយឡែកណាមួយដែលមានចែងផ្សេង ។

**មាត្រា ៨៨.-**

សម្រាប់គោលដៅនៃជំពូកនេះ :

១- ពាក្យ "ពន្ធ" មានន័យថា ពន្ធនិងអាករទាំងឡាយ ។

២- ពាក្យ "បុគ្គល" មានន័យថា រូបវន្តបុគ្គលឬនីតិបុគ្គល ។

៣- ពាក្យ "អ្នកជាប់ពន្ធ" មានន័យថាជាបុគ្គលដែលមានកាតព្វកិច្ចត្រូវបង់ពន្ធ ។

៤- ពាក្យ "រដ្ឋបាលសារពើពន្ធ" មានន័យថាជាអង្គការចាត់តាំងនៃនាយកដ្ឋានពន្ធដារ ។

៥- ពាក្យ "លិខិតប្រកាសសារពើពន្ធ" មានន័យថាជាឯកសារដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានតម្រូវឱ្យអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក បំពេញទៅតាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងច្បាប់នេះ ។

៦- ពាក្យ "ភ្នាក់ងារកាត់ទុក" មានន័យថាជាបុគ្គលដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យធ្វើការកាត់ទុកនិងបង់ប្រាក់ពន្ធចូលថវិកាក្នុងនាមនៃតតិយជន ។

៧- ពាក្យ "សកម្មភាពសេដ្ឋកិច្ច" មានន័យថាជាសកម្មភាពរបស់បុគ្គលដែលធ្វើជានិច្ចកាលជាប់បន្តឬមួយដងមួយគ្រា ដើម្បីរកឬមិនរកចំណេញ ក្នុងការផ្គត់ផ្គង់ឬមានបំណងផ្គត់ផ្គង់ទំនិញឬសេវាឱ្យដល់បុគ្គលដទៃ ក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ ។

**មាត្រា ៤៩.-**

បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងអន្តរជាតិទាក់ទិននឹងបញ្ហាពន្ធ ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយ ត្រូវមានវិសាលភាពគ្របដណ្តប់លើបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៥០.-**

លិខិតប្រកាសសារពើពន្ធទាំងអស់ ក៏ដូចជាឯកសារនិងលិខិតទាក់ទងផ្សេងៗ ដែលចាំបាច់សម្រាប់ការកំណត់ពន្ធ ការប្រមូលពន្ធនិងការបង្ខំឱ្យប្រតិបត្តិតាមច្បាប់ពន្ធឬដែលជាប់ទាក់ទងនឹងបែបបទផ្សេងទៀតក្នុងការកំណត់ពន្ធ ត្រូវធ្វើជាភាសាខ្មែរ ។

## ផ្នែកទី២

## សិទ្ធិនិងភារកិច្ច

**មាត្រា ៥១.-**

សិទ្ធិនិងភារកិច្ចរបស់អ្នកជាប់ពន្ធ ត្រូវបានកំណត់ដូចតទៅ :

១- អ្នកជាប់ពន្ធមានសិទ្ធិដូចតទៅ :

ក. ត្រូវបានទុកជាការសម្ងាត់ ហើយត្រូវបានយកមកប្រើប្រាស់តែក្នុងគោលដៅដែលមានបញ្ជាក់នៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ នូវព័ត៌មានទាំងឡាយទាក់ទិននឹងកិច្ចការអាជីវកម្មរបស់ខ្លួនដែលបានផ្តល់ឱ្យរដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងមាត្រា៩៤ នៃច្បាប់នេះ ។

ខ. ទទួលព័ត៌មានជាប្រចាំអំពីកិច្ចដំណើរការនៃប្រព័ន្ធពន្ធដារ ហើយនិងនីតិវិធីនៃការកំណត់ពន្ធ ដូចមានចែងក្នុងមាត្រា៩៦ និងមាត្រា១១៨ នៃច្បាប់នេះ ។

គ. ទទួលព័ត៌មានអំពីសិទ្ធិរបស់ខ្លួនរួមទាំងសិទ្ធិក្នុងការប្តឹងតវ៉ា ដូចមានចែងក្នុងមាត្រា១១៨ និងមាត្រា១២២ នៃច្បាប់នេះ ។

ឃ. ប្តឹងតវ៉ាដូចមានចែងនៅក្នុងច្បាប់នេះ ចំពោះរាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងមាត្រា១១៨ និងមាត្រា១២២ នៃច្បាប់នេះ ។

ង. បង់ពន្ធមិនឱ្យលើសពីបទប្បញ្ញត្តិស្តីពីពន្ធដារកំណត់ដូចមានចែងក្នុងមាត្រា១០៧នៃច្បាប់នេះ។

២- អ្នកជាប់ពន្ធមានភារកិច្ចដូចតទៅ :

ក. ចុះឈ្មោះក្នុងបញ្ជីរបស់រដ្ឋបាលសារពើពន្ធ ដូចមានចែងនៅក្នុងមាត្រា១០១នៃច្បាប់នេះ។

ខ. ដាក់លិខិតប្រកាសសារពើពន្ធ និងផ្តល់ព័ត៌មានតាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា៩៨ និងមាត្រា១០៤ នៃច្បាប់នេះ ។

គ. បង់ពន្ធតាមកាលបរិច្ឆេទកំណត់ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ។

ឃ. កាន់កាប់ ថែរក្សានិងត្រូវបង្ហាញបញ្ជី លិខិតយុត្តិកានិងឯកសារផ្សេងៗ ដល់រដ្ឋបាលសារពើពន្ធ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ និងមាត្រា៩៨ នៃច្បាប់នេះ ។

ង. បង្ហាញខ្លួនចំពោះរដ្ឋបាលសារពើពន្ធតាមកាលបរិច្ឆេទដែលមានចុះនៅក្នុងលិខិតអញ្ជើញរបស់រដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងមាត្រា៩៩ នៃច្បាប់នេះ ។

ច. បង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែមនិងការប្រាក់ផ្សេងៗ ដែលរដ្ឋបាលសារពើពន្ធបានកំណត់ទៅតាមកាលបរិច្ឆេទ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ឬដែលរដ្ឋបាលសារពើពន្ធបានជូនដំណឹងជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ និងមាត្រា១០៧ មាត្រា១៣០ មាត្រា១៣១ និងមាត្រា១៣២ នៃច្បាប់នេះ ។

**មាត្រា ៩២.-**

អំណាចរបស់រដ្ឋបាលសារពើពន្ធមានដូចខាងក្រោមនេះ :

១. កំណត់មូលដ្ឋានគិតពន្ធ លើអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា១១៦ និងមាត្រា១១៧ នៃច្បាប់នេះ ។

២. តម្រូវឱ្យអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកបង្ហាញខ្លួន ដូចមានចែងក្នុងមាត្រា៩៩ នៃច្បាប់នេះ ។

៣. កំណត់បញ្ជី ឯកសារចាំបាច់នានានិងលិខិតយុត្តិការ ដែលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកត្រូវកាន់រក្សាទុកនិងផ្តល់ជូនរដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងមាត្រា៩៨ និងមាត្រា១០០ នៃច្បាប់នេះ ។

៤. ទាមទារឱ្យអ្នកជាប់ពន្ធ ឬកតិយជនផ្តល់ព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា៩៩ នៃច្បាប់នេះ ។

៥. ចូលទៅដ្ឋានឬគ្រឹះស្ថានអាជីវកម្មរបស់អ្នកជាប់ពន្ធ ភ្នាក់ងារកាត់ទុកឬតតិយជន ដើម្បីទទួលបាននូវព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា១០០ នៃច្បាប់នេះ ។

៦. ទទួលពីស្ថាប័នរដ្ឋទាំងឡាយនូវព័ត៌មានស្តីពីឬដែលទាក់ទិននឹងអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា១១៦ នៃច្បាប់នេះ ។

៧. អនុវត្តវិធានការពិន័យចំពោះអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកនៅពេលដែលបុគ្គលនោះមិនបានបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែមនិងការប្រាក់ផ្សេងៗតាមការតម្រូវនៃច្បាប់នេះ ដូចមានចែងក្នុងមាត្រា១០៩ ដល់មាត្រា១១៥ នៃច្បាប់នេះ ។

៨. កំណត់ឡើងវិញនូវកិច្ចការជំនួញរវាងអ្នកជាប់ពន្ធទាំងឡាយដែលមានជាប់ទាក់ទង ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ។

រដ្ឋបាលសារពើពន្ធមានកាតព្វកិច្ចដូចតទៅ :

១. ប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗ ដូចមានចែងក្នុងមាត្រា៩៣ នៃច្បាប់នេះ ។

២. រក្សាការសម្ងាត់នូវព័ត៌មាន ដែលអ្នកជាប់ពន្ធឬតតិយជនបានផ្តល់ឱ្យ ហើយផ្តល់ព័ត៌មានទាំងនេះអោយដល់តែបុគ្គលណាដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់ប៉ុណ្ណោះ ដូចមានចែងក្នុងមាត្រា៩៤ មាត្រា១២៨និងមាត្រា១៣៨ នៃច្បាប់នេះ ។

៣. ផ្តល់ព័ត៌មានដល់អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក សំដៅធានាឱ្យការអនុវត្តបានសមស្របទៅតាមបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា៩៦ នៃច្បាប់នេះ ។

៤. បង្វិលសងវិញ ឬទាត់ជាឥណទានពន្ធ នូវប្រាក់ពន្ធដែលបង់លើស ដូចដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ។

៥. ផ្តល់លិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឱ្យអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដូចមានចែងនៅក្នុងមាត្រា១១៦ ដល់ មាត្រា១១៨ នៃច្បាប់នេះ ។

## ផ្នែកទី៣

## រដ្ឋបាលសារពើពន្ធ

**មាត្រា ៩៣.-**

ស្ថាប័នទាំងឡាយដែលទទួលខុសត្រូវគ្រប់គ្រងការអនុវត្តបទបញ្ញត្តិស្តីពីពន្ធដារមានដូចខាងក្រោម :

- នាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាលដែលបទបញ្ញត្តិស្តីពីពន្ធដារបានផ្តល់អំណាចឱ្យ ។

រដ្ឋបាលសារពើពន្ធមានភារកិច្ចប្រមូលពន្ធ អនុវត្តទោសទណ្ឌតាមការកំណត់នៃបទបញ្ញត្តិស្តីពីពន្ធដារ និងប្តឹងទៅតុលាការ ក្នុងករណីមានការរំលោភច្បាប់ ។

**មាត្រា ៩៤.-**

រដ្ឋបាលសារពើពន្ធ ហើយនិងបុគ្គលគ្រប់រូបដែលជាឬធ្លាប់ជាមន្ត្រី និងភ្នាក់ងារនៃរដ្ឋបាលសារពើពន្ធ ត្រូវរក្សាសម្ងាត់នូវព័ត៌មានទាក់ទងនឹងអ្នកជាប់ពន្ធ ដែលបានទទួលនៅក្នុងពេលបំពេញភារកិច្ចជាផ្លូវការ ហើយអាចផ្តល់ព័ត៌មានទៅឱ្យតែបុគ្គលដែលមាត្រានេះបានអនុញ្ញាតប៉ុណ្ណោះ ។

មន្ត្រីនិងភ្នាក់ងារនៃរដ្ឋបាលសារពើពន្ធអាចផ្តល់ព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធឱ្យចំពោះតែ :

១. មន្ត្រីនិងភ្នាក់ងារផ្សេងទៀតរបស់រដ្ឋបាលសារពើពន្ធ នៅក្នុងពេលនិងក្នុងគោលដៅបំពេញភារកិច្ចតាមបទបញ្ញត្តិស្តីពីពន្ធដារ ។

២. អាជ្ញាធរព្រហ្មទណ្ឌ សម្រាប់គោលដៅប្តឹងចោទប្រកាន់អំពីបទល្មើសពន្ធដារ ។

៣. តុលាការ នៅក្នុងដំណាក់ការជំរះក្តី ដើម្បីកំណត់ពន្ធត្រូវបង់របស់អ្នកជាប់ពន្ធ ឬក៏ការទទួលខុសត្រូវចំពោះការរំលោភបទបញ្ញត្តិស្តីពីពន្ធដារ ។

៤. អាជ្ញាធរពន្ធដាររបស់ប្រទេសណាមួយទៀត ស្របតាមកិច្ចព្រមព្រៀងអន្តរជាតិ ។

បុគ្គលដែលបានទទួលព័ត៌មានពីបុគ្គលម្នាក់ទៀត ដែលបានការអនុញ្ញាតឱ្យផ្តល់ព័ត៌មាន ដូចមានចែងក្នុងកថាខ័ណ្ឌ២ នៃមាត្រានេះ ត្រូវរក្សាសម្ងាត់លើព័ត៌មាននោះទៅតាមការកំណត់នៃមាត្រានេះ លើកលែងតែកំរិតអប្បបរមាណាមួយដែលចាំបាច់ត្រូវអនុញ្ញាតឱ្យផ្តល់ព័ត៌មាននេះ ។

ព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធអាចផ្តល់ទៅឱ្យបុគ្គលម្នាក់ទៀតបាន បើសិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកជាប់ពន្ធ ។

**មាត្រា ៩៥.-**

លិខិតស្នាមឬការជូនដំណឹង ដែលរដ្ឋបាលសារពើពន្ធផ្តល់ទៅឱ្យអ្នកជាប់ពន្ធមានលក្ខណៈជាផ្លូវការធ្វើឱ្យអ្នកជាប់ពន្ធនោះមានភារកិច្ចចំពោះរដ្ឋបាលសារពើពន្ធ លុះណាតែលិខិតស្នាមឬការជូនដំណឹងនោះត្រូវបានធ្វើជាលាយលក្ខណ៍អក្សរនិងត្រូវបានប្រគល់ឱ្យដល់អ្នកជាប់ពន្ធ ។

ក្នុងករណីដែលបទបញ្ញត្តិស្តីពីពន្ធដារ តម្រូវឱ្យរដ្ឋបាលសារពើពន្ធផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរទៅឱ្យបុគ្គលលិខិតជូនដំណឹងនោះត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវ លុះណាតែលិខិតនោះត្រូវបានប្រគល់ឱ្យដោយផ្ទាល់ដល់បុគ្គលនោះ ឬក៏បានផ្ញើតាមប្រៃសណីយ៍ជាលិខិតអនុសិដ្ឋ ទៅអាស័យដ្ឋានតាមផ្លូវច្បាប់របស់បុគ្គលនោះ ។

កាលបរិច្ឆេទនៃការជូនដំណឹង ឬឯកសារផ្សេងៗ គឺជាកាលបរិច្ឆេទនៃការប្រគល់ឱ្យដល់ដៃបុគ្គល ។ ក្នុងករណីលិខិតជូនដំណឹងត្រូវបានផ្ញើតាមលិខិតអនុសិដ្ឋ កាលបរិច្ឆេទនៃការជូនដំណឹង គឺជាកាលបរិច្ឆេទនៃការបោះត្រាលើលិខិតអនុសិដ្ឋរបស់ការិយាល័យប្រៃសណីយ៍ ដែលលិខិតអនុសិដ្ឋនោះត្រូវបានទទួលដោយអ្នកជាប់ពន្ធ ។

លិខិតជូនដំណឹងត្រូវចាត់ទុកថាបានប្រគល់ទទួលត្រឹមត្រូវ កាលបើល័ក្ខខ័ណ្ឌក្នុងកថាខ័ណ្ឌ២ នៃមាត្រានេះ ត្រូវបានបំពេញរួចហើយ ទោះបីជាបុគ្គលដែលត្រូវបានជូនដំណឹងនោះបដិសេធការប្រគល់ដោយផ្ទាល់ឬដោយលិខិតអនុសិដ្ឋក្តី ។

ក្នុងករណីដែលអាស័យដ្ឋានរបស់បុគ្គលត្រូវបានផ្លាស់ប្តូរ ហើយបុគ្គលមិនបានជូនដំណឹងដល់រដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរនោះទេ លិខិតជូនដំណឹងដែលបានបញ្ជូនទៅអាស័យដ្ឋាន ដែលបានស្គាល់ចុងក្រោយបង្អស់ ត្រូវចាត់ទុកថាបានប្រគល់ទទួលត្រឹមត្រូវ ។

**មាត្រា ៩៦.-**

រដ្ឋបាលសារពើពន្ធត្រូវរៀបចំសៀវភៅពន្យល់ខ្លីៗ ស្តីពីខ្លឹមសារសំខាន់ៗនៃប្រភេទពន្ធនីមួយៗ ។

ចំពោះប្រភេទពន្ធណាមួយ ដែលរដ្ឋបាលសារពើពន្ធកំណត់ថា គួរចុះធ្វើការពន្យល់ណែនាំនោះ មន្ត្រីពន្ធដារនៅតាមមូលដ្ឋាន ត្រូវចុះអប់រំដល់អ្នកជាប់ពន្ធឱ្យបានយល់អំពីកាតព្វកិច្ចនិងសិទ្ធិរបស់អ្នកជាប់ពន្ធទាំងនោះ ។

**មាត្រា ៩៧.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកសាងប្រព័ន្ធលើកទឹកចិត្តមួយសម្រាប់មន្ត្រីភ្នាក់ងាររដ្ឋបាលសារពើពន្ធ។ នីតិវិធីសម្រាប់ដំណើរការប្រព័ន្ធលើកទឹកចិត្តនេះ ត្រូវកំណត់ដោយប្រកាស ។

**មាត្រា ៩៨.-**

អ្នកជាប់ពន្ធត្រូវកាន់កាប់ កត់ត្រានិងរក្សាទុកបញ្ជី លិខិតយុត្តិការនិងឯកសារហិរញ្ញវត្ថុផ្សេងៗ ដូចដែលបទបញ្ញត្តិស្តីពីពន្ធដារបានកំណត់និងត្រូវដាក់បញ្ជីនិងឯកសារទាំងនោះតាមការតម្រូវ ជូនរដ្ឋបាលសារពើពន្ធដើម្បីពិនិត្យ។

ចំពោះអ្នកជាប់ពន្ធដែលពុំមានកាតព្វកិច្ចកាន់កាប់បញ្ជីគណនេយ្យតាមប្លង់គណនេយ្យទូទៅនៃព្រះរាជាណាចក្រកម្ពុជា ត្រូវកាន់ទិន្នានុប្បវត្តិដោយកត់ត្រាចុះតាមលំដាប់ថ្ងៃ ខែ នូវចំណូលនិងចំណាយផ្សេងៗទាំងអស់ដែលទាក់ទិននិងអាជីវកម្មទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ ។

បុគ្គលដែលត្រូវកាន់កាប់ កត់ត្រាឬរក្សាទុកបញ្ជី ឯកសារទាក់ទងឬទិន្នានុប្បវត្តិ ដែលបានកំណត់ដោយបទបញ្ញត្តិស្តីពីពន្ធដារឬបទបញ្ញត្តិដទៃ ត្រូវរក្សាទុកបញ្ជីឬឯកសារទាំងនោះ ក្នុងរយៈពេល១០ឆ្នាំ គិតពីដំណាច់ឆ្នាំជាប់ពន្ធ ។

វិក្កយប័ត្រត្រូវតែចេញឱ្យលើរាល់កិច្ចការជំនួញរវាងអ្នកជាប់ពន្ធនិងបុគ្គលដទៃទៀត។ វិធាននិងខ្លឹមសារនៃវិក្កយប័ត្រ ត្រូវកំណត់ដោយអនុក្រឹត្យ ។

អ្នកជាប់ពន្ធត្រូវកត់ត្រាសេចក្តីរាយលំអិតនៃវិក្កយប័ត្រឱ្យបានត្រឹមត្រូវចូលក្នុងទិន្នានុប្បវត្តិ ។

**មាត្រា ៩៩.-**

ក្នុងគោលដៅកំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់ឬដើម្បីប្រមូលពន្ធ រដ្ឋបាលសារពើពន្ធអាចធ្វើ

លិខិតជូនដំណឹងដល់អ្នកជាប់ពន្ធឬតតិយជនឱ្យ :

ផ្តល់ព័ត៌មានដែលទាក់ទិននឹងអ្នកជាប់ពន្ធដូចមានចែងក្នុងលិខិតជូនដំណឹង ដូចជាព័ត៌មានស្តីពីអ្នកផ្គត់ផ្គង់ អតិថិជនឬគណនីនៅធនាគារ

- បង្ហាញខ្លួននៅកាលពេលវេលា និងទីកន្លែងដែលមានបញ្ជាក់នៅក្នុងលិខិតជូនដំណឹងដើម្បីផ្តល់ព័ត៌មាននិងដើម្បីបង្ហាញឬផ្តល់ឯកសារឬទិន្នន័យ ដល់បុគ្គលនោះគ្រប់គ្រង ដែលមានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងលិខិតជូនដំណឹង ។

បន្ថែមលើព័ត៌មានដែលបានតម្រូវដូចមានចែងនៅក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះ លិខិតជូនដំណឹងត្រូវមានចុះឈ្មោះនិងលេខអត្តសញ្ញាណកម្មនៃបុគ្គលអ្នកជាប់ពន្ធ (បើសិនជាមាន) ហើយនិងហត្ថលេខារបស់រដ្ឋបាលសារពើពន្ធដែលចេញលិខិតជូនដំណឹង ។

**មាត្រា ១០០.-**

ចំពោះមុខ សម្រាប់ការស៊ើបអង្កេតនីមួយៗដោយមានលិខិតបញ្ជាបេសកកម្ម រដ្ឋបាលសារពើពន្ធមានសិទ្ធិចូលទៅក្នុងគ្រឹះស្ថានអាជីវកម្ម ទីកន្លែងដែលបានចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្ម ជាកន្លែងដែលបើកជាសាធារណៈ ឬទីកន្លែងដទៃទៀត ដើម្បីធ្វើការកំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់ឬដើម្បីប្រមូលពន្ធ :

- នៅក្នុងពេលម៉ោងអាជីវកម្ម
- នៅគ្រប់ពេលទាំងអស់ស្របតាមល័ក្ខខ័ណ្ឌ និង ហេតុផលដែលមានបញ្ជាក់នៅក្នុងដីកាដែលចៅក្រមបានចេញអោយ ។

រដ្ឋបាលសារពើពន្ធដែលបានចូលដោយស្របច្បាប់ទៅក្នុងទីកន្លែង ដូចដែលមានចែងក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះ អាច :

- ធ្វើសម្រង់ឬចម្លងឯកសារនានាដែលស្ថិតនៅក្នុងកន្លែងនោះ
- រឹបអូស ឯកសារនានាឬវត្ថុតាងដទៃទៀត ដែលអាចក្លាយជាព័ត៌មានសម្រាប់កំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់
- ដាក់ឧបករណ៍សម្រាប់ត្រួតពិនិត្យផ្សេងៗឬបោះត្រាបិទសំគាល់ឃាត់ទុកទំនិញ បើសិនជាមានជាប់ទាក់ទងដល់ការអនុវត្តពន្ធណាមួយ
- ធ្វើសារពើភ័ណ្ឌទ្រព្យសកម្ម វត្ថុធាតុដើម ផលិតផលកំពុងផលិត ផលិតផលសម្រេចនិងស្តុកដទៃទៀត ។

រដ្ឋបាលសារពើពន្ធអាចតម្រូវឱ្យស្ថាប័នធនាគារដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ផ្តល់ព័ត៌មានអំពីគណនីរបស់អ្នកជាប់ពន្ធនៅធនាគារ ។

ពេលចូលទៅធ្វើការស៊ើបអង្កេត រដ្ឋបាលសារពើពន្ធត្រូវមានអាកប្បកិរិយាសមរម្យ ចៀសវាងប្រការដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយសនិងអាជីវកម្មរបស់អ្នកជាប់ពន្ធ ។ ទោះជាយ៉ាងណាក៏ដោយ ការស៊ើបអង្កេតដល់ទីកន្លែងនេះ ពុំត្រូវអនុវត្តឱ្យហួសកំរិតនៃការចាំបាច់ឡើយ ។

**មាត្រា ១០១.-**

បុគ្គលទាំងឡាយត្រូវតែទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងកំឡុង១៥ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ។

បុគ្គលទាំងឡាយត្រូវជូនដំណឹងទៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល១៥ថ្ងៃ ក្រោយពីការផ្លាស់ប្តូរអាស័យដ្ឋាន ទ្រង់ទ្រាយ ឧបករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់សហគ្រាស ។

**មាត្រា ១០២.-**

នៅពេលបានអនុវត្តការចុះបញ្ជីរួចរាល់ហើយ រដ្ឋបាលសារពើពន្ធត្រូវចេញនូវលិខិតបញ្ជាក់ការចុះបញ្ជីមួយ ដែលមានចុះលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់បុគ្គល ។ លេខអត្តសញ្ញាណកម្មនេះ ត្រូវយកទៅប្រើលើគ្រប់ឯកសារទាក់ទិននឹងពន្ធដារ ។

គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវតែប្រើលេខអត្តសញ្ញាណកម្មក្នុងមាត្រានេះ។ រាល់កិច្ចសន្យាជាមួយស្ថាប័នរដ្ឋ ត្រូវតែមានចុះលេខអត្តសញ្ញាណកម្មសារពើពន្ធទើបទុកជាបានការ ។

**មាត្រា ១០៣.-**

រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជី ចំពោះបុគ្គលទាំងឡាយដែលច្បាប់បានកំណត់ឱ្យចុះបញ្ជី ហើយពុំបានមកចុះបញ្ជី ក្នុងករណីនេះរដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធិភាពនៃការចុះបញ្ជី ។

## ជំពូកទី ៤

## ប្រកាសសារពើពន្ធ

**មាត្រា ១០៤.-**

អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ពេលវេលានិងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់ ។

លិខិតប្រកាសសារពើពន្ធត្រូវចុះហត្ថលេខាដោយអ្នកជាប់ពន្ធឬតំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ ។

**មាត្រា ១០៥.-**

បុគ្គលណាមួយដែលបានបើកប្រាក់អោយទៅបុគ្គលផ្សេងទៀត ត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធនូវលិខិតប្រកាសពត៌មានស្តីពីការបើកប្រាក់នោះ ទៅតាមបែបបទដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ ។

**មាត្រា ១០៦.-**

បុគ្គលដែលជាតំណាងអ្នកជាប់ពន្ធ ត្រូវមានសិទ្ធិជំនួសមុខឱ្យអ្នកជាប់ពន្ធ ដើម្បី :

- ដាក់លិខិតប្រកាសសារពើពន្ធ
- បង្ហាញរបាយការណ៍ឬលិខិតស្នាមផ្សេងៗ
- បង់ពន្ធអាករទាំងឡាយដែលកំណត់ដោយបទបញ្ញត្តិស្តីពីពន្ធដារ
- ធ្វើបណ្តឹងតវ៉ានិងបណ្តឹងឧទ្ធរណ៍
- បំពេញរាល់កាតព្វកិច្ចដែលអ្នកជាប់ពន្ធត្រូវទទួលខុសត្រូវចំពោះមុខបទបញ្ញត្តិស្តីពីពន្ធដារ ។

អ្នកជាប់ពន្ធអាចធ្វើការផ្ទេរសិទ្ធិ ជាលាយលក្ខណ៍អក្សរទៅឱ្យបុគ្គលម្នាក់ទៀត និងធ្វើសកម្មភាពជំនួសមុខខ្លួនក្នុងបញ្ហាពន្ធដារ ដោយមានសិទ្ធិនិងកាតព្វកិច្ចដូចមានចែងនៅក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះ ។ អ្នកជាប់ពន្ធអាចកំណត់ព្រំដែនសិទ្ធិអំណាចនៃការផ្ទេរសិទ្ធិនេះ ។

រដ្ឋបាលសារពើពន្ធអាចតម្រូវឱ្យបុគ្គលដែលធ្វើសកម្មភាពក្នុងនាមអ្នកជាប់ពន្ធលើមូលដ្ឋាននៃការផ្ទេរសិទ្ធិ ដាក់ជូនពិនិត្យនូវភស្តុតាងជាលាយលក្ខណ៍អក្សរនៃការផ្ទេរសិទ្ធិនោះ ។

អ្នកជាប់ពន្ធត្រូវមានភារកិច្ចទទួលខុសត្រូវដោយផ្ទាល់ចំពោះរាល់សកម្មភាពរបស់បុគ្គលដែលជាតំណាងតាមផ្លូវច្បាប់របស់ខ្លួនឬបុគ្គលដែលបានទទួលការផ្ទេរសិទ្ធិពីខ្លួន រហូតដល់ពេលណាដែលរដ្ឋបាលសារពើពន្ធបានទទួលសេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សរពីអ្នកជាប់ពន្ធ ស្តីអំពីការលុបចោលនូវការផ្ទេរសិទ្ធិនោះ ។

បុគ្គលដែលជាតំណាងរបស់អ្នកជាប់ពន្ធត្រូវចុះបញ្ជីនូវទំនាក់ទំនងរបស់ខ្លួនទៅរដ្ឋបាលសារពើពន្ធ ក្នុងកំឡុងពេល១៥ថ្ងៃ ក្រោយពេលដែលទំនាក់ទំនងនោះបានកើតឡើង ។

## ផ្នែកទី ៥

## ការប្រមូលពន្ធ

**មាត្រា ១០៧.-**

ការបង់ពន្ធត្រូវបានកំណត់ដូចតទៅ :

១- ប្រាក់ពន្ធត្រូវដល់កំណត់និងត្រូវបង់ នៅក្នុងរយៈពេលដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានតម្រូវឱ្យធ្វើការដាក់លិខិតប្រកាសសារពើពន្ធ ។

២- បំណុលសារពើពន្ធ ត្រូវដល់កំណត់និងត្រូវបង់ ក្នុងរយៈពេល៣០ថ្ងៃក្រោយពីការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ ។

៣- ប្រាក់ពន្ធត្រូវដល់កំណត់និងត្រូវបង់ ក្នុងរយៈពេល៣ថ្ងៃក្រោយពីការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ ដូចមានចែងក្នុងកថាខណ្ឌ៤ មាត្រា១១៦ នៃច្បាប់នេះ ។

៤- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងកំណត់ដោយប្រកាសនូវវិធាននិងនីតិវិធី ដើម្បី :

ក. កំណត់កាលបរិច្ឆេទទារបំណុលពន្ធ ដើម្បីជៀសវាងការខាតបង់ ដោយទារបំណុលពន្ធមិនបាន ។

ខ. ចាត់ទុកបំណុលពន្ធជាប្រាក់ពន្ធដែលមិនអាចប្រមូលបាន ។

**មាត្រា ១០៨.-**

ប្រសិនបើអភិបាល ឬបណ្ណាធិការឬកម្មសិទ្ធិករ របស់សហគ្រាសណាមួយដឹងឮ ឬមានចេតនាធ្វើឱ្យសហគ្រាសមិនរាយការណ៍ ឬរាយការណ៍បន្ថយនូវប្រាក់ពន្ធ ដោយរំលោភទៅលើបទប្បញ្ញត្តិស្តីពីពន្ធដារ ឬមិនឱ្យបង់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធ អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករទាំងនោះ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រាក់ពន្ធដែលត្រូវបង់ ។

## ជំពូកទី៦

## អំណាចរបស់រដ្ឋបាលសារពើពន្ធក្នុងការប្រមូលប្រាក់ពន្ធ

**មាត្រា ១០៩.-**

ប្រសិនបើបុគ្គលដែលមានកាតព្វកិច្ចបង់ពន្ធ តាមការតម្រូវនៃបទបញ្ញត្តិស្តីពីពន្ធដារ ធ្វេសប្រហែស ឬបដិសេធមិនព្រមបង់ពន្ធក្រោយពេលដែលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ ត្រូវបានប្រគល់ត្រឹមត្រូវ រដ្ឋបាលសារពើពន្ធត្រូវមានសិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិបុគ្គលនោះ សមស្របនឹងបំណុលពន្ធ ។

សិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ កើតមានឡើងនៅថ្ងៃដែលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ ត្រូវបានប្រគល់ទៅអោយអ្នកជាប់ពន្ធ ដូចមានចែងក្នុងមាត្រា៩៥ នៃច្បាប់នេះ ។

បើលក្ខខណ្ឌទាំងឡាយនៃមាត្រានេះ ត្រូវបានបំពេញត្រឹមត្រូវហើយនោះ សិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិ ដូចមានចែងក្នុងកថាខណ្ឌ១ មានសុពលភាពនិងអាទិភាពលើសិទ្ធិដទៃទៀតទាំងអស់ ដែលមានពីមុនមកឬដែលកើតឡើងក្រោយសិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ។

បុគ្គលទាំងឡាយអាចធ្វើការតវ៉ាទៅរដ្ឋបាលសារពើពន្ធ ដើម្បីសុំឱ្យលើកសិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិរបស់ខ្លួនដូចមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ដោយលើកឡើងនូវកំហុសឆ្គងក្នុងការដាក់សិទ្ធិនោះ ។

ប្រសិនបើរដ្ឋបាលសារពើពន្ធបានពិនិត្យឃើញថាការដាក់សិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិនោះមានការខុសឆ្គង រដ្ឋបាលសារពើពន្ធត្រូវចេញលិខិតបញ្ជាក់អំពីការលើកសិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិក្នុងរយៈពេល១០ថ្ងៃបន្ទាប់ពីពិនិត្យឃើញ ព្រមទាំងចុះក្នុងលិខិតបញ្ជាក់នោះថាការដាក់សិទ្ធិឃុំគ្រងនោះមានការខុសឆ្គង ។

**មាត្រា ១១០.-**

រដ្ឋបាលសារពើពន្ធត្រូវផ្ញើលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធទៅអ្នកជាប់ពន្ធយ៉ាងតិច១៥ថ្ងៃ មុនអនុវត្តវិធានការតឹងទារ ។

**មាត្រា ១១១.-**

ការរឹបអូសទ្រព្យសម្បត្តិអ្នកជាប់ពន្ធ ត្រូវបានកំណត់ដូចតទៅ ៖

១- ប្រសិនបើអ្នកជាប់ពន្ធមិនបានបង់បំណុលពន្ធក្នុងរយៈពេល១៥ថ្ងៃ ក្រោយពីបានទទួលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ រដ្ឋបាលសារពើពន្ធអាចរឹបអូសទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ដើម្បីធានាបំណុលពន្ធ ព្រមទាំងសោហ៊ុយចំណាយក្នុងការប្រមូលពន្ធនោះ។ សម្រាប់គោលដៅនៃច្បាប់នេះ ពាក្យ "ការរឹបអូស" សំដៅដល់ការរឹបអូសតាមគ្រប់មធ្យោបាយនិងការលក់ទ្រព្យសម្បត្តិអ្នកជាប់ពន្ធដោយរដ្ឋបាលសារពើពន្ធ តែមិនត្រូវរឹបអូសទ្រព្យសម្បត្តិឱ្យហួសពីបំណុលពន្ធនិងចំណាយក្នុងការប្រមូលពន្ធឡើយ ។

២- បុគ្គលដែលមានភារៈកាន់កាប់និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ដែលត្រូវរដ្ឋបាលសារពើពន្ធរឹបអូស ដូចក្នុងកថាខណ្ឌ១ នៃមាត្រានេះ មិនអាចបង្វិលទ្រព្យសម្បត្តិនោះទៅឱ្យអ្នកជាប់ពន្ធវិញ ឬក៏យកទ្រព្យសម្បត្តិនោះ ទៅធ្វើការទូទាត់ផ្សេងៗបានទេ លើកលែងតែការទូទាត់ដែលរដ្ឋបាលសារពើពន្ធបានអនុញ្ញាត ។

៣- រដ្ឋបាលសារពើពន្ធអាចអនុវត្តការរឹបអូសទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ដែលស្ថិតក្រោមការកាន់កាប់និងគ្រប់គ្រងដោយបុគ្គលដទៃទៀត យ៉ាងតិច១៥ថ្ងៃក្រោយពេលជូនដំណឹងដល់អ្នកកាន់កាប់និងគ្រប់គ្រងទ្រព្យសម្បត្តិនោះ

អគ្គនាយកដ្ឋាន ពន្ធដារ

៤- បុគ្គលអ្នកកាន់កាប់និងគ្រប់គ្រងលើទ្រព្យសម្បត្តិដែលត្រូវរឹបអូស ត្រូវប្រគល់ទ្រព្យសម្បត្តិនោះ ឬក៏បង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម ការប្រាក់និងសោហ៊ុយចំណាយក្នុងការប្រមូលពន្ធជូនរដ្ឋបាលសារពើពន្ធ លើកលែងតែចំណែកទ្រព្យសម្បត្តិណាមួយដែលស្ថិតនៅក្នុងដំណើរការជំរះបញ្ជីរំលាយសកម្មភាពអាជីវកម្ម ។

៥- បុគ្គលដែលមិនបានប្រគល់ទ្រព្យសម្បត្តិ ដូចមានចែងក្នុងកថាខ័ណ្ឌ៤ នៃមាត្រានេះ ត្រូវទទួលខុសត្រូវលើចំនួនទឹកប្រាក់នៃតម្លៃទ្រព្យសម្បត្តិនោះ ប៉ុន្តែមិនលើសពីចំនួនទឹកប្រាក់ដែលជាកម្មវត្ថុនៃការរឹបអូសនោះទេ ។

៦- បុគ្គលណាដែលបានប្រតិបត្តិតាមការតម្រូវក្នុងកថាខ័ណ្ឌ២ និងកថាខ័ណ្ឌ៤ នៃមាត្រានេះ ត្រូវបានរួចផុតអំពីការទទួលខុសត្រូវចំពោះអ្នកជាប់ពន្ធឬតតិយជន លើទ្រព្យសម្បត្តិ ប្រាក់ពន្ធឬកាតព្វកិច្ចផ្សេងទៀត ដែលបានប្រគល់ជូនទៅរដ្ឋបាលសារពើពន្ធ ។

៧- ប្រសិនបើរដ្ឋបាលសារពើពន្ធមានមូលដ្ឋានត្រឹមត្រូវជឿជាក់ថា ការប្រមូលពន្ធអាចមានឧបសគ្គ រដ្ឋបាលសារពើពន្ធអាចទាមទារឱ្យអ្នកជាប់ពន្ធបង់ពន្ធភ្លាម ហើយបើអ្នកជាប់ពន្ធមិនបានបំពេញតាមការទាមទារនេះទេ អាចរឹបអូសទ្រព្យសម្បត្តិអ្នកជាប់ពន្ធភ្លាម ។

៨- ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដូចមានកំណត់ក្នុងអនុក្រឹត្យ ត្រូវបានរួចផុតពីការរឹបអូស ។

៩- ការលក់ទ្រព្យសម្បត្តិរឹបអូសត្រូវធ្វើឡើងតាមការដាក់ឱ្យដេញថ្លៃ ។ សោហ៊ុយចំណាយផ្សេងៗក្នុងការលក់ទ្រព្យសម្បត្តិ គឺជាបន្ទុករបស់អ្នកជាប់ពន្ធ ។

**មាត្រា ១១២.-**

ទ្រព្យសម្បត្តិដែលត្រូវរឹបអូសដោយច្បាប់នេះ ត្រូវរឹបអូស កាន់កាប់និងទទួលខុសត្រូវដោយរដ្ឋបាលសារពើពន្ធតែប៉ុណ្ណោះ ។ ស្ថាប័នផ្សេងរបស់រាជរដ្ឋាភិបាលមិនអាចប្រើច្បាប់នេះ ដើម្បីរឹបអូសឬកាន់កាប់ទ្រព្យសម្បត្តិនោះដោយផ្ទាល់ឡើយ ។ បើមានការលក់នូវទ្រព្យសម្បត្តិដែលបានរឹបអូសដោយច្បាប់នេះ ចំណែកណាមួយនៃប្រាក់លក់បានដែលលើសអំពីបំណុលពន្ធរបស់អ្នកជាប់ពន្ធនៅក្រោមច្បាប់នេះ ត្រូវបង្វិលទៅឱ្យម្ចាស់កម្មសិទ្ធិទ្រព្យសម្បត្តិនោះវិញ ។

**មាត្រា ១១៣.-**

ការរឹបអូសក្នុងមាត្រា១១១ នៃច្បាប់នេះ អាចមានទាំងការឃាត់ទុកគណនីរបស់អ្នកជាប់ពន្ធនៅធនាគារ តាមលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ហើយដែលមានប្រសិទ្ធិភាពអនុវត្តភ្លាមក្រោយពីការប្រគល់លិខិតនោះទៅឱ្យធនាគារ ។

តាមរយៈការជូនដំណឹងឱ្យឃាត់ទុកគណនីធនាគារនេះ ធនាគារមិនអាចបើកគណនីថ្មីទៀតឱ្យអ្នកជាប់ពន្ធដែលបានទេ ហើយក៏មិនអាចធ្វើការទូទាត់ផ្សេងៗចេញពីគណនីនោះបានឡើយ លើកលែងតែការបង់ប្រាក់ដែលរដ្ឋបាលសារពើពន្ធកំណត់ឱ្យ ដើម្បីទូទាត់ប្រាក់ពន្ធត្រូវបង់ ការប្រាក់ ហើយនិងពន្ធបន្ថែមផ្សេងទៀត ។

គណនីធនាគារដែលបានឃាត់ទុកអាចបើកឱ្យប្រើវិញបាន លុះត្រាតែមានលិខិតជូនដំណឹងពីរដ្ឋបាលសារពើពន្ធ ។

ធនាគារដែលមិនបានអនុវត្តតាមលិខិតជូនដំណឹងក្នុងកថាខ័ណ្ឌ១នៃមាត្រានេះ ត្រូវទទួលខុសត្រូវចំពោះរដ្ឋបាលសារពើពន្ធ នូវកំរិតទឹកប្រាក់ដែលមាននៅក្នុងគណនីរបស់អ្នកជាប់ពន្ធ នៅពេលដែលលិខិតជូនដំណឹងត្រូវបានប្រគល់ឱ្យ ។

**មាត្រា ១១៤.-**

ការរឹបអូស នៅក្នុងមាត្រា១១១នៃច្បាប់នេះ អាចរួមបញ្ចូលផងដែរនូវការបញ្ឈប់ប្រតិបត្តិការនាំចេញ-នាំចូល ។ ការបញ្ឈប់ប្រតិបត្តិការនាំចេញ-នាំចូល សំដៅដល់ការឃាត់ទុកដោយរដ្ឋបាលគយនូវទំនិញនាំចូលបញ្ជូនឱ្យអ្នកជាប់ពន្ធនិងទំនិញដែលត្រូវនាំចេញដោយអ្នកជាប់ពន្ធ តាមលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ដែលមានប្រសិទ្ធិភាពអនុវត្តភ្លាម ក្រោយពេលដែលលិខិតនោះបានប្រគល់ឱ្យរដ្ឋបាលគយ ។

រដ្ឋបាលសារពើពន្ធអាចរឹបអូស និងលក់ទំនិញរបស់អ្នកជាប់ពន្ធដែលបានឃាត់ទុកដោយរដ្ឋបាលគយ នៅតាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងមាត្រា១១១ នៃច្បាប់នេះ ។

ការអនុញ្ញាតិឱ្យប្រតិបត្តិការនាំចេញ-នាំចូល រួចពីការបញ្ឈប់ត្រូវអនុវត្តតាមលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ។

ទំនិញឃាត់ទុកដោយរដ្ឋបាលគយ ដែលមិនមែនជារបស់អ្នកជាប់ពន្ធ ត្រូវបានរួចផុតពីការឃាត់ទុកដោយមានការយល់ព្រមពីរដ្ឋបាលសារពើពន្ធ ។

**មាត្រា ១១៥.-**

ការរឹបអូស ក្នុងមាត្រា១១១ នៃច្បាប់នេះ អាចមានទាំងការចេញលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ទៅកាន់អាជ្ញាធរមានសមត្ថកិច្ចស្នើសុំឱ្យទុកជាមោឃៈនូវលិខិតអនុញ្ញាតនិងអាជ្ញាប័ណ្ណផ្សេងៗរបស់អ្នកជាប់ពន្ធ ដើម្បីអនុវត្តសកម្មភាពណាមួយ ។

## ជំពូកទី៧

## ការកំណត់ពន្ធ

**មាត្រា ១១៦.-**

ចំនួនប្រាក់ពន្ធត្រូវបានកំណត់ដូចតទៅ :

១- ក្នុងករណីដែលប្រាក់ពន្ធរបស់អ្នកជាប់ពន្ធត្រូវបានបង់តាមវិធីកាត់ទុក ហើយអ្នកជាប់ពន្ធគ្មានកាតព្វកិច្ចធ្វើប្រកាសសារពើពន្ធទេនោះ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ គឺជាការកំណត់ចំនួនប្រាក់ពន្ធដែលបានកាត់ទុកនៅក្នុងឆ្នាំប្រតិទិន ។

២- ក្នុងករណីដែលអ្នកជាប់ពន្ធ ឬ ភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចត្រូវដាក់លិខិតប្រកាសសារពើពន្ធ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក គឺជាការកំណត់ពន្ធដែលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកបានគណនានៅលើលិខិតប្រកាសសារពើពន្ធ ដែលដាក់ជូនរដ្ឋបាលសារពើពន្ធ ។

៣- ក្នុងករណីដែលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធ ប៉ុន្តែមិនបានធ្វើលិខិតប្រកាស មិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីគណនេយ្យឬឯកសារផ្សេងទៀតតាមការតម្រូវឬមិនបានផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធ ដើម្បីកំណត់ពន្ធឱ្យបានត្រឹមត្រូវ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក គឺជាការកំណត់ពន្ធជាឯកតោភាគីដែលរដ្ឋបាលសារពើពន្ធបានធ្វើ និងបានប្រគល់ឱ្យបុគ្គលនោះ ។ ការកំណត់ពន្ធជាឯកតោភាគី ត្រូវផ្អែកលើ :

ក. ពត៌មានដែលមានចុះនៅក្នុងលិខិតប្រកាសសារពើពន្ធនានា ឬឯកសារផ្សេងទៀតដែលអ្នកជាប់ពន្ធបានដាក់ជូនរដ្ឋបាលសារពើពន្ធ ។

ខ. ពត៌មានដែលមានចុះក្នុងលិខិតប្រកាសពត៌មាន ។

គ. ពត៌មានផ្សេងទៀត ដែលរដ្ឋបាលសារពើពន្ធបានទទួល ។

៤- បើសិនជាមានមូលដ្ឋានបញ្ជាក់ថា ការប្រមូលពន្ធអាចមានឧបសគ្គ រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធលើអ្នកជាប់ពន្ធ នៅពេលណាមួយក៏បាន ។

**មាត្រា ១១៧.-**

ការកំណត់ពន្ធឡើងវិញនិងរយៈពេលកំណត់ពន្ធឡើងវិញ ត្រូវដំណើរការដូចតទៅ :

១- ចំពោះការកំណត់ពន្ធដែលផ្អែកតាមកថាខ័ណ្ឌ១ នៃមាត្រា១១៦ នៃច្បាប់នេះ រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធឡើងវិញក្នុងរយៈពេល៣ឆ្នាំ បន្ទាប់ពីឆ្នាំប្រតិទិនដែលការកាត់ទុកបានកើតឡើង ។

២- ចំពោះការកំណត់ពន្ធដែលផ្អែកតាមកថាខ័ណ្ឌ២និងកថាខ័ណ្ឌ៣ នៃមាត្រា១១៦ នៃច្បាប់នេះ រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធឡើងវិញ ក្នុងរយៈពេលណាមួយខាងក្រោមនេះ :

ក. ក្នុងរយៈពេល ៣ឆ្នាំ ក្រោយថ្ងៃដាក់លិខិតប្រកាសសារពើពន្ធ

ខ. ក្នុងរយៈពេល ១០ឆ្នាំ ក្រោយកាលបរិច្ឆេទដែលត្រូវឱ្យដាក់លិខិតប្រកាសសារពើពន្ធ ប្រសិនបើមានភស្តុតាងបញ្ជាក់ថាមានអំពើរាំងស្ទះដល់ការអនុវត្តបទបញ្ញត្តិស្តីពីពន្ធដារ

គ. ក្នុងរយៈពេលណាមួយក៏បានតាមការយល់ព្រមជាលាយលក្ខណ៍អក្សររបស់អ្នកជាប់ពន្ធ ។

៣- អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក អាចស្នើសុំធ្វើការកែតម្រូវលិខិតប្រកាសសារពើពន្ធ ក្នុងរយៈពេល៣ឆ្នាំក្រោយកាលបរិច្ឆេទនៃការដាក់លិខិតប្រកាសសារពើពន្ធតាមកថាខ័ណ្ឌ២ នៃមាត្រា១១៦ នៃច្បាប់នេះ ដោយផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រឡំឬការភ្លាំងភ្លាត់ដែលអ្នកជាប់ពន្ធបានធ្វើនៅក្នុងលិខិតប្រកាសពីមុន ។ ប្រសិនបើលទ្ធផលប្រកាសសារពើពន្ធកែតម្រូវនោះបណ្តាលឱ្យមានការបង្វិលសងប្រាក់ពន្ធឬឥណទានពន្ធ រដ្ឋបាលសារពើពន្ធអាចធ្វើការពិនិត្យបញ្ជាក់តាមនីតិវិធីត្រួតពិនិត្យសារពើពន្ធ ។

៤- អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក អាចស្នើសុំឱ្យរដ្ឋបាលសារពើពន្ធធ្វើការកែតម្រូវការកំណត់ពន្ធឡើងវិញ ក្នុងរយៈពេល៣ឆ្នាំក្រោយកាលបរិច្ឆេទដែលរដ្ឋបាលសារពើពន្ធកំណត់ពន្ធឡើងវិញ ដោយផ្អែកលើពត៌មានបន្ថែមដែលអ្នកជាប់ពន្ធឬរដ្ឋបាលសារពើពន្ធមិនបានទទួលក្នុងពេលកំណត់ពន្ធឡើងវិញនោះ ។

៥- ក្នុងករណីដែលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកធ្វើការកែតម្រូវការកំណត់ពន្ធរបស់ខ្លួន ឬស្នើសុំឱ្យរដ្ឋបាលសារពើពន្ធកែតម្រូវការកំណត់ពន្ធឡើងវិញ អាយុកាលនៃការកំណត់ពន្ធឡើងវិញ ក្នុងកថាខ័ណ្ឌ១និងកថាខ័ណ្ឌ២ នៃមាត្រានេះ ត្រូវចាប់ផ្តើមគិតពីកាលបរិច្ឆេទនៃការដាក់លិខិតប្រកាសសារពើពន្ធកែតម្រូវ ឬកាលបរិច្ឆេទដែលរដ្ឋបាលសារពើពន្ធធ្វើការកែតម្រូវការកំណត់ពន្ធឡើងវិញ ។

**មាត្រា ១១៨.-**

ការកំណត់ពន្ធឡើងវិញ ត្រូវបានដំណើរការតាមនីតិវិធីដូចតទៅ :

១- រដ្ឋបាលសារពើពន្ធត្រូវផ្ញើលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញដល់អ្នកជាប់ពន្ធ ។

២- អ្នកជាប់ពន្ធមានរយៈពេល៣០ថ្ងៃ ដើម្បីឆ្លើយតបចំពោះការកំណត់ពន្ធឡើងវិញទៅអង្គភាពរបស់នាយកដ្ឋានពន្ធដារ ដែលទទួលបន្ទុកធ្វើការកំណត់ពន្ធឡើងវិញនោះ ។ ក្នុងរយៈពេលនេះ អ្នកជាប់ពន្ធអាចទទួលយក

ឬជំទាស់ចំពោះការកំណត់ពន្ធឡើងវិញ ។ អ្នកជាប់ពន្ធត្រូវចាត់ទុកថាយល់ព្រមចំពោះការកំណត់ពន្ធឡើងវិញ បើសិនជាពុំបានឆ្លើយតប ។

៣- បើសិនជាមានការជំទាស់ចំពោះការកំណត់ពន្ធឡើងវិញ អ្នកជាប់ពន្ធត្រូវដាក់ពាក្យតវ៉ាទៅប្រធាននាយកដ្ឋានពន្ធដារតាមនីតិវិធីដែលមានចែងក្នុងមាត្រា១២០ នៃច្បាប់នេះ ។

៤- ការិយាល័យទទួលបន្ទុកការកំណត់ពន្ធឡើងវិញរបស់នាយកដ្ឋានពន្ធដារ ត្រូវបញ្ជូនលទ្ធផលនៃការកំណត់ពន្ធឡើងវិញទៅការិយាល័យប្រមូលពន្ធក្នុងរយៈពេល៣០ថ្ងៃ ក្រោយការចេញលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញ ។

**មាត្រា ១១៩.-**

នៅពេលដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឯកសារគ្រប់គ្រាន់ ឬក៏មិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ពន្ធលើអ្នកជាប់ពន្ធដោយផ្អែកលើមូលដ្ឋាននៃព័ត៌មានជាក់លាក់ ដែលរដ្ឋបាលសារពើពន្ធមាន ។ បន្ទុកភស្តុតាងដើម្បីបញ្ជាក់ថា ប្រាក់ពន្ធដែលរដ្ឋបាលសារពើពន្ធកំណត់មិនត្រឹមត្រូវ គឺស្ថិតនៅលើអ្នកជាប់ពន្ធ ។

នៅពេលណាដែលប្រាក់ចំណូលជាប់ពន្ធឬប្រាក់ចំណូលដែលបានប្រកាសដោយអ្នកជាប់ពន្ធមានភាពខុសគ្នាច្រើនធៀបទៅនឹងការទិញទ្រព្យសកម្មឬវត្ថុនានា ដែលធ្វើឱ្យឃើញចំណាយរបស់អ្នកជាប់ពន្ធលេចធ្លោឡើងនោះ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ពន្ធដោយផ្អែកលើមូលដ្ឋាននៃប្រាក់ចំណូលជាក់ស្តែង សមស្របទៅនឹងទំហំនៃចំណាយដើម្បីទិញទ្រព្យសកម្មឬវត្ថុនានាដែលលេចធ្លោនោះ ។ បន្ទុកភស្តុតាងដើម្បីបញ្ជាក់ថា ប្រាក់ពន្ធដែលរដ្ឋបាលសារពើពន្ធកំណត់មិនត្រឹមត្រូវ គឺស្ថិតនៅលើអ្នកជាប់ពន្ធ ។

## ផ្នែកទី៨

## ដំណោះស្រាយការតវ៉ារបស់អ្នកជាប់ពន្ធ

**មាត្រា ១២០.-**

វិធាននៃដំណោះស្រាយការតវ៉ារបស់អ្នកជាប់ពន្ធអំពីបញ្ហាសារពើពន្ធត្រូវបានកំណ[illegible]

១- អ្នកជាប់ពន្ធដែលមិនពេញចិត្តនឹងការកំណត់ពន្ធឡើងវិញឬសេចក្តីសម្រេចផ្សេងទៀត ដែលធ្វើឡើងដោយរដ្ឋបាលសារពើពន្ធ អាចធ្វើការតវ៉ាទៅប្រធាននាយកដ្ឋានពន្ធដារ ។ ការតវ៉ាត្រូវមានកំរិតត្រឹមតែត្រឹមដើមហេតុឬព័ត៌មានផ្សេងទៀត ដែលមាននៅក្នុងការកំណត់ពន្ធឡើងវិញ សេចក្តីសម្រេចឬនីតិវិធីនៃការកំណត់ពន្ធឡើងវិញប៉ុណ្ណោះ ។

២- ការតវ៉ាខាងរដ្ឋបាលត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅតាមទម្រង់ដែលមានចែងនៅក្នុងមាត្រា១២១ នៃច្បាប់នេះ និងត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធក្នុងរយៈពេល៣០ថ្ងៃ ក្រោយថ្ងៃដែលអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងទារបំណុលពន្ធរបស់រដ្ឋបាលសារពើពន្ធ ។

៣- ការតវ៉ាខាងរដ្ឋបាលពុំធ្វើឱ្យអ្នកជាប់ពន្ធរួចផុតពីភារកិច្ចបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែមនិងការប្រាក់ផ្សេងៗ ដែលបញ្ជាក់នៅក្នុងលិខិតជូនដំណឹងទារបំណុលពន្ធឡើយ ។

**មាត្រា ១២១.-**

ការតវ៉ាខាងរដ្ឋបាលអាចនឹងទទួលយកបាន បើសិនជាក្នុងពាក្យតវ៉ានោះមាន[illegible]ក្រោម៖

១- លេខអត្តសញ្ញាណកម្មរបស់អ្នកជាប់ពន្ធដែលធ្វើពាក្យតវ៉ា បើសិនជាមាន ។

២- សេចក្តីយោងទៅរក ការកំណត់ សេចក្តីសម្រេចឬលទ្ធផល ដែលជាកម្មវត្ថុនៃពាក្យតវ៉ា ។

៣- ដើមហេតុឬអំពើដែលជាកម្មវត្ថុនៃពាក្យតវ៉ា ។

៤- ហេតុផលនៃការតវ៉ា ។

៥- កាលបរិច្ឆេទនិងហត្ថលេខារបស់អ្នកជាប់ពន្ធនិងហត្ថលេខារបស់តំណាងមានការអនុញ្ញាតិរបស់អ្នកជាប់ពន្ធ បើសិនមានភាពចាំបាច់ ។

**មាត្រា ១២២.-**

រដ្ឋបាលសារពើពន្ធត្រូវចេញសេចក្តីសម្រេចជាថ្មីក្នុងរយៈពេល៦០ថ្ងៃ ក្រោយពីថ្ងៃបានទទួលពាក្យតវ៉ា ដើម្បីបញ្ជាក់ភាពត្រឹមត្រូវឬមិនត្រឹមត្រូវទាំងស្រុងឬប៉ុណ្ណែកណាមួយនៃការកំណត់ពន្ធឬសេចក្តីសម្រេចផ្សេងៗដែលអ្នកជាប់ពន្ធតវ៉ា ។ រដ្ឋបាលសារពើពន្ធត្រូវបញ្ជាក់ផងដែរនូវមូលដ្ឋាននៃការសម្រេចនេះ ។

ប្រសិនបើអ្នកជាប់ពន្ធមិនយល់ព្រមលើសេចក្តីសម្រេចថ្មីនេះរបស់រដ្ឋបាលសារពើពន្ធទេនោះ អ្នកជាប់ពន្ធអាចដាក់ពាក្យតវ៉ាទៅគណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធក្នុងរយៈពេលយ៉ាងយូរ៣០ថ្ងៃ ។

**មាត្រា ១២៣.-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធ ត្រូវកំណត់ដោយអនុក្រឹត្យតាមសេចក្តីស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ១២៤.-**

អ្នកជាប់ពន្ធមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ច ជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធក្នុងរយៈពេល៣០ថ្ងៃក្រោយពីបានទទួលដំណឹងស្តីពីសេចក្តីសម្រេចនោះ ។

អ្នកជាប់ពន្ធត្រូវតម្កល់ទុកនៅរតនាគារជាតិនូវប្រាក់ចំនួនស្មើនឹង ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែមនិងការប្រាក់ផ្សេងៗដែលទាក់ទិននឹងវិវាទតាមការកំណត់របស់រដ្ឋបាលសារពើពន្ធ មុននឹងដាក់ពាក្យបណ្តឹងទៅតុលាការ ។

## ជំពូកទី៩

## បទល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ

**មាត្រា ១២៥.-**

អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ត្រូវបានចាត់ទុកថាមានការធ្វេសប្រហែស បើសិនជាប្រាក់ពន្ធដែលបានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារ មិនលើសពី ១០ភាគរយ ។

អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកត្រូវបានចាត់ទុកថាមានការធ្វេសប្រហែស បើសិនជាមិនបានដាក់លិខិតប្រកាសសារពើពន្ធឬមិនបានបង់ពន្ធតាមកាលបរិច្ឆេទដែលច្បាប់បានកំណត់ ។

**មាត្រា ១២៦.-**

អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ត្រូវបានចាត់ទុកថាមានការធ្វេសប្រហែសធ្ងន់ធ្ងរ បើសិនជាប្រាក់ពន្ធដែលបានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារ លើសពី ១០ភាគរយ

**មាត្រា ១២៧.-**

ការគេចវេសពន្ធ គឺជាបទល្មើសដោយចេតនា ដោយដឹងជាមុន មានការរៀបចំទុកនិងច្រើនដងទៅលើបទប្បញ្ញត្តិស្តីពីពន្ធដារ ក្នុងបំណងបន្ថយឬបំបាត់ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យបង់ ។

ត្រូវបានចាត់ទុកថាជាការគេចវេសពន្ធផងដែរ ក្នុងករណីដែលការរំលោភបំពានធ្ងន់ធ្ងរ ដូចមានចែងក្នុងមាត្រា១២៦ នៃច្បាប់នេះ បានប្រព្រឹត្តឡើង :

១. ពីរលើកដាច់ពីគ្នា ក្នុងរយៈពេល៣ឆ្នាំ នៃឆ្នាំប្រតិទិន ។

២. បីលើកឬច្រើនជាងនេះដាច់ពីគ្នា ក្នុងរយៈពេលណាមួយក៏ដោយ ។

**មាត្រា ១២៨.-**

អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ រួមមាន :

១- ករណីដែលបុគ្គល :

ក. មិនបានរក្សាបញ្ជីគណនេយ្យនិងឯកសារផ្សេងទៀតឬមិនបានចេញវិក្កយប័ត្រលើកិច្ចការជំនួញ ។

ខ. មិនអនុញ្ញាតឱ្យមន្ត្រីពន្ធដារធ្វើការពិនិត្យបញ្ជីគណនេយ្យឬឯកសារផ្សេងៗ ។

គ. មិនបានចុះបញ្ជីនៅមន្ត្រីពន្ធដារ ។

ឃ. មិនបានជូនដំណឹងទៅមន្ត្រីពន្ធដារ អំពីការផ្លាស់ប្តូរក្នុងការចុះបញ្ជី ដូចមានចែងក្នុងច្បាប់នេះ ។

ង. កសាងឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ឬព័ត៌មានក្លែងបន្លំផ្សេងៗ ។

ច. លាក់ទុក ឬ បំផ្លាញចោលដោយចេតនានូវបញ្ជីគណនេយ្យ កំណត់ត្រា ឯកសារ របាយការណ៍ឬព័ត៌មានផ្សេងៗទៀត ។

ឆ. ព្យាយាមធ្វើឱ្យរាំងស្ទះដល់ការកំណត់និងការប្រមូលពន្ធ ។

ជ. មិនបានដាក់លិខិតប្រកាសសារពើពន្ធដែលគ្មានប្រាក់ពន្ធត្រូវបង់ក្នុងរយៈពេល៣០ថ្ងៃ ក្រោយកាលបរិច្ឆេទដែលច្បាប់បានកំណត់ ។

ឈ. ជួយជ្រោមជ្រែងដោយចេតនា ដល់អំពើទាំងឡាយខាងលើ ។

២- ករណីដែលមន្ត្រីរាជការ :

ក. ធ្វើអោយធ្លាយពត៌មានសម្ងាត់ដោយគ្មានការអនុញ្ញាត ។

ខ. ព្យាយាមធ្វើឱ្យរាំងស្ទះដល់ការកំណត់និងការប្រមូលពន្ធ ។

គ. ជួយជ្រោមជ្រែងដោយចេតនា ដល់អំពើទាំងឡាយខាងលើ ។

**មាត្រា ១២៩.-**

ក្រៅពីទោសទណ្ឌផ្នែករដ្ឋបាលផ្សេងទៀត បុគ្គលណាមួយបានធ្វើសកម្មភាពគេចវេសពន្ធដូចមានចែងក្នុងមាត្រា១២៧ នៃច្បាប់នេះ ឬធ្វើការរាំងស្ទះដល់ការគ្រប់គ្រងប្រព័ន្ធសារពើពន្ធដូចមានចែងក្នុងមាត្រា១២៨ នៃច្បាប់នេះ ត្រូវចាត់ទុកថាបានប្រព្រឹត្តបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ។

# ជំពូកទី១០

## ពន្ធបន្ថែម

**មាត្រា ១៣០.–**

ពន្ធបន្ថែមត្រូវអនុវត្តចំពោះបទល្មើសបទបញ្ញត្តិស្តីពីពន្ធដារ ។

ពន្ធបន្ថែមសម្រាប់ការបង់ពន្ធខ្វះឬការបង់យឺត ត្រូវគណនាដាច់ដោយឡែកពីពន្ធបន្ថែមសម្រាប់ការរំលងការអនុវត្តបទបញ្ញត្តិស្តីពីពន្ធដារ ។

ក្នុងករណីមានការបង់ពន្ធខ្វះ ពន្ធបន្ថែមនិងការប្រាក់ ត្រូវដល់កំណត់និងត្រូវបង់ តាមបែបបទដូចប្រាក់ពន្ធដែលបានបង់ខ្វះនោះ ។

ទោះជាក្នុងករណីណាក៏ដោយ ការដាក់ឱ្យអនុវត្តពន្ធបន្ថែម មិនមានផលប៉ះពាល់ដល់ការអនុវត្តទោសទណ្ឌចំពោះបទល្មើសផ្នែកព្រហ្មទណ្ឌលើបទបញ្ញត្តិស្តីពីពន្ធដារឡើយ ។

**មាត្រា ១៣១.–**

ចំពោះបុគ្គលដែលមានការធ្វេសប្រហែស ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង ១០ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ២ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធខ្វះមិនទាន់បានបង់ ។

ចំពោះបុគ្គលដែលមានការធ្វេសប្រហែសធ្ងន់ធ្ងរ ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង ២៥ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ២ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់ ។

ក្នុងករណីការកំណត់ពន្ធជាឯកតោភាគី ប្រាក់ពន្ធបន្ថែមត្រូវស្មើ ៤០ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ២ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់ ។

ការប្រាក់មិនត្រូវអនុវត្តទេ ក្នុងរយៈពេលកំណត់ពន្ធឡើងវិញតាមមាត្រា១១៨ នៃច្បាប់នេះ ឬក្នុងរយៈពេល៣០ថ្ងៃក្រោយការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ ។

**មាត្រា ១៣២.–**

ចំពោះបុគ្គលដែលមិនបានបង់ពន្ធតាមកាលកំណត់ ពន្ធបន្ថែមត្រូវកំណត់តាមអត្រា ១០ភាគរយ នៃទឹកប្រាក់ពន្ធបង់យឺត បូកនឹងការប្រាក់ ២ភាគរយ នៃទឹកប្រាក់ពន្ធបង់យឺតសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធនោះនៅមិនទាន់បានបង់ ។

បើសិនជាបុគ្គលមិនបានបង់ពន្ធក្នុងរយៈ១៥ថ្ងៃ ក្រោយពេលបានទទួលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ ពន្ធបន្ថែមត្រូវកំណត់តាមអត្រា ២៥ភាគរយ នៃទឹកប្រាក់ពន្ធបង់យឺត បូកនឹងការប្រាក់ ២ភាគរយ នៃទឹកប្រាក់ពន្ធបង់យឺតសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធនោះនៅមិនទាន់បានបង់ ។

ក្នុងករណីការកំណត់ពន្ធជាឯកតោភាគី សម្រាប់ការមិនដាក់លិខិតប្រកាស ប្រាក់ពន្ធបន្ថែមត្រូវស្មើ ៤០ភាគរយ នៃចំនួនប្រាក់ពន្ធដែលបានកំណត់ បូកបន្ថែមការប្រាក់ ២ភាគរយ នៃចំនួនប្រាក់ពន្ធដែលបានកំណត់សម្រាប់ខែ

នីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធមិនទាន់បានបង់ ។

ការប្រាក់យឺតយ៉ាវត្រូវគិតចាប់ពីថ្ងៃទី០១ នៃខែបន្ទាប់ ពីខែដែលត្រូវបង់ពន្ធ ។ ចំពោះពន្ធលើប្រាក់ចំណេញ ការប្រាក់យឺតយ៉ាវត្រូវគិតចាប់ពីថ្ងៃទី០១ នៃខែបន្ទាប់ ដែលជាខែផុតរយៈពេលកំណត់សម្រាប់ការដាក់លិខិតប្រកាសលទ្ធផលប្រចាំឆ្នាំ ។

ពន្ធបន្ថែមចំពោះការយឺតយ៉ាវក្នុងការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវស្មើនឹង ១០០ភាគរយ នៃប្រាក់ពន្ធត្រូវបង់ ។

**មាត្រា ១៣៣.-**

ចំពោះការប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តបទបញ្ញត្តិស្តីពីពន្ធដារ ពន្ធបន្ថែមត្រូវកំណត់ដូចខាងក្រោមនេះ សម្រាប់អំពើនីមួយៗ :

១- ២.០០០.០០០ រៀល (ពីរលានរៀល) ចំពោះបុគ្គល អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកក្រោមរបបពិត ឬមន្ត្រីរាជការ ។

២- ៥០០.០០០ រៀល (ប្រាំសែនរៀល) ចំពោះអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកក្រោមរបបបំព្រួញឬរបបម៉ៅការ ។

## ជំពូកទី១១

## អំពើបទល្មើសព្រហ្មទណ្ឌ

**មាត្រា ១៣៤.-**

លើកលែងតែចំពោះបទល្មើសមានចែងនៅក្នុងមាត្រា១៣៩និងមាត្រា១៤០ នៃច្បាប់នេះ ការប្តឹងចោទប្រកាន់និងទាមទារការដាក់ទោសចំពោះបទល្មើសព្រហ្មទណ្ឌលើបទបញ្ញត្តិស្តីពីពន្ធដារ ត្រូវធ្វើឡើងដោយប្រធាននាយកដ្ឋានពន្ធដារ ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ១៣៥.-**

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត អភិបាល បណ្ណាធិការ កម្មសិទ្ធិកររបស់សហគ្រាសណាមួយ ឬបុគ្គលទទួលខុសត្រូវឱ្យសហគ្រាសណាមួយដែលបានប្រព្រឹត្តអំពើគេចវេសពន្ធ ដូចមានចែងក្នុងមាត្រា១២៧ នៃច្បាប់នេះ ត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ រៀល (ដប់លានរៀល) ដល់ ២០.០០០.០០០ រៀល (ម្ភៃលានរៀល) ឬជាប់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ឬទោសទាំងពីរនេះ ។

**មាត្រា ១៣៦.-**

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត បុគ្គលណាដែលបានប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទបញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា១២៨ នៃច្បាប់នេះ ត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ រៀល (ប្រាំលានរៀល) ដល់ ១០.០០០.០០០ រៀល (ដប់លានរៀល) ឬជាប់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ ឬទោសទាំងពីរនេះ ។

**មាត្រា ១៣៧.-**

បុគ្គលណាដែលមានចេតនាជួយ ជ្រោមជ្រែង ឬអូសទាញបុគ្គលម្នាក់ទៀតឱ្យប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌចំពោះច្បាប់នេះ ឬក៏ដោយចេតនាបានផ្តល់គំនិតឬជំរុញបុគ្គលម្នាក់ទៀតឱ្យប្រព្រឹត្តិបទល្មើសបែបនេះត្រូវជាប់ពិរុទ្ធ ហើយត្រូវទទួលរងការផ្តន្ទាទោសដូចគ្នានឹងការប្រព្រឹត្តិបទល្មើសផ្ទាល់ខ្លួនផងដែរ ។

**មាត្រា ១៣៨.-**

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត បុគ្គលណាដែលបានបំពានមាត្រា៩៤ នៃច្បាប់នេះ ត្រូវជាប់ពិរុទ្ធអំពីបទល្មើសនឹងច្បាប់ ហើយត្រូវទទួលរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ រៀល (ប្រាំលានរៀល) ដល់ ១០.០០០.០០០ រៀល (ដប់លានរៀល) ឬជាប់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ ឬទោសទាំងពីរនេះ ។

**មាត្រា ១៣៩.-**

បុគ្គលណាដែលបានទទួលការតែងតាំងជាអ្នកអនុវត្តបទបញ្ញត្តិស្តីពីពន្ធដារ ហើយដោយចេតនាបានប្រព្រឹត្តអំពើដូចខាងក្រោមនេះ ត្រូវជាប់ពិរុទ្ធអំពីបទល្មើសនឹងច្បាប់ ហើយត្រូវទទួលរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ រៀល (ប្រាំលានរៀល) ដល់ ១០.០០០.០០០ រៀល (ដប់លានរៀល) ឬជាប់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ ឬទោសទាំងពីរនេះ :

១- ដកប្រាក់ពន្ធសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនឬការប្រើប្រាស់ណាផ្សេង ដែលគ្មានចែងក្នុងបទបញ្ញត្តិស្តីពីពន្ធដារ ។

២- ធ្វើរបាយការណ៍មិនត្រឹមត្រូវ អំពីចំនួនប្រាក់ពន្ធដែលខ្លួនប្រមូលបានឬទទួលបាន ។

៣- ប្រើប្រាស់តួនាទីជាមន្ត្រីពន្ធដារ ដើម្បីទទួលយកប្រាក់ឬអត្ថប្រយោជន៍ផ្សេងទៀតពីអ្នកជាប់ពន្ធឬបុគ្គលផ្សេងទៀត ។

៤- ប្រមូលឬព្យាយាមប្រមូលប្រាក់ពន្ធ ដោយគ្មានការអនុញ្ញាត ។

បុគ្គលណាដែលបានទទួលការតែងតាំងជាអ្នកអនុវត្តបទបញ្ញត្តិស្តីពីពន្ធដារ ហើយដោយចេតនាបានទាមទារប្រាក់លើសពីច្បាប់អនុញ្ញាត ត្រូវទទួលទោសវីតិក្រមតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

បុគ្គលណាដែលបានទទួលការតែងតាំងជាអ្នកអនុវត្តបទបញ្ញត្តិស្តីពីពន្ធដារ ហើយដោយចេតនាបានទាមទារឬទទួលសំណូក ត្រូវទទួលទោសពីបទស៊ីសំណូកតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។ អ្នកសូកត្រូវទទួលទោសពីបទសូកតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ១៤០.-**

បើសិនជាអ្នកជាប់ពន្ធយល់ឃើញថា ខ្លួនបានទទួលរងនូវការខូចខាតខាងហិរញ្ញវត្ថុឬការរងគ្រោះផ្ទាល់ខ្លួនអំពីសកម្មភាពខុសឆ្គងឬខុសច្បាប់ពីសំណាក់រដ្ឋបាលសារពើពន្ធ អ្នកជាប់ពន្ធអាចប្តឹងទាមទារសំណងនៃការខូចខាត ឬការរងគ្រោះនោះទៅតុលាការក្នុងរយៈពេលបីឆ្នាំក្រោយកាលបរិច្ឆេទនៃការខូចខាតខាងហិរញ្ញវត្ថុឬការរងគ្រោះផ្ទាល់ខ្លួនចុងក្រោយបំផុត ។

អគ្គនាយកដ្ឋាន ពន្ធដារ

# ជំពូកទី១៦

# អវសានប្បញ្ញត្តិ

**មាត្រា ១៥១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៥២.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ១៩៩៧

ព្រះហស្តលេខា

នរោត្តម សីហនុ

បានបង្គំទូលថ្វាយនិងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១និងទី២

ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការពិសេស

សេដ្ឋកិច្ចនិងហិរញ្ញវត្ថុរដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|
| ព្រះហស្តលេខា | ហត្ថលេខា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

លេខ : ២១ ច.ល.

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ កុម្ភៈ ឆ្នាំ ១៩៩៧

[illegible]រដ្ឋាភិបាល

[illegible] តាន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

# អាករលើតម្លៃបន្ថែម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១០៨/០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៨
- បានការឯកភាព ពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៩

**<u>សំរេច</u> :**

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់វិធាននិងនីតិវិធីសម្រាប់គ្រប់គ្រងនិងអនុវត្តអាករលើតម្លៃបន្ថែម ហៅកាត់ថា អតប លើការផ្គត់ផ្គង់ទំនិញឬសេវា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

# ជំពូកទី២
# វិធាននិងនីតិវិធីសម្រាប់ការចុះបញ្ជីបុគ្គលជាប់អតប

**មាត្រា២ .-**

វិធាននិងនីតិវិធី នៃការចុះបញ្ជីអតប មានដូចតទៅ :

១. ដូចមានចែងក្នុងមាត្រា៩៥ និងមាត្រា៧៦ នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធតាមរបបពិត ដែលបានធ្វើការផ្គត់ផ្គង់ជាប់អតបដូចមានចែងក្នុងមាត្រា៦០ នៃច្បាប់ស្តីពីសារពើពន្ធ គឺជាបុគ្គលជាប់អតប ។ បុគ្គលដូចមានចែងក្នុងវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌ១ នៃមាត្រានេះ ត្រូវដាក់ពាក្យស្នើសុំទៅនាយកដ្ឋានពន្ធដារដើម្បីធ្វើការចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែមឱ្យបានស្រេចបាច់មុនពេលចាប់ផ្តើមប្រកបអាជីវកម្ម ។ បុគ្គលដទៃទៀតត្រូវដាក់ពាក្យស្នើសុំទៅនាយកដ្ឋានពន្ធដារដើម្បីធ្វើការចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែមឱ្យបានស្រេចបាច់ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃដែលបុគ្គលនោះក្លាយជាបុគ្គលជាប់អតប ។ បុគ្គលទាំងនោះរួមមាន :

- ក- ក្រុមហ៊ុនគ្រប់ប្រភេទ សហគ្រាសនិហ័រណអាហារ័ណ និង សហគ្រាសវិនិយោគទាំងអស់ ។
- ខ- សហគ្រាសដទៃទៀតដែលមានផលរបរជាប់អតប ក្នុងរយៈពេល៣ខែប្រតិទិនជាប់គ្នាណាមួយ ចាប់ពី១២៥លានរៀលឡើងទៅសម្រាប់ការផ្គត់ផ្គង់ទំនិញ ឬចាប់ពី៦០លានរៀលឡើងទៅសម្រាប់ការផ្គត់ផ្គង់សេវា ។
- គ- សហគ្រាសទាំងឡាយដែលក្នុងពេលចាប់ផ្តើមនៃរយៈពេល៣ខែប្រតិទិនជាប់គ្នាណាមួយ មានមូលដ្ឋានជឿជាក់ថាក្នុងរយៈពេល៣ខែប្រតិទិនជាប់គ្នានោះ នឹងមានផលរបរជាប់អតបចាប់ពី១២៥លានរៀលឡើងទៅសម្រាប់ការផ្គត់ផ្គង់ទំនិញ ឬចាប់ពី៦០លានរៀលឡើងទៅសម្រាប់ការផ្គត់ផ្គង់សេវា ។
- ឃ- សហគ្រាសទាំងឡាយដែលក្នុងពេលចាប់ផ្តើមនៃរយៈពេល៣ខែប្រតិទិនជាប់គ្នាណាមួយ មានមូលដ្ឋានជឿជាក់ថាក្នុងរយៈពេល៣ខែប្រតិទិនជាប់គ្នានោះ នឹងមានផលរបរជាប់អតបបានមកពីការធ្វើកិច្ចសន្យាជាមួយរដ្ឋ ចាប់ពី៣០លានរៀលឡើងទៅ។

ក្នុងករណីដែលបុគ្គលធ្វើការផ្គត់ផ្គង់ទំនិញផង ផ្គត់ផ្គង់សេវាផង មានផលរបរជាប់អតប លើសពីកម្រិតអប្បបរមានៃផលរបរត្រូវចុះបញ្ជីដែលបានកំណត់ក្នុងវាក្យខ័ណ្ឌ ខ វាក្យខ័ណ្ឌ គ និងវាក្យខ័ណ្ឌ ឃ នៃកថាខ័ណ្ឌ ១ នៃមាត្រានេះ បុគ្គលនោះត្រូវដាក់ពាក្យស្នើសុំចុះបញ្ជី ។

សម្រាប់គោលដៅនៃបទប្បញ្ញត្តិទាំងឡាយនៃអនុក្រឹត្យនេះ ពាក្យ "ផលរបរជាប់អតប" សំដៅដល់ផលរបរដែលបានមកពីការផ្គត់ផ្គង់ជាប់អតប នូវទំនិញឬសេវា ឬ ការចុះកិច្ចសន្យាជាមួយរដ្ឋ ដោយមិនទាន់គិតបញ្ចូលអតបទេ ។

២. កម្រិតអប្បបរមានៃផលរបរជាប់អតបប្រចាំឆ្នាំ សម្រាប់ការចុះបញ្ជីអនុវត្តចំពោះបុគ្គលដែលមិនមានលក្ខណៈជាក្រុមហ៊ុន សហគ្រាសនិហរ័ណ-អាហរ័ណ ឬ សហគ្រាសវិនិយោគ គឺ ៥០០លានរៀលសម្រាប់ការផ្គត់ផ្គង់ទំនិញ ២៥០លានរៀលសម្រាប់ការផ្គត់ផ្គង់សេវា និង ១២៥លានរៀល សម្រាប់ការធ្វើកិច្ចសន្យាជាមួយនឹងរដ្ឋ ។

៣. ស្ថាប័នរដ្ឋ ឬ អង្គភាពរបស់ស្ថាប័នរដ្ឋគ្រប់លំដាប់ថ្នាក់ ដែលធ្វើសកម្មភាពអាជីវកម្ម ត្រូវដាក់ពាក្យស្នើសុំធ្វើការចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែមឱ្យបានស្រេចបាច់ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃដែលស្ថាប័នរដ្ឋឬអង្គភាពនោះ ក្លាយជាបុគ្គលជាប់អតប ។

៤. បុគ្គលណាមួយដែលធ្វើការផ្គត់ផ្គង់ទំនិញ ឬសេវា ដោយមានតម្លៃ ដែលជាចំណែកមួយនៃសកម្មភាពអាជីវកម្មរបស់ខ្លួន ហើយដែលមិនស្ថិតក្រោមកាតព្វកិច្ចចុះបញ្ជីតាមការតម្រូវនៃកថាខ័ណ្ឌ១ ឬ កថាខ័ណ្ឌ៣ នៃមាត្រានេះ បុគ្គលនោះអាចធ្វើការស្នើសុំទៅនាយកដ្ឋានពន្ធដារដើម្បីចុះបញ្ជីស្របទៅតាមបទប្បញ្ញត្តិនៃជំពូកទី៣ នៃអនុក្រឹត្យនេះ ។

## ជំពូកទី៣
## ការតម្រូវចំពោះការចុះបញ្ជី

**មាត្រា៣ .-**

ការដាក់ពាក្យស្នើសុំចុះបញ្ជី ដូចមានចែងក្នុងមាត្រា២នៃអនុក្រឹត្យនេះ ត្រូវធ្វើឡើងតាមទម្រង់ដែលនាយកដ្ឋានពន្ធដារបានកំណត់ ហើយបុគ្គលដែលបានដាក់ពាក្យស្នើសុំត្រូវផ្តល់ពត៌មាននានា ទៅតាមការតម្រូវរបស់នាយកដ្ឋានពន្ធដារ ។

**មាត្រា៤ .-**

នាយកដ្ឋានពន្ធដារ ត្រូវចុះបញ្ជីបុគ្គលដែលបានដាក់ពាក្យស្នើសុំ ដូចមានចែងក្នុងកថាខ័ណ្ឌ១ និងកថាខ័ណ្ឌ៣ នៃមាត្រា២នៃអនុក្រឹត្យនេះ ហើយត្រូវចេញឱ្យបុគ្គលនោះនូវវិញ្ញាបនប័ត្រចុះបញ្ជី ដែលក្នុងនោះមានទាំងលេខអត្តសញ្ញាណកម្មអតប ផង លើកលែងតែក្នុងករណីដែលនាយកដ្ឋានពន្ធដារយល់ឃើញថា បុគ្គលដែលបានដាក់ពាក្យស្នើសុំពុំមានកាតព្វកិច្ចចុះបញ្ជីតាមមាត្រា២ នៃអនុក្រឹត្យនេះ ឬចំពោះករណីនៃការដាក់ពាក្យស្នើសុំតាមកថាខ័ណ្ឌ៤ នៃមាត្រា២ នៃអនុក្រឹត្យនេះដោយមូលហេតុ :

ក- បុគ្គលពុំមានទីលំនៅ ឬ កន្លែងធ្វើអាជីវកម្មជាប់លាប់ ។

ខ- នាយកដ្ឋានពន្ធដារមានមូលដ្ឋានត្រឹមត្រូវជឿជាក់ថាបុគ្គលនោះ :

- នឹងមិនកាន់កាប់កត់ត្រាបានត្រឹមត្រូវ នូវបញ្ជីឯកសារគណនេយ្យជាប់ទាក់ទិននឹងសកម្មភាពអាជីវកម្មរបស់ខ្លួន
- នឹងមិនដាក់លិខិតប្រកាសសារពើពន្ធឱ្យបានទៀតទាត់ និងច្បាស់លាស់អាចប្រើការបាន តាមការតម្រូវដូចមានចែងក្នុងមាត្រា៧០ នៃច្បាប់ស្តីពីសារពើពន្ធ ។

**មាត្រា៥ .-**

កាលបរិច្ឆេទមានប្រសិទ្ធិភាពនៃការចុះបញ្ជី គឺជាកាលបរិច្ឆេទដែលបុគ្គលស្នើសុំចុះបញ្ជី ក្លាយជាបុគ្គលជាប់អតប ។ កាលបរិច្ឆេទមានប្រសិទ្ធិភាពនេះចាប់ផ្តើម :

ក- ពីដើមខែ បន្ទាប់ពីខែដែលកាតព្វកិច្ចដាក់ពាក្យស្នើសុំចុះបញ្ជីបានកើតមានឡើង សម្រាប់ករណីនៃការដាក់ពាក្យស្នើសុំដូចមានចែងក្នុងកថាខ័ណ្ឌ១ ឬ កថាខ័ណ្ឌ៣ នៃមាត្រា២ នៃអនុក្រឹត្យនេះ

ខ- ពីដើមខែ បន្ទាប់ពីខែដែលបុគ្គលបានដាក់ពាក្យស្នើសុំចុះបញ្ជី សម្រាប់ករណីនៃការដាក់ពាក្យស្នើសុំដូចមានចែងក្នុងកថាខ័ណ្ឌ៤ នៃមាត្រា២ នៃអនុក្រឹត្យនេះ ។

**មាត្រា៦ ._**

វិញ្ញាបនប័ត្រចុះបញ្ជីត្រូវមានចុះឈ្មោះ លេខអត្តសញ្ញាណកម្មអតប កាលបរិច្ឆេទមានប្រសិទ្ធិភាពនៃការចុះបញ្ជី និង ពត៌មានលំអិតផ្សេងទៀតរបស់បុគ្គលជាប់អតប ។

**មាត្រា៧ ._**

បុគ្គលជាប់អតបដែលបានចុះបញ្ជីអាចដាក់តាំងឬព្យួរវិញ្ញាបនប័ត្រចុះបញ្ជីដែលបានចេញឱ្យតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ នៅទីកន្លែងអាជីវកម្មជាសំខាន់របស់ខ្លួន ។

**មាត្រា៨ ._**

នាយកដ្ឋានពន្ធដារត្រូវមានបញ្ជីសម្រាប់កត់ត្រាតាមដាននូវពត៌មានលំអិត ដែលទាក់ទិននឹងបុគ្គលជាប់អតបម្នាក់ៗ ។

**មាត្រា៩ ._**

ប្រធាននាយកដ្ឋានពន្ធដារ មានសិទ្ធចុះបញ្ជីបុគ្គលណាមួយ បើសិនមានមូលដ្ឋានត្រឹមត្រូវជឿជាក់ថាបុគ្គលនោះមានកាតព្វកិច្ចដាក់ពាក្យស្នើសុំចុះបញ្ជីដូចមានចែងក្នុងកថាខ័ណ្ឌ១ និង កថាខ័ណ្ឌ៣ នៃមាត្រា២ នៃអនុក្រឹត្យនេះ ក៏ប៉ុន្តែមិនបានដាក់ពាក្យស្នើសុំ ហើយការចុះបញ្ជីត្រូវមានប្រសិទ្ធិភាពចាប់ពីកាលបរិច្ឆេទដែលមានចុះនៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជី ។

**មាត្រា១០ ._**

នាយកដ្ឋានពន្ធដារ ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរ អំពីការសំរេចយល់ព្រមឬមិនយល់ព្រមចុះបញ្ជី ឱ្យដល់បុគ្គលដែលបានដាក់ពាក្យស្នើសុំដូចមានចែងក្នុងមាត្រា៤នៃអនុក្រឹត្យនេះ ក្នុងរយៈពេល៣០ថ្ងៃ ក្រោយបានទទួលពាក្យស្នើសុំ ។

**មាត្រា១១ ._**

នាយកដ្ឋានពន្ធដារ ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរអំពីការសំរេចចុះបញ្ជីជាឯកតោភាគីឱ្យដល់បុគ្គលដូចមានចែងក្នុងមាត្រា៩ នៃអនុក្រឹត្យនេះ ក្នុងរយៈពេល៣០ថ្ងៃក្រោយពេលមានការសំរេច ។

**មាត្រា១២ ._**

បុគ្គលជាប់អតប ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរដល់នាយកដ្ឋានពន្ធដារ អំពីការប្រែប្រួល :

- ក- នាមករណ៍ ឬ អាសយដ្ឋានរបស់បុគ្គលនោះ ។
- ខ- ស្ថានភាពផ្សេងៗ ដែលបណ្តាលឱ្យបុគ្គលនោះមិនអាចបំពេញល័ក្ខខ័ណ្ឌ នៃការចុះបញ្ជីតទៅទៀត ។
- គ- ប្រភេទនៃសកម្មភាពអាជីវកម្ម ឬប្រភេទនៃការផ្គត់ផ្គង់ជាប់អតបដែលកំពុងអនុវត្ត និងពត៌មានផ្សេងៗទៀត ។

ការជូនដំណឹងនេះត្រូវធ្វើក្នុងរយៈពេល១៥ថ្ងៃ ក្រោយការប្រែប្រួលបានកើតមានឡើង ។

## ជំពូកទី៤
## ការចុះបញ្ជីអតបសម្រាប់សហគ្រាសវិនិយោគ

**មាត្រា១៣ ._**

បុគ្គលដែលមានការទទួលស្គាល់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសហគ្រាសវិនិយោគ ហើយដែលមិនទាន់បានធ្វើការផ្គត់ផ្គង់ជាប់អតប អាចស្នើសុំទៅនាយកដ្ឋានពន្ធដារ ដើម្បីធ្វើការចុះបញ្ជីអតបសម្រាប់សហគ្រាសវិនិយោគ ដោយមានសុពលភាព មិនលើសពី ២ឆ្នាំ ចំពោះការស្នើសុំមួយលើក ១ ។

**មាត្រា១៤ .-**

បុគ្គលដែលស្នើសុំចុះបញ្ជីអតបសម្រាប់សហគ្រាសវិនិយោគ ត្រូវផ្តល់នូវកិច្ចសន្យានិងវត្ថុធានាទៅតាមការតម្រូវរបស់នាយកដ្ឋានពន្ធដារ សម្រាប់ទូទាត់សងវិញនូវប្រាក់អតបដែលនាយកដ្ឋានពន្ធដារបានបង្វិលសង បើសិនជាបុគ្គលនោះមិនបានធ្វើការផ្គត់ផ្គង់ជាប់អតបក្នុងរយៈពេលដែលត្រូវបានចុះបញ្ជីសហគ្រាសវិនិយោគ ។

**មាត្រា១៥ .-**

សហគ្រាសវិនិយោគអាចទាមទារ និងត្រូវបានបង្វិលសងវិញនូវអតបលើធាតុចូលដែលបានបង់លើចំណាយលើធាតុចូល ទោះបីជាការនាំចូល ឬជាការទទួលក្នុងស្រុកក្តី ដែលទាក់ទិនទៅនឹងគំរោងសកម្មភាពអាជីវកម្មជាប់អតបរបស់សហគ្រាស ។

**មាត្រា១៦ .-**

សហគ្រាសវិនិយោគត្រូវគោរពប្រតិបត្តិរាល់ភារកិច្ច និងកាតព្វកិច្ចទាំងអស់របស់បុគ្គលជាប់អតបដែលបានចុះបញ្ជី មានជាអាទិ៍ ការកាន់កាប់ថែរក្សាបញ្ជីគណនេយ្យ និង ការដាក់លិខិតប្រកាសឱ្យបានទៀតទាត់ ។

**មាត្រា១៧ .-**

ការចុះបញ្ជីអតបសម្រាប់សហគ្រាសវិនិយោគ ត្រូវបានបញ្ឈប់ភ្លាមកាលណា :

- ក- សហគ្រាសវិនិយោគបានធ្វើការផ្គត់ផ្គង់ជាប់អតបក្នុងដំណើរការប្រកបអាជីវកម្ម ។
- ខ- ផុតរយៈពេល២ឆ្នាំក្រោយពីកាលបរិច្ឆេទចុះបញ្ជី ប្រសិនបើសហគ្រាសវិនិយោគនោះពុំបានធ្វើការផ្គត់ផ្គង់ជាប់អតប វៀរលែងតែមានការស្នើសុំជាថ្មី ។

## ជំពូកទី៥

## ការលុបចោលការចុះបញ្ជី

**មាត្រា១៨ .-**

បុគ្គលជាប់អតបត្រូវស្នើសុំជាលាយល័ក្ខអក្សរទៅនាយកដ្ឋានពន្ធដារ ឱ្យលុបចោលការចុះបញ្ជីរបស់ខ្លួន បើសិនជាបុគ្គលនោះឈប់ធ្វើការផ្គត់ផ្គង់ទំនិញឬសេវាដោយមានតម្លៃ ដែលជាចំណែកមួយនៃសកម្មភាពអាជីវកម្មរបស់ខ្លួន ។

**មាត្រា១៩ .-**

បុគ្គលជាប់អតបអាចស្នើសុំជាលាយល័ក្ខអក្សរទៅនាយកដ្ឋានពន្ធដារ ឱ្យធ្វើការលុបចោលការចុះបញ្ជីរបស់ខ្លួន ប្រសិនបើកម្រិតផលរបរជាប់អតបរបស់ខ្លួនក្នុងរយៈពេល៣ខែប្រតិទិនចុងក្រោយ មានចំនួនមិនលើសពីកម្រិតអប្បបរមានៃផលរបរត្រូវចុះបញ្ជី ដូចមានចែងក្នុងកថាខ័ណ្ឌ១ នៃមាត្រា២ នៃអនុក្រឹត្យនេះ ឬប្រសិនបើកម្រិតផលរបរជាប់អតប សម្រាប់រយៈពេល១២ខែប្រតិទិនចុងក្រោយមានចំនួនមិនលើសពី ៧៥ ភាគរយ នៃកម្រិតអប្បបរមានៃផលរបរប្រចាំឆ្នាំត្រូវចុះបញ្ជី ។

**មាត្រា២០ .-**

ចំពោះបុគ្គលជាប់អតបដែលស្នើសុំចុះបញ្ជីតាមកថាខ័ណ្ឌ៤នៃមាត្រា២នៃអនុក្រឹត្យនេះ ការស្នើសុំលុបចោលការចុះបញ្ជីតាមមាត្រា១៩នៃអនុក្រឹត្យនេះ អាចធ្វើទៅបានតែក្រោយរយៈពេល២ឆ្នាំនៃកាលបរិច្ឆេទចុះបញ្ជីប៉ុណ្ណោះ ។

**មាត្រា២១ .-**

ប្រធាននាយកដ្ឋានពន្ធដារ មានសិទ្ធិលុបចោលការចុះបញ្ជី :

- ក- របស់បុគ្គលដែលបានស្នើសុំលុបតាមមាត្រា១៨ ឬមាត្រា១៩ នៃអនុក្រឹត្យនេះ ។
- ខ- របស់បុគ្គលដែលមិនបានស្នើសុំលុបការចុះបញ្ជី ដោយប្រធាននាយកដ្ឋានពន្ធដារយល់ឃើញថាបុគ្គលនោះគ្មានការតម្រូវឬគ្មានសិទ្ធិចុះបញ្ជីតាមមាត្រា២ នៃអនុក្រឹត្យនេះ ។

គ- របស់បុគ្គលដែលមិនបានដាក់ពាក្យស្នើសុំលុបចោលការចុះបញ្ជី ក៏ប៉ុន្តែមិនបានប្រកាសអំពីការផ្គត់ផ្គង់ជាប់អតប ក្នុងរយៈពេល៣ខែប្រតិទិនជាប់គ្នា ។

**មាត្រា២២ .-**

ប្រធាននាយកដ្ឋានពន្ធដារ មានសិទ្ធិលុបចោលការចុះបញ្ជីរបស់បុគ្គលដែលស្នើសុំចុះបញ្ជីតាមកថាខ័ណ្ឌ៤ នៃមាត្រា២ នៃអនុក្រឹត្យនេះ ក្នុងករណីដែលបុគ្គលនោះ :

ក- ពុំមានទីលំនៅ ឬ កន្លែងអាជីវកម្មជាប់លាប់ ។

ខ- មិនបានរក្សាទុកបញ្ជីគណនេយ្យត្រឹមត្រូវដែល ទាក់ទិនទៅនឹងសកម្មភាពអាជីវកម្មណាមួយរបស់បុគ្គលនោះ ។

គ- មិនបានដាក់លិខិតប្រកាសអតបទៀងទាត់និងត្រឹមត្រូវ ដូចមានចែងក្នុងមាត្រា៧០ នៃច្បាប់ស្តីពីសារពើពន្ធ ។

**មាត្រា២៣ .-**

នាយកដ្ឋានពន្ធដារត្រូវជូនដំណឹងជាលាយល័ក្ខអក្សរដល់បុគ្គលជាប់អតប អំពីការសំរេចយល់ព្រម ឬមិនយល់ព្រមលុបចោលការចុះបញ្ជីតាមជំពូកនេះ ក្នុងរយៈពេល៣០ថ្ងៃក្រោយពេលទទួលពាក្យស្នើសុំលុបចោលការចុះបញ្ជីតាមកថាខ័ណ្ឌ ក នៃមាត្រា២១ នៃអនុក្រឹត្យនេះ ឬ ក្នុងរយៈពេល៣០ថ្ងៃក្រោយការសំរេចលុបចោលការចុះបញ្ជីតាមកថាខ័ណ្ឌ ខ នៃមាត្រា២១ និងមាត្រា២២ នៃអនុក្រឹត្យនេះ។

**មាត្រា២៤ .-**

ការលុបចោលការចុះបញ្ជីត្រូវមានប្រសិទ្ធិភាពចាប់ពីថ្ងៃ ដែលការចុះបញ្ជីត្រូវបានលុបចោល ។

**មាត្រា២៥ .-**

ក្នុងករណីដែលការចុះបញ្ជីរបស់បុគ្គលត្រូវបានលុបចោល នាយកដ្ឋានពន្ធដារត្រូវលុបឈ្មោះបុគ្គលនោះ និងពត៌មានលំអិតដូចមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យនេះចេញពីបញ្ជីបុគ្គលជាប់អតប ។

**មាត្រា២៦ .-**

នៅពេលដែលបុគ្គលជាប់អតបត្រូវបានលុបឈ្មោះចេញពីបញ្ជីតាមជំពូកនេះ បុគ្គលជាប់អតបនោះត្រូវបានចាត់ទុកថាបានធ្វើការផ្គត់ផ្គង់ជាប់អតប នូវទំនិញទាំងអស់ដែលមាននៅក្នុងដៃ រួមទាំងទំនិញជាមូលធនផង ហើយត្រូវទទួលខុសត្រូវក្នុងការបង់អតបលើធាតុចេញ លើរាល់ទំនិញទាំងអស់ដែលបានទទួលឥណទានអតបលើធាតុចូលរួចមកហើយ ។ អតបលើធាតុចេញដែលត្រូវបង់ ត្រូវផ្អែកតាមតម្លៃទីផ្សារនៃទំនិញ នៅពេលលុបចោលការចុះបញ្ជីនោះ។

**មាត្រា២៧ .-**

ការលុបចោលការចុះបញ្ជីរបស់បុគ្គល ពុំមានផលប៉ះពាល់ដល់ កាតព្វកិច្ច បំណុល និងទោសទណ្ឌ របស់បុគ្គល ដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ រួមទាំងការតម្រូវឱ្យដាក់លិខិតប្រកាសតាមមាត្រា៧០ នៃច្បាប់ស្តីពីសារពើពន្ធ ដែលបុគ្គលបានធ្វើឬមិនបានធ្វើនៅពេលដែលខ្លួនជាបុគ្គលជាប់អតប ។

## ជំពូកទី៦

## ឥណទានអតបលើធាតុចូល

**មាត្រា២៨ .-**

ឥណទានអតបលើធាតុចូលនៅពេលចាប់ផ្តើម អនុវត្តអាករលើតម្លៃបន្ថែម ត្រូវបានកំណត់ដូចតទៅ :

១. បន្ទាប់ពីបានចុះបញ្ជី បុគ្គលជាប់អតបត្រូវបានអនុញ្ញាតឱ្យនូវឥណទានសម្រាប់អតបលើធាតុចូល ដែលបានបង់ឬត្រូវបង់ចំពោះ :

ក- ការផ្គត់ផ្គង់ជាប់អតបទាំងអស់នូវទំនិញ រួមទាំងទ្រព្យសកម្មជាមូលធន ដែលបុគ្គលបានទទួលមុនពេលចុះបញ្ជី ។

ខ- ការនាំចូលទាំងអស់នូវទំនិញរួមទាំងទ្រព្យសកម្មជាមូលធន ដែលបុគ្គលបានធ្វើមុនពេលចុះបញ្ជី ។

២. ល័ក្ខខ័ណ្ឌនៃការអនុញ្ញាតឱ្យជាឥណទានត្រូវបានកំណត់ដូចតទៅ :

ក- ទំនិញត្រូវបានទិញសម្រាប់ការលក់ជាប់អតប ឬសម្រាប់ប្រើប្រាស់ដើម្បីធ្វើការផ្គត់ផ្គង់ជាប់អតបរបស់បុគ្គលជាប់អតប ។

ខ- ទំនិញដែលមានចុះក្នុងបញ្ជីសារពើភ័ណ្ឌ ត្រូវនៅក្នុងដៃនាកាលបរិច្ឆេទមានប្រសិទ្ធិភាពនៃការចុះបញ្ជី ។

គ- ការផ្គត់ផ្គង់ ឬ ការនាំចូលទាំងនោះត្រូវបានធ្វើឡើងមិនលើសពី៦០ថ្ងៃ មុនកាលបរិច្ឆេទមានប្រសិទ្ធិភាពនៃការចុះបញ្ជី ។

ឃ- ពាក្យស្នើសុំឥណទាន ត្រូវបានធ្វើឡើងតាមទម្រង់ដែលនាយកដ្ឋានពន្ធដារបានកំណត់ ។

ង- ត្រូវមានឯកសារភស្តុតាងត្រឹមត្រូវច្បាស់លាស់ជូននាយកដ្ឋានពន្ធដារ បញ្ជាក់ថាបុគ្គលបានបង់អតប ពិតមែន ដែលអាចអនុញ្ញាតជាឥណទាន ។

**មាត្រា២៩ .-**

នៅពេលបុគ្គលជាប់អតបគណនាប្រាក់អតបដែលត្រូវបង់ក្នុងខែ បុគ្គលជាប់អតបនោះត្រូវបានអនុញ្ញាតឱ្យជាឥណទានសម្រាប់តែអតបដែលបានបង់លើ :

ក- រាល់ការផ្គត់ផ្គង់ជាប់អតបដែលបុគ្គលជាប់អតបបានទទួលក្នុងខែ ។

ខ- រាល់ការនាំចូលទំនិញដោយបុគ្គលជាប់អតបក្នុងខែ ។

ឥណទានអតប ត្រូវបានអនុញ្ញាតផ្តល់ឱ្យតែចំពោះការផ្គត់ផ្គង់ជាប់អតប ឬការនាំចូលសម្រាប់ប្រើប្រាស់ដើម្បីធ្វើការផ្គត់ផ្គង់ជាប់អតបតែប៉ុណ្ណោះ ។

**មាត្រា៣០ .-**

ឥណទានអតបលើធាតុចូលត្រូវកើតមានឡើងនៅពេលដូចខាងក្រោមនេះ :

ក- នៅពេលដែលទំនិញឬសេវា ត្រូវបានផ្គត់ផ្គង់ឱ្យបុគ្គលជាប់អតប ឬនាំចូលដោយបុគ្គលជាប់អតបក្នុងករណីឥណទានអតប ដូចមានចែងក្នុងមាត្រា២៩ នៃអនុក្រឹត្យនេះ ។

ខ- នៅពេលបុគ្គលជាប់អតបត្រូវបានចុះបញ្ជី ក្នុងករណីឥណទានអតប ដូចមានចែងក្នុងមាត្រា២៨ នៃអនុក្រឹត្យនេះ ។

**មាត្រា៣១ .-**

មិនត្រូវបានអនុញ្ញាតឱ្យជាឥណទានអតបលើធាតុចូលទេ ចំពោះប្រាក់អតប ដែលបានបង់លើ :

ក- ចំណាយទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ លើកលែងតែបុគ្គលជាប់អតប មានអាជីវកម្មជាអ្នកផ្គត់ផ្គង់ការទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ ។

ខ- ការទិញឬការនាំចូល រថយន្ត លើកលែងតែបុគ្គលជាប់អតបប្រកបអាជីវកម្មជាអ្នកលក់ ឬជួលរថយន្ត ។

គ- ការទិញឬការនាំចូលផលិតផលគេលសិលាមួយចំនួន លើកលែងតែបុគ្គលជាប់អតបប្រកបអាជីវកម្មជាអ្នកផ្គត់ផ្គង់ផលិតផលគេលសិលាទាំងនោះ ។

វៀរលែងតែមានចែងយ៉ាងណាផ្សេងវិញនោះ សម្រាប់គោលដៅនៃអនុក្រឹត្យនេះ :

- ពាក្យ " ការទទួលភ្ញៀវ " មានន័យថា ការផ្គត់ផ្គង់ម្ហូបអាហារ ភេសជ្ជៈ ថ្នាំជក់ កន្លែងស្នាក់អាស្រ័យ ឬ បដិសណ្ឋារកិច្ចណាមួយ ។

- ពាក្យ "រថយន្ត" សំដៅដល់រថយន្តសម្រាប់តែដឹកមនុស្សដែលមានកន្លែងអង្គុយមិនលើសពី ១០។
- ពាក្យ "ផលិតផលតេលសិលា" សំដៅដល់ប្រេងសាំងធម្មតា ប្រេងសាំងស៊ុបពែរ និងប្រេងរំអិល ។

**មាត្រា៣២ .-**

ក្នុងករណីទំនិញឬសេវាទិញចូល ត្រូវបានប្រើប្រាស់មួយចំណែកជាការផ្គត់ផ្គង់ជាប់អតប និងមួយចំណែកទៀតជាការផ្គត់ផ្គង់មិនជាប់អតប ឥណទានអតបត្រូវបានអនុញ្ញាតឱ្យតែចំពោះចំណែកដែលបានប្រើប្រាស់ជាការផ្គត់ផ្គង់ជាប់អតប ប៉ុណ្ណោះ ។

**មាត្រា៣៣ .-**

អតបលើធាតុចូលដែលអាចអនុញ្ញាតជាឥណទានឱ្យបុគ្គលជាប់អតបក្នុងរយៈពេលជាប់អតបគឺ :

១- អតបលើធាតុចូលទាំងអស់ដែលមានបញ្ជាក់នៅក្នុងមាត្រា២៩ នៃអនុក្រឹត្យនេះ ក្នុងករណីដែលការផ្គត់ផ្គង់ទាំងអស់របស់បុគ្គលជាប់អតបក្នុងរយៈពេលជាប់អតប ជាការផ្គត់ផ្គង់ជាប់អតប ។

២- ក្នុងករណីដែលការផ្គត់ផ្គង់របស់បុគ្គលជាប់អតបនៅក្នុងរយៈពេលជាប់អតប មានតែមួយផ្នែកប៉ុណ្ណោះ ជាការផ្គត់ផ្គង់ជាប់អតប ចំនួនឥណទានដែលអាចផ្តល់ឱ្យត្រូវបានគណនាតាមរូបមន្ត $\text{ក} \times \frac{\text{ខ}}{\text{គ}}$ ។

ក : ទឹកប្រាក់សរុបនៃ អតបលើធាតុចូលក្នុងរយៈពេលជាប់អតប

ខ : តម្លៃសរុបមិនទាន់គិតអតប នៃការផ្គត់ផ្គង់ជាប់អតប ដែលធ្វើឡើងដោយបុគ្គលជាប់អតបក្នុងរយៈពេលជាប់អតប

គ : តម្លៃសរុបមិនទាន់គិតអតប នៃការផ្គត់ផ្គង់ជាប់អតបនិងការផ្គត់ផ្គង់មិនជាប់អតបដែលធ្វើឡើងដោយបុគ្គលជាប់អតបក្នុងរយៈពេលជាប់អតប លើកលែងតែតម្លៃនៃការផ្គត់ផ្គង់មិនជាប់អតបនៃការផ្ទេរអាជីវកម្ម ។

**មាត្រា៣៤ .-**

ក្នុងករណីដែលប្រភាគ $\frac{\text{ខ}}{\text{គ}}$ ក្នុងមាត្រា៣៣ នៃអនុក្រឹត្យនេះ តិចជាង ០.០៥ បុគ្គលជាប់អតបមិនត្រូវបានផ្តល់ឥណទានអតបលើធាតុចូលនៅក្នុងរយៈពេលជាប់អតបទេ ។

**មាត្រា៣៥ .-**

ក្នុងករណីដែលប្រភាគ $\frac{\text{ខ}}{\text{គ}}$ ក្នុងមាត្រា៣៣ នៃអនុក្រឹត្យនេះ ចាប់ពី ០.០៥ ដល់ ០.៩៥ បុគ្គលជាប់អតបត្រូវបានអនុញ្ញាតនូវឥណទានអតបលើធាតុចូល តាមសមាមាត្រនៃរូបមន្តដូចមានចែងក្នុងកថាខ័ណ្ឌ ២ នៃមាត្រា៣៣ នៃអនុក្រឹត្យនេះ។

**មាត្រា៣៦ .-**

ក្នុងករណីដែលប្រភាគ $\frac{\text{ខ}}{\text{គ}}$ ក្នុងមាត្រា៣៣ នៃអនុក្រឹត្យនេះ ច្រើនជាង ០.៩៥ បុគ្គលជាប់អតបត្រូវបានអនុញ្ញាតនូវឥណទានអតបចំពោះអតបលើធាតុចូលទាំងអស់នៅក្នុងរយៈពេលជាប់អតប ។

**មាត្រា៣៧ .-**

ក្នុងករណីដែលបុគ្គលជាប់អតបធ្វើការផ្គត់ផ្គង់ជាប់អតបផងនិងការផ្គត់ផ្គង់មិនជាប់អតបផង មានផលវិបាកដោយសារការអនុវត្តន៍បទប្បញ្ញត្តិនៃកថាខ័ណ្ឌ២នៃមាត្រា៣៣នៃអនុក្រឹត្យនេះ នាយកដ្ឋានពន្ធដារអាចអនុញ្ញាតឱ្យបុគ្គលជាប់អតបអនុវត្តតាមរបៀបមួយផ្សេងទៀតដូចខាងក្រោមនេះ ដើម្បីគណនាអតបលើធាតុចូលដែលអាចកាត់កងបាន :

ក- បែងចែកអតបលើធាតុចូលនៃការផ្គត់ផ្គង់ជាប់អតប និងអតបលើធាតុចូលនៃការផ្គត់ផ្គង់មិនជាប់អតបក្នុងករណីដែលអាចធ្វើទៅបាន ។ ក្នុងករណីនេះបុគ្គលជាប់អតបអាចស្នើសុំឥណទាន

សម្រាប់អតបលើធាតុចូលទាំងអស់ដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ជាប់អតប តែមិនអាចស្នើសុំឥណទានសម្រាប់អតបលើធាតុចូលដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់មិនជាប់អតបទេ ។

ខ- ចំពោះអតបលើធាតុចូលនៅសល់ ដែលមិនអាចបែងចែកតាមវាក្យខ័ណ្ឌ ក នៃមាត្រានេះបាន ឥណទានអតបត្រូវគណនាតាមបទប្បញ្ញត្តិនៃកថាខ័ណ្ឌ ២ នៃមាត្រា៣៣ នៃអនុក្រឹត្យនេះ ។

**មាត្រា៣៨ .-**

នៅក្នុងខែដំបូងនៃឆ្នាំប្រតិទិនបន្ទាប់ បុគ្គលជាប់អតបដែលបានគណនាអតបលើធាតុចូល តាមកថាខ័ណ្ឌ ២ នៃមាត្រា៣៣ វាក្យខ័ណ្ឌ ខ នៃមាត្រា៣៧ នៃអនុក្រឹត្យនេះ ត្រូវធ្វើការគណនាឥណទានអតបដែលអាចកាត់កងបានសម្រាប់ឆ្នាំប្រតិទិនកន្លងមក តាមរូបមន្តក្នុងកថាខ័ណ្ឌ ២ នៃមាត្រា៣៣ នៃអនុក្រឹត្យនេះ ដោយផ្អែកលើចំនួនទឹកប្រាក់សរុបប្រចាំឆ្នាំនៃ :

ក- អតបលើធាតុចូលដែលមិនអាចបែងចែកបាន ។

ខ- ការផ្គត់ផ្គង់ជាប់អតបមិនទាន់គិតអតប ។

គ- ការផ្គត់ផ្គង់ជាប់អតបមិនទាន់គិតអតប និងការផ្គត់ផ្គង់មិនជាប់អតប លើកលែងតែការផ្គត់ផ្គង់មិនជាប់អតបនៃការផ្ទេរអាជីវកម្ម ។

**មាត្រា៣៩ .-**

ក្នុងករណីដែលឥណទានអតបប្រចាំឆ្នាំប្រតិទិនមានចំនួន :

ក- ច្រើនជាងឥណទានអតបក្នុងលិខិតប្រកាស សមតុល្យត្រូវចាត់ទុកជាឥណទានអតប សម្រាប់ខែដំបូងនៃឆ្នាំប្រតិទិនបន្ទាប់ ។

ខ- តិចជាងឥណទានអតបក្នុងលិខិតប្រកាស សមតុល្យត្រូវចាត់ទុកជាឥណពន្ធអតប ដែលត្រូវបង់តាមរយៈលិខិតប្រកាសអតបសម្រាប់ខែដំបូងនៃឆ្នាំប្រតិទិនបន្ទាប់ ។

សម្រាប់គោលដៅនៃមាត្រានេះ :

- ពាក្យ " ឥណទានអតបប្រចាំឆ្នាំប្រតិទិន " មានន័យថា អតបលើធាតុចូលសរុបដែលអាចកាត់កងបានសម្រាប់ឆ្នាំប្រតិទិន ដោយផ្អែកលើការគណនាសរុបប្រចាំឆ្នាំ ។
- ពាក្យ " ឥណទានអតបក្នុងលិខិតប្រកាស " មានន័យថា អតបលើធាតុចូលសរុបដែលបានស្នើសុំជាឥណទាន ក្នុងខែនីមួយៗនៃឆ្នាំប្រតិទិន ។
- ពាក្យ " ឥណពន្ធអតប " មានន័យថា ឥណទានអតបប្រចាំឆ្នាំប្រតិទិនតិចជាងឥណទានអតបក្នុងលិខិតប្រកាស ។
- ពាក្យ " សមតុល្យ " គឺជាចំនួនលំអៀង នៃឥណទានអតបប្រចាំឆ្នាំប្រតិទិន និងឥណទានអតបក្នុងលិខិតប្រកាស ។

**មាត្រា៤០ .-**

ដើម្បីស្នើសុំឥណទានអតបលើធាតុចូលដែលអាចកាត់កងបានតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ បុគ្គលជាប់អតបត្រូវមាន :

ក- ច្បាប់ដើមនៃវិក្កយប័ត្រអតបសម្រាប់ការផ្គត់ផ្គង់ជាប់អតប ។

ខ- ប្រតិវេទន៍នាំចូលដែលបញ្ជាក់ដោយទីចាត់ការគយនិងរដ្ឋាករ ជាភស្តុតាងនៃទឹកប្រាក់អតបដែលបានបង់លើការនាំចូលទំនិញ ។

**មាត្រា៤១ .-**

ការបង្វិលសង ឥណទានអតបលើធាតុចូលលើស ត្រូវបានកំណត់ដូចខាងក្រោមនេះ :

១. ដូចមានចែងក្នុងមាត្រា៧២ និងមាត្រា៧៣ នៃច្បាប់ស្តីពីសារពើពន្ធ បុគ្គលជាប់អតបដែលធ្វើការនាំចេញឬបានចុះបញ្ជីអតបសម្រាប់សហគ្រាសវិនិយោគ បុគ្គលនោះអាចស្នើសុំបង្វិលសងឥណទានអតបលើធាតុចូលលើសជារៀងរាល់ខែ ។ រីឯបុគ្គលជាប់អតបដទៃទៀតដែលមានឥណទានអតបលើធាតុចូលលើសក្នុងរយៈពេល៣ខែជាប់បន្តឬច្រើនជាង បុគ្គលនោះអាចស្នើសុំទៅនាយកដ្ឋានពន្ធដារឱ្យបង្វិលសងនូវឥណទានអតបលើធាតុចូលលើសនោះនៅដំណាច់ខែទី៣ ឬនៅក្នុងខែណាមួយជាបន្តមកទៀត ។

២. ចំពោះបុគ្គលជាប់អតបស្នើសុំបង្វិលសងឥណទានអតបលើធាតុចូលលើស ក៏ប៉ុន្តែមិនបានប្រកាសនូវការផ្គត់ផ្គង់ជាប់អតប នាយកដ្ឋានពន្ធដារមិនត្រូវធ្វើការបង្វិលសងឡើយ លើកលែងតែបុគ្គលជាប់អតបនោះបានចុះបញ្ជីអតបសម្រាប់សហគ្រាសវិនិយោគ។

៣. នាយកដ្ឋានពន្ធដារត្រូវបង្វិលសងឥណទានអតបលើធាតុចូលលើស នៅដំណាច់ខែ បន្ទាប់ពីខែដែលការស្នើសុំបានធ្វើឡើង ។

៤. បើសិនជាបុគ្គលជាប់អតប ដែលស្នើសុំបង្វិលសងឥណទានអតបលើធាតុចូលលើស មានការតម្រូវពីនាយកដ្ឋានពន្ធដារឱ្យផ្តល់ឯកសារគណនេយ្យ ឬកំណត់ត្រា ដើម្បីបញ្ជាក់ភស្តុតាងនៃការស្នើសុំបង្វិលសង មិនបានផ្តល់ឯកសារទាំងនោះទៅតាមបែបបទដែលកំណត់ដោយនាយកដ្ឋានពន្ធដារក្នុងរយៈពេល១៥ថ្ងៃ ក្រោយមានការតម្រូវទេនោះ នាយកដ្ឋានពន្ធដារត្រូវបង្វិលសងឥណទានអតបលើធាតុចូលលើសនោះ នៅដំណាច់ខែបន្ទាប់ពីខែដែលបុគ្គលជាប់អតប បានផ្តល់ឯកសារគ្រប់គ្រាន់តាមការតម្រូវ ។

៥. ទម្រង់បែបបទ នៃការបង្វិលសង ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៧
## វិក្កយប័ត្រអតប

**មាត្រា៤២ .-**

បន្ថែមលើសេចក្តីចែងនៃមាត្រា៧៧ នៃច្បាប់ស្តីពីសារពើពន្ធ ការប្រើប្រាស់វិក្កយប័ត្រអតប ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិដូចតទៅ :

ក- នៅពេលធ្វើការផ្គត់ផ្គង់ទៅឱ្យបុគ្គលជាប់អតបម្នាក់ទៀត បុគ្គលជាប់អតបត្រូវចេញវិក្កយប័ត្រអតបដល់បុគ្គលជាប់អតបម្នាក់ទៀតនោះ ។

ខ- វិក្កយប័ត្រអតបត្រូវមានចុះលេខអត្តសញ្ញាណកម្មនៃការចុះបញ្ជីអតប នៃអ្នកទិញ

គ- បុគ្គលជាប់អតបអាចទាមទារឱ្យបុគ្គលជាប់អតបម្នាក់ទៀត ដែលជាអ្នកធ្វើការផ្គត់ផ្គង់ទំនិញឬសេវាឱ្យខ្លួន ផ្តល់វិក្កយប័ត្រអតបនៃការផ្គត់ផ្គង់នោះ ។

ឃ- បុគ្គលជាប់អតប ដែលមិនបានផ្តល់វិក្កយប័ត្រអតប ឱ្យទៅបុគ្គលជាប់អតបផ្សេងទៀតត្រូវទទួលទោសទណ្ឌ ដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ ។

ង- បុគ្គលជាប់អតបមិនត្រូវចេញវិក្កយប័ត្រអតប ទៅឱ្យអតិថិជនដែលមិនមែនជាបុគ្គលជាប់អតបទេ ប៉ុន្តែត្រូវចេញវិក្កយប័ត្រធម្មតា ឬ ឯកសារផ្សេងទៀតទៅឱ្យអតិថិជនដែលមិនមែនជាបុគ្គលជាប់អតប ។

ច- នៅពេលធ្វើការផ្គត់ផ្គង់ បុគ្គលជាប់អតបត្រូវរក្សាសំណៅដើមនៃ វិក្កយប័ត្រអតប វិក្កយប័ត្រធម្មតា ឬឯកសារផ្សេងទៀតដែលបានចេញឱ្យអតិថិជនរបស់ខ្លួន ។

## ជំពូកទី ៨
## ការផ្គត់ផ្គង់មិនជាប់អតបចំពោះបេសកកម្មទូតនិងអង្គការអន្តរជាតិ

**មាត្រា៤៣ .-**

ការផ្គត់ផ្គង់មិនជាប់អតបចំពោះបេសកកម្មទូតនិងអង្គការអន្តរជាតិ ត្រូវបានកំណត់ដូចតទៅ :

១. ការនាំចូលទំនិញសម្រាប់ ឬដោយបេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា សម្រាប់យកមកប្រើប្រាស់ក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន ត្រូវកំណត់ថាជាការផ្គត់ផ្គង់មិនជាប់អតប ។ ការផ្គត់ផ្គង់មិនជាប់អតបត្រូវបានផ្តល់ឱ្យតែក្នុងករណីមានការបញ្ជាក់ពីប្រធានបេសកកម្ម និងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជូននាយកដ្ឋានពន្ធដារថា ទំនិញទាំងនោះត្រូវបាននាំចូលមកសម្រាប់គោលដៅនៃការប្រើប្រាស់ដូចខាងលើនេះមែន ។

២. បេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា អាចដាក់ពាក្យស្នើសុំបង្វិលសងប្រាក់អតបលើទំនិញដែលបានទិញក្នុងស្រុក ដែលមានចុះនៅក្នុងបញ្ជីរាយមុខទំនិញ កំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ការបង្វិលសងប្រាក់អតបអាចអនុវត្តទៅបានតែក្នុងករណីមានការបញ្ជាក់ពីប្រធានបេសកកម្ម និងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជូននាយកដ្ឋានពន្ធដារថា ទំនិញត្រូវបានទិញសម្រាប់យកទៅប្រើប្រាស់នៅក្នុង ការបំពេញមុខងារជាផ្លូវការរបស់អង្គភាពសាមី ។

៣. ការស្នើសុំបង្វិលសងប្រាក់អតបដូចមានចែងក្នុងកថាខ័ណ្ឌ២ នៃមាត្រានេះ ត្រូវអនុវត្តតាមលក្ខខ័ណ្ឌដូចខាងក្រោម:

ក- ពាក្យស្នើសុំត្រូវធ្វើតាមទម្រង់ដែលនាយកដ្ឋានពន្ធដារបានកំណត់ ។

ខ- វិក្កយប័ត្រទិញនីមួយៗ ត្រូវមានទឹកប្រាក់សរុបមិនទាន់គិតអតប នៃទំនិញដែលបានអនុញ្ញាតឱ្យបង្វិលសងប្រាក់អតប ចាប់ពី ២០០.០០០ រៀលឡើងទៅ ។

គ- ពាក្យស្នើសុំបង្វិលសងនីមួយៗត្រូវមានទឹកប្រាក់សរុបមិនទាន់គិតអតបចាប់ពី ១.០០០.០០០រៀលឡើងទៅ

ឃ- ការស្នើសុំអាចធ្វើបានតែ១ ដងក្នុងមួយខែ ។

ចំពោះការស្នើសុំបង្វិលសងប្រាក់អតប ដូចមានចែងក្នុងកថាខ័ណ្ឌ២នៃមាត្រានេះ នាយកដ្ឋានពន្ធដារត្រូវជូនដំណឹងពីការយល់ព្រម ឬមិនយល់ព្រមបង្វិលសងប្រាក់អតប ក្នុងរយៈពេល១ខែ ក្រោយពេលទទួលពាក្យស្នើសុំ ។

## ជំពូកទី ៩
## ទីកន្លែង ពិធាន និងនីតិវិធី សម្រាប់ការផ្គត់ផ្គង់ជាប់អតប

**មាត្រា៤៤ .-**

ការផ្គត់ផ្គង់ទំនិញ ត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាទំនិញនោះត្រូវបានប្រគល់ឱ្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះបីការប្រគល់នោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងក្តី ។ ចំពោះករណីដែលការផ្គត់ផ្គង់ត្រូវមានការដឹកជញ្ជូន ការផ្គត់ផ្គង់ត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាទំនិញនោះស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដែលការដឹកជញ្ជូនត្រូវបានចាប់ផ្តើម ។

**មាត្រា៤៥ .-**

ការផ្គត់ផ្គង់សេវា ត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាសេវានោះត្រូវបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយឡែកតែ :

ក- ការផ្គត់ផ្គង់សេវាដែលជាប់ទាក់ទងនឹងអចលនទ្រព្យ ត្រូវកំណត់ថាសេវានោះបានធ្វើឡើងនៅទីកន្លែងដែលអចលនទ្រព្យនោះស្ថិតនៅ ។

ខ- ការផ្គត់ផ្គង់សេវាដែលជាប់ទាក់ទងនឹងការដឹកជញ្ជូន ត្រូវកំណត់ថាសេវានោះបានធ្វើឡើងនៅទីកន្លែងនៃការដឹកជញ្ជូននោះ ។

គ- ការផ្គត់ផ្គង់សេវាសម្រាប់ការប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ថាបានធ្វើឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៤៦ .-**

ទីកន្លែងផ្គត់ផ្គង់នៃការនាំចូល គឺជាទីកន្លែងដែលទំនិញត្រូវបាននាំចូលមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា និងជាទីកន្លែងត្រូវបង់ពន្ធគយនិងបន្ទុកសារពើពន្ធផ្សេងទៀតនៃការនាំចូល ។

**មាត្រា៤៧ .-**

ក្នុងករណីដែលបុគ្គលជាប់អតបធ្វើការផ្គត់ផ្គង់លាយឡំគ្នារវាងទំនិញនិងសេវា ការផ្គត់ផ្គង់ទាំងនោះត្រូវបានកំណត់ដូចតទៅ :

១. ការផ្គត់ផ្គង់នូវសេវាបន្ទាប់បន្សំដែលរួមជាមួយនិងការផ្គត់ផ្គង់ទំនិញ គឺជាចំណែកមួយនៃការផ្គត់ផ្គង់ទំនិញ ។

២. ការផ្គត់ផ្គង់នូវទំនិញបន្ទាប់បន្សំដែលរួមជាមួយនិងការផ្គត់ផ្គង់សេវា គឺជាចំណែកមួយនៃការផ្គត់ផ្គង់សេវា ។

៣. ការផ្គត់ផ្គង់នូវសេវាបន្ទាប់បន្សំដែលរួមជាមួយនិងការនាំចូល គឺជាចំណែកមួយនៃការនាំចូល ។

៤. វិធាន និងនីតិវិធី សម្រាប់អនុវត្តមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា៤៨ .-**

ពេលផ្គត់ផ្គង់ ត្រូវបានកំណត់ដូចខាងក្រោមនេះ ដើម្បីគណនាប្រាក់អតប សម្រាប់រយៈពេលជាប់អតបនីមួយ ៗ ដែលបុគ្គលជាប់អតប ត្រូវប្រកាសបង់ជូននាយកដ្ឋានពន្ធដារ ។

១. ពេលផ្គត់ផ្គង់ទំនិញ ឬសេវា ត្រូវបានកំណត់ដូចតទៅ :

ក- ពេលផ្គត់ផ្គង់ទំនិញនិងសេវា គឺជាពេលដែលអ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយប័ត្រ ឬជាពេលដែលអ្នកផ្គត់ផ្គង់បានចេញវិក្កយប័ត្រ ប្រសិនបើវិក្កយប័ត្រនោះត្រូវបានចេញមុនពេលដែលអ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយប័ត្រ ។ អ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយប័ត្រអតប យ៉ាងយឺតបំផុត ៧ថ្ងៃក្រោយការបញ្ជូនទំនិញឬការបំពេញសេវា ឬ ក្រោយការទូទាត់ ក្នុងករណីដែលការទូទាត់ត្រូវបានធ្វើឡើងមុនការបញ្ជូនទំនិញឬការបំពេញសេវា ។

ខ- ក្នុងករណីដែលទំនិញត្រូវបានយកទៅប្រើប្រាស់ផ្ទាល់ខ្លួន ពេលផ្គត់ផ្គង់គឺជាពេលដែលទំនិញនោះត្រូវបានយកទៅប្រើប្រាស់ដំបូង ។

គ- ក្នុងករណីទំនិញឬសេវាត្រូវបានផ្គត់ផ្គង់ក្នុងលក្ខណៈជាអំណោយ ពេលផ្គត់ផ្គង់គឺជាពេលដែលទំនិញត្រូវបានប្រគល់ឱ្យ ទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងក្តី ឬពេលដែលសេវាផ្គត់ផ្គង់ឱ្យត្រូវបានបំពេញរួចរាល់ ។

២. ពេលផ្គត់ផ្គង់ទំនិញក្រោមកិច្ចសន្យាជួលដោយមានល័ក្ខខ័ណ្ឌទិញផ្តាច់ ឬកតិសន្យាហិរញ្ញវត្ថុ គឺជាពេលដែលទំនិញត្រូវបានប្រគល់ឱ្យ ទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងក្តី ។

៣. ក្នុងករណីដែល :

- ទំនិញត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យាជួល ឬ
- ទំនិញឬសេវាត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យាឬច្បាប់ដែលចែងអំពីការទូទាត់ច្រើនលើក ឬ
- សេវាត្រូវបានផ្គត់ផ្គង់ជាប់បន្ត

ទំនិញឬសេវានោះ ត្រូវចាត់ទុកថាបានផ្គត់ផ្គង់រួចរាល់ចំពោះចំណែកដែលបានផ្គត់ផ្គង់រួចរាល់ក្នុងរយៈពេលនៃកិច្ចសន្យាឬរយៈពេលដែលច្បាប់បានកំណត់ ហើយពេលផ្គត់ផ្គង់នៃចំណែកដែលបានផ្គត់ផ្គង់រួចរាល់នីមួយៗ គឺជាកាលបរិច្ឆេទមុនគេ ក្នុងចំណោមកាលបរិច្ឆេទដែលការទូទាត់ត្រូវដល់កំណត់ និងកាលបរិច្ឆេទដែលបានទទួលការទូទាត់ ។

៤- ចំពោះការនាំចូលទំនិញ ពេលផ្គត់ផ្គង់គឺជាពេលដែលអ្នកនាំចូលដាក់លិខិតប្រកាសជូនអាជ្ញាធរគយ និងរដ្ឋាករ ទៅតាមគោលការណ៍ជាធរមាន ហើយពន្ធគយនិងអាករនានាត្រូវបានបង់ ។

## ជំពូកទី ១០

## ការកែតម្រូវទឹកប្រាក់អតប

**មាត្រា៥៩ .-**

វិធាន និង នីតិវិធី សម្រាប់កែតម្រូវទឹកប្រាក់អតបនៅក្រោយពេលផ្គត់ផ្គង់ឬពេលចេញវិក្កយប័ត្រ ត្រូវបានកំណត់ដូចតទៅ :

១. បុគ្គលជាប់អតបដែលបានចេញវិក្កយប័ត្រអតបឬបានដាក់លិខិតប្រកាសប្រចាំខែរួចហើយ បុគ្គលនោះអាចធ្វើការកែតម្រូវទឹកប្រាក់អតបឡើងវិញបានបើសិនជាមានហេតុការណ៍ដូចខាងក្រោមនេះបានកើតឡើង :

- ការផ្គត់ផ្គង់ត្រូវបានលុបចោល ឬ
- ចរិតនៃការផ្គត់ផ្គង់ត្រូវបានប្រែប្រួល ឬបានផ្លាស់ប្តូរជាមូលដ្ឋាន ឬ
- អត្ថប្រយោជន៍សម្រាប់ការផ្គត់ផ្គង់ដែលបានព្រមព្រៀងគ្នាពីពេលមុន ត្រូវបានប្រែប្រួល ឬបានផ្លាស់ប្តូរដោយកិច្ចព្រមព្រៀងថ្មីជាមួយនឹងអ្នកទទួលការផ្គត់ផ្គង់ ដោយមូលហេតុនៃការបញ្ចុះថ្លៃ ឬ ដោយហេតុផលផ្សេងទៀត ឬ
- ទំនិញឬចំណែកណាមួយនៃទំនិញឬសំបកវេចខ្ចប់ ត្រូវបានបញ្ជូនត្រឡប់មកអ្នកផ្គត់ផ្គង់វិញ ឬសេវាមិនត្រូវបានបំពេញរួចរាល់ ។

២. ក្នុងករណីមានការកែតម្រូវដូចមានចែងក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះ បុគ្គលជាប់អតបត្រូវធ្វើការកែតម្រូវទឹកប្រាក់អតបរបស់ខ្លួនដូចតទៅ :

ក- បើសិនជាប្រាក់អតបលើធាតុចេញកែតម្រូវមានចំនួនលើសពីប្រាក់អតបលើធាតុចេញដែលបុគ្គលជាប់អតបបានកត់ត្រា ចំនួនលើសត្រូវបានចាត់ទុកជាប្រាក់អតបដែលបុគ្គលជាប់អតបបានប្រមូលនៅក្នុងខែដែលហេតុការណ៍ដូចមានចែងក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះបានកើតឡើង ។

ខ- បើសិនជាប្រាក់អតបលើធាតុចេញដែលបុគ្គលជាប់អតបបានកត់ត្រាមានចំនួនលើសពីប្រាក់អតបលើធាតុចេញកែតម្រូវ ចំនួនលើសត្រូវបានចាត់ទុកជាឥណទានអតបសម្រាប់ខែដែលហេតុការណ៍ដូចមានចែងក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះបានកើតឡើង ។

៣. ចំពោះការផ្គត់ផ្គង់ឱ្យបុគ្គលដែលមិនមែនជាបុគ្គលជាប់អតប ប្រាក់អតបលើសដូចមានចែងក្នុងវាក្យខ័ណ្ឌ ខ នៃកថាខ័ណ្ឌ២ នៃមាត្រានេះ មិនត្រូវបានអនុញ្ញាតជាឥណទានអតបទេ លើកលែងតែបុគ្គលជាប់អតបបានទូទាត់សងប្រាក់អតបលើសឱ្យអ្នកទទួលការផ្គត់ផ្គង់វិញជាសាច់ប្រាក់ ឬជាការកាត់កងនឹងបំណុលដែលអ្នកទទួលការផ្គត់ផ្គង់ជំពាក់បុគ្គលជាប់អតប ។

៤. ក្នុងករណីដែលបុគ្គលជាប់អតបបានចេញវិក្កយប័ត្រអតប ដោយមកពីហេតុការណ៍ដូចមានចែងក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះ ហើយចំនួនប្រាក់អតបដែលបានកត់ត្រាលើវិក្កយប័ត្រមានចំនួនលើសពីប្រាក់អតបកែតម្រូវនៃការផ្គត់ផ្គង់ទំនិញ បុគ្គលជាប់អតបដែលធ្វើការផ្គត់ផ្គង់ទំនិញត្រូវផ្តល់អោយអ្នកទទួលការផ្គត់ផ្គង់នូវលិខិតឥណទានអតបដែលមាននិទ្ទេសដូចមានចែងក្នុងជំពូក៧ នៃអនុក្រឹត្យនេះ និង មាត្រា៧៧ នៃច្បាប់ស្តីពីសារពើពន្ធ ។

៥. ក្នុងករណីដែលបុគ្គលជាប់អតបបានចេញវិក្កយប័ត្រអតប ដោយមកពីហេតុការណ៍ដូចមានចែងក្នុងកថាខ័ណ្ឌ១នៃមាត្រានេះ ហើយប្រាក់អតបដែលបានកត់ត្រាលើវិក្កយប័ត្រមានចំនួនតិចជាងប្រាក់អតបកែតម្រូវនៃការផ្គត់ផ្គង់ទំនិញ បុគ្គលជាប់អតបដែលធ្វើការផ្គត់ផ្គង់ទំនិញត្រូវផ្តល់អោយអ្នកទទួលការផ្គត់ផ្គង់នូវ លិខិតឥណពន្ធអតបដែលមាននិទ្ទេសដូចមានចែងក្នុងជំពូក៧ នៃអនុក្រឹត្យនេះ និងមាត្រា៧៧ នៃច្បាប់ស្តីពីសារពើពន្ធ ។

៦. បុគ្គលជាប់អតបជាអ្នកធ្វើការផ្គត់ផ្គង់ ឬជាអ្នកទទួលការផ្គត់ផ្គង់ដែលបានចេញឬបានទទួលលិខិតឥណពន្ធឬលិខិតឥណទានអតប ត្រូវកត់ត្រាចលនាទឹកប្រាក់នៃលិខិតឥណពន្ធឬលិខិតឥណទានអតបដូចគ្នាទៅនឹងចលនាទឹកប្រាក់នៃវិក្កយប័ត្រអតបដែរ ។

## ជំពូកទី ១១

## បញ្ជីគណនេយ្យ កំណត់ត្រា និង ពត៌មាន

**មាត្រា៥០ .-**

បុគ្គលជាប់អតបត្រូវកាន់កាប់និងកត់ត្រាបញ្ជីគណនេយ្យនៃការផ្គត់ផ្គង់ទាំងអស់ដែលខ្លួនបានធ្វើ និងបានទទួលនៅក្នុងដំណើរការប្រកបអាជីវកម្មរួមទាំងការផ្គត់ផ្គង់ដែលជាប់អតបតាមអត្រាសូន្យនិងការផ្គត់ផ្គង់មិនជាប់អតប។

សម្រាប់គោលដៅនៃអតប បុគ្គលជាប់អតបត្រូវកាន់កាប់ និងថែរក្សា បញ្ជីគណនេយ្យ កំណត់ត្រា និង ពតិមាន ដូចខាងក្រោមនេះ :

ក- គណនីអាករលើតម្លៃបន្ថែមប្រចាំខែ ដែលបញ្ជាក់អំពីអតបលើធាតុចេញសរុប អតបលើធាតុចូលសរុប ប្រាក់អតបត្រូវបង់ ឬ ឥណទានអតបលើសត្រូវយោងទៅមុខឬដល់កំណត់ត្រូវបង្វិលសងវិញ ។

ខ-កំណត់ត្រាទិញដែលលំអិតអំពីការទិញដែលបានបង់អតប និងការទិញទាំងអស់ដែលគ្មានបង់អតប ច្បាប់ដើមនៃវិក្កយប័ត្រអតបសម្រាប់ការទិញក្នុងស្រុកដែលបានបង់អតប ប្រតិវេទន៍នាំចូលបញ្ជាក់ដោយទីចាត់ការគយដែលបង្ហាញអំពីអតបបានបង់ ហើយនិងវិក្កយប័ត្រនៃការទិញដែលគ្មានបង់អតប ត្រូវរក្សាទុកតាមលំដាប់ថ្ងៃខែ និង លេខរៀង ។

គ- កំណត់ត្រាលក់ទាំងអស់ដែលរួមមានការលក់ជាប់អតបតាមអត្រា១០ភាគរយ អត្រាសូន្យ និងការលក់មិនជាប់អតប ។ សំណៅដើមនៃវិក្កយប័ត្រដែលទាក់ទិននឹងការលក់ជាប់អតប ហើយនិងវិក្កយប័ត្រដែលទាក់ទិននឹងការលក់មិនជាប់អតប ត្រូវរក្សាទុកតាមលំដាប់ថ្ងៃខែនិងលេខរៀង ។

ឃ- លិខិតឥណពន្ធនិងលិខិតឥណទាន ដែលបានចេញនិងបានទទួល ត្រូវរក្សាទុកតាមលំដាប់ថ្ងៃ ខែ និងលេខរៀង ។

ង- កំណត់ត្រាលើរាល់ការនាំចេញនូវទំនិញឬសេវាតាមអត្រាសូន្យ ព្រមទាំងប្រតិវេទន៍គយសម្រាប់ការនាំចេញ សំណៅដើមនៃវិក្កយប័ត្រដែលបានចេញឱ្យអ្នកទិញបរទេស ឯកសារដឹកជញ្ជូនសម្រាប់ការនាំចេញទំនិញ លិខិតបញ្ជាទិញឬកិច្ចសន្យាជាមួយអ្នកទិញបរទេសហើយនិងភស្តុតាងនៃការទូទាត់ប្រាក់តាមវិធីផ្ទេរប្រាក់តាមធនាគារដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬតាមលិខិតឥណទាន ។ ចំពោះលិខិតឥណទាន ត្រូវមានចុះបញ្ជាក់ឱ្យបើកប្រាក់ទូទាត់ពីធនាគារបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការយល់ព្រមណាមួយ ។

ច- កំណត់ត្រាចលនាសាច់ប្រាក់របស់អ្នកលក់រាយដែលរួមមានបញ្ជីបេឡា និងបញ្ជីប្រាក់នៅធនាគារ ប័ណ្ណចំណាយប្រាក់បេឡា និងកំណត់ត្រាគណនេយ្យផ្សេងទៀត រួមទាំងសំណៅដើមនៃបង្កាន់ដៃទទួលប្រាក់ ឬបញ្ជីលំអិតអំពីចំនួនទឹកប្រាក់នៃការលក់ដូរប្រចាំថ្ងៃ ។

ឆ- កំណត់ត្រាដោយកុំព្យូទ័រ ប្រសិនបើបុគ្គលជាប់អតប ប្រើប្រាស់គណនេយ្យតាមប្រព័ន្ធពត៌មានវិទ្យា ។

ជ- ពត៌មានលំអិតស្តីពីការគណនាអតបលើធាតុចូល ក្នុងករណីដែលបុគ្គលជាប់អតបធ្វើការផ្គត់ផ្គង់ជាប់អតបផង និងការផ្គត់ផ្គង់មិនជាប់អតបផង ។

ឈ-ឯកសារ កំណត់ត្រានានា និងទម្រង់ស្នើសុំឥណទានចំពោះអាករលើផលរបរនិងអាករប្រើប្រាស់ក្នុងរយៈពេលអន្តរកាល ។

ញ- កំណត់ត្រាស្តុក ដែលបង្ហាញអំពីការបញ្ចូលបញ្ចេញទំនិញ និង កំណត់ត្រាផលិតកម្ម ។

ដ- កំណត់ត្រាបញ្ជាទិញ និងប័ណ្ណប្រគល់ទំនិញ ។

ឋ- លិខិតឆ្លើយឆ្លងអាជីវកម្ម ។

ឌ- សៀវភៅការងារ ។

ឍ- របាយការណ៍គណនេយ្យប្រចាំឆ្នាំ រួមមានគណនីលទ្ធផល តារាងតុល្យការ និងតារាងពតិមានបន្ថែម ។

ណ-កំណត់ត្រាខាងធនាគារ រួមមានសម្រង់គណនី គល់សៀវភៅមូលប្បទានប័ត្រ និងប័ណ្ណបង់ប្រាក់ចូលធនាគារ ។

កំណត់ត្រាទាំងអស់ ត្រូវធ្វើឡើងទៅតាមទម្រង់ដែលនាយកដ្ឋានពន្ធដារបានកំណត់ឬបានទទួលស្គាល់ហើយ ត្រូវថែរក្សានិងត្រៀមបំរុងសម្រាប់ការត្រួតពិនិត្យ ក្នុងរយៈពេល១០ឆ្នាំ ។

## ជំពូកទី១២

## ការផ្គត់ផ្គង់ទំនិញឬសេវាដល់អ្នកប្រើប្រាស់

**មាត្រា៥១** .-

បុគ្គលជាប់អតបដែលធ្វើការផ្គត់ផ្គង់ជាប់អតបតាមអត្រាស្តង់ដា ឱ្យដល់បុគ្គលមិនជាប់អតប ត្រូវកាន់បញ្ជីគណនេយ្យ និងកំណត់ត្រានានា ដូចមានចែងក្នុងមាត្រា៥០ នៃអនុក្រឹត្យនេះ ហើយត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោមនេះ :

ក. ក្នុងករណីដែលបានចេញវិក្កយប័ត្រធម្មតា បើសិនជានៅលើវិក្កយប័ត្រមានបញ្ជាក់ចំនួនទឹកប្រាក់អតបដោយឡែកនោះ ប្រាក់អតបដល់កំណត់ក្នុងខែ ត្រូវគណនាចេញពីកំណត់ត្រាការលក់ ។

ខ. បើសិនជានៅលើវិក្កយប័ត្រគ្មានបញ្ជាក់ចំនួនទឹកប្រាក់អតបដោយឡែកទេ ឬបុគ្គលជាប់អតបធ្វើការលក់រាយដោយមិនបានចេញវិក្កយប័ត្រ បុគ្គលជាប់អតបត្រូវកាន់កំណត់ត្រាការលក់សរុបប្រចាំថ្ងៃនៃការលក់ជាប់អតបនិងការលក់មិនជាប់អតប ។ ក្នុងការគណនាប្រាក់អតប ត្រូវយកតម្លៃសរុបមានអតបនៃការលក់ទៅគុណប្រភាគអតប។

ប្រភាគអតបសម្រាប់អត្រា១០ភាគរយ គឺ : $\frac{១}{១១}$ ។

ដើម្បីរកតម្លៃជាប់អតបត្រូវយកតម្លៃសរុបនៃការលក់ ដកទឹកប្រាក់អតបចេញ ។

## ជំពូកទី ១៣

## ការផ្គត់ផ្គង់ដោយភ្នាក់ងារ

**មាត្រា៥២** .-

លក្ខខណ្ឌនៃការផ្គត់ផ្គង់ទំនិញ ឬសេវា ដោយភ្នាក់ងារ ត្រូវបានកំណត់ដូចតទៅ :

១. ការផ្គត់ផ្គង់ទំនិញឬសេវា ធ្វើឡើងដោយបុគ្គលជាភ្នាក់ងារដើម្បីជាគុណប្រយោជន៍របស់បុគ្គលម្នាក់ទៀតដែលជាបុគ្គលដើម ត្រូវបានចាត់ទុកថាជាការផ្គត់ផ្គង់របស់បុគ្គលដើមនោះ ។

២. ក្នុងករណីដែលភ្នាក់ងារជាបុគ្គលជាប់អតប ភ្នាក់ងារនោះត្រូវគិតអតបលើកម្រៃដែលបានមកពីការផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមបុគ្គលម្នាក់ទៀតដែលជាបុគ្គលដើម ។ បើសិនជាបុគ្គលដើមនិងភ្នាក់ងារជាបុគ្គលជាប់អតបទាំងពីរនាក់ ប្រាក់អតបដែលកំណត់លើប្រាក់កម្រៃដោយភ្នាក់ងារត្រូវចាត់ទុកជាអតបលើធាតុចូលរបស់បុគ្គលដើម ។

## ជំពូកទី ១៩

## ការប្រមូលអតបលើការនាំចូល

**មាត្រា៥៣ .-**

ការប្រមូលអតបនៅពេលនាំចូល ត្រូវបានកំណត់ដូចតទៅ :

១. អតបដល់កំណត់នៅពេលនាំចូល និងត្រូវប្រមូលដោយទីចាត់ការគយនិងរដ្ឋាករ ។

២. អតបត្រូវបានប្រមូលតាមរយៈការប្រកាសក្នុងប្រតិវេទន៍គយសម្រាប់ការនាំចូល ហើយត្រូវបានចាត់ចែងតាមរបៀបដូចគ្នានឹងពន្ធគយ ។

៣. តម្លៃជាប់អតបនៃការនាំចូលទំនិញគឺជាចំនួនសរុបនៃ :

ក- តម្លៃទំនិញ សម្រាប់គិតពន្ធគយស្របតាមច្បាប់ដែលទាក់ទិននឹងពន្ធគយ ។

ខ- ចំនួនទឹកប្រាក់នៃពន្ធគយ អាករពិសេសលើទំនិញនិងសេវាមួយចំនួន និងបន្ទុកសារពើពន្ធផ្សេងទៀត ដែលត្រូវបង់លើទំនិញទាំងនោះក្រៅពីអាករលើតម្លៃបន្ថែម ។

គ- តម្លៃសេវាណាមួយដែលមានចែងក្នុងកថាខ័ណ្ឌ៣ នៃមាត្រា៤៧ នៃអនុក្រឹត្យនេះ ដែលមិនបានបូកបញ្ចូលក្នុងតម្លៃទំនិញសម្រាប់គិតពន្ធគយ ដូចមានចែងក្នុងវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌ៣ នៃមាត្រានេះ ។

៤. ទីចាត់ការគយនិងរដ្ឋាករ ត្រូវផ្តល់ឱ្យអ្នកនាំចូលនូវ ប្រតិវេទន៍គយសម្រាប់ការនាំចូលមួយច្បាប់ ដែលក្នុងនោះត្រូវ :

ក- ចុះលេខអត្តសញ្ញាណកម្ម អតប បើសិនជាអ្នកនាំចូលជាបុគ្គលជាប់អតប ។

ខ- សរសេរថា "គ្មាន" ក្នុងប្រអប់សម្រាប់ចុះលេខអត្តសញ្ញាណកម្ម បើសិនជាអ្នកនាំចូលមិនមែនជាបុគ្គលជាប់អតប ។

គ- បញ្ជាក់នូវចំនួនប្រាក់អតបដែលបានបង់ លើប្រតិវេទន៍គយសម្រាប់ការនាំចូល បើសិនជាអ្នកនាំចូល ជាបុគ្គលជាប់អតបធ្វើការនាំចូលដើម្បីប្រកបអាជីវកម្មជាប់អតប ។

ឃ-បញ្ជាក់អំពីអសុពលភាពនៃការបង្វិលសងប្រាក់អតប ប្រសិនបើអ្នកនាំចូលមិនមែនជាបុគ្គលជាប់អតប ឬធ្វើការនាំចូលដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន ។

# ជំពូកទី ១៥

## អត្រាសូន្យភាគរយនៃការនាំចេញនូវទំនិញនិងសេវា

**មាត្រា៥៤ .-**

ដែនអនុវត្តនៃអត្រាសូន្យភាគរយ សម្រាប់ការនាំចេញនូវទំនិញឬសេវា ត្រូវបានកំណត់ដូចតទៅ :

១. ស្របតាមកថាខ័ណ្ឌ២ នៃមាត្រា៦៤ នៃច្បាប់ស្តីពីសារពើពន្ធ អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រាសូន្យភាគរយ លើតម្លៃជាប់អតបនៃការផ្គត់ផ្គង់ទំនិញទីមួយៗដែលបាននាំចេញពីព្រះរាជាណាចក្រកម្ពុជា ឬការផ្គត់ផ្គង់ជាប់អតបនៃសេវាដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជា ។ ដែនអនុវត្តនៃបទបញ្ញត្តិនេះត្រូវរួមបញ្ចូល :

ក- ការផ្គត់ផ្គង់ទំនិញ ទៅទីកន្លែងណាមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា ដែលមានឯកសារភស្តុតាងគ្រប់គ្រាន់សម្រាប់នាយកដ្ឋានពន្ធដារពិនិត្យនិងសំរេច ។

ខ- ការផ្គត់ផ្គង់សេវា សម្រាប់ការប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា ដែលមានឯកសារភស្តុតាងគ្រប់គ្រាន់សម្រាប់នាយកដ្ឋានពន្ធដារពិនិត្យនិងសំរេច ។

គ- ការផ្គត់ផ្គង់សេវាដឹកជញ្ជូនអ្នកដំណើរនិងទំនិញជាអន្តរជាតិ ។

ឃ- ការផ្គត់ផ្គង់សេវាដែលទាក់ទិននឹងការដឹកជញ្ជូនអ្នកដំណើរនិងទំនិញជាអន្តរជាតិ ។

២. សម្រាប់គោលដៅនៃវាក្យខ័ណ្ឌ គ នៃកថាខ័ណ្ឌ១ នៃមាត្រានេះ ការដឹកជញ្ជូនអ្នកដំណើរ និងទំនិញតាមផ្លូវគោក ផ្លូវទឹក ឬផ្លូវអាកាស គឺជាការដឹកជញ្ជូនអន្តរជាតិ បើសិនជាការដឹកជញ្ជូននោះត្រូវបានធ្វើឡើង :

ក- ពីកន្លែងមួយក្នុងព្រះរាជាណាចក្រកម្ពុជា ទៅកន្លែងមួយទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជា

ខ- ពីកន្លែងមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា មកកន្លែងមួយក្នុងព្រះរាជាណាចក្រកម្ពុជា ។

គ- ពីកន្លែងមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា ទៅកន្លែងមួយទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងករណីដែលការដឹកជញ្ជូនឬចំណែកណាមួយនៃការដឹកជញ្ជូនឆ្លងកាត់ដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

# ជំពូកទី ១៦

## ការផ្ទេរអាជីវកម្ម

**មាត្រា៥៥ .-**

ការផ្ទេរអាជីវកម្មពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតស្របទៅតាមល័ក្ខខ័ណ្ឌខាងក្រោមនេះ មិនត្រូវជាប់អាករលើតម្លៃបន្ថែមទេ :

ក- អាជីវកម្មត្រូវបានផ្ទេរពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតដើម្បីបន្តធ្វើអាជីវកម្មក្រោមកម្មសិទ្ធិថ្មី ។

ខ- បុគ្គលជាប់អតបដែលផ្ទេរអាជីវកម្មត្រូវជូនដំណឹងដល់នាយកដ្ឋានពន្ធដារ អំពីការផ្ទេរអាជីវកម្មក្នុងរយះពេល១០ថ្ងៃក្រោយកាលបរិច្ឆេទនៃការផ្ទេរ ។

គ- បុគ្គលជាប់អតបដែលផ្ទេរអាជីវកម្ម ត្រូវស្នើសុំលុបចោលការចុះបញ្ជីរបស់ខ្លួន ហើយត្រូវអនុវត្ត ទៅតាមបទប្បញ្ញត្តិនៃមាត្រា៨១ នៃច្បាប់ស្តីពីសារពើពន្ធ និងមាត្រាដែលពាក់ព័ន្ធទាំងឡាយ ក្នុងជំពូកទី៥ នៃអនុក្រឹត្យនេះ ។

ឃ- អ្នកទទួលអាជីវកម្ម ត្រូវចុះបញ្ជីជាបុគ្គលជាប់អតបសម្រាប់អាករលើតម្លៃបន្ថែម នៅពេលដែល ទទួលអាជីវកម្ម និងត្រូវគិតអតបលើទំនិញក្នុងស្តុកនិងទ្រព្យសកម្មដែលបានទទួលនៅពេលធ្វើ ការផ្គត់ផ្គង់ទំនិញនិងទ្រព្យសកម្មទាំងនោះ ។

ង- បុគ្គលដែលទទួលអាជីវកម្ម ត្រូវរក្សាទុកឯកសារអតបដែលទាក់ទិននឹងអាជីវកម្មដែលបានផ្ទេរ នោះ ក្នុងរយះពេល១០ឆ្នាំដូចមានចែងក្នុងមាត្រា៩៨ នៃច្បាប់ស្តីពីសារពើពន្ធ ។

## ជំពូកទី១៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៥៦.-**

អាករលើតម្លៃបន្ថែមនៃទំនិញដែលរាយមុខខាងក្រោម ត្រូវអនុវត្តតាមបែបបទដែលត្រូវកំណត់ដោយ ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ :

- បារី
- មាស
- ស្រាដែលមានជាតិសុរាក្នុងឯកតាចំណុះពី ៣៥ភាគរយ នៃចំណុះឬលើសពីនេះ
- ទោចក្រយានយន្ត
- ថាមពលអគ្គិសនី និង ទឹក ។

# ជំពូកទី ១៨

# អវសានប្បញ្ញត្តិ

**មាត្រា ៥៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ [illegible] ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជម្រាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ